ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ



## ២០២៥ - ២០៣០

រាជរដ្ឋាភិបាលកម្ពុជា

# មាតិកា


**បុព្វកថា** ........ V

**ខ្លឹមសារសង្ខេប** ........ VIII

**ជំពូក ១ ទិដ្ឋភាពទូទៅ** ........ ១

I. សេចក្តីផ្តើម ........ ១

II. ស្ថានភាព និងទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច ........ ១

III. ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជា ........ ២

IV. ប្រព័ន្ធអេកូឡូស៊ីនៃវិស័យហិរញ្ញវត្ថុ ........ ២

V. ការរៀបចំរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ ........ ៣

**ជំពូក ២ វិស័យធនាគារ** ........ ៤

I. ទិដ្ឋភាពទូទៅ ........ ៤

II. ការកែទម្រង់ និងសមិទ្ធផល ........ ៤

III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៧

IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យធនាគារ ........ ៩

**ជំពូក ៣ វិស័យមីក្រូហិរញ្ញវត្ថុ** ........ ១៥

I. ទិដ្ឋភាពទូទៅ ........ ១៥

II. ការកែទម្រង់ និងសមិទ្ធផល ........ ១៥

III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ១៦

IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ........ ១៦

**ជំពូក ៤ វិស័យភតិសន្យាហិរញ្ញវត្ថុ និងហាយភើផែស** ........ ១៧

I. ទិដ្ឋភាពទូទៅ ........ ១៧

II. ការកែទម្រង់ និងសមិទ្ធផល ........ ១៧

III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ១៧

IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យភតិសន្យាហិរញ្ញវត្ថុ ........ ១៨

**ជំពូក ៥ ប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុ** ........ ២០

I. ទិដ្ឋភាពទូទៅ ........ ២០

II. ការកែទម្រង់ និងសមិទ្ធផល ........ ២០

III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ២២

IV. ផែនការយុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុ ........ ២៣

**ជំពូក ៦ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ** ........ ២៥

I. ទិដ្ឋភាពទូទៅ ........ ២៥

II. សមិទ្ធផលរួមរបស់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ........ ២៦

III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ២៨

iv. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ........ ២៨
**ជំពូក ៧ វិស័យធានារ៉ាប់រង ........ ៣១**
i. ទិដ្ឋភាពទូទៅ ........ ៣១
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៣១
iii. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៣៣
iv. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យធានារ៉ាប់រង ........ ៣៦
**ជំពូក ៨ វិស័យសោធន ........ ៣៩**
i. ទិដ្ឋភាពទូទៅ ........ ៣៩
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៣៩
iii. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៤០
iv. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យសោធន ........ ៤២
**ជំពូក ៩ វិស័យមូលបត្រ ........ ៤៤**
i. ទិដ្ឋភាពទូទៅ ........ ៤៤
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៤៤
iii. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៤៧
iv. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យមូលបត្រ ........ ៤៨
**ជំពូក ១០ វិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ........ ៥២**
i. ទិដ្ឋភាពទូទៅ ........ ៥២
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៥២
iii. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៥៣
iv. ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ........ ៥៤
**ជំពូក ១១ វិស័យគណនេយ្យ និងសវនកម្ម ........ ៥៦**
i. ទិដ្ឋភាពទូទៅ ........ ៥៦
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៥៦
iii. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៦០
iv. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យគណនេយ្យនិងសវនកម្ម ........ ៦១
**ជំពូក ១២ វិស័យបរធនបាលកិច្ច ........ ៦២**
i. ទិដ្ឋភាពទូទៅ ........ ៦២
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៦២
iii. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ........ ៦៣
iv. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យបរធនបាលកិច្ច ........ ៦៤
**ជំពូក ១៣ បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ........ ៦៦**
i. ទិដ្ឋភាពទូទៅ ........ ៦៦
ii. ការកែទម្រង់ និងសមិទ្ធផល ........ ៦៦

III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ ..................... ៦៨
IV. ផែនការយុទ្ធសាស្ត្រសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ..................... ៦៩
**ជំពូក ១៤ បញ្ហាអន្តរវិស័យពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ..................... ៧១**
I. ការចែករំលែកព័ត៌មានឥណទាន ..................... ៧១
II. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ..................... ៧៣
III. ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ..................... ៧៨
IV. ហិរញ្ញវត្ថុប្រកបដោយចីរភាព ..................... ៨១
V. យុទ្ធសាស្ត្រផ្នែកព័ត៌មាន អប់រំ និងទំនាក់ទំនង ..................... ៨៧
VI. កិច្ចការពារអតិថិជន ..................... ៩២
**ជំពូក ១៥ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ..................... ៩៦**
**ជំពូក ១៦ សេចក្តីសន្និដ្ឋាន ..................... ៩៦**
**ឧបសម្ព័ន្ធ ១៖ តារាងផែនការអនុវត្តយុទ្ធសាស្ត្រ ..................... ៩៩**
**ឧបសម្ព័ន្ធ ២៖ ក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការតាមដាន និងវាយតម្លៃ ..................... ១៦៥**

# បុព្វកថា

វឌ្ឍនភាព និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន មិនអាចមើលរំលងនូវវិភាគទាន និងតួនាទីដ៏សំខាន់របស់វិស័យហិរញ្ញវត្ថុ ជាពិសេស ក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមជាង ៧% ប្រចាំឆ្នាំ សម្រាប់រយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ បានទេ។ ក្រោមម្លប់នៃសន្តិភាព និងស្ថិរភាពនយោបាយ ជាពិសេស ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា វិស័យហិរញ្ញវត្ថុកម្ពុជាមានភាពរឹងមាំជាលំដាប់ ដោយបានជំរុញបន្ថែមការវិនិយោគ ពាណិជ្ជកម្ម និងការអភិវឌ្ឍស្ទើរគ្រប់វិស័យ។

ដោយផ្អែកលើការអនុវត្តនូវអភិក្រម **"កសាងជាមុន ពង្រីកតាមក្រោយ"** វិស័យហិរញ្ញវត្ថុកម្ពុជាត្រូវបានអភិវឌ្ឍបន្តិចម្តងៗ ក្នុងល្បឿនមួយយឺត តែមានសារៈសំខាន់ និងបានបោះជំហានទៅមុខយ៉ាងរឹងមាំ។ យើងពិតជាពិបាកស្រមើស្រមៃណាស់ថា វិស័យហិរញ្ញវត្ថុធនាគារអាចទទួលបានកម្រិតអភិវឌ្ឍទំនើបដូចបច្ចុប្បន្ននេះ បើធៀបនឹងប៉ុន្មានទសវត្សរ៍កន្លងមក។ លើសពីនេះ តួនាទីរបស់ប្រព័ន្ធធនាគារត្រូវបានចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗ ពីតូចទៅធំ និងពីតិចទៅច្រើន ព្រមទាំងការឆ្លងកាត់ធ្វើនិម្មាបនកម្មវិស័យហិរញ្ញវត្ថុតាមរបត់ថ្មីៗ ដូចជាបដិវត្តន៍ឧស្សាហកម្មទី៤ និងការធ្វើឌីជីថលូបនីយកម្មលើគ្រប់វិស័យ ដែលសុទ្ធសឹងជាវិញ្ញាសារសំខាន់ៗ ក្នុងការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

ជាក់ស្តែង ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ក៏បានឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានឆ្លងកាត់ឧបសគ្គ និងការផ្លាស់ប្តូរជាច្រើនដំណាក់កាល ក្នុងការកសាងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុទំនើបមួយ ចេញពីបាតដៃទទេ។ ទន្ទឹមនេះ វិស័យហិរញ្ញវត្ថុ បានចូលរួមចំណែកដល់ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្លងកាត់នូវគ្រប់ស្ថានការណ៍នៃព្រឹត្តិការណ៍សកល ដូចជា វិបត្តិសេដ្ឋកិច្ចសកល ការទទួលរងនូវការប៉ះទង្គិចពីជំងឺរាតត្បាតកូវីដ-១៩ វិបត្តិអតិផរណាសកល ការដំឡើងអត្រាការប្រាក់របស់សហរដ្ឋអាម៉េរិកភ្លាម និង វិបត្តិសាកលផ្សេងៗទៀតជាបន្តបន្ទាប់។ ម្យ៉ាងវិញទៀត ការបង្កើតឱ្យមានច្បាប់គ្របដណ្តប់បានទូលំទូលាយ ការកែសម្រួលហេដ្ឋារចនាសម្ព័ន្ធស្ថាប័នជាបន្តបន្ទាប់ និងការកើនឡើងនូវផលិតផល និងសេវាហិរញ្ញវត្ថុថ្មីៗ ស្របតាមនិន្នាការ និងស្តង់ដារអន្តរជាតិ វិស័យហិរញ្ញវត្ថុកម្ពុជាត្រូវបានធ្វើបច្ចុប្បន្នកម្ម និងទំនើបកម្មឱ្យកាន់តែមានភាពស៊ីជម្រៅជាងមុន។

ជាមួយគ្នានេះ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏ចាប់ផ្តើមក្លាយជាផលិតផលហិរញ្ញវត្ថុថ្មី និងមានសក្តានុពលនៅកម្ពុជា ដោយក្នុងនោះ អនុវិស័យធានារ៉ាប់រងបានចូលរួមអត្រាភាគទាន ១,១៦% ក្នុងសេដ្ឋកិច្ចជាតិក្នុងឆ្នាំ ២០២៣ និងក្នុងឆ្នាំដដែល មូលធនូបនីយកម្មសម្រាប់ទីផ្សារមូលបត្រមានចំនួនសរុប ៣,១៣ ប៊ីលានដុល្លារអាម៉េរិក ដែលចំនួននេះស្មើនឹង ៩,៧៩% នៃផលិតផលក្នុងស្រុកសរុប។ សមិទ្ធផលទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញពីលទ្ធភាព និងការកសាងឧបករណ៍ហិរញ្ញវត្ថុ ក្នុងការកាត់បន្ថយការពឹងផ្អែកខ្លាំងពេកលើមូលធនវិនិយោគពីបរទេស និងការរួមចំណែកយ៉ាងសំខាន់ក្នុងកៀរគរធនធានហិរញ្ញវត្ថុក្នុងស្រុក ដើម្បីបន្តជំរុញការអភិវឌ្ឍ។

ក្នុងន័យនេះ វិស័យហិរញ្ញវត្ថុកម្ពុជានឹងក្លាយជាកាតាលីករដ៏សំខាន់មួយ និងមិនអាចខ្វះបាន ក្នុងការឈានទៅសម្រេចបាននូវចក្ខុវិស័យឆ្នាំ ២០៥០។ ក្នុងន័យនេះ វិស័យហិរញ្ញវត្ថុកាន់តែមានភាពចាំបាច់ក្នុងការអភិវឌ្ឍខ្លួន ដោយបន្ថែមលើមុខងារជាអន្តរការីហិរញ្ញវត្ថុ ការបង្កើនទំនាក់ទំនងកាន់តែរឹងមាំឡើងរវាងប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរូបវន្ត និងការអភិវឌ្ឍផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនូវតម្រូវការចម្រុះ ទាំងសម្រាប់ធុរជន និងគេហជន។

ខ្ញុំសូមធ្វើការកត់សម្គាល់លើចំណុចមួយចំនួន ក្នុងការជំរុញវិស័យហិរញ្ញវត្ថុកម្ពុជា ឱ្យកាន់តែមានភាពរឹងមាំបន្ថែម និងផ្សារភ្ជាប់កាន់តែខ្លាំងជាមួយនឹងវិស័យរូបវន្ត រួមមាន៖ (១). បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែមានភាពស៊ីជម្រៅ និងទំនើប ជាពិសេសពង្រឹងលើអ្វីដែលមានស្រាប់ឱ្យកាន់តែរឹងមាំ និងពង្រីកឱ្យកាន់តែសម្បូរបែប (២). ជំរុញការផ្សារភ្ជាប់វិស័យហិរញ្ញវត្ថុគ្រប់សសរស្តម្ភទៅនឹងបរិវត្តកម្មឌីជីថល ដើម្បីជំរុញការអភិវឌ្ឍ និងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងយុគសម័យឌីជីថល (៣). បន្តលើកកម្ពស់ស្ថិរភាព និងការប្រើប្រាស់រូបិយប័ណ្ណជាតិឱ្យបានជាអតិបរមា តាមរយៈការអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុ ទីផ្សារប្តូរប្រាក់ ទីផ្សារអន្តរធនាគារ និងការប្រើប្រាស់ប្រាក់រៀលជាឯកតារង្វាស់តម្លៃ និងជាមធ្យោបាយទូទាត់ផ្សេងៗក្នុងសេដ្ឋកិច្ចជាតិឱ្យកាន់តែទូលំទូលាយក្នុងគ្រប់មជ្ឈដ្ឋាន (៤). ច្បាមយកអត្ថប្រយោជន៍ឱ្យបានអតិបរមាពីទីផ្សារហិរញ្ញវត្ថុ ដូចជាទីផ្សារមូលបត្រ ទីផ្សាររូបិយវត្ថុ និងអន្តរធនាគារ ដើម្បីពង្រឹងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាឱ្យកាន់តែមានឯករាជ្យភាព និងមានសន្ទនីយភាពខ្ពស់ (៥). បន្តអភិវឌ្ឍធនធានមនុស្សក្រោមវិស័យពាក់ព័ន្ធ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបំពេញមុខងារ និងភារកិច្ចស្របតាមការកើនឡើងនៃសមាហរណកម្មក្នុងតំបន់ និងនវានុវត្តន៍ឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (៦). បន្តបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់ប្រជាជនគ្រប់ស្រទាប់ ជាពិសេសសហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីបង្កើនផលិតភាពជាតិសរុប និង (៧). បន្តពង្រឹងការកៀរគរហិរញ្ញប្បទានក្នុងស្រុក ដើម្បីលើកកម្ពស់ភាពម្ចាស់ការនៃហិរញ្ញប្បទានអភិវឌ្ឍ ខណៈដែលកម្ពុជានឹងចាកចេញពីប្រទេសមានកម្រិតអភិវឌ្ឍន៍តិចតួច (LDCs)។

អាស្រ័យហេតុនេះ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ផែនការសកម្មភាពដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០** នឹងក្លាយជាមគ្គុទ្ទេសក៍បង្ហាញផ្លូវដ៏សំខាន់មួយ ដើម្បីបំផុសឱ្យមានការផ្លាស់ប្តូរជាក់ស្តែង ដែលអាចទ្រទ្រង់កំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងអាចផ្តល់ហិរញ្ញប្បទានកាន់តែទូលំទូលាយជូនប្រជាពលរដ្ឋគ្រប់កម្រិត។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ **ធនាគារអភិវឌ្ឍន៍អាស៊ី** ដែលបានផ្តល់ជំនួយបច្ចេកទេសចាំបាច់ផ្សេងៗ ដើម្បីញ៉ាំងឱ្យដំណើរការនៃការរៀបចំយុទ្ធសាស្ត្រនេះអាចប្រព្រឹត្តទៅបានយ៉ាងរលូន និងទទួលបានជោគជ័យជាស្ថាពរ។ ខ្ញុំក៏សូមលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់បន្តចូលរួមអនុវត្តតាមយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលមានក្នុងយុទ្ធសាស្ត្រនេះ ដើម្បីធានាថាវិស័យហិរញ្ញវត្ថុនៅបន្តជាវិស័យចម្បងមួយ ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។

ថ្ងៃច័ន្ទ ៨ រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# អក្សរកាត់

| | |
|---|---|
| ក.ជ.អ.ច. | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| គ.ម.ក. | គណៈកម្មការមូលបត្រកម្ពុជា |
| គ.ស.ហ. | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ផ.ម.ក. | ទីផ្សារមូលបត្រកម្ពុជា |
| ធ.ស.ក. | ធនាគារសហគ្រាសធុនតូចនិងមធ្យម |
| ម.ជ.ជ. | មូលនិធិជាតិជំនួយសង្គម |
| ន.ម.ក. | និយ័តករមូលបត្រកម្ពុជា |
| ន.គ.ស. | និយ័តករគណនេយ្យនិងសវនកម្ម |
| ន.ប.ធ. | និយ័តករបរធនបាលកិច្ច |
| ន.ធ.ក. | និយ័តករធានារ៉ាប់រងកម្ពុជា |
| ន.ស.ស. | និយ័តករសន្តិសុខសង្គម |
| ន.អ.ប. | និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ |
| វ.គ.ស.ក. | វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា |
| ស.ធ.ក. | សាជីវកម្មធានាឥណទានកម្ពុជា |
| ស.ហ.ក. | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| អ.ស.ហ. | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| ប.ជ.អ. | បេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន |
| ប.ជ.ស. | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| អ.ក.គ. | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម |

# ខ្លឹមសារសង្ខេប

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមួយនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ជាមធ្យមក្នុងអត្រា ៧% ប្រចាំឆ្នាំ។ និន្នាការនៃកំណើនសេដ្ឋកិច្ចនេះ បានធ្វើឱ្យតម្រូវការផលិតផល និងសេវាហិរញ្ញវត្ថុរបស់អតិថិជន និងសហគ្រាសគ្រប់ប្រភេទមានការកើនឡើងជាលំដាប់ ដែលការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញបាន តាមរយៈការកើនឡើងនូវចំនួនគណនីប្រាក់បញ្ញើ និងចំនួនគណនីអ្នកខ្ចីប្រាក់ក្នុងប្រព័ន្ធធនាគារ។ យ៉ាងណាក្តី ផ.ស.ស. បានធ្លាក់ចុះក្នុងអត្រា -៣,៦% វិញនាឆ្នាំ ២០២០ ដោយសារវិបត្តិជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់វិស័យសក្តានុពលជាច្រើន រួមមានវិស័យទេសចរណ៍ វិស័យសំណង់ និងវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូប ជាដើម។ ឆ្លើយតបទៅនឹងវិបត្តិនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការចំពោះមុខមួយចំនួនទាំងក្នុងរយៈពេលខ្លី មធ្យម និងវែង កំណើនសេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញជាបន្តបន្ទាប់ ពោលគឺសម្រេចបានកំណើនក្នុងអត្រា ៦% នាឆ្នាំ ២០២៤។

មិនខុសពីបណ្តាប្រទេសដទៃក្នុងពិភពលោក កម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហ តែងាយប្រឈមនឹងការប្រែប្រួលនៃចរន្តសេដ្ឋកិច្ចខាងក្រៅ ដូចជាការអូសបន្លាយសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន ជម្លោះប្រដាប់អាវុធនៅមជ្ឈិមបូព៌ា បញ្ហាអស្ថិរភាពនយោបាយនៅប្រទេសមួយចំនួន ក៏ដូចជាបញ្ហាដក់សល់ពីវិបត្តិកូវីដ-១៩ ដែលបាន និងកំពុងជះឥទ្ធិពលអវិជ្ជមានដោយផ្ទាល់ និងដោយប្រយោល មកលើវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងភាពមិនប្រាកដប្រជាខ្ពស់នៃកត្តាខាងក្រៅទាំងនេះ ក៏ដូចជាសម្របខ្លួនតាមស្ថានភាពនៃសេដ្ឋកិច្ចសង្គមកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើបច្ចុប្បន្នកម្ម **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥** ទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០** ដែលមានចក្ខុវិស័យវែងឆ្ងាយ ដោយប្រកាន់យកបដិវត្តន៍ឧស្សាហកម្ម ៤.០ ជានិន្នាការដឹកមុខ និងឈរលើគោលការណ៍ទីផ្សារដែលមានលក្ខណៈពិពិធភាព ភាពរឹងមាំ និងបរិយាបន្ន។

ជាការពិតណាស់ យុទ្ធសាស្ត្រនេះ ត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ចំនួន ៣ លើក និងបានដាក់ឱ្យអនុវត្តអស់រយៈកាលជាង ២៥ ឆ្នាំរួចមកហើយ។ ដើម្បីផ្តល់ដំណោះស្រាយឱ្យចំគោលដៅ និងធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់លើដំណោះស្រាយដែលបានដាក់ចេញ ឯកសារយុទ្ធសាស្ត្រនេះមានចក្ខុវិស័យៈ ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការកសាងប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយភាពធន់ ពិពិធភាព បរិយាបន្ន និងនវានុវត្តន៍ និងមានគោលដៅជំរុញបរិយាបន្នហិរញ្ញវត្ថុ ពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាដែលកំពុងរីកចម្រើននៅគ្រប់សសរស្តម្ភទាំងអស់នៃវិស័យហិរញ្ញវត្ថុ។ ក្នុងន័យនេះ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងជា ១៦ ជំពូក ដោយជំពូកនីមួយៗត្រូវបានរៀបចំផ្តោតសំខាន់តែលើមួយវិស័យ/អនុវិស័យប៉ុណ្ណោះ ពោលគឺការសិក្សាលម្អិតអំពីទិដ្ឋភាពទូទៅ ការកែទម្រង់សមិទ្ធផល បញ្ហាប្រឈម ក៏ដូចជាការដាក់ចេញនូវផែនការយុទ្ធសាស្ត្រផ្សេងគ្នា តែមានភាពប្រទាក់ក្រឡាយ៉ាងជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមក។ ការកំណត់ក្របខ័ណ្ឌអនុវត្តត្រឹម ៥ ឆ្នាំនេះដែលខុសពីវដ្តនៃការអនុវត្តកន្លងមក គឺជាជំហានដែលធានាបាននូវភាពបត់បែនខ្ពស់ និងអាចឆ្លើយតបបានទាន់ពេលវេលាចំពោះបម្រែបម្រួលយ៉ាងលឿននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ បរិយាកាសវិនិយោគ និងគន្លងសេដ្ឋកិច្ចក្នុងតំបន់ ក៏ដូចជាការអាចសម្របខ្លួនបានយ៉ាងឆាប់រហ័សទៅនឹងកម្មវិបាកនានា ដែលអាចកើតមានឡើងកាន់តែញឹកញាប់ឡើង នាពេលអនាគត។

ការចូលរួមចំណែកមួយផ្នែកធំនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានគ្របដណ្តប់ដោយវិស័យធនាគារ ដែលវិស័យនេះត្រូវបានវាយតម្លៃថាមានការអភិវឌ្ឍឆាប់រហ័សជាងគេ ទាំងទំហំ និងវិសាលភាព។ ចាប់តាំងពីការដាក់ចេញ **ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០** កាលពីឆ្នាំ ២០០១ មក ដោយអនុលោមតាមឧត្តមានុវត្តន៍ និងស្តង់ដារអន្តរជាតិ ក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើន វិស័យធនាគារត្រូវបានពង្រឹងជាលំដាប់

ពោលគឺការដាក់ចេញនូវបទប្បញ្ញត្តិប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងការត្រួតពិនិត្យជាប្រចាំ ផ្អែកតាមវិធីសាស្ត្រចំនួន ២ គឺការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត និងវិធីសាស្ត្រស្រេប (SREP) ដើម្បីធានាឱ្យបាននូវភាពរឹងមាំទាំងដើមទុន សន្ទនីយភាព និងសមត្ថភាពគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ដោយវិស័យធនាគារមានការអភិវឌ្ឍកាន់តែស៊ីជម្រៅ និងទំនើប ធនាគារជាតិនៃកម្ពុជាបាន និងកំពុងពង្រឹងសមត្ថភាពមន្ត្រីរបស់ស្ថាប័ន និងកិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរត្រួតពិនិត្យក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា ដើម្បីតាមដានស្ថិរភាពហិរញ្ញវត្ថុ និងវាយតម្លៃហានិភ័យនានាក្នុងវិស័យធនាគារឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា។ យ៉ាងណាក្ដី វិស័យធនាគារនៅកម្ពុជា កំពុងមានបញ្ហាប្រឈមមួយចំនួនរួមមាន ការមិនទាន់ដាក់ឱ្យដំណើរការប្រព័ន្ធការពារប្រាក់បញ្ញើ ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត និងភាពមានកម្រិតក្នុងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុផ្សេងៗ។ ជាផែនការយុទ្ធសាស្ត្រសម្រាប់វិស័យធនាគារ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការសរុបចំនួន ១០២ ក្រោមវិស័យធនាគារ ដោយក្នុងនោះ វិស័យធនាគារមាន ៥៣ វិធានការ វិស័យភតិសន្យាហិរញ្ញវត្ថុ និងហាយភើឆែសមាន ២៨ វិធានការ និងប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុមាន ២១ វិធានការ។ ក្នុងនោះ រាជរដ្ឋាភិបាលនឹងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ និងបទប្បញ្ញត្តិដោះស្រាយសម្រាប់សហគ្រាសដែលប្រឈមការដួលរលំ ធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាដែលមានស្រាប់ បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ។

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងទសវត្សរ៍ចុងក្រោយនេះ ទាំងទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើ ក៏ដូចជាចំនួនគ្រឹះស្ថាន។ និយ័តករ និងជាអាជ្ញាធរត្រួតពិនិត្យវិស័យមីក្រូហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ដោយផ្អែកលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ ការត្រួតពិនិត្យនិងប្រព័ន្ធរាយការណ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងការកសាងសមត្ថភាព។ បញ្ហាប្រឈមចម្បងៗសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ គឺការតម្រូវឱ្យបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងទ្រព្យធានាផ្ទាល់ខ្លួននៅពេលស្នើសុំឥណទានដែលអាជីវកម្មភាគច្រើន ពុំមានទិន្នន័យ និងរបាយការណ៍ហិរញ្ញវត្ថុ។ ជាផែនការយុទ្ធសាស្ត្រសម្រាប់អនុវិស័យនេះ រាជរដ្ឋាភិបាលនឹងជំរុញដំណើរការវិភាគអតិថិជន តាមរយៈប្រព័ន្ធឌីជីថល ដើម្បីជួយសម្រួលដល់ដំណើរការវិភាគឥណទានរបស់អតិថិជនតាមប្រព័ន្ធអនឡាញ ហើយដំណើរការនេះនឹងផ្ដល់អត្ថប្រយោជន៍ទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជន។

ភតិសន្យាហិរញ្ញវត្ថុ និងហាយភើឆែសក៏ជាអនុវិស័យសំខាន់មួយទៀតក្នុងប្រព័ន្ធធនាគារដែលបានផ្ដល់ការគាំទ្រដល់បុគ្គល និងសហគ្រាស។ ដោយឡែក បញ្ហាប្រឈមក្នុងអនុវិស័យនេះ គឺការមិនទាន់មានក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ការអនុវត្តប្រតិបត្តិការហាយភើឆេស និងមានបញ្ហាពាក់ព័ន្ធនឹងពន្ធដារ និងគណនេយ្យ ការដោះស្រាយវិវាទ ការផ្សព្វផ្សាយនិងការលើកកម្ពស់ការយល់ដឹង និងក្របខ័ណ្ឌវាយតម្លៃហានិភ័យអតិថិជន។ វិធានការសរុបដែលបានដាក់ចេញក្នុងអនុវិស័យនេះមានចំនួន ២៨។ ជាផែនការយុទ្ធសាស្ត្រ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវបទប្បញ្ញត្តិស្ដីពីកិច្ចសន្យាហាយភើឆេស ផ្ដល់ការគាំទ្រពេញលេញដើម្បីជំរុញការអនុលោមតាមស្តង់ដារគណនេយ្យ ការបង្កើតតុលាការពាណិជ្ជកម្មសម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្ម និងការវាយតម្លៃសមិទ្ធិលទ្ធភាពនៃការបង្កើតសមាគមភតិសន្យាហិរញ្ញវត្ថុ។

ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ក៏ត្រូវបានធ្វើទំនើបកម្មជាលំដាប់ ដែលបានផ្ដល់ការគាំទ្រយ៉ាងខ្លាំងដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ សេដ្ឋកិច្ចឌីជីថល និងការប្រើប្រាស់ប្រាក់រៀល។ ប្រព័ន្ធទូទាត់សងប្រាក់ក៏ត្រូវបានតភ្ជាប់ជាមួយបណ្ដាប្រទេសជាច្រើនក្នុងតំបន់ដែលរួមមាន ប្រទេសថៃ វៀតណាម ឡាវ ម៉ាឡេស៊ី កូរ៉េ និងក្រុមហ៊ុនផ្ដល់សេវាទូទាត់អន្តរជាតិ រួមមាន ក្រុមហ៊ុនយូញៀនផេអន្តរជាតិ និងក្រុមហ៊ុនអាលីផេ ជាដើម ដើម្បីជួយសម្រួល

ដល់ប្រតិបត្តិការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន។ បញ្ហាប្រឈមចម្បងរួមមាន ហានិភ័យថ្មីៗពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់ ការមិនទាន់រៀបចំនិងដាក់ចេញក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ការទាមទារឱ្យមានការធ្វើបច្ចុប្បន្នកម្មលើប្រព័ន្ធទូទាត់ និងការគ្រប់គ្រងថ្នាលឥណទានឌីជីថល។ វិធានការសរុបដែលបានដាក់ចេញក្នុងអនុវិស័យនេះមានចំនួន ២១ ដោយក្នុងនោះ រាជរដ្ឋាភិបាលនឹងកសាងហេដ្ឋារចនា-សម្ព័ន្ធប្រព័ន្ធទូទាត់ សេវាទូទាត់សងប្រាក់ និងការតភ្ជាប់ប្រតិបត្តិការទូទាត់ឆ្លងដែន និងនវានុវត្តន៍ហិរញ្ញវត្ថុ។

វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានវិវត្តខ្លួនយ៉ាងឆាប់រហ័សក្នុងរយៈកាល ២ ទសវត្សរ៍ចុងក្រោយ ទាំងកំណើន និងការធ្វើពិពិធកម្មវិស័យ។ បន្ទាប់ពីបានអនុម័ត **ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (អ.ស.ហ.) កាលពីឆ្នាំ ២០២១ អ.ស.ហ. មានភារកិច្ចអភិវឌ្ឍ ត្រួតពិនិត្យ និងតាមដានផែនការយុទ្ធសាស្ត្រ និងសកម្មភាព ព្រមទាំងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ បញ្ហាប្រឈមក្នុងវិស័យនេះ រួមមានចំនួននិងសមត្ថភាពមន្ត្រីបច្ចេកទេសនៅមានកម្រិត និងលិខិតបទដ្ឋានគតិយុត្តមិនទាន់គ្រប់គ្រាន់ដូចជា ក្របខ័ណ្ឌគាំពារអតិថិជន ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម ជាដើម។ វិធានការសរុបដែលបានដាក់ចេញក្នុងអនុវិស័យនេះមានចំនួន ៧៧ ដោយក្នុងនោះ រាជរដ្ឋា-ភិបាលនឹងអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយយុទ្ធសាស្ត្រ អភិវឌ្ឍស្ថាប័ន អភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមិនមែនធនាគារ ធានាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុមិនមែនធនាគារ និងជំរុញប្រសិទ្ធភាពនៃប្រតិបត្តិការ របស់ អ.ស.ហ.។

និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.) បានបំពេញការងារពង្រឹងវិស័យធានារ៉ាប់រងយ៉ាងសកម្ម រួមមានការ-រៀបចំ និងដាក់ឱ្យអនុវត្តនូវ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជាឆ្នាំ ២០២១-២០៣០** ដើម្បីជំរុញពិពិធកម្មផលិតផលធានារ៉ាប់រងក្នុងទីផ្សារ ជំរុញការរៀបចំនិងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិ និងគោលការណ៍ណែនាំគាំទ្រដែលមានភាពចាំបាច់។ បញ្ហាប្រឈមចម្បងៗក្នុងអនុវិស័យនេះ គឺកង្វះការយល់ដឹង និងអត្ថរកម្មធានារ៉ាប់រងភាពមានកម្រិតក្នុងការអភិវឌ្ឍទីផ្សារធានារ៉ាប់រងនានា កង្វះខាតក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ បញ្ហាខ្វះខាតមូល-ធនមនុស្សផ្នែកបច្ចេកវិទ្យា និងធនធានមនុស្ស។ វិធានការសរុបដែលបានដាក់ចេញក្នុងអនុវិស័យនេះមានចំនួន ៧២ ដោយនឹងលើកកម្ពស់ការយល់ដឹង អភិវឌ្ឍទីផ្សារធានារ៉ាប់រងពាក់ព័ន្ធ ពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង អភិវឌ្ឍក្របខ័ណ្ឌគតិយុត្តនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធ រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង និងកសាងសមត្ថភាព។

និយ័តករសន្តិសុខសង្គម (ន.ស.ស.) ក៏បានបំពេញមុខងារលើការងារនិយ័តកម្ម និងត្រួតពិនិត្យប្រតិបត្តិការរបបសន្តិសុខសង្គម ដែលគ្រប់គ្រង និងចាត់ចែងដោយបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) និងមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) និងបានរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់លើផ្នែកប្រាក់សោធន។ បញ្ហាប្រឈមក្នុងអនុវិស័យនេះគឺ កង្វះក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុនៃរបបសោធន ការគ្រប់គ្រងនិងចាត់ចែងមូលនិធិប្រាក់សោធន ក្របខ័ណ្ឌត្រួតពិនិត្យនិងដោះស្រាយវិវាទ និងភាពមានកម្រិតនៃការយល់ដឹងអំពីផ្នែកប្រាក់សោធន។ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការសរុបចំនួន ៥៣ ដោយក្នុងនោះ នឹងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិសំខាន់ៗស្របតាមតម្រូវការជាក់ស្តែង ធ្វើសមាហរណកម្មមូលនិធិសោធនដែលកំពុងស្ថិតនៅដាច់ដោយឡែក កែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ជំរុញការរៀបចំបង្កើតអធិការសន្តិសុខសង្គម អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាផ្ទៃក្នុង អភិវឌ្ឍថ្នាលដោះស្រាយវិវាទឌីជីថល និងធ្វើសន្ទានកម្មទិន្នន័យពីប្រតិបត្តិករក្នុងពេលជាក់ស្តែង និងលើកកម្ពស់ការយល់ដឹងលើអនុវិស័យនេះ។

វិស័យមូលបត្រកម្ពុជា ក្រោមនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ នាពេលបច្ចុប្បន្ន ថ្វីបើវិស័យនេះស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍនៅឡើយ។ បន្ទាប់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបោះផ្សាយមូលបត្ររដ្ឋជាលើកដំបូង នៅខែ កញ្ញា ឆ្នាំ ២០២២ ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) បានដាក់ឱ្យ

ដំណើរការជាផ្លូវការនូវប្រព័ន្ធបើកគណនីជួញដូរមូលបត្រតាមអនឡាញជំនាន់ទី២ ជាមួយនឹងតំណភ្ជាប់ប្រព័ន្ធទៅកាន់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា និងបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធផ្តល់លេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញរបស់ ន.ម.ក.។ បញ្ហាប្រឈមក្នុងវិស័យមូលបត្រកម្ពុជាគឺនៅលើទំហំ និងការអភិវឌ្ឍទីផ្សារ ខណៈការចូលរួមរបស់វិនិយោគិនស្ថាប័នទាំងក្នុងស្រុក និងបរទេស ពុំមានសកម្មភាពគួរឱ្យកត់សម្គាល់នៅឡើយ។ ឆ្លើយតបនឹងបញ្ហាទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការសរុបចំនួន ១១០ ដោយនឹងយកចិត្តទុកដាក់បន្ថែមលើអ្នកចូលរួមទីផ្សារ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍទីផ្សារខុម៉ូឌីធីអនាគតនិងទីផ្សារឧបករណ៍និស្សន្ទ ការពង្រឹងក្របខ័ណ្ឌត្រួតពិនិត្យ កសាងសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធ ជាដើម។

វិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាននៅកម្ពុជា មានកំណើនគួរឱ្យកត់សម្គាល់ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥** មក។ ស្របពេលដែលការយល់ដឹងរបស់សាធារណជន និងប្រតិបត្តិករអាជីវកម្មត្រូវបានលើកកម្ពស់ និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ (ន.អ.ប.) បានរៀបចំដាក់ចេញ និងកែសម្រួលបទប្បញ្ញត្តិជាច្រើន ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងកិច្ចការពារអាជីវកម្មស្របច្បាប់ក្នុងវិស័យនេះ។ បញ្ហាប្រឈមក្នុងអនុវិស័យនេះមាន ៤ សំខាន់ គឺបញ្ហារបាយការណ៍ត្រួតពិនិត្យនិងអនុលោមភាព កង្វះខាតធនធានមនុស្ស ការខ្វះខាតនូវការយល់ដឹងជាសាធារណៈ និងភាពមានកម្រិតនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ វិធានការសរុបចំនួន ១១២ ត្រូវបានដាក់ចេញ ហើយជាផែនការយុទ្ធសាស្ត្រ គឺនឹងអភិវឌ្ឍស្ថាប័ន ការតាមដាននិងវិភាគស្ថានភាពក្នុងវិស័យ រៀបចំបទប្បញ្ញត្តិនិងគោលនយោបាយពាក់ព័ន្ធ បណ្តុះបណ្តាលនិងផ្សព្វផ្សាយ ធ្វើទំនើបកម្ម និងកសាងប្រព័ន្ធទិន្នន័យគ្រប់ជ្រុងជ្រោយ។

និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) ដែលទទួលបន្ទុកគ្រប់គ្រង និងអភិវឌ្ឍវិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា មានតួនាទីសំខាន់ក្នុងការរៀបចំព័ត៌មាន និងរបាយការណ៍ហិរញ្ញវត្ថុប្រកបដោយតម្លាភាពសម្រាប់អង្គភាពឯកជន និងសាធារណៈ។ ន.គ.ស. បានសហការជាមួយវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ក្នុងការរៀបចំសិក្ខាសាលាដោយផ្ទាល់ និងតាមអនឡាញ បានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីពង្រឹងការគ្រប់គ្រង និងលើកកម្ពស់កម្រិតអនុលោមភាព។ បញ្ហាប្រឈមនៃអនុវិស័យនេះ គឺកង្វះខាតធនធានមនុស្សទាំងផ្នែកតម្រូវការនិងផ្នែកផ្គត់ផ្គង់ និងភាពមានកម្រិតក្នុងការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។ វិធានការសរុបចំនួន ៨៩ នឹងត្រូវបានដាក់ចេញ ដោយក្នុងនោះ រាជរដ្ឋាភិបាលនឹងពង្រឹងនូវការអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥** ដែលទទួលបានការអនុម័តដោយក្រុមប្រឹក្សា អ.ស.ហ. កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤។

វិស័យបរធនបាលកិច្ចត្រូវបានគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍដោយនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) ដែលមានតួនាទីសំខាន់ក្នុងការបង្កបរិយាកាសអំណោយផលដល់រំហូរវិនិយោគពីបរទេស និងការជួយគ្រប់គ្រងទ្រព្យសកម្មរបស់វិនិយោគិន។ គិតត្រឹមឆ្នាំ ២០២៣ កម្ពុជាបានដាក់ឱ្យដំណើរការទីផ្សារបរធនបាលកិច្ចជាមួយនឹងប្រតិបត្តិការពេញលេញ ដែលក្នុងនោះបរធនបាលកិច្ចដែលបានចុះបញ្ជីកើនឡើងដល់ចំនួន ៧៨៨ ករណី ជាមួយនឹងបរធនទំហំ ១ ២៧១ លានដុល្លារអាម៉េរិក។ បញ្ហាប្រឈមក្នុងវិស័យបរធនបាលកិច្ចមានចំនួនច្រើន ដោយវិស័យនេះនៅជាសញ្ញាណថ្មីនៅឡើយ ដោយក្នុងនោះមានដូចជាការខ្វះខាតធនធានមនុស្ស ដោយមិនទាន់អាចឆ្លើយតបទៅនឹងការវិវត្តន៍របស់ទីផ្សារបាន មិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ខណៈចំណេះដឹង និងការយល់ដឹងពីវិស័យបរធនបាលកិច្ចនៅមានកម្រិត។ ជារួម វិធានការសរុបដែលបានដាក់ចេញក្នុងអនុវិស័យនេះមានចំនួន ៦៩។ ជាផែនការសកម្មភាព ន.ប.ធ. នឹងផ្តោតសំខាន់លើការជំរុញការអភិវឌ្ឍ ការស្រាវជ្រាវ និងលើកកម្ពស់ការយល់ដឹងតាមរយៈការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលដល់វិនិយោគិនសក្តានុពល អ្នកចូលរួមទីផ្សារ និងសាធារណ-

ជនទូទៅ។ បន្ថែមលើនេះ ន.ប.ធ. នឹងបន្តពង្រឹងមុខងារស្ថាប័ន រួមមានការត្រួតពិនិត្យ ការលើកកម្ពស់ និងការពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិ និងកិច្ចការពារវិនិយោគិន។

រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ឱ្យប្រើប្រាស់ **គោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឆ្នាំ ២០២៣-២០២៨** ក្នុងគោលដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង។ ការសន្សំ ធានារ៉ាប់រង មូលបត្រ និងផលិតផលហិរញ្ញវត្ថុផ្សេងៗ នឹងក្លាយជាទិសដៅសំខាន់ ក្នុងការធ្វើសន្ទានកម្មទៅនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលអនាគត ក្នុងវិចារណកម្មដែលថា បច្ចេកវិទ្យាហិរញ្ញវត្ថុនឹងជួយជំរុញកំណើនដល់វិស័យផ្សេងៗ ដោយផ្តោតលើប្រព័ន្ធបច្ចេកវិទ្យា ជាពិសេសពាណិជ្ជកម្មអេឡិចត្រូនិក និងធុរកិច្ចថ្មី។ បញ្ហាប្រឈមសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ គឺកង្វះខាតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការមិនទាន់អភិវឌ្ឍថ្នាលឌីជីថលគ្រឹះថ្មីៗ ការខ្វះខាតធនធានមនុស្ស និងមិនមានការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ជាដើម។ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការសរុបចំនួន ២៦ ដោយក្នុងនោះ ធនាគារជាតិនៃកម្ពុជា និង អ.ស.ហ. នឹងសហការដោះស្រាយនូវកង្វះខាតចម្បងៗក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន យុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ វិធានការធនាគារបើកចំហ និងច្បាប់ទាក់ទងនឹងការចែករំលែកទិន្នន័យ និងឯកជនភាព។

ក្រៅពីបញ្ហាប្រឈមនៅតាមអនុវិស័យហិរញ្ញវត្ថុនីមួយៗ ក៏មានបញ្ហាអន្តរវិស័យពាក់ព័ន្ធចំនួន ៦ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ពោលគឺការចែករំលែកព័ត៌មានឥណទាន ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ហិរញ្ញវត្ថុប្រកបដោយចីរភាព យុទ្ធសាស្ត្រផ្នែកព័ត៌មាន អប់រំ និងទំនាក់ទំនង និងកិច្ចការពារអតិថិជន។ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវក្របខ័ណ្ឌនៃការតាមដាន និងវាយតម្លៃក្រោម **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដោយមាន **គណៈកម្មាធិការដឹកនាំការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០២៥-២០៣០** ជាសេនាធិការដោះស្រាយបញ្ហាប្រឈម និងធ្វើការរាយការណ៍ពីលទ្ធផលការងារជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជាចុងក្រោយ បន្ទាប់ពីដាក់ចេញ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០** វិធានការសរុបរួមទាំងវិស័យធនាគារ និងវិស័យមិនមែនធនាគារមានចំនួន ៨៦៦ វិធានការ ដោយក្នុងនោះ វិធានការក្រោមវិស័យធនាគារមានចំនួន ១០២ វិធានការ វិស័យមិនមែនធនាគារមានចំនួន ៦០៨ វិធានការ និងបញ្ហាអន្តរវិស័យពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមានចំនួន ១៥៦ វិធានការ។ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០** នឹងត្រូវបានប្រើប្រាស់ជាទិសដៅអនុវត្តរួមគ្នា ដោយត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តវិធានការដែលបានដាក់ចេញតាមវិស័យ និងអនុវិស័យនីមួយៗ។ ផ្អែកលើសមិទ្ធផលពីការអនុវត្តនូវវិធានការទាំងនេះ វិស័យហិរញ្ញវត្ថុអាចនឹងមានលទ្ធភាពវិវត្តខ្លួនទៅជាវិស័យរូបវន្តមួយ និងប្រែក្លាយជារបៀបវារៈគោលនយោបាយអាទិភាពយ៉ាងសំខាន់មួយសម្រាប់ការអភិវឌ្ឍកម្ពុជាបន្ថែមនាពេលអនាគត។

# ជំពូក ១

# និដ្ឋភាពទូទៅ

## I. សេចក្តីផ្តើម

ការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនារយៈពេលកន្លងមក បានធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ស្របពេលដែលរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បង្កើតការងារទាំងបរិមាណនិងគុណភាព លើកកម្ពស់សមភាព តាមរយៈការបន្តកាត់បន្ថយភាពក្រីក្រនិងបង្កើនការគាំពារសង្គម និងពង្រឹងស្ថាប័នសាធារណៈ ក្នុងគោលដៅឈានទៅជាប្រទេសដែលមានចំណូលខ្ពស់នាឆ្នាំ ២០៥០។ ដើម្បីសម្រេចបានគោលដៅទាំងនេះ រាជរដ្ឋាភិបាលបានសម្រេចធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០ ដើម្បីមានភាពរឹងមាំ ជវភាព ភាពធន់ និងពិពិធភាព ដែលអាចមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការសេវាហិរញ្ញវត្ថុក្នុងស្រុក ហើយរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ការធ្វើបច្ចុប្បន្នភាពនេះ គិតគូរលើចំណុចសំខាន់ៗចំនួន ៣ រួមមាន៖ i/-ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមក ក្រោមម្លប់សន្តិភាពនិងស្ថិរភាពនយោបាយ និងក្នុងអន្តរកាលចេញពីប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ii/-ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ និងការបែកខ្ញែកភូមិសាស្ត្រនយោបាយមកលើសេដ្ឋកិច្ចពិភពលោក និងតំបន់ និង iii/-ការខិតខំរិះរកវិធីសាស្ត្រថ្មីៗ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្នលើគ្រប់វិស័យ។

## II. ស្ថានភាព និងទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច

មុនវិបត្តិកូវីដ-១៩ កម្ពុជាជាប្រទេសមួយ ក្នុងចំណោមប្រទេសដទៃទៀត ដែលសម្រេចបានកំណើនសេដ្ឋកិច្ចលឿនជាងគេនៅក្នុងពិភពលោកក្នុងអត្រាមធ្យម ៧%។ កំណើនខ្ពស់នេះត្រូវបានទ្រទ្រង់ដោយវិស័យសេដ្ឋកិច្ចចម្បងៗ គួបផ្សំនឹងការដាក់ចេញ និងការបន្តអនុវត្តជាលំដាប់នូវយុទ្ធសាស្ត្រសំខាន់ៗ រួមមាន៖ យុទ្ធសាស្ត្រចតុកោណទាំង៤ ដំណាក់កាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងកម្មវិធីកែទម្រង់ចម្បងៗ របស់រាជរដ្ឋាភិបាល។ ទោះយ៉ាងណា ការថមថយកំណើនសេដ្ឋកិច្ចពិភពលោក ដោយសារវិបត្តិកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យដែលពឹងផ្អែកលើតម្រូវការខាងក្រៅ និងវិនិយោគផ្ទាល់ពីបរទេស ទទួលរងផលប៉ះពាល់ ជាពិសេសក្នុងឆ្នាំ ២០២០ ជាមួយនឹងកំណើន -៣,៦%។ ស្ថានភាពអតិផរណា ចាប់តាំងពីឆ្នាំ ២០១២ មកបន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ដោយអត្រាអតិផរណាមានការប្រែប្រួល ក្នុងចន្លោះ ១,២%។ នាឆ្នាំ ២០២២ អត្រាអតិផរណាបានកើនឡើងគួរឱ្យកត់សម្គាល់ ដល់ ៥,៥% ប៉ុន្តែបានធ្លាក់ចុះមកវិញ ត្រឹម ២,១% ក្នុងឆ្នាំ ២០២៣ ដោយសារការធ្លាក់ចុះនៃថ្លៃប្រេងអន្តរជាតិ និងម្ហូបអាហារ ក្រោយពីបានកើនខ្ពស់ក្នុងឆ្នាំ ២០២២។ ទន្ទឹមនេះ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ធៀបនឹងប្រាក់ដុល្លារអាម៉េរិក ក៏បានចូលរួមរក្សាអត្រាអតិផរណាឱ្យស្ថិតក្នុងកម្រិតទាប និងមានស្ថិរភាព ផងដែរ។ នាពេលខាងមុខ ការបង្កើនភាពបត់បែននៃអត្រាប្តូរប្រាក់ នឹងជួយលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ដែលនឹងបង្កើនប្រសិទ្ធភាពនយោបាយរូបិយវត្ថុជាតិ។ ប៉ុន្តែ កម្ពុជាបានគ្រប់គ្រងដោយជោគជ័យនៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងបានជួយស្រោចស្រង់និងជំរុញសកម្មភាពសេដ្ឋកិច្ចនិងធុរកិច្ច ព្រមទាំងរក្សាបានលំនឹងជីវភាពរស់នៅរបស់កម្មករនិយោជិត ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ ដែលកត្តាទាំងនេះបានធ្វើឱ្យសង្គម-សេដ្ឋកិច្ចកម្ពុជាវិលត្រលប់ទៅរកប្រក្រតីភាព និងងើបឡើងជាលំដាប់ បន្ទាប់ពីការបើកប្រទេសទាំងស្រុងនាចុងឆ្នាំ ២០២១។ ទន្ទឹមនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាមាននិន្នាការរីកចម្រើនជាបន្តបន្ទាប់ដោយនវានុវត្តន៍ថ្មីៗត្រូវបានសង្កេតឃើញនៅក្នុងវិស័យធនាគារ។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាច្រើនបានដាក់ឱ្យប្រើប្រាស់

សេវាធនាគារ តាមរយៈថ្នាលឌីជីថល ដែលរួមមាន សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត និងការទូទាត់សងប្រាក់តាមរយៈឃ្យូអរកូត។ ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុនេះ បានជំរុញឱ្យសេវាទូទាត់សងប្រាក់ឌីជីថលនៅក្នុងប្រទេសកម្ពុជាមានការពេញនិយមខ្លាំង ដោយសារភាពងាយស្រួល តម្លៃសមរម្យ និងសុវត្ថិភាព។ ដោយឡែកកម្ពុជាអាចប្រឈមនឹងហានិភ័យមួយចំនួនដែលអាចគំរាមកំហែងលើសន្ទុះកំណើន រួមមាន៖ i/-ភាពតានតឹងភូមិសាស្ត្រនយោបាយ និងការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច ii/-ការធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍យឺតជាងការរំពឹងទុក និង iii/-ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។

ក្នុងបរិការណ៍នៃការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ប្រព័ន្ធឌីជីថលនិងនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុត្រូវបានចាត់ទុកថានឹងរួមចំណែកយ៉ាងសំខាន់នៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។ ឧស្សាហកម្ម៤.០ត្រូវបានរំពឹងថានឹងនាំមកនូវបដិវត្តន៍នៅក្នុងដំណើរការនៃប្រព័ន្ធផលិតកម្ម ស្របពេលដែលហេដ្ឋារចនាសម្ព័ន្ធឌីជីថលក៏រំពឹងថានឹងផ្តល់នូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពខ្ពស់ ក្នុងការបង្កើនលទ្ធភាពស្វែងរកប្រាក់ចំណេញ កាត់បន្ថយការចំណាយ ធ្វើឱ្យប្រសើរឡើងនូវតម្លាភាព សន្តិសុខនិងសុវត្ថិភាព និងគុណភាពនៃសេវានិងផលិតផលហិរញ្ញវត្ថុ។

## III. ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជា

វិស័យហិរញ្ញវត្ថុកម្ពុជាបានអភិវឌ្ឍយ៉ាងឆាប់រហ័ស ហើយត្រូវបានគ្របដណ្តប់មួយភាគធំដោយវិស័យធនាគារ។ ប៉ុន្តែដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រនិន្នាការថ្មីៗទាក់ទងនឹងការអភិវឌ្ឍផលិតផល និងសេវាហិរញ្ញវត្ថុទាំងមូល រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅកម្ពុជា។

លើសពីនេះ ក្នុងការសម្រេចបានការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយភាពគ្រប់ជ្រុងជ្រោយ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវយុទ្ធសាស្ត្រនិងគោលនយោបាយជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដូចជាយុទ្ធសាស្ត្រតាមអាណត្តិរាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា និងគោលនយោបាយអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។ ម៉្យាងទៀត ក្របខ័ណ្ឌនិងផែនការអភិវឌ្ឍន៍ដែលផ្តោតលើវិស័យមួយចំនួន ក៏ត្រូវបានដាក់ចេញផងដែរ រួមមាន ក្របខ័ណ្ឌជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជាឆ្នាំ ២០២១-២០៣០។

## IV. ប្រព័ន្ធអេកូឡូស៊ីនៃវិស័យហិរញ្ញវត្ថុ

ផ្អែកទៅលើអាជ្ញាធរត្រួតពិនិត្យ វិស័យហិរញ្ញវត្ថុត្រូវបានបែងចែកជា ២ ផ្នែកធំៗ ដូចខាងក្រោម៖

- **ផ្នែកទី១៖** វិស័យធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានឥណទានជនបទ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន គ្រឹះស្ថានទូទាត់សងប្រាក់ និងអាជីវកម្មប្តូរប្រាក់។
- **ផ្នែកទី២៖** វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមមាន វិស័យធានារ៉ាប់រង វិស័យមូលបត្រ វិស័យសន្តិសុខសង្គម វិស័យអចលនវត្ថុនិងបញ្ចាំ វិស័យបរធនបាលកិច្ច និងវិស័យគណនេយ្យនិងសវនកម្ម ដែលស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ដោយឡែក វិស័យនេះស្ថិតក្រោមដំណាក់កាលនៃការអភិវឌ្ឍផ្សេងៗគ្នា ដូចជា វិស័យធានារ៉ាប់រងមានកំណើនគួរឱ្យកត់សម្គាល់

ចាប់តាំងពីឆ្នាំ ២០១២ ខណៈដែលវិស័យមូលបត្រស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ និងរបបសោធននិវត្តន៍ស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។

## V. ការរៀបចំរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ

ការរៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ មានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធ រួមមានៈ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ស្ថាប័នហិរញ្ញវត្ថុឯកជន ក្រុមហ៊ុនមកពីវិស័យឧស្សាហកម្ម និងអង្គការមិនមែនរដ្ឋាភិបាល។ ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភព-លោក អង្គការសហប្រជាជាតិ អង្គការពលកម្មអន្តរជាតិ និងមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានចូលរួមពិភាក្សាក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រនេះផងដែរ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពត្រូវបានបង្កើតឡើងដោយផ្អែកលើធាតុចូល និងមតិកែលម្អពីភាគីពាក់ព័ន្ធ និងរួមបញ្ចូលឧត្តមានុវត្តន៍អន្តរជាតិដែលសមស្របទៅនឹងបរិការណ៍កម្ពុជា។



# ជំពូក ២
# វិស័យធនាគារ

## I. និដ្ឋភាពទូទៅ

វិស័យធនាគារនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍ចុងក្រោយនេះ ទាំងទំហំទ្រព្យសកម្ម ឥណទាន ប្រាក់បញ្ញើ និងចំនួនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ក្នុងអំឡុងឆ្នាំ ២០១២ ដល់ឆ្នាំ ២០២៤ ទំហំទ្រព្យសកម្មរបស់វិស័យធនាគារកើនពី ៤៣,៦ ទ្រីលានរៀល ដល់ ៣៩៤,៧ ទ្រីលានរៀល។ ជាមួយគ្នានេះ ឥណទានកើនពី ២៣,៤ ទ្រីលានរៀល ដល់ ២១៩,៧ ទ្រីលានរៀល ហើយប្រាក់បញ្ញើកើនពី ២៦,៩ ទ្រីលានរៀល ដល់ ២១៩,៣ ទ្រីលានរៀល។ ចំនួនគណនីអ្នកខ្ចីប្រាក់កើនពី ៣៥៣.៦០៦ គណនី ដល់ ២,៣៩ លានគណនី និងចំនួនគណនីអ្នកដាក់ប្រាក់បញ្ញើកើនពីប្រមាណ ១,៤៩ លានគណនី ដល់ ២១,៦៩ លានគណនី។ ឥណទានមិនដំណើរការស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ជាមធ្យម ៧,៣%។ ទន្ទឹមនេះ លទ្ធភាពស្វែងរកប្រាក់ចំណេញមានការថមថយ ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម ជាមធ្យមមានកម្រិត ០,៩% និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក ជាមធ្យម មានកម្រិត ៥,៧%។

ធនាគារជាតិនៃកម្ពុជាលើកទឹកចិត្ត និងគាំទ្រការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការផ្តល់សេវាហិរញ្ញវត្ថុឌីជីថល ដែលរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់គោលដៅពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដល់ ៧០% ត្រឹមឆ្នាំ ២០២៥ និងកាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្តាលពី ២៧% មកត្រឹម ១៣%។ ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងវិស័យហិរញ្ញវត្ថុមានសារៈសំខាន់កាន់តែខ្លាំង សម្រាប់ពង្រីកអន្តរការិយកម្ម និងធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុនៅក្នុងទីផ្សារប្រកួតប្រជែង។ បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ជាចម្បងនៅក្នុងសេវាទូទាត់សងប្រាក់ និងសេវាផ្ទេរប្រាក់ និងបន្តពង្រីកជាបណ្តើរៗទៅសេវាសន្សំប្រាក់ និងសេវាឥណទាន។ ការដាក់ឱ្យប្រើប្រាស់យ៉ាងឿននូវបច្ចេកវិទ្យាហិរញ្ញវត្ថុ គឺជាការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យា ជាពិសេសក្នុងដំណើរការនៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការគាំទ្រដល់សេដ្ឋកិច្ចឌីជីថល។

## II. ការកែទម្រង់ និងសមិទ្ធផល

បន្ទាប់ពីបានដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ផែនការសកម្មភាពជាច្រើនត្រូវបានអនុវត្ត និងទទួលលទ្ធផលគួរឱ្យកត់សម្គាល់។ ផែនការសកម្មភាពសំខាន់ៗដែលសម្រេចបាន សម្រាប់វិស័យធនាគារ មានដូចខាងក្រោម៖

### ក. ច្បាប់និងបទប្បញ្ញត្តិ

ច្បាប់និងបទប្បញ្ញត្តិ មួយចំនួនសម្រាប់វិស័យធនាគារ ត្រូវបានដាក់ឱ្យអនុវត្ត និងកែសម្រួលជាបន្តបន្ទាប់ ស្របតាមនិយាមអន្តរជាតិនិងក្របខ័ណ្ឌបាសែល ដែលក្នុងនោះ បទប្បញ្ញត្តិប្រុងប្រយ័ត្នសំខាន់ៗដែលគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ រួមមាន ប្រកាសស្តីពី៖ i/-ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ឹមភែរមិន ii/-ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/-ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង iv/-ប្រកាស និងសេចក្តីណែនាំពាក់ព័ន្ធនឹងក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងពិនិត្យ និងកែសម្រួលបន្ថែមនូវបទប្បញ្ញត្តិមួយចំនួន រួមមាន ប្រកាសស្តីពី៖ i/-នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់ ii/-ការកំណត់ទ្រនាប់ដើមទុន និង iii/-ការផ្តល់សន្ទនីយភាព។

## ខ. ស្ថិរភាពហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបានបង្កើនសមត្ថភាពមន្ត្រី ក្នុងការវាយតម្លៃហានិភ័យជាប្រព័ន្ធ និងរៀបចំគោលនយោបាយ ពាក់ព័ន្ធនឹងស្ថិរភាពហិរញ្ញវត្ថុ។ ជាលទ្ធផល របាយការណ៍ដែលមានលក្ខណៈស្តង់ដារស្តីពីស្ថិរភាពហិរញ្ញវត្ថុកម្ពុជា ត្រូវបានរៀបចំឡើងនិងចេញផ្សាយជាលើកដំបូងនៅឆ្នាំ ២០១៩។ របាយការណ៍នេះវាយតម្លៃហានិភ័យចម្បងៗដែលអាចកើតមានចំពោះស្ថិរភាពហិរញ្ញវត្ថុ រួមមានហានិភ័យម៉ាក្រូសេដ្ឋកិច្ច ហានិភ័យជាប្រព័ន្ធ និងបញ្ហាផ្សេងៗ ពាក់ព័ន្ធនឹងម៉ាក្រូហិរញ្ញវត្ថុ ព្រមទាំងផ្តល់ជាគោលនយោបាយសំខាន់ៗ សំដៅកាត់បន្ថយហានិភ័យជាប្រព័ន្ធ។ នៅចុងឆ្នាំ ២០២៣ នាយកដ្ឋានស្ថិរភាពហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដើម្បីពង្រឹងគុណភាពនៃការវាយតម្លៃស្ថិរភាពហិរញ្ញវត្ថុឱ្យកាន់តែមានភាពស៊ីជម្រៅ។

លើសពីនេះ គណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា ដែលដឹកនាំដោយ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៩ ដើម្បីតាមដាននិងត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុជារួម និងដាក់ចេញនូវគោលនយោបាយ និងអន្តរាគមន៍សំខាន់ៗ។ ចំពោះការត្រៀមទប់ទល់នឹងវិបត្តិ និងការគ្រប់គ្រងវិបត្តិ ធនាគារជាតិនៃកម្ពុជា បានបង្កើតប្រព័ន្ធផ្តល់សញ្ញាជាមុនដែលមន្ត្រីត្រួតពិនិត្យធ្វើការវិភាគទិន្នន័យ និងតាមដានស្ថានភាពរបស់គ្រឹះស្ថាន ដោយពិនិត្យអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលបានដាក់ឱ្យអនុវត្ត ព្រមទាំងធ្វើស្ត្រេសតេស្ត ដើម្បីកំណត់ភាពរឹងមាំរបស់ប្រព័ន្ធធនាគារទៅនឹងហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។

សម្រាប់ការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ (DPS) ធនាគារជាតិនៃកម្ពុជាបាន៖ i/-បង្កើតក្រុមការងារលើប្រព័ន្ធ DPS ដែលដឹកនាំដោយធនាគារជាតិនៃកម្ពុជា ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០ និង ii/-បង្កើតនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ (DPD) នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ដោយស្ថិតក្រោមរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

## គ. ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុ

ទីផ្សារអន្តរធនាគារ និងរូបិយវត្ថុកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ដំបូងនៅឡើយ។ មូលបត្រអាចជួញដូរបាន (NCDs) (ជាប្រាក់រៀល និងដុល្លារអាម៉េរិក) ជាប័ណ្ណបំណុលរយៈពេលខ្លីដែលត្រូវបានបោះផ្សាយតាំងពីឆ្នាំ ២០១៣ ដើម្បីស្រូបយកសន្ទនីយភាពលើស និងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចូលរួមក្នុងទីផ្សាររូបិយវត្ថុអន្តរធនាគារ។ លើសពីនេះ ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការឧបករណ៍គោលនយោបាយផ្អែកលើយន្តការទីផ្សារ រួមទាំងផ្សារផ្សេងៗ ដូចខាងក្រោម៖

- ផ្សារធនាគារជាតិនៃកម្ពុជា (NBCP) ជាប្រព័ន្ធជួញដូរអេឡិចត្រូនិកដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធ្វើប្រតិបត្តិការតាមអនឡាញជាមួយសមាជិកដូចគ្នា ឬជាមួយធនាគារជាតិនៃកម្ពុជា។ បច្ចុប្បន្ន NBCP មានមុខងារក្នុងការដេញថ្លៃ ការចុះបញ្ជីមូលបត្រ ការជួញដូរមូលបត្ររដ្ឋ/រូបិយប័ណ្ណរវាងសមាជិកក្នុងផ្សារ ការរក្សាទុកមូលបត្រ ការទូទាត់ទឹកប្រាក់ចំពោះប្រតិបត្តិការជួញដូរ និងចែករំលែកព័ត៌មានជូនសមាជិក។ សមាជិកអាចប្រើប្រាស់ NBCP សម្រាប់ការដេញថ្លៃប្រតិបត្តិការ ផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដេញថ្លៃ NCDs ដេញថ្លៃមូលបត្ររដ្ឋ (Government Bond) ប្រតិបត្តិការជួញដូររូបិយប័ណ្ណ (FX) និងស្នើសុំសន្ទនីយភាព តាមរយៈការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) និងប្រតិបត្តិការអន្តរធនាគារដែលបានដាក់ឱ្យអនុវត្តដោយធនាគារជាតិនៃកម្ពុជា។
- មូលបត្រអាចជួញដូរបាន (ជាប្រាក់រៀល និងដុល្លារអាម៉េរិក) ជាប័ណ្ណបំណុលរយៈពេលខ្លីដែលត្រូវបានបោះផ្សាយតាំងពីឆ្នាំ ២០១៣ ដែលដើរតួនាទីជាឧបករណ៍រូបិយវត្ថុ ក្នុងការស្រូបសន្ទនីយភាពពីប្រព័ន្ធធនាគារ និងត្រូវបានប្រើប្រាស់ជាទ្រព្យធានាក្នុងប្រតិបត្តិការអន្តរធនាគារ។

- ប្រតិបត្តិការផ្តល់ LPCO ជាប្រតិបត្តិការទទួលទិញវិញ (Repo) ដែលបានដាក់ឱ្យដំណើរការ ដើម្បីផ្តល់សន្ទនីយភាពជារៀលដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមរយៈការដេញថ្លៃ។ ដើម្បីចូលរួមក្នុងប្រតិបត្តិការនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវដាក់មូលបត្រអាចជួញដូរបាន និង/ឬ មូលបត្ររដ្ឋជាទ្រព្យធានានៅធនាគារជាតិនៃកម្ពុជា បន្ទាប់ពីដេញថ្លៃឈ្នះ។
- ឧបករណ៍ផ្តល់ MLF ជាការផ្តល់សន្ទនីយភាពជារៀល ក្នុងរយៈពេល ១ ថ្ងៃដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដោយមានមូលបត្រអាចជួញដូរបាន និង/ឬ មូលបត្ររដ្ឋជាទ្រព្យធានា។ ឧបករណ៍នេះត្រូវបានដាក់ចេញ ដើម្បីអនុវត្តជាអត្រាការប្រាក់ពិដាននៃកូរីដ័រអត្រាការប្រាក់ (Interest Rate Corridor)។

មុខងារប្រតិបត្តិការអន្តរធនាគាររួមមាន កម្ចីដោយមានការធានា (Secured Lending) និងកម្ចីដោយមិនមានការធានា (Unsecured Lending) ត្រូវបានបញ្ចូលទៅក្នុងថ្នាលធនាគារជាតិនៃកម្ពុជា។ ការសិក្សាសមិទ្ធលទ្ធភាពក៏កំពុងត្រូវបានធ្វើឡើង ដើម្បីពិនិត្យលទ្ធភាពបញ្ចូលប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទៅក្នុងថ្នាលធនាគារជាតិនៃកម្ពុជារបស់ធនាគារជាតិនៃកម្ពុជាផងដែរ។

ច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី) ឆ្នាំ ២០២០ ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋឆ្នាំ ២០២១ និងក្របខ័ណ្ឌគោលនយោបាយស្តីពីថ្នាលធនាគារជាតិនៃកម្ពុជា ការអភិវឌ្ឍមូលបត្ររដ្ឋឆ្នាំ ២០២៣-២០២៨ គឺជាមូលដ្ឋានគ្រឹះ ក្នុងការអភិវឌ្ឍមូលបត្ររដ្ឋ ក្នុងនោះ ការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង ត្រូវបានធ្វើឡើងនាខែ កញ្ញា ឆ្នាំ ២០២២ និងបន្តរហូតមកទល់បច្ចុប្បន្ន។ ដំណើរការទីផ្សារមូលបត្ររដ្ឋនឹងជួយធនាគារជាតិនៃកម្ពុជាអនុវត្តប្រតិបត្តិការទីផ្សារចំហ ដើម្បីគ្រប់គ្រងសន្ទនីយភាពជាប្រាក់រៀលនៅក្នុងប្រព័ន្ធធនាគារ និងជួយកៀរគរមូលនិធិ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀល ព្រមទាំងដើរតួនាទីជាឧបករណ៍ហិរញ្ញវត្ថុដែលមានសុវត្ថិភាពនៅក្នុងទីផ្សាររូបិយវត្ថុអន្តរធនាគារ។

### ឃ. បរិយាបន្នហិរញ្ញវត្ថុ

បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាបានបង្ហាញពីនិន្នាការកើនឡើងជាលំដាប់ ដោយគិតត្រឹមឆ្នាំ ២០២១[១] ចំនួនប្រជាជនដែលទទួលបានសេវាហិរញ្ញវត្ថុមានកម្រិត ៦៧% នៃចំនួនប្រជាជនពេញវ័យសរុប។ ក្នុងគោលដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុប្រកបដោយចីរភាព រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់នូវ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ ២០១៩-២០២៥ សំដៅបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់បានទទួលសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្តាលពី ២៧% មកត្រឹម ១៣% និងបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី ៥៩% ទៅ ៧០% ត្រឹមឆ្នាំ ២០២៥។

ដើម្បីរួមចំណែកបង្កើនបរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសហការជាមួយដៃគូពាក់ព័ន្ធទាំងក្នុងប្រទេសនិងអន្តរជាតិ រួមមាន៖ i/-សហការជាមួយក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី ក្រោមគម្រោង "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី" ii/-សហការជាមួយគណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ (UNESCAP) ក្នុងការចាប់ផ្តើមអនុវត្តគម្រោង "ការជំរុញសហគ្រិនភាពរបស់ស្ត្រី" និងវគ្គបណ្តុះបណ្តាលសម្រាប់សហគ្រិនស្ត្រី iii/-សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ជ្រាបមុខវិជ្ជាហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ដើម្បីបង្កើនការយល់ដឹង និងការប្រើប្រាស់សេវាហិរញ្ញវត្ថុឱ្យមានភាពល្អប្រសើរឡើង។ ការសិក្សាមុខវិជ្ជាហិរញ្ញវត្ថុ ត្រូវបានចាប់ផ្តើមអនុវត្ត ហើយក្រសួងបានរៀបចំជាសៀវភៅមេរៀន និងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅតាមសាលាគោលដៅនៅក្នុងខេត្តចំនួន ៣ (ខេត្តកំពង់ចាម តាកែវ និងសៀមរាប) iv/-សហការជាមួយអង្គការ Good Return និងធនាគារអភិវឌ្ឍន៍អាស៊ីធ្វើយុទ្ធនាការផ្សព្វផ្សាយ "តោះនិយាយពីលុយៈ តក់ៗពេញបំពង់" ដែលផ្តោតលើសារៈសំខាន់នៃការសម្រេចចិត្តត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ និងជួយឱ្យ

---

[១] ប្រភព៖ Finscope

អតិថិជនអាចទទួលបានសេវាហិរញ្ញវត្ថុ សៀវភៅអប់រំផ្នែកហិរញ្ញវត្ថុមួយចំនួនក៏ត្រូវបានបែងចែកទៅតាមខេត្តគោលដៅ ផងដែរ និង v/-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ដើម្បីចែករំលែកព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន សាធារណជន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងសារៈសំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តបទប្បញ្ញត្តិ និងការត្រួតពិនិត្យ ព្រមទាំងភាតព្វកិច្ចនិងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងចំណេះដឹងក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីការពារសាធារណជនពីបញ្ហាបំណុលលើសលប់។

### ង. លទ្ធភាពទទួលបានឥណទានសហគ្រាសធុនតូចនិងមធ្យម

សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០២០ ជាសហគ្រាសសាធារណៈ ដើម្បីជំរុញបរិយាបន្នហិរញ្ញវត្ថុ និងការរីកចម្រើននៃសហគ្រាសធុនតូចនិងមធ្យម។ សាជីវកម្មធានាឥណទានកម្ពុជាធ្វើប្រតិបត្តិការក្រោមអាណាព្យាបាលបច្ចេកទេសនិងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ សាជីវកម្មធានាឥណទានកម្ពុជាបានដាក់ឱ្យដំណើរការនូវគម្រោងធានាឥណទាន រួមមាន៖ i/-គម្រោងធានាឥណទានសម្រាប់ស្តារអាជីវកម្ម ii/-គម្រោងធានាឥណទានសម្រាប់សហហិរញ្ញប្បទាន សម្រាប់វិស័យទេស-ចរណ៍ iii/-គម្រោងធានាឥណទានសម្រាប់សហគ្រិនស្ត្រី iv/-គម្រោងធានាឥណទានសម្រាប់វិស័យផលផលក្រោយប្រមូលផល v/-គម្រោងធានាឥណទានលើការប្រកួតប្រជែងខ្សែច្រវាក់តម្លៃកសិកម្ម និងលើកកម្ពស់សុវត្ថិភាពកសិកម្ម vi/-គម្រោងធានាឥណទានសម្រាប់ការនាំចេញអង្ករ vii/-គម្រោងហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព និង viii/-គម្រោងធានាឥណទានជាកញ្ចប់ ដើម្បីធានាលើកម្ចីដែលបញ្ចេញដោយបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមមួយចំនួនទៀតផងដែរ។ សាជីវកម្មធានាឥណទានកម្ពុជាមានគណនីធានាចំនួន ៣.១៣៩ ក្នុងទំហំទឹកប្រាក់សរុបចំនួន ២៥៦,៥៨ លានដុល្លារអាម៉េរិក (ប្រមាណ ១.០២៦,៣២ ប៊ីលានរៀល)។ សន្និធិឥណទានដែលមានការធានាសរុបមានចំនួន ១៤៩,៥៨លានដុល្លារអាម៉េរិក (ប្រមាណ ៥៩៨,៣២ ប៊ីលានរៀល) និងសមតុល្យសន្និធិទំហំការធានាឥណទានសរុបមានចំនួន ១០៩,៦១ លានដុល្លារអាម៉េរិក (ប្រមាណ ៤៣៨,៤៤ ប៊ីលានរៀល)។

ធនាគារសហគ្រាសធុនតូចនិងមធ្យម ម.ក (ធ.ស.ក.) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០២០ ក្នុងរូបភាពជាធនាគារគ្រប់គ្រងដោយរដ្ឋ ដែលមានបេសកកម្មជួយដល់អាជីវកម្មខ្នាតតូចនិងមធ្យមក្នុងស្រុក តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុ។ ធនាគារសហគ្រាសធុនតូចនិងមធ្យមក៏បានផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ដល់អតិថិជនគោលដៅ និងកៀរគរប្រាក់បញ្ញើពីសាធារណជនក្នុងគោលបំណងជំរុញដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច បង្កើនការនាំចេញ និងលើក-កម្ពស់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យម ដោយកាត់បន្ថយតម្រូវការទ្រព្យធានា។ ទន្ទឹមនេះ ធនាគារសហគ្រាសធុនតូចនិងមធ្យមជួយសម្រួលដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីទទួលបានមូលនិធិ តាមរយៈធនាគារកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្សេងទៀត។ ធនាគារ ធ.ស.ក. ក៏ផ្តល់សេវាហិរញ្ញវត្ថុផ្សេងទៀតដូចជា គម្រោងសហហិរញ្ញប្បទានសហគ្រាសធុនតូចនិងមធ្យម (SCFS) គម្រោងសហគ្រាសធុនតូចនិងមធ្យមកម្ពុជា (CSMES) សេវាគណនីសន្សំ និងគណនីសោធននិវត្តន៍ ផងដែរ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

### ក. ច្បាប់និងបទប្បញ្ញត្តិ

ប្រព័ន្ធការពារប្រាក់បញ្ញើនៅមិនទាន់ដាក់ឱ្យអនុវត្តនៅកម្ពុជានៅឡើយ។ បន្ទាប់ពីធនាគារជាតិនៃកម្ពុជាសម្រេចបង្កើតនាយកដ្ឋានការពារប្រាក់បញ្ញើ ការវិភាគដោយប្រើប្រាស់វិធីសាស្ត្របរិមាណនឹងត្រូវបានអនុវត្ត ដើម្បីកំណត់កម្រិតប្រាក់បញ្ញើដែលត្រូវបានការពារ ព្រមទាំងកំណត់ប្រភេទអតិថិជនដែលត្រូវបានធានាក្រោមប្រព័ន្ធការពារប្រាក់បញ្ញើ។

### ខ. ស្ថិរភាពហិរញ្ញវត្ថុ

ឆ្លើយតបនឹងផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវគោលនយោបាយ ដើម្បីជួយសម្រួលដល់ការរៀបចំឥណទានឡើងវិញ កាលពីខែ ឧសភា ឆ្នាំ ២០២០។ នៅពេលស្ថានភាពកូវីដ-១៩ មានភាពធូរស្រាល ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវសេចក្តីណែនាំស្តីពីកាតព្វកិច្ចសំវិធានធនទៅលើឥណទានដែលបានរៀបចំឡើងវិញ ខណៈដែលបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនមិនទាន់ត្រូវបានអនុវត្តទៅតាមកម្រិតកំណត់មុនការរីករាលដាលនៃជំងឺកូវីដ-១៩នៅឡើយ។ គិតត្រឹមខែ មិថុនា ឆ្នាំ ២០២២ ឥណទានរៀបចំឡើងវិញចំនួន ១០% ត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការ ហើយនៅឆ្នាំ ២០២៤ អនុបាតឥណទានមិនដំណើរការបានកើនឡើងដល់ ៧,៣% ធៀបនឹងឆ្នាំ ២០២៣ (៥,៤%) ដែលបានរួមចំណែកដល់ការថយចុះលទ្ធភាពស្វែងរកប្រាក់ចំណេញតាមរយៈកំណើនចំណាយសំវិធានធន ជាមួយនឹងអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិកចំនួន ០,៩% និង ៤,៧% រៀងគ្នា ទាបជាងឆ្នាំ ២០២៣ (១,១% និង ៥,៧%)។

ក្របខ័ណ្ឌដំណោះស្រាយចំពោះគ្រឹះស្ថានធនាគារដែលអសាធនភាព មិនទាន់ត្រូវបានដាក់ចេញនៅឡើយ។ ក្របខ័ណ្ឌនេះនឹងត្រូវបានរៀបចំឡើងផ្អែកលើឧត្តមានុវត្តន៍អន្តរជាតិ និងផ្តល់សិទ្ធិអំណាចនិងការណែនាំដល់អាជ្ញាធរត្រួតពិនិត្យទាក់ទងនឹងដំណើរការដែលត្រូវអនុវត្ត ក្នុងករណីដែលគ្រឹះស្ថានធនាគារណាមួយមានអសាធនភាពនាពេលខាងមុខ។ បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជានៅមិនទាន់មានការរំខានជាប្រព័ន្ធណាមួយដែលកើតចេញពីការបរាជ័យរបស់គ្រឹះស្ថានធនាគារនៅឡើយទេ។ យ៉ាងណាមិញ វិស័យធនាគារមានភាពប្រទាក់ក្រឡាខ្លាំងជាមួយវិស័យអចលនទ្រព្យ។ ហេតុនេះ ក្នុងករណីវិស័យអចលនទ្រព្យមានការធ្លាក់ចុះ នោះតារាងតុល្យការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏នឹងទទួលរងផលប៉ះពាល់ផងដែរ ដែលអាចនាំឱ្យទ្រព្យសកម្មមិនដំណើរការកើនឡើង។

### គ. ការរាយការណ៍ និងការអនុលោមផ្នែកត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់ប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ (SRS) ដើម្បីត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ប្រព័ន្ធនេះកំពុងត្រូវបានកែលម្អ ដើម្បីពង្រឹងប្រសិទ្ធភាពសម្រាប់កំណត់សូចនាករទស្សនអនាគតក្នុងការវិភាគនិងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ឃ. លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ

ការយល់ដឹងនិងការស្វែងយល់អំពីដំណើរការពាក់ព័ន្ធនឹងការស្នើសុំឥណទានផ្លូវការ នៅមានកម្រិតនៅឡើយ។ ទន្ទឹមនេះ លទ្ធភាពមិនគ្រប់គ្រាន់ក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ បានបង្កើនការពឹងផ្អែកលើប្រភពឥណទានក្រៅផ្លូវការដែលមានអត្រាការប្រាក់ខ្ពស់ខ្លាំង។

### ង. ការចែករំលែកព័ត៌មានឥណទាន

ការិយាល័យឥណទាន ជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលរួមចំណែកដល់ការវាយតម្លៃលទ្ធភាពសងរបស់អតិថិជន។ ទោះយ៉ាងណា ដើម្បីវាយតម្លៃលទ្ធភាពសងរបស់អតិថិជន គ្រឹះស្ថានត្រូវមានលទ្ធភាពពេញលេញក្នុងការទទួលបានប្រវត្តិឥណទានរបស់អ្នកខ្ចីប្រាក់។ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា មិនតម្រូវឱ្យចែករំលែកទិន្នន័យជាមួយការិយាល័យឥណទាននោះទេ។

### ច. ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ

#### ច.១. ទីផ្សាររូបិយវត្ថុ

ទោះបីជាមានវត្តមានទីផ្សាររូបិយវត្ថុអន្តរធនាគារ ប៉ុន្តែចំនួនប្រតិបត្តិការអ្នកចូលរួម និងឧបករណ៍ហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។ ម៉្យាងទៀត ឧបករណ៍ទីផ្សាររូបិយវត្ថុពុំទាន់មានវត្តមានទូលំទូលាយលើទីផ្សារនៅឡើយទេ

ដែលឧបករណ៍ទាំងនោះ រួមមាន ប័ណ្ណរតនាគារ ផលបត្រពាណិជ្ជកម្ម និងការផ្ដល់កម្ចីមានកាលកំណត់រវាងធនាគារជាដើម។ នៅក្នុងសេដ្ឋកិច្ច វិស័យសាជីវកម្មពឹងផ្អែកលើធនាគារសម្រាប់តម្រូវការហិរញ្ញវត្ថុខាងក្រៅ ស្របពេលដែលធនាគារទាំងនោះពឹងផ្អែកលើធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងសន្ទនីយភាព។ បច្ចុប្បន្ន អត្រាការប្រាក់ដេញថ្លៃដែលទទួលបានជោគជ័យនៅក្នុងការដេញថ្លៃប្រតិបត្តិការ LPCO ត្រូវបានប្រើជាអត្រាគោលសម្រាប់កំណត់អត្រាការប្រាក់ឥណទាន។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងប្រើប្រាស់ MLF NCD និងឧបករណ៍នយោបាយរូបិយវត្ថុផ្សេងទៀតសម្រាប់ការបង្កើតអត្រាការប្រាក់គោល និងការអនុវត្តនយោបាយរូបិយវត្ថុ។ កម្រិតខ្ពស់នៃការប្រើប្រាស់ប្រាក់ដុល្លារអាម៉េរិកនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនៅតែបន្តជាឧបសគ្គចម្បងក្នុងការប្រើប្រាស់ឧបករណ៍ផ្អែកលើយន្តការទីផ្សារសម្រាប់ការអនុវត្តនយោបាយរូបិយវត្ថុ។ ការធ្វើប្រតិបត្តិការទីផ្សារចំហ និងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់បន្តមានបញ្ហាប្រឈមក្នុងការអនុវត្តនយោបាយរូបិយវត្ថុ។

**ច.២. ទីផ្សារមូលបត្ររដ្ឋ**

ទីផ្សារមូលបត្ររដ្ឋស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។ បច្ចុប្បន្ន ការគ្រប់គ្រងសន្ទនីយភាពត្រូវបានធ្វើឡើងតាមរយៈការប្រើប្រាស់មូលបត្រជួញដូរបាន ប្រាក់បម្រុងកាតព្វកិច្ច និងការដេញថ្លៃប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា។ ទោះយ៉ាងណា នៅពេលដែលប្រទេសឈានទៅរកការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែច្រើន នោះតម្រូវការក្នុងការគ្រប់គ្រងសន្ទនីយភាពប្រាក់រៀលនឹងកើនឡើង។ បើទោះបីជាមូលបត្ររដ្ឋ ត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងរង្វង់អន្តរធនាគារតាមថ្នាលរបស់ធនាគារជាតិនៃកម្ពុជាក៏ដោយ ក៏ប៉ុន្តែ ជាក់ស្តែង ពុំទាន់មានប្រតិបត្តិការជួញដូរណាមួយនៅលើទីផ្សារនៅឡើយទេ។

**ច.៣. ទីផ្សារហិរញ្ញវត្ថុ**

ដោយសារប្រភពទុនភាគច្រើនជាប្រាក់ដុល្លារអាម៉េរិក ក្នុងគោលដៅជួយគាំទ្រនិងជំរុញការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយជាប្រាក់រៀល ធនាគារជាតិនៃកម្ពុជានឹងអភិវឌ្ឍឧបករណ៍ហិរញ្ញវត្ថុពីរបន្ថែមទៀត គឺឧបករណ៍ហ្វរវើត (Forward) និងឧបករណ៍ស្វប់ (Swap) សម្រាប់ការពារហានិភ័យប្តូរប្រាក់។ វត្តមានឧបករណ៍ទាំងពីរនេះនឹងជួយដល់វិនិយោគិនដែលមានប្រភពទុនជាប្រាក់ដុល្លារអាម៉េរិក និងមានបំណងវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុដែលចរិតជាប្រាក់រៀលទទួលបានជម្រើស និងមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការការពារហានិភ័យអត្រាប្តូរប្រាក់។

**ឆ. ផ្នែកផ្សេងៗ**

ការផ្ដល់កម្ចីក្រៅផ្លូវការនៅតែមានសមាមាត្រគួរឱ្យកត់សម្គាល់ ធៀបនឹងឥណទានសរុបនៅកម្ពុជា។ កម្ចីក្រៅផ្លូវការមានអត្រាការប្រាក់ខ្ពស់ និងទាមទារឯកសារនិងទ្រព្យធានាតិចតួច។ ការណ៍នេះបានជះឥទ្ធិពលអវិជ្ជមានដល់អ្នកខ្ចីដែលមិនមានលទ្ធភាពសងត្រលប់ និងរាំងការទទួលបានឥណទានផ្លូវការពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យធនាគារ

### ក. ស្ថិរភាពហិរញ្ញវត្ថុ

**បង្កើនភាពញឹកញាប់នៃការបោះផ្សាយរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ៖** ធនាគារជាតិនៃកម្ពុជាបានយល់ឃើញពីសារៈសំខាន់នៃការវាយតម្លៃស្ថិរភាពហិរញ្ញវត្ថុជាប្រចាំ និងការបោះផ្សាយរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ។ របាយការណ៍នេះបានបង្ហាញពីការវាយតម្លៃយ៉ាងលម្អិតលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជាជាមួយនឹងការវាយតម្លៃការអនុវត្តកាតព្វកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ បន្ថែមពីនេះ របាយការណ៍ស្ថិរភាពហិរញ្ញវត្ថុបានរំលេចនូវការយល់ឃើញសំខាន់ៗដែលបានមកពីការវាយតម្លៃពីស្ថានភាពនិងស្ថិរភាពរបស់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រង និងវិស័យមិនមែនធនាគារផ្សេងៗទៀត។ និន្នាការវិវត្តន៍នៅក្នុងប្រព័ន្ធទូទាត់និងផាត់ទាត់ក៏ត្រូវបានបង្ហាញក្នុងរបាយការណ៍នេះផងដែរ។ ក្នុងសេណារីយ៉ូនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពិភពលោកដែលមានលក្ខណៈជវភាព គួបផ្សំនឹងការវិវត្តន៍នៃទំនាក់ទំនងរវាងប្រទេសនានា

ការកំណត់និងវាស់វែងឥទ្ធិពលសក្តានុពលនៃហានិភ័យទាំងនោះមកលើវិស័យហិរញ្ញវត្ថុកម្ពុជាជាប្រចាំពិតជាមានសារៈសំខាន់ណាស់។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការបង្កើនការបោះផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឱ្យបានញឹកញាប់។

**ដំណោះស្រាយធនាគារ៖** ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំសេចក្តីព្រាងនៃក្របខ័ណ្ឌនិងបទប្បញ្ញត្តិដោះស្រាយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានបញ្ហា ដោយចាត់វិធានការចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលប្រឈមនឹងការដួលរលំ។

**ប្រព័ន្ធការពារប្រាក់បញ្ញើ៖** ការបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើនឹងត្រូវបានអនុវត្តជាមូលដ្ឋានបន្តិចម្តងៗ។ ជាការចាប់ផ្តើម ធនាគារជាតិនៃកម្ពុជា បានបង្កើតនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ ដែលទទួលខុសត្រូវលើះ i/-ការរៀបចំបទប្បញ្ញត្តិស្តីពីកិច្ចការពារប្រាក់បញ្ញើ និង ii/-ការរៀបចំសេចក្តីព្រាងប្រកាសដោយឡែកពាក់ព័ន្ធនឹងការអនុវត្តយន្តការកិច្ចការពារប្រាក់បញ្ញើដូចជាៈ នីតិវិធីចូលជាសមាជិក ការកំណត់បុព្វលាភ ទំហំអតិបរមានៃសំណង នីតិវិធីក្នុងការផ្តល់សំណង ប្រភពនិងការប្រើប្រាស់មូលនិធិកិច្ចការពារប្រាក់បញ្ញើ ការវិនិយោគមូលនិធិកិច្ចការពារប្រាក់បញ្ញើ ជាដើម។

**ខ. របាយការណ៍ត្រួតពិនិត្យ និងការអនុលោមតាមបទប្បញ្ញត្តិ**

ធនាគារជាតិនៃកម្ពុជា កំពុងធ្វើបច្ចុប្បន្នភាពលើហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាដែលមានស្រាប់សម្រាប់ការត្រួតពិនិត្យដោយរួមបញ្ចូលសមត្ថភាពនៃបច្ចេកវិទ្យាត្រួតពិនិត្យ និងបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលនៃប្រព័ន្ធត្រួតពិនិត្យទូទៅ។

**គ. លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ**

**គ.១. ការតាមដាននិងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ**

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាស្ថាប័នដឹកនាំបានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ ដើម្បីសម្រេចបានគោលដៅជាបន្តបន្ទាប់នៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុដែលនៅសេសសល់។ ទន្ទឹមនេះ ការអនុវត្តយុទ្ធសាស្ត្រជាតិនេះក៏ទាមទារឱ្យមានការតាមដាននិងវាយតម្លៃ ដែលនឹងផ្តល់ជាធាតុចូលដើម្បីអភិវឌ្ឍដំណាក់កាលបន្ទាប់សម្រាប់យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ។

**គ.២. ការបង្កើនលទ្ធភាពទទួលបាននិងការផ្តល់សេវាឥណទានចំគោលដៅ**

**១/-លើកកម្ពស់ការអភិវឌ្ឍថ្នាលហិរញ្ញប្បទានធានាដោយចលនវត្ថុ ដើម្បីពង្រីកការទទួលបានដើមទុនអាជីវកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យម៖** ធនាគារជាតិនៃកម្ពុជាបានចុះ MOU ជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីអនុវត្តគម្រោងការអភិវឌ្ឍខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុកម្ពុជា ដែលមានគោលដៅអភិវឌ្ឍន៍ទីផ្សារខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ និងពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងកម្ពុជា។ យោងតាម MOU នេះ ការបណ្តុះបណ្តាលមួយចំនួនត្រូវបានរៀបចំជូនមន្ត្រីធនាគារជាតិនៃកម្ពុជា។ ការបង្កើតថ្នាលគណនីត្រូវទទួល (Account Receivable) លើកដំបូង និងថ្នាលហិរញ្ញប្បទានខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងកម្ពុជា ជាជំហានដ៏សំខាន់មួយ ដើម្បីដោះស្រាយការខ្វះខាតនៃទុនបង្វិលរបស់អាជីវកម្ម។ វិធីសាស្ត្រមួយចំនួន សម្រាប់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីរបស់គណនីដែលត្រូវទទួល និងថ្នាលហិរញ្ញប្បទានខ្សែច្រវាក់ផ្គត់ផ្គង់ មានដូចជាៈ

- **លើកទឹកចិត្តដល់ការបង្កើតបន្ថែមនូវថ្នាលគណនីដែលត្រូវទទួល និងហិរញ្ញប្បទានខ្សែច្រវាក់ផ្គត់ផ្គង់៖** សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានគាំទ្រ "ក្រុមហ៊ុនបញ្ជី" ក្នុងការរៀបចំបង្កើតថ្នាលគណនីដែលត្រូវទទួលលើកដំបូង និងហិរញ្ញប្បទានខ្សែច្រវាក់ផ្គត់ផ្គង់នៅកម្ពុជា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងប្រើប្រាស់វិធានការលើកទឹកចិត្តនានា រួមមាន ការផ្តល់ហិរញ្ញប្បទាន ការប្រឹក្សាយោបល់ និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីជំរុញសហគ្រាស/អង្គការនានា ឱ្យអភិវឌ្ឍថ្នាលបន្ថែមទៀត។
- **ការចូលរួមរបស់ CGCC ក្នុងថ្នាលគណនីដែលត្រូវទទួល និងហិរញ្ញប្បទានខ្សែច្រវាក់ផ្គត់ផ្គង់៖** ការចូលរួមរបស់សាជីវកម្មធានាឥណទានកម្ពុជាទៅក្នុងថ្នាលទាំងនេះ គឺការផ្តល់ការធានាដល់គ្រឹះស្ថានហិរញ្ញវត្ថុ

លើហានិភ័យឥណទាន ដែលកើតចេញពីការមិនសងបំណុលរបស់អ្នកលក់ (ក្នុងករណីហិរញ្ញប្បទានលើការលក់គណនីត្រូវទទួល) និងរបស់ក្រុមហ៊ុនជាអ្នកទិញ (ក្នុងករណីហិរញ្ញប្បទានលើការលក់គណនីត្រូវទទួលត្រលប់) ដែលនឹងលើកកម្ពស់ដល់ការចូលរួមរបស់គ្រឹះស្ថានហិរញ្ញវត្ថុទៅក្នុងថ្នាលទាំងនេះ។ វិសាលភាពនិងទំហំនៃការធានាឥណទាន (ដែលនឹងផ្តល់ជូន) នឹងត្រូវបានកំណត់ ដោយកិច្ចពិគ្រោះពិភាក្សារវាងសាជីវកម្មធានាឥណទានកម្ពុជា ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា។

- **បង្កើនការធានាដែលផ្តល់ដោយសាជីវកម្មធានាឥណទានកម្ពុជា៖** ទំហំនៃការធានារបស់សាជីវកម្មធានាឥណទានកម្ពុជានឹងត្រូវបានកំណត់ ក្នុងកម្រិតមួយ ដោយផ្អែកលើគុណភាពឥណទានរបស់សហគ្រាស។ លទ្ធភាពបង្កើនទំហំនៃការធានារបស់សាជីវកម្មធានាឥណទានកម្ពុជា ដោយមានការចូលរួមពីក្រុមហ៊ុនធានារ៉ាប់រង និងការគាំទ្រចាំបាច់ផ្សេងទៀតពីរាជរដ្ឋាភិបាលនឹងត្រូវបានសិក្សាផងដែរ។
- **លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចូលរួមក្នុងថ្នាល ក្នុងនាមជាគ្រឹះស្ថានផ្តល់សេវាហិរញ្ញប្បទានលើការលក់គណនីត្រូវទទួល៖** គ្រឹះស្ថានធនាគារនឹងត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងថ្នាលទាំងនេះ ក្នុងនាមជាគ្រឹះស្ថានផ្តល់សេវាហិរញ្ញប្បទានលើការលក់គណនីត្រូវទទួល ស្របពេលដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏នឹងទទួលបានព័ត៌មានអំពីអត្ថប្រយោជន៍ និងជំរុញឱ្យមានការចូលរួមផងដែរ។
- **កំណត់ការប្រើប្រាស់ថ្នាលទាំងនេះសម្រាប់បណ្តាក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖** បណ្តាក្រសួង-ស្ថាប័នដើរតួនាទីដ៏សំខាន់ក្នុងការជួយផ្សព្វផ្សាយនិងគាំទ្រការប្រើប្រាស់ថ្នាលទាំងនេះ ក៏ដូចជាបង្ហាញអំពីការទទួលបានអត្ថប្រយោជន៍ពីសេវាហិរញ្ញប្បទាន លើការលក់គណនីត្រូវទទួលត្រលប់ដែលអាចធានាបានថាការទូទាត់សងប្រាក់ជូនសហគ្រាសធុនតូចនិងមធ្យម ត្រូវបានធ្វើឡើងទាន់ពេលវេលា។ បណ្តាក្រសួង-ស្ថាប័ននានាត្រូវមានទំនួលខុសត្រូវក្នុងការជំរុញការប្រើប្រាស់ថ្នាលនេះ។ ជំហានបន្ទាប់នឹងត្រូវតម្រូវឱ្យមានការចូលរួមអនុវត្តពីបណ្តារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញការផ្សព្វផ្សាយនិងប្រើប្រាស់ថ្នាលខាងលើ។
- **លើកទឹកចិត្តឱ្យមានការចូលរួមពីសហគ្រាសរដ្ឋ និងសហគ្រាសផ្សេងៗក្នុងវិស័យឯកជននៅក្នុងថ្នាល៖** ផែនទីមគ្គុទេសក៍មួយសម្រាប់ដំណើរការនៃការចូលរួមរបស់សហគ្រាសរដ្ឋទៅក្នុងថ្នាល កំពុងត្រូវបានរៀបចំជាបណ្តើរៗ។ កម្មវិធីលើកកម្ពស់ការយល់ដឹងនានា នឹងត្រូវរៀបចំឡើងដើម្បីបង្ហាញអំពីសារៈប្រយោជន៍នៃថ្នាលទាំងនេះដល់សហគ្រាសរដ្ឋ និងសហគ្រាសផ្សេងៗក្នុងវិស័យឯកជន ដើម្បីជំរុញសហគ្រាសទាំងនោះឱ្យចូលរួមប្រើប្រាស់ថ្នាលនេះទាំងអស់គ្នា។
- **ការចេញវិក្កយបត្របង់ប្រាក់ជាមុន ដោយក្រុមហ៊ុនសាជីវកម្ម ដើម្បីសម្រួលការទទួលហិរញ្ញប្បទានធានាដោយគណនីដែលត្រូវទទួល សម្រាប់ម្ចាស់សហគ្រាសធុនតូចនិងមធ្យម៖** ក្រុមហ៊ុនសាជីវកម្មដែលមានសមតុល្យសាច់ប្រាក់លើស និងមានភាពងាយស្រួល ក្នុងការទទួលបានហិរញ្ញប្បទាន ពីគ្រឹះស្ថានធនាគារ អាចទូទាត់វិក្កយបត្រជាមុនជូនម្ចាស់អាជីវកម្មក្នុងតម្លៃអប្បហារ ដោយមានការព្រមព្រៀងគ្នា ដែលការណ៍នេះនឹងជួយដោះស្រាយលើតម្រូវការដើមទុនអាជីវកម្ម សម្រាប់ម្ចាស់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងជួយដល់ក្រុមហ៊ុនសាជីវកម្មក្នុងការគ្រប់គ្រងសាច់ប្រាក់របស់ខ្លួនឱ្យបានល្អប្រសើរ។ សកម្មភាពបែបនេះអាចធ្វើបាននៅលើថ្នាលដែលមានស្រាប់ចំពោះវិក្កយបត្រដែលមានតម្លៃអប្បហារ ឬថ្នាលដែលត្រូវបានបង្កើតឡើងតាមតម្រូវការសម្រាប់គោលបំណងជាក់លាក់។

**២/-ការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំង៖** ជាវិធីសាស្ត្រដ៏សំខាន់មួយផ្សេងទៀតក្នុងការអនុវត្តការផ្តល់ហិរញ្ញប្បទានធានាដោយចលនវត្ថុ ដែលអាចជួយដល់សហគ្រាសក្នុងការពង្រឹងដំណើរការគ្រប់គ្រងសន្និធិ និងបង្កើនលទ្ធភាពទទួលបានលំហូរសាច់ប្រាក់។ រាជរដ្ឋាភិបាលកម្ពុជាគាំទ្រការបង្កើតប្រព័ន្ធអេកូឡូស៊ីហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំងដែលមានប្រសិទ្ធភាព ហើយបានធ្វើការសិក្សាសមិទ្ធិលទ្ធភាពក្នុងការងារនេះ។ ឃ្លាំងទំនើបចំនួន ១៨ ត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រងទំនិញកសិកម្មនៅទីតាំងផ្សេងៗគ្នាក្នុងប្រទេស ហើយអាចជួយដល់ការអនុវត្ត

ការផ្ដល់ហិរញ្ញប្បទានដោយផ្អែកលើស្តុកកសិផលក្នុងឃ្លាំងផងដែរ។ វិធីសាស្ត្រមួយចំនួនដែលបានគ្រោងទុកសម្រាប់ពង្រឹងការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំង ត្រូវបានរៀបរាប់ដូចខាងក្រោម៖

- **រៀបចំសេចក្តីណែនាំសម្រាប់ការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំង៖** សេចក្តីណែនាំសម្រាប់ការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំង នឹងត្រូវបានរៀបចំឡើងតាមរយៈការយល់ដឹងពីការសិក្សាសមិទ្ធិលទ្ធភាពនេះ។ សេចក្តីណែនាំនឹងក្លាយជាគោលការណ៍សម្រាប់ធានាបាននូវសុចរិតភាព ប្រសិទ្ធភាព និងស្ថិរភាពនៃការផ្តល់ហិរញ្ញប្បទាន។ សេចក្តីណែនាំនឹងចង្អុលបង្ហាញស្តង់ដារគ្រប់គ្រងទ្រព្យធានា (អនុវត្តបានសម្រាប់ការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំង) តម្រូវការនៃសេចក្តីបញ្ជាក់និងធានារ៉ាប់រងសម្រាប់ទំនិញក្នុងឃ្លាំង លក្ខខណ្ឌហិរញ្ញប្បទាន ត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំរបាយការណ៍។
- **បង្កើតទម្រង់នៃកិច្ចព្រមព្រៀងតាមដានស្តុកទំនិញ (SMA) និងកិច្ចព្រមព្រៀងការគ្រប់គ្រងទ្រព្យធានា (CoMA)៖** កិច្ចព្រមព្រៀងទាំងពីរនេះជាប្រភេទនៃការរៀបចំត្រីភាគី (រួមមាន អ្នកផ្តល់ឥណទាន អ្នកទិញ និងក្រុមហ៊ុនគ្រប់គ្រងទ្រព្យធានា) សម្រាប់អនុវត្តយន្តការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើសន្និធិក្នុងឃ្លាំង។ ទម្រង់មួយៗនៃកិច្ចព្រមព្រៀងទាំងពីរនេះ នឹងត្រូវបានរៀបចំ ហើយដាក់ឱ្យប្រើប្រាស់ជាសាធារណៈ។
- **រៀបចំវគ្គបណ្តុះបណ្តាលការយល់ដឹងអំពីវិធីសាស្ត្រនិងអត្ថប្រយោជន៍នៃការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើស្តុកទំនិញក្នុងឃ្លាំង៖** សកម្មភាពសម្រាប់ដំណាក់កាលបន្ទាប់នឹងមានគោលដៅបង្កើតការយល់ដឹងអំពីយន្តការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើស្តុកទំនិញក្នុងឃ្លាំង និងលើកកម្ពស់ការចូលរួមពីអង្គភាពពាក់ព័ន្ធ។ ធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានឹងសហការគ្នាដើម្បីផ្សព្វផ្សាយពីបទប្បញ្ញត្តិ និងអត្ថប្រយោជន៍នៃការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើស្តុកទំនិញក្នុងឃ្លាំងក្នុងចំណោមសមាសភាពចូលរួមដែលមានសក្តានុពល។ លើសពីនេះ បញ្ជីឈ្មោះក្រុមហ៊ុនគ្រប់គ្រងទ្រព្យធានាដែលបានចុះបញ្ជីនឹងត្រូវបានប្រកាសជាសាធារណៈ ហើយព័ត៌មានលម្អិតនៃក្រុមហ៊ុនចុះបញ្ជីទាំងនេះក៏នឹងត្រូវបានផ្សព្វផ្សាយក្នុងវគ្គបណ្តុះបណ្តាលចំណេះដឹងផងដែរ។
- **គាំទ្រការអភិវឌ្ឍថ្នាលអេឡិចត្រូនិកសម្រាប់សម្រួលដល់ការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើស្តុកទំនិញក្នុងឃ្លាំង៖** ការបង្កើតថ្នាលអេឡិចត្រូនិកសម្រាប់ការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើទំនិញក្នុងឃ្លាំងនឹងនាំមកនូវការប្រើប្រាស់កាន់តែងាយស្រួល លទ្ធភាពទទួលបានកាន់តែច្រើនចំពោះភាគីពាក់ព័ន្ធ និងតម្លាភាពកាន់តែប្រសើរ។ ក្រុមហ៊ុន ឬសហគ្រាស ដែលបង្កើតថ្នាលទាំងនេះ នឹងទទួលបានការលើកទឹកចិត្ត និងជំនួយសមស្របណាមួយ។ លើសពីនេះ ប្រតិបត្តិករនៃថ្នាលហិរញ្ញប្បទានធានាដោយគណនីដែលត្រូវទទួល និងខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ នឹងទទួលការលើកទឹកចិត្តក្នុងការពង្រីកសំពៀតសេវាកម្មផ្សេងៗ ដើម្បីរួមបញ្ចូលការផ្តល់ហិរញ្ញប្បទានដោយផ្អែកលើស្តុកទំនិញក្នុងឃ្លាំង។

**គ.៣. រៀបចំបង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយចំណេះដឹងនិងការយល់ដឹងសម្រាប់វិស័យធនាគារ**

យុទ្ធសាស្ត្រនេះនឹងត្រូវរៀបចំឡើងសម្រាប់រយៈពេលមធ្យមនិងវែង ដោយបញ្ចូលនូវបញ្ហាប្រឈមកំពុងកើតមានគោលបំណងសំខាន់ៗ និងវិធានការរំពឹងទុក ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការយល់ដឹងសម្រាប់វិស័យធនាគារ ដែលត្រូវបានអមដោយផែនទីមគ្គុទេសក៍ និងវិធីសាស្ត្រផ្គូផ្គងភាគីពាក់ព័ន្ធ ដើម្បីធានាថាភាគីពាក់ព័ន្ធយល់ដឹងអំពីទំនួលខុសត្រូវ និងអនុវត្តទៅតាមភារកិច្ចរៀងៗខ្លួន។

**គ.៤. បង្កើតថ្នាលសម្រាប់លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ**

មធ្យោបាយផ្សាភ្ជាប់គ្នាទាំងឌីជីថលនិងដោយផ្ទាល់ អាចពង្រឹងប្រសិទ្ធភាពនៃវិធីសាស្ត្រសម្រាប់លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ ការបង្កើតថ្នាលជាច្រកចេញ-ចូលតែមួយនេះ នឹងត្រូវបានសិក្សាដើម្បីធានាថាពាល់ជំនួយការសិក្សា កម្មវិធីបណ្តុះបណ្តាល និងនវានុវត្តន៍ឌីជីថល អាចរកបានយ៉ាងទូលំទូលាយជាសាធារណៈ។

### ឃ. ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

ដើម្បីពង្រឹងការដាក់ពិន្ទុឥណទានរបស់ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ ខេមបូឌា ទិន្នន័យចាំបាច់ត្រូវប្រមូលពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលមិនស្ថិតក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់ឆ្លុះបញ្ចាំងពីលទ្ធភាពសងរបស់អតិថិជន។ ធនាគារជាតិនៃកម្ពុជា នឹងសហការជាមួយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធានាថាទិន្នន័យ ពាក់ព័ន្ធនឹងវិស័យផ្សេងៗដែលស្ថិតក្រោមបទប្បញ្ញត្តិជារួមរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានចែករំលែកជាមួយអ្នកផ្តល់សេវាចែករំលែកប្រព័ន្ធព័ត៌មានឥណទាន ផងដែរ។

### ង. ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ

ទោះបីជាមានការកកើតទីផ្សារហិរញ្ញវត្ថុក៏ដោយ វិសាលភាព (គ្រឹះស្ថានចូលរួម និងឧបករណ៍ហិរញ្ញវត្ថុ) និងភាពស៊ីជម្រៅទីផ្សារ (ចំនួនប្រតិបត្តិការ) នៅមានកម្រិតនៅឡើយ។ នៅពេលដែលការប្រើប្រាស់ប្រាក់ដុល្លារអាម៉េរិកថយចុះ និងការប្រើប្រាស់ប្រាក់រៀលកើនឡើង នោះនឹងនាំឱ្យមានតម្រូវការ ក្នុងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដោយទាក់ទាញអ្នកចូលរួម និងមានឧបករណ៍ជួញដូរកាន់តែច្រើន។

**ទីផ្សាររូបិយវត្ថុ៖** ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍអត្រាការប្រាក់គូរីដ័រ ដែលនឹងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់សន្ទនីយភាពលើស និងទទួលបានកម្ចីរយៈពេលខ្លីពីគ្នាទៅវិញទៅមកក្នុងអត្រាការប្រាក់សមស្រប។ នៅពេលដែលសេដ្ឋកិច្ចឆ្ពោះទៅរកការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើននៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុ នោះទីផ្សាររូបិយវត្ថុនឹងជាតម្រូវការយ៉ាងសំខាន់ក្នុងការអនុវត្តនយោបាយរូបិយវត្ថុ។ ការបោះជំហានទៅរកទីផ្សាររូបិយវត្ថុសកម្មគឺពិតជាមានសារៈសំខាន់ណាស់ ស្របពេលដែលការប្រើប្រាស់ប្រាក់រៀលកំពុងមានសន្ទុះ។ វិធានការមួយចំនួនដែលគួរអនុវត្តមានដូចខាងក្រោម៖

- ធនាគារជាតិនៃកម្ពុជា នឹងរៀបចំបទប្បញ្ញត្តិសម្រាប់ការបោះផ្សាយផលបត្រពាណិជ្ជកម្ម (រយៈពេល ៣ ខែ ៦ ខែ និង ១ ឆ្នាំ)។
- ធនាគារជាតិនៃកម្ពុជាអាចនឹងបង្កើតថ្នាលអនាមិក សម្រាប់ការជួញដូរនិងការទូទាត់នៅក្នុងទីផ្សាររូបិយវត្ថុអន្តរធនាគារ ដើម្បីស្វែងរកថ្លៃទីផ្សារបានកាន់តែប្រសើរ។

**ទីផ្សារមូលបត្ររដ្ឋ៖** មូលបត្ររដ្ឋត្រូវបានបោះផ្សាយនៅក្នុងទីផ្សារដំបូង ប៉ុន្តែមូលបត្រនេះមិនទាន់ត្រូវបានជួញដូរនៅទីផ្សារបន្ទាប់នៅឡើយ ដែលទាមទារឱ្យទីផ្សារមូលបត្ររដ្ឋនឹងត្រូវអភិវឌ្ឍបន្ថែមទៀត។ ដើម្បីជាជំនួយក្នុងការជួញដូរមូលបត្របំណុលនេះ ទីផ្សារបន្ទាប់ដែលមានទម្រង់ជាថ្នាលជួញដូរ នឹងត្រូវបានបង្កើតឡើង សម្រាប់សម្រួលដល់ប្រតិបត្តិការទីផ្សារចំហ។ មូលបត្ររដ្ឋ និងទីផ្សារបន្ទាប់ សម្រាប់មូលបត្ររដ្ឋនឹងក្លាយទៅជាឧបករណ៍គោលសម្រាប់ទីផ្សារសញ្ញាបណ្ណសាជីវកម្ម ដែលនឹងគាំទ្រដល់ការអភិវឌ្ឍទីផ្សារនេះកាន់តែប្រសើរឡើង។

### ច. ចំណុចផ្សេងៗ

ការផ្តល់ប្រាក់កម្ចីក្រៅផ្លូវការ នៅតែបន្តមានភាពទាក់ទាញ ដោយសារតែលទ្ធភាពទទួលបានឥណទានផ្លូវការនៅមានកម្រិត។ បញ្ហានេះអាចត្រូវបានដោះស្រាយមួយផ្នែកធំ ប្រសិនបើវិស័យហិរញ្ញវត្ថុផ្លូវការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការវាយតម្លៃ និងផ្តល់ឥណទាន។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងសកម្មជាមួយភាគីពាក់ព័ន្ធនានា ដើម្បីកាត់បន្ថយការប្រើប្រាស់កម្ចីក្រៅផ្លូវការ តាមរយៈគំនិតផ្តួចផ្តើមនានាក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជនទូទៅ និងក្រុមគោលដៅ ដែលមានដូចជា៖ i/-កិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ii/-កិច្ចសហការជាមួយក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី iii/-កិច្ចសហការជាមួយអង្គការ Good Return ក្នុងការលើកកម្ពស់ចំណេះដឹងក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និង iv/-កិច្ចសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធនាគារនៅកម្ពុជា អង្គការ Cerise+SPTF អង្គការ ADA និងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី

ក្នុងការអនុវត្តគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ បង្កើនភាពអង់អាចរបស់អ្នកប្រើប្រាស់ និងពង្រឹងកិច្ចការពារអតិថិជន។

បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បានសហការយ៉ាងជិតស្និតជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិក្នុងការ-ចូលរួមទប់ស្កាត់សកម្មភាពកម្ចីក្រៅផ្លូវការ រួមមាន ប្រតិបត្តិការធនាគារមិនស្របច្បាប់ និង/ឬ មិនមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជានិងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញសេចក្តីថ្លែងការណ៍រួមក្រោមបរិបទការបង្ក្រាបសកម្មភាពផ្សព្វផ្សាយ និងផ្តល់ឥណទានដោយខុសច្បាប់ សំដៅចូលរួមទប់ស្កាត់ឱ្យទាន់ពេលវេលានូវបទល្មើសនានា ដែលអាចបង្កជាហានិភ័យចំពោះគ្រឹះស្ថាន អតិថិជន និងវិស័យធនាគារទាំងមូល។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការជាមួយអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ក្នុងការសម្របសម្រួលកិច្ចសន្ទនាកម្រិតខ្ពស់រវាងពហុភាគីពាក់ព័ន្ធស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដែលមានការចូលរួមពីតំណាងរាជរដ្ឋាភិបាល និយ័តករ ស្ថាប័ននិងសមាគមវិជ្ជាជីវៈធនាគារនិងហិរញ្ញវត្ថុ វិនិយោគិន សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដើម្បីលើកកម្ពស់ការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ និងកាត់បន្ថយបំណុលលើសលប់ ដែលមួយផ្នែកបណ្តាមកពីការប្រើប្រាស់កម្ចីក្រៅផ្លូវការផងដែរ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១។***

# ជំពូក ៣
# វិស័យមីក្រូហិរញ្ញវត្ថុ

## I. និន្នាការទូទៅ

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍ចុងក្រោយនេះ ទាំងទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើ ក៏ដូចជាចំនួនគ្រឹះស្ថាន។ ចាប់ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២៤ ទំហំទ្រព្យសកម្មបានកើនពីចំនួន ៤,៣ ទ្រីលានរៀល ដល់ ២៥,៥ ទ្រីលានរៀល។ ទន្ទឹមនេះ ឥណទានសរុបដែលផ្តល់ដោយវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងពី ៣,៥ ទ្រីលានរៀល ដល់ ២១,៤ ទ្រីលានរៀល ខណៈដែលប្រាក់បញ្ញើក៏បានកើនឡើងពី ១,១ ទ្រីលានរៀល ដល់ ៩,៩ ទ្រីលានរៀល។

## II. ការកែទម្រង់ និងសមិទ្ធផល

ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ សកម្មភាពមួយចំនួនដែលបានគ្រោងទុកសម្រាប់អភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ត្រូវបានអនុវត្តនិងបាននាំមកនូវវឌ្ឍនភាពសំខាន់ៗនៃការកែទម្រង់ដំណើរការនេះ។ សកម្មភាពចម្បងៗដែលសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ មានដូចខាងក្រោម៖

### ក. ច្បាប់និងបទប្បញ្ញត្តិ

បទប្បញ្ញត្តិអនុវត្តចំពោះវិស័យមីក្រូហិរញ្ញវត្ថុមួយចំនួន ត្រូវបានពិនិត្យឡើងវិញ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ចាប់តាំងពីការដាក់ឱ្យប្រើប្រាស់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ក្នុងនោះរួមមាន៖ i/-បទប្បញ្ញត្តិទាក់ទងនឹងការផ្តល់វិញ្ញាបនបត្រចំពោះគ្រឹះស្ថានឥណទានជនបទ ii/-បទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់បង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និង iii/-ប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន (ក្នុងគោលបំណងគាំទ្រកិច្ចការពារអតិថិជន)។ បទប្បញ្ញត្តិទាំងនេះមានសារៈសំខាន់សម្រាប់ការអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងទទួលប្រាក់បញ្ញើនិងមិនទទួលប្រាក់បញ្ញើទាំងឡាយណាដែលផ្តល់ឥណទានក្នុងអត្រាការប្រាក់ខ្ពស់ពេក។ ធនាគារជាតិនៃកម្ពុជាបានកំណត់ពិដានអត្រាការប្រាក់ឥណទានត្រឹមកម្រិត ១៨%។

### ខ. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត

ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើអនុវត្តតាមវិធីសាស្ត្រនៃការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគតដែរ។ ដោយឡែក ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ធនាគារឯកទេស គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ អនុវត្តតាមវិធីសាស្ត្រ CAMELS។

### គ. បរិយាបន្នហិរញ្ញវត្ថុ

បន្ថែមលើសកម្មភាពអាទិភាពសម្រាប់វិស័យធនាគារដែលបានលើកឡើងក្នុង យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" និងការចែករំលែកព័ត៌មានជាមួយអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ លើទិដ្ឋភាពមួយចំនួនរួមមាន៖ i/-សារៈសំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការងារបទប្បញ្ញត្តិ និងការត្រួតពិនិត្យក្នុងវិស័យនេះ ii/-កាតព្វកិច្ចនិងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និង iii/-ចំណេះដឹងក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីការពារសាធារណជនពីបំណុលលើសលប់។ សិក្ខាសាលានេះក៏ផ្តល់ឱកាសដល់អ្នកចូលរួមចោទជាសំណួរ និងលើកជាបញ្ហា ព្រមទាំងផ្តល់ជាយោបល់លើទិដ្ឋភាពផ្សេងៗនៃសេវាហិរញ្ញវត្ថុ

បន្ថែមលើការលើកកម្ពស់ការយល់ដឹងអំពីវិស័យមីក្រូហិរញ្ញវត្ថុក្នុងចំណោមប្រជាពលរដ្ឋមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធផងដែរ។

**ឃ. ការកសាងសមត្ថភាព**

បន្ថែមលើការកសាងសមត្ថភាពសម្រាប់មន្ត្រី-បុគ្គលិក ធនាគារជាតិនៃកម្ពុជា ក៏បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រឹះស្ថានឥណទានជនបទ អំពីគំរូរបាយការណ៍និងបញ្ហាប្រឈមផ្សេងៗនៅក្នុងដំណើរការផ្តល់ឥណទានផងដែរ ក្នុងគោលបំណងបង្កើនសុក្រឹតភាព និងគុណភាពនៃទិន្នន័យក្នុងការរាយការណ៍។ បន្ថែមពីនេះទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏បានលើកទឹកចិត្តឱ្យបុគ្គលិករបស់ខ្លួនអភិវឌ្ឍជំនាញ តាមរយៈការចូលរួមកម្មវិធីបណ្តុះ-បណ្តាលពាក់ព័ន្ធផ្សេងៗ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ទោះបីជាវិស័យមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនខ្លាំងក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ វិស័យនេះក៏នៅតែប្រឈមនឹងបញ្ហាជាច្រើន ដែលបញ្ហាខ្លះនៅមានលក្ខណៈជាប្រពៃណី និងខ្លះទៀតវិវត្តស្របតាមប្រព័ន្ធអេកូឡូស៊ីបច្ចុប្បន្ន។ បញ្ហាប្រឈមសំខាន់ៗ និងភាពខ្វះចន្លោះក្នុងវិស័យមីក្រូហិរញ្ញវត្ថុ មានដូចខាងក្រោម៖

- អតិថិជនស្វែងរកឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវតែបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងទ្រព្យធានាផ្ទាល់ខ្លួន ដែលជាផ្នែកមួយនៃនីតិវិធីផ្តល់ឥណទាន។ បញ្ហាចម្បង គឺអាជីវកម្មភាគច្រើនពុំទាន់មានទិន្នន័យ និងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។ បញ្ហានេះធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការលំបាក ក្នុងការវាយ-តម្លៃឥណទាន ដែលជាឧបសគ្គក្នុងការផ្តល់ឥណទានដល់អតិថិជន។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពឹងផ្អែកលើបុគ្គលិកឥណទាន ក្នុងការពិនិត្យនិងស្វែងរកអតិថិជនដែលមានតម្រូវការឥណទាន។ នីតិវិធីត្រូវបានធ្វើដោយដៃ ដែលអាចនាំឱ្យមានការយឺតយ៉ាវ មិនមានប្រសិទ្ធភាព និងអាចមានការខ្វះខាត។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ

**ដំណើរការវិភាគអតិថិជនតាមរយៈឌីជីថល៖** ភាពអំណោយផលនៃច្បាប់និងបទប្បញ្ញត្តិ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យជាកត្តាចាំបាច់ដើម្បីជួយសម្រួលដល់ដំណើរការវិភាគឥណទានរបស់អតិថិជនតាមប្រព័ន្ធអនឡាញ ហើយដំណើរការនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអតិថិជន។ ហេតុនេះ ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗ សម្រាប់ការវិភាគលទ្ធភាពសងរបស់អតិថិជនអាចកាត់បន្ថយចំណាយប្រតិបត្តិការ អនុម័តឥណទានបានឆាប់រហ័ស និងបង្កើនប្រាក់ចំណេញជាអតិបរមា។

# ជំពូក ៤
# វិស័យភតិសន្យាហិរញ្ញវត្ថុ និងហាយភើឆេស

## I. និន្នាការទូទៅ

វិស័យភតិសន្យាហិរញ្ញវត្ថុ បានបន្តរីកចម្រើន ចាប់តាំងពីច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ត្រូវបានដាក់ឱ្យអនុវត្ត។ ទំហំប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុសរុបដែលផ្តល់ដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ កើនឡើងពី ០,៧១ ទ្រីលានរៀល ក្នុងឆ្នាំ ២០១៨ ដល់ ១,២៦ ទ្រីលានរៀល ក្នុងឆ្នាំ ២០២៤[៦]។ បន្ថែមលើនេះ សេវាភតិសន្យាហិរញ្ញវត្ថុ ត្រូវបានផ្តល់ដោយធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផងដែរ។

## II. ការកែទម្រង់ និងសមិទ្ធផល

ចាប់តាំងពីការដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ផែនការសកម្មភាពដែលបានកំណត់ក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ កំណែទម្រង់ភាគច្រើនត្រូវបានធ្វើឡើងចំពោះក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ក្នុងការដាក់ចេញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ។ ផែនការសកម្មភាពដែលបានអនុវត្តស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ សម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ រួមមាន៖ i/-បទប្បញ្ញត្តិប្រុង-ប្រយ័ត្នពាក់ព័ន្ធនឹងដើមទុនអប្បបរមា សម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និង ii/-គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យធ្វើសំវិធានធនដូចបានកំណត់ក្នុងប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន (ឆ្នាំ ២០១៧) ដែលជាផ្នែកមួយនៃការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឥណទាន។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

### ក. ក្របខ័ណ្ឌបទប្បញ្ញត្តិ

ការកើនឡើងនៃតម្រូវការផលិតផលរបស់អ្នកប្រើប្រាស់ ទាមទារឱ្យមានការបង្កើនជម្រើសនៃហិរញ្ញប្បទាន ដើម្បីបំពេញតម្រូវការរបស់អតិថិជនប្រកបដោយប្រសិទ្ធភាព។ ក្នុងចំណោមជម្រើសទាំងនេះ កិច្ចសន្យាប្រតិបត្តិការហាយភើឆេសចាប់ផ្តើមកកើតជាយន្តការកម្ចី Hybrid និងមានភាពពេញនិយមខ្លាំង។ យ៉ាងណាមិញ ការអនុវត្តប្រតិបត្តិការហាយភើឆេសចាំបាច់ត្រូវមានក្របខ័ណ្ឌបទប្បញ្ញត្តិសមស្រប ដើម្បីគ្រប់គ្រងដំណើរការប្រតិបត្តិការប្រកបដោយភាពច្បាស់លាស់ ភាពត្រឹមត្រូវ និងអនុលោមតាមក្របខ័ណ្ឌបទប្បញ្ញត្តិ។

### ខ. ពន្ធដារ និងគណនេយ្យ

អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ការប្រកាសបង់ពន្ធ ដោយត្រូវធ្វើនិយ័តកម្មសំវិធានធន សម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។ ដោយឡែក ក្រៅពីគ្រឹះស្ថានធនាគារក្នុងស្រុក សំវិធានធនដែលធ្វើឡើងដោយសហគ្រាសផ្សេងទៀតសម្រាប់រ៉ាប់រងបន្ទុកចំណាយ ឬការខាតបង់នានាដែលមិនទាន់កើតឡើងជាក់ស្តែង មិនត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយឡើយ។ យ៉ាងណាមិញ ប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញ-វត្ថុមានលក្ខណៈស្រដៀង និងមានបញ្ហាប្រឈមលើហានិភ័យដូចគ្នានឹងគ្រឹះស្ថានធនាគារដែរ។ ក្នុងន័យនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គួរធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ និងពិនិត្យលទ្ធភាពក្នុងកម្រិតគោលនយោបាយ

[៦] ប្រភព៖ របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ ២០២៤ របស់ធនាគារជាតិនៃកម្ពុជា

បាយ ដើម្បីអនុញ្ញាតឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ អាចកាត់កងសំវិធានធនកម្រិតជាក់លាក់ណាមួយ សម្រាប់គោលដៅពន្ធលើប្រាក់ចំណូល។

**គ. ការដោះស្រាយវិវាទ**

ទោះបីជាច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ អនុញ្ញាតឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុអនុវត្តការទាមទារចលនវត្ថុដែលបានជួលមកវិញដោយសន្តិវិធី បច្ចុប្បន្នការអនុវត្តនៅមានកម្រិតនៅឡើយ។ ការទាមទារចលនវត្ថុ ត្រូវឆ្លង-កាត់នីតិវិធីតុលាការ ខណៈដែលឧត្តមានុវត្តជាអន្តរជាតិ អនុញ្ញាតឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុទាមទារចលនវត្ថុដោយខ្លួនឯងបាន។ ការអនុវត្តតាមឧត្តមានុវត្តនេះ អាចជួយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុកាត់បន្ថយពេលវេលា និងការចំណាយបានមួយចំណែក។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមួយចំនួនប្រឈមនឹងបញ្ហាដែលអតិថិជនរបស់ខ្លួនបានយកចលនវត្ថុដែលបានជួលយកទៅលក់បន្ត ដោយមិនបំពេញកាតព្វកិច្ចទូទាត់សងឱ្យបានពេញលេញ។ ក្នុងន័យនេះ ការចុះបញ្ជីសិទ្ធិប្រាតិភោគរបស់ភតិបតីនៅក្រសួងពាណិជ្ជកម្មមានសារៈសំខាន់ដល់ការធានាទ្រព្យរបស់ភតិបតី។

**ឃ. ការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹង**

អតិថិជនមានការយល់ឃើញថាផលិតផលភតិសន្យាហិរញ្ញវត្ថុស្ទើរតែដូចគ្នាទៅនឹងផលិតផលឥណទាន/កម្ចី ដោយសារចរិកលក្ខណៈ និងរចនាសម្ព័ន្ធស្រដៀងគ្នានៃផលិតផលដែលមានស្រាប់ក្នុងប្រទេស។

**ង. ក្របខ័ណ្ឌវាយតម្លៃហានិភ័យអតិថិជន**

បច្ចុប្បន្ន ដំណើរការសម្រាប់ការវិភាគ និងការវាយតម្លៃហានិភ័យមិនត្រូវបានធ្វើឡើងជាស្វ័យប្រវត្តិទេ ដែលធ្វើឱ្យដំណើរការវាយតម្លៃប្រើប្រាស់ពេលវេលាច្រើន និងពុំសូវមានប្រសិទ្ធភាព។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យភតិសន្យាហិរញ្ញវត្ថុ

**ក. ការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ**

**ក១. កិច្ចសន្យាហាយភើឆេស**

ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញនូវបទប្បញ្ញត្តិស្តីពីកិច្ចសន្យាហាយភើឆេស បន្ទាប់ពីវាយតម្លៃលើសមិទ្ធិ-លទ្ធភាព។ គោលបំណងនៃបទប្បញ្ញត្តិនេះ គឺដើម្បីបង្កើតមូលដ្ឋានគ្រឹះ សម្រាប់ការប្រើប្រាស់កិច្ចសន្យាហាយភើ-ឆេសនៅក្នុងបរិបទនៃកំណើនហិរញ្ញប្បទាន។ ការណ៍នេះ នឹងអនុញ្ញាតឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុអាចបង្កើតកិច្ចសន្យាហាយភើឆេសបាន។ ដូចគ្នានឹងផលិតផលភតិសន្យាដែរ កិច្ចសន្យាហាយភើឆេសនឹងជួយជំរុញដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។

**ក២. ការពិនិត្យលទ្ធភាពធ្វើសមាហរណកម្មភតិសន្យាហិរញ្ញវត្ថុទៅក្នុងប្រព័ន្ធចុះបញ្ជីប្រតិបត្តិការដែលមានកិច្ចធានា៖** ធនាគារជាតិនៃកម្ពុជា រួមជាមួយក្រសួងពាណិជ្ជកម្មនឹងសិក្សាទៅលើសមិទ្ធិលទ្ធភាពនៃការធ្វើសមាហ-រណកម្មភតិសន្យាហិរញ្ញវត្ថុទៅក្នុងប្រព័ន្ធចុះបញ្ជីនៃប្រតិបត្តិការដែលមានកិច្ចធានា។ ការណ៍នេះនឹងជួយដោះ-ស្រាយនូវបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់ទ្រព្យសកម្ម សុពលភាពកម្មសិទ្ធិ និងដំណើរការផ្ទេរកម្មសិទ្ធិ ដើម្បីពង្រីកផលិតផលហិរញ្ញប្បទានសម្រាប់ចលនវត្ថុ។

**ខ. ឧបសគ្គក្នុងការអនុវត្តស្តង់ដារគណនេយ្យ**

**ការផ្តល់ការគាំទ្រពេញលេញដើម្បីជំរុញការអនុលោមតាមស្តង់ដារគណនេយ្យ៖** ធនាគារជាតិនៃកម្ពុជានឹងពិនិត្យឡើងវិញលើដំណើរការរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ឆ្ពោះទៅរកការអនុវត្តស្តង់ដារគណនេយ្យអន្តរជាតិ (IFRS 16) ក៏ដូចជាការអនុវត្ត CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម។ និយ័តករគណនេយ្យនិងសវនកម្មនឹងគាំទ្រដល់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុដោយផ្តល់សិក្ខាសាលាបណ្តុះបណ្តាលសម្រាប់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុស្តីពីការអនុលោមតាមស្តង់ដារគណនេយ្យ សម្រាប់សហគ្រាសធុនតូចនិងមធ្យម។

### គ. ការដោះស្រាយវិវាទពាណិជ្ជកម្មបានឆាប់រហ័សក្នុងទម្រង់ដែលមានតម្លាភាព

#### គ១. ការបង្កើតតុលាការពាណិជ្ជកម្មសម្រាប់ដោះស្រាយវិវាទពាណិជ្ជកម្ម

ការរីកចម្រើននៃសេវាហិរញ្ញវត្ថុដែលមានលក្ខណៈសម្បូរបែប បច្ចេកទេស និងស្មុគស្មាញ ទាមទារឱ្យមានតុលាការដែលមានជំនាញដើម្បីដោះស្រាយ។ ជាក់ស្តែង ប្រព័ន្ធច្បាប់នៅកម្ពុជាមានតែតុលាការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ ហើយករណីទាំងអស់ដែលពាក់ព័ន្ធនឹងវិវាទពាណិជ្ជកម្មនិងការងារ ត្រូវបានបញ្ជូនទៅដោះស្រាយនៅតុលាការរដ្ឋប្បវេណី។ រាជរដ្ឋាភិបាលកំពុងបង្កើតប្រព័ន្ធតុលាការពាណិជ្ជកម្ម ដើម្បីធានានូវប្រព័ន្ធតុលាការដែលប្រើប្រាស់បានសម្រាប់ករណីពាណិជ្ជកម្ម។ តុលាការពាណិជ្ជកម្មនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម និងបង្កើតបរិយាកាសអាជីវកម្មដែលអំណោយផល។ បច្ចុប្បន្ន ក្រសួងយុត្តិធម៌កំពុងពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ដើម្បីដំណើរការតុលាការពាណិជ្ជកម្ម។

ការបង្កើតតុលាការពាណិជ្ជកម្មនាពេលអនាគត ទាមទារនូវការបណ្តុះបណ្តាលថៅក្រមលើបញ្ហាអាជីវកម្មក្រោមវិវាទពាណិជ្ជកម្ម ស្តង់ដារគណនេយ្យ និងការអនុវត្តច្បាប់ក្ស័យធន។ល។ នៅក្នុងដំណើរការពិគ្រោះយោបល់សម្រាប់ការបណ្តុះបណ្តាលដែលដឹកនាំដោយក្រសួងយុត្តិធម៌ ត្រូវមានការចូលរួមពីតំណាងពីធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធុរកិច្ចអន្តរជាតិ។

#### គ.២ ការវាយតម្លៃសមិទ្ធិលទ្ធភាពនៃការទាមទារចលនវត្ថុដែលបានជួលមកវិញដោយគ្មានការឆ្លងកាត់តាមប្រព័ន្ធតុលាការសម្រាប់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដូចដែលមានចែងក្នុងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ

យោងតាមច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ ភតិបតីអាចយកមកវិញនូវកម្មសិទ្ធិនៃចលនវត្ថុដែលបានជួលដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ។ ជាក់ស្តែង ការទាមទារចលនវត្ថុរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវឆ្លង-កាត់នីតិវិធីតុលាការ។

ធនាគារជាតិនៃកម្ពុជា និងក្រសួងយុត្តិធម៌ នឹងរួមគ្នាវាយតម្លៃសមិទ្ធិលទ្ធភាពនៃការអនុវត្តឡើងវិញនូវការទាមទារចលនវត្ថុដែលបានជួលមកវិញ ដោយគ្មានការឆ្លងកាត់តាមប្រព័ន្ធតុលាការសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ។ ក្នុងករណីមានការបំពានកិច្ចព្រមព្រៀង អាជ្ញាធរតុលាការនឹងចាត់វិធានការដើម្បីពង្រឹងការអនុវត្តបទប្បញ្ញត្តិនៃការទាមទារចលនវត្ថុដែលបានជួលមកវិញដោយគ្មានការឆ្លងកាត់តាមប្រព័ន្ធតុលាការ ដូចជាការបង្កើតឱ្យមានយន្តការគាំទ្រ ឬចាត់ចែងការទាមទារការកាន់កាប់វិញដោយគ្មានការឆ្លងកាត់តាមប្រព័ន្ធតុលាការសម្រាប់ភតិបតី។

### ឃ. ការកសាងចំណេះដឹងសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ

**ការវាយតម្លៃសមិទ្ធិលទ្ធភាពនៃការបង្កើតសមាគមភតិសន្យាហិរញ្ញវត្ថុៈ** គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុអាចទទួលបានអត្ថប្រយោជន៍ពីសមាគមនៃវិស័យនេះដូចជា ការចែករំលែកចំណេះដឹង ការផ្សព្វផ្សាយ និងពង្រឹងទំនាក់ទំនងជាមួយអាជ្ញាធរ ម្ចាស់ជំនួយ និងវិនិយោគិន។ សមាគមធនាគារនៅកម្ពុជានឹងស្វែងយល់ពីលទ្ធភាព និងវាស់ស្ទង់ចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធក្នុងការបង្កើតសមាគមភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា។ ការបង្កើតសមាគមនេះនឹងជួយសម្រួលដល់ការធ្វើសិក្ខាសាលាដែលគ្របដណ្តប់លើប្រធានបទសំខាន់ៗ ដូចជា គុណភាពរបាយការណ៍ហិរញ្ញវត្ថុ ម៉ូដែលនិងការវាស់វែងហានិភ័យឥណទាន ការវាយតម្លៃសំណៀតឥណទាន និងផលិតផលហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតសម្រាប់ចលនវត្ថុ។ សមាគមនឹងជួយសមាជិកឱ្យមានការយល់ដឹងពីការអនុវត្តត្រឹមត្រូវនៃប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និន្នាការភតិសន្យាហិរញ្ញវត្ថុនៅទូទាំងពិភពលោក និងផ្តល់មតិយោបល់ក្នុងនាមគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុដល់ភាគីពាក់ព័ន្ធ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី២។***

# ជំពូក ៥
# ប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុ

## I. ទិដ្ឋភាពទូទៅ

ការរីកចម្រើននៃវិស័យធនាគារត្រូវបានគាំទ្រដោយការវិវត្តន៍យ៉ាងឆាប់រហ័សនៃប្រព័ន្ធទូទាត់សងប្រាក់។ ប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាព និងនវានុវត្តន៍នឹងជួយសម្រួលដល់ការចរាចរសាច់ប្រាក់ជាអេឡិចត្រូនិក ដែលនឹងជួយបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់រូបិយវត្ថុ និងការប្រើប្រាស់សន្ទនីយភាពក្នុងសេដ្ឋកិច្ច។ ប្រព័ន្ធទូទាត់សងប្រាក់ក៏បានចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការជំរុញអន្តរប្រតិបត្តិការ ភាពងាយស្រួល តម្លៃសមរម្យ ប្រសិទ្ធភាព និងនវានុវត្តន៍។ ដោយមើលឃើញពីសារៈសំខាន់នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់សងប្រាក់ជាច្រើនរួមមាន ប្រព័ន្ធទូទាត់តម្លៃរាយ និងតម្លៃធំ សម្រាប់ការទូទាត់ និងការផ្ទេរប្រាក់អន្តរធនាគារ។ ដើម្បីបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់ និងឆ្លើយតបនឹងការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់ជំនាន់ថ្មី រួមជាមួយនឹងគំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូតដែលជាឃ្យូអរកូតស្តង់ដារសម្រាប់ការទូទាត់ក៏ត្រូវបានដាក់ឱ្យដំណើរការផងដែរ។ នវានុវត្តន៍ហិរញ្ញវត្ថុក្នុងវិស័យធនាគារបានបង្ហាញពីភាពកាន់តែប្រសើរជាងមុន ជាពិសេសការរីកចម្រើនលើការទូទាត់ឌីជីថល និងការផ្ទេរប្រាក់។ នវានុវត្តន៍ហិរញ្ញវត្ថុមានសក្តានុពលក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការ និងចូលរួមបង្កើនការទទួលបានសេវាហិរញ្ញវត្ថុសម្រាប់ប្រជាជនកម្ពុជាដែលមានប្រាក់ចំណូលទាប និងមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបានសេវាហិរញ្ញវត្ថុបែបប្រពៃណី។

## II. ការកែទម្រង់ និងសមិទ្ធផល

### ក. បទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធទូទាត់សងប្រាក់ ដូចមានចែងក្នុងច្បាប់ស្តីពីៈ i/-ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ii/-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង iii/-ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ មានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យ អភិវឌ្ឍ និងរៀបចំបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ដើម្បីធានាបាននូវស្ថិរភាព និងនិរន្តភាពនៃដំណើរការប្រព័ន្ធ កាត់បន្ថយហានិភ័យជាប្រព័ន្ធ ការពារផលប្រយោជន៍អតិថិជន ជំរុញការប្រកួតប្រជែងនិងការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិក ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ បទប្បញ្ញត្តិដែលត្រូវបានដាក់ចេញពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់មានដូចជា ប្រកាសស្តីពី ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បទប្បញ្ញត្តិពាក់ព័ន្ធនឹងស្តង់ដារនៃមូលប្បទានបត្រ ការបញ្ជាទូទាត់ ខេអេចឃ្យូអរកូត និងស្តង់ដារ EMV សម្រាប់ប័ណ្ណទូទាត់ គោលការណ៍ណែនាំអំពីការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងផែនទីមគ្គុទេសក៍អភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុឆ្នាំ ២០២០-២០២៥។ លើសពីនេះវិធាននិងនីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធផ្សេងៗ ក៏ត្រូវបានដាក់ឱ្យអនុវត្តដើម្បីគាំទ្រដល់ប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលដំណើរការដោយធនាគារជាតិនៃកម្ពុជា។

### ខ. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ ត្រូវបានបន្តអភិវឌ្ឍន៍ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យានិងប្រតិបត្តិការទូទាត់ជាមួយគ្នានេះវិធាននិងនីតិវិធីក៏ត្រូវបានពង្រឹងជាលំដាប់។ ប្រព័ន្ធធនាគារអនឡាញ (OBS) ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីជួយសម្រួលដល់ប្រតិបត្តិការទូទាត់តម្លៃធំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបើកគណនីនៅធនាគារជាតិ

នៃកម្ពុជា។ ប្រព័ន្ធទូទាត់បាគងក៏ត្រូវបានអភិវឌ្ឍនិងដាក់ឱ្យដំណើរការនៅឆ្នាំ ២០២០ ក្នុងគោលបំណងជំរុញអន្តរប្រតិបត្តិការ ផ្តល់ភាពងាយស្រួល និងសុវត្ថិភាពក្នុងការផ្ទេរប្រាក់រវាងគ្រឹះស្ថានផ្សេងគ្នា។ ទន្ទឹមនឹងការអភិវឌ្ឍប្រព័ន្ធបាគង ស្តង់ដារខេអេចឃ្យូអរកូត (KHQR Code) ត្រូវបានបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់នាឆ្នាំ ២០២២ ដើម្បីលើកកម្ពស់ប្រតិបត្តិការទូទាត់រាយ និងប្រតិបត្តិការទូទាត់ឆ្លងដែន។ ក្នុងគោលបំណងសម្រួលដល់សាធារណជនឱ្យមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់សងប្រាក់អន្តរគ្រឹះស្ថាន ធនាគារជាតិនៃកម្ពុជា បានដាក់ដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម កាលពីខែ ឧសភា ឆ្នាំ ២០២៤ ដែលធ្វើសមាហរណកម្មប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗទៅជាប្រព័ន្ធតែមួយ។ ប្រព័ន្ធទូទាត់សងប្រាក់រួមនេះ ត្រូវបានប្រើប្រាស់ជាហេដ្ឋារចនាសម្ព័ន្ធគ្រឹះ ដែលរួមមានម៉ូឌុលបាគង និងម៉ូឌុលទូទាត់សុទ្ធ (Defferred Net Settlement-DNS) ក្នុងនោះម៉ូឌុលបាគងរួមមានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ ហើយម៉ូឌុលទូទាត់សុទ្ធរួមមាន សេវាប័ណ្ណទូទាត់ និងសេវាទូទាត់មូលប្បទានបត្រ។ វិធាននិងនីតិវិធីនៃប្រព័ន្ធទូទាត់សងប្រាក់រួមនេះ ក៏កំពុងត្រូវបានរៀបចំ ដើម្បីឱ្យគ្រឹះស្ថានសមាជិកអនុវត្តតាមប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។ គិតត្រឹមឆ្នាំ ២០២៤ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលបានដាក់ឱ្យដំណើរការដោយធនាគារជាតិនៃកម្ពុជា បានសម្រួលប្រតិបត្តិការទូទាត់ចំនួន ៦០០ លានប្រតិបត្តិការដែលមានទំហំប្រាក់ប្រមាណ ៦ ដងនៃផលិតផលក្នុងស្រុកសរុប។

### គ. សេវាទូទាត់សងប្រាក់

សេវាទូទាត់សងប្រាក់នៅកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ តាមរយៈការដាក់ចេញនូវផលិតផល ឬ សេវាទូទាត់បែបឌីជីថល ប្រកបដោយនវានុវត្តន៍។ គិតត្រឹមឆ្នាំ ២០២៤ ទំហំប្រតិបត្តិការមានចំនួន ២,៦ ប៊ីលានប្រតិបត្តិការ គិតជាទឹកប្រាក់ចំនួន ១.៥៥០ ទ្រីលានរៀល ស្មើនឹងប្រមាណ ៨ ដងនៃ ផ.ស.ស. និងចំនួនពាណិជ្ជករទទួលការទូទាត់កើនដល់ ៤,៥ លានទីតាំង។

ទោះបីជាប្រតិបត្តិការឌីជីថលមានការរីកចម្រើនក៏ដោយ ក៏ភ្នាក់ងារធនាគារ នៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់មធ្យោបាយទូទាត់នៅតាមបញ្ជរ ដូចជា ប្រតិបត្តិការដាក់-ដកប្រាក់ ផ្ទេរប្រាក់ទូទាត់សងកម្ចី និងទូទាត់វិក្កយបត្រជាដើម។ បណ្តាញភ្នាក់ងារទាំងនេះផ្តល់ជាច្រកសម្រាប់អតិថិជនដែលមិនមានគណនីមានលទ្ធភាពចាប់យកប្រតិបត្តិការឌីជីថល និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។

### ឃ. ការទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែន

ការទូទាត់សងប្រាក់ និងការផ្ទេរប្រាក់ឆ្លងដែន ជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍ និងពង្រីកកិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែន តាមរយៈការដាក់ឱ្យដំណើរការជាផ្លូវការគម្រោងទូទាត់ឆ្លងដែនជាបន្តបន្ទាប់ទាំងក្នុងតំបន់និងអន្តរជាតិ។ ចាប់តាំងពីឆ្នាំ ២០២០ មក ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ការទូទាត់ឆ្លងដែនទ្វេភាគីជាមួយបណ្តាប្រទេសជាច្រើនរួមមាន ប្រទេសថៃ វៀតណាម ឡាវ ម៉ាឡេស៊ី កូរ៉េខាងត្បូង និងចិន រួមទាំងកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ UnionPay International និងក្រុមហ៊ុន Alipay Connect។ ជាជំហានបន្ទាប់ ធនាគារជាតិនៃកម្ពុជាគ្រោងនឹងដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនទ្វេភាគីជាមួយប្រទេសសិង្ហបុរី ជប៉ុន ឥណ្ឌា ហ្វីលីពីន និងឥណ្ឌូនេស៊ី ក្នុងពេលឆាប់ៗខាងមុខ។ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) ជាមួយធនាគារកណ្តាលនៃប្រទេសទីម័រខាងកើត វ៉ាន់ដា កោះសូឡូម៉ូន ហ្វីជី និងម៉ាដាហ្គាស្កា ដើម្បីបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ព្រមទាំងបានចែករំលែកបទពិសោធន៍ និងផ្លាស់ប្តូរចំណេះដឹងអំពីការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាជាមួយ ប្រទេសប៊ូតង់ ឡេសូតូ និងប៉ាគីស្ថាន។

ចំពោះកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនពហុភាគី ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងគម្រោង Regional Payment Connectivity (RPC) ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែន និងជំរុញការធ្វើសមាហរណកម្មនៅក្នុងតំបន់

អាស៊ាន។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមជាសមាជិកសង្កេតការណ៍ក្នុងគម្រោង mBridge និង NEXUS ដែលផ្តួចផ្តើមអភិវឌ្ឍដោយធនាគារសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (BIS) ក្នុងគោលដៅពន្លឿនការតភ្ជាប់ការទូទាត់ឆ្លងដែន និងបង្កើនប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែនពហុភាគីដោយប្រើប្រាស់រូបិយវត្ថុចម្រុះ និងរូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល (CBDCs)។

### ង. នវានុវត្តន៍ហិរញ្ញវត្ថុ

នវានុវត្តន៍ហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុតាមរយៈការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល បច្ចេកវិទ្យាទំនើប និងគំរូអាជីវកម្មប្រកបដោយនវានុវត្តន៍។ ធនាគារជាតិនៃកម្ពុជាបានដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រនិងជំរុញឱ្យមានវឌ្ឍនភាពនៃនវានុវត្តន៍ហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់តាមរយៈការអភិវឌ្ឍប្រព័ន្ធអេក្ទ្រូនិចរបស់ប្រព័ន្ធបាគង ដែលជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលដ៏សំខាន់។ នវានុវត្តន៍ប្រព័ន្ធទូទាត់សងប្រាក់ដែលបានដាក់ចេញនាពេលថ្មីៗនេះ មានដូចជា នីតិវិធីសម្គាល់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង មុខងារតភ្ជាប់គណនីបាគង នីតិវិធីទទួលបណ្តឹងរបស់អតិថិជនដែលប្រើប្រាស់ប្រព័ន្ធបាគង ប្រព័ន្ធទូទាត់តម្លៃធំបាគង កម្មវិធីទូទាត់បាគងទេសចរ និងការទូទាត់សម្រាប់សេវាសាធារណៈជាដើម។ នវានុវត្តន៍ទាំងអស់នេះត្រូវបានអភិវឌ្ឍឡើងក្នុងគោលបំណងពង្រឹងសុវត្ថិភាព កាត់បន្ថយចំណាយ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុឱ្យកាន់តែប្រសើរជាងមុន។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមជាមួយដៃគូសហការអភិវឌ្ឍន៍ គម្រោងច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor-FTC) និង គម្រោងសាកល្បង Universal Trusted Credentials (UTC)។ គម្រោងទាំងពីរនេះ មានគោលបំណងជួយសម្រួលដល់សកម្មភាពពាណិជ្ជកម្មឆ្លងដែន និងហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម តាមរយៈការផ្លាស់ប្តូរទិន្នន័យប្រកបដោយតម្លាភាព និងសុវត្ថិភាពរវាងគ្រឹះស្ថានសមាជិក។ ស្ថិតក្នុងបរិបទនៃការរីកចម្រើននវានុវត្តន៍ហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ដែលក្នុងនោះប្រកាសនេះក៏នឹងដាក់បទប្បញ្ញត្តិលើបុគ្គលផ្តល់សេវាទ្រព្យសកម្មគ្រីបតូបន្ថែមទៀត។ មួយផ្នែកទៀតនៃប្រកាសនេះក៏គាំទ្រដល់នវានុវត្តបច្ចេកវិទ្យាឌីអិលធី ដោយប្រកាសនេះបានអនុញ្ញាតឱ្យធនាគារពាណិជ្ជដែលមានបំណងមានអ៊ិចស្ពូស៊ើទ្រព្យសកម្មគ្រីបតូ ក្រុម ១ អាចស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏គ្រោងនឹងដាក់ចេញបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់អ៊ិចស្ពូស៊ើទ្រព្យសកម្មគ្រីបតូ ដើម្បីធានាការត្រៀមខ្លួនរួចរាល់ផ្នែកបទប្បញ្ញត្តិក្នុងការគាំទ្រដល់នវានុវត្តន៍នេះ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ស្របពេលដែលមានសមិទ្ធផលសម្រេចបានក្នុងប្រព័ន្ធទូទាត់សងប្រាក់ នវានុវត្តន៍បច្ចេកវិទ្យាក៏នាំមកនូវបញ្ហាប្រឈមដែលចាំបាច់ទាមទារឱ្យមានការយកចិត្តទុកដាក់និងដោះស្រាយឱ្យបានទាន់ពេលវេលា។

- ហានិភ័យថ្មីៗពាក់ព័ន្ធនិងប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់ នៅតែជាបញ្ហាប្រឈម ខណៈពេលដែលមានការកើនឡើងប្រតិបត្តិការទូទាត់បែបឌីជីថល និងការលេចចេញនូវគំរូអាជីវកម្មថ្មីៗ។ ការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាគាំទ្រ ដូចជាបច្ចេកវិទ្យាឌីអិលធី (DLT) បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាទិន្នន័យធំ (Big Data) ក្នុងការផ្តល់សេវាហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។ ដូចនេះ ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌបទប្បញ្ញត្តិ គោលនយោបាយគាំទ្រ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដូចជា អត្តសញ្ញាណឌីជីថល សន្តិសុខសាយប័រ ការការពារទិន្នន័យ និងកិច្ចការពារអ្នកប្រើប្រាស់មានភាពចាំបាច់ ដើម្បីធានាស្ថិរភាពប្រព័ន្ធ និងសេវាទូទាត់សងប្រាក់ គាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថល បង្កើនផលិតភាព សុវត្ថិភាព និងប្រសិទ្ធភាព ក៏ដូចជាលើកកម្ពស់នវានុវត្តន៍។
- ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្តីពីប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ សម្រាប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់យកទៅអនុវត្ត ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យនេះ

ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព ជំនឿទុកចិត្ត និងនវានុវត្តន៍។ ទោះជាយ៉ាងនេះក៏ដោយ ដើម្បីទ្រទ្រង់វិស័យនេះឱ្យរីកលូតលាស់ ទាមទារឱ្យមានការសិក្សានិងដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតដើម្បីគ្រប់គ្រងនិងបង្ការនូវហានិភ័យនានា។

- បច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់និងនវានុវត្តន៍សេវាទូទាត់ ព្រមទាំងឧបករណ៍ទូទាត់ផ្សេងៗត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់នៅកម្ពុជា។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ដោយបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់តម្លៃរាយ និងតម្លៃធំ។ ទោះយ៉ាងណា ប្រព័ន្ធទូទាត់ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់មានមុខងារ និងដំណើរការផ្សេងៗគ្នាទៅតាមដំណាក់កាលនៃការអភិវឌ្ឍនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនិងតម្រូវការទីផ្សារ ដែលទាមទារឱ្យមានការធ្វើបច្ចុប្បន្នកម្ម ដើម្បីបង្កើនប្រសិទ្ធភាពនិងភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់។
- ភ្នាក់ងារផ្តល់សេវាទូទាត់សងប្រាក់ ដែលមានលក្ខណៈជាហាងលក់គ្រឿងទេស ឬ ហាងលក់ទំនិញតូចៗ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដល់អតិថិជន។ ក្រៅពីនេះ ភ្នាក់ងារមួយចំនួនបានសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ ក្នុងការប្រមូលការទូទាត់សងប្រាក់កម្ចីពីអតិថិជន ដែលប្រតិបត្តិការនេះជួយបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ ងាយស្រួល និងមានទំនុកចិត្តថែមទៀត។ ទោះយ៉ាងណា ក្របខ័ណ្ឌបទប្បញ្ញត្តិក្នុងការគ្រប់គ្រងភ្នាក់ងារក្នុងវិស័យ ធនាគារនៅមិនទាន់បានរៀបចំនៅឡើយទេ។ ក្របខ័ណ្ឌនេះមានសារៈសំខាន់ក្នុងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធ និងការកំណត់ពីសកម្មភាពដែលភ្នាក់ងារអាចធ្វើប្រតិបត្តិការបាន។
- ការគ្រប់គ្រងថ្នាលឥណទានឌីជីថលមិនទាន់មានភាពពេញលេញនៅឡើយ ខណៈពេលដែលប្រតិបត្តិការឥណទានអនឡាញមានការរីកលូតលាស់គួរឱ្យកត់សម្គាល់។ បច្ចុប្បន្ន ប្រតិបត្តិការឥណទានអនឡាញដែលមិនមានការគ្រប់គ្រងច្បាស់លាស់បានបង្កការគម្រាមកំហែងដល់សាធារណជនទូទៅ ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល។ សកម្មភាពទាំងនោះភាគច្រើនមានរូបភាពជាឥណទានក្រៅផ្លូវការ ដែលកិច្ចសន្យាឥណទានមានលក្ខណៈកេងប្រវ័ញ្ច អត្រាការប្រាក់ខ្ពស់ និងមិនទាមទារទ្រព្យធានាពីកូនបំណុល។ ការណ៍នេះបានជះឥទ្ធិពលជាអវិជ្ជមានមកលើសេវាឥណទានផ្លូវការនៅកម្ពុជា ហើយអតិថិជនក៏មិនត្រូវបានការការពារដោយបទប្បញ្ញត្តិផងដែរ។ ការដាក់ចេញនូវបទប្បញ្ញត្តិសមស្របសម្រាប់គ្រប់គ្រងថ្នាលឥណទានឌីជីថលជាការងារចាំបាច់មួយ ដើម្បីផ្តល់ជាបរិស្ថានអំណោយផលដល់ការប្រកួតប្រជែងដោយតម្លាភាពរវាងអ្នកផ្តល់សេវា និងការពារផលប្រយោជន៍អ្នកប្រើប្រាស់ សំដៅបង្កើនជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។
- ដោយសារក្របខ័ណ្ឌបទប្បញ្ញត្តិ និងស្តង់ដារបច្ចេកទេសនៃការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឆ្លងដែនរបស់ប្រទេសនីមួយៗមិនដូចគ្នា ធនាគារជាតិនៃកម្ពុជានឹងបន្តពិនិត្យលទ្ធភាពពង្រីកកិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនជាលក្ខណៈពហុភាគីជាមួយដៃគូពាក់ព័ន្ធ។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុ

### ក. ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់

- ប្រព័ន្ធទូទាត់សងប្រាក់រួម៖ ការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទូទាត់នាពេលបច្ចុប្បន្ន តាមរយៈការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដោយធ្វើការរួមបញ្ចូលគ្នានូវប្រព័ន្ធទូទាត់ដែលមានស្រាប់ទាំងអស់ និងកាត់បន្ថយហានិភ័យ

ជាប្រព័ន្ធ ផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ និងរួមចំណែកបង្កើនប្រសិទ្ធភាពនៃការទូទាត់តាមឌីជីថលនៅកម្ពុជា និង

- វិធាននិងនីតិវិធីសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រួម៖ ការដាក់ចេញវិធាននិងនីតិវិធីសម្រាប់ប្រព័ន្ធទូទាត់-សងប្រាក់រួមនឹងធានាបាននូវមូលដ្ឋានច្បាប់ និងផ្តល់នូវតម្រូវការចាំបាច់ដើម្បីប្រើប្រាស់ប្រព័ន្ធប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព។ វិធាននិងនីតិវិធីនឹងកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធ ក៏ដូចជាគោល-ការណ៍ណែនាំផ្សេងៗដើម្បីកាត់បន្ថយហានិភ័យនៅក្នុងប្រព័ន្ធ និងការទទួលបានទំនុកចិត្តពីសាធារណជន។

**ខ. សេវាទូទាត់សងប្រាក់**

- ថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ៖ ការដាក់ចេញបទប្បញ្ញត្តិពេញលេញ និងគ្រប់គ្រាន់សម្រាប់គ្រប់គ្រងប្រតិបត្តិការឥណទានអនឡាញនឹងបង្កើនជំនឿទុកចិត្តពីសាធារណជន កាត់បន្ថយភាពស្មុគស្មាញក្នុងការ-វាយតម្លៃហានិភ័យឥណទាន បង្កើនសុវត្ថិភាពប្រតិបត្តិការ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ក៏ដូចជាការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង
- បទប្បញ្ញត្តិពាក់ព័ន្ធភ្នាក់ងារធនាគារ៖ រៀបចំបទប្បញ្ញត្តិសមស្រប ដែលអនុញ្ញាតឱ្យភ្នាក់ងារអាចធ្វើប្រតិបត្តិការជាក់លាក់មួយចំនួនក្នុងនាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសាមី។

**គ. ការតភ្ជាប់ប្រតិបត្តិការទូទាត់ឆ្លងដែន**

- បញ្ចប់ និងដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី និង
- ពិនិត្យលទ្ធភាពក្នុងការតភ្ជាប់គម្រោងទូទាត់ឆ្លងដែនពហុភាគី ដែលជាគំនិតផ្តួចផ្តើមនៅក្នុងតំបន់និងសកល។

**ឃ. នវានុវត្តន៍ហិរញ្ញវត្ថុ**

- ផ្តល់នូវបរិស្ថានអំណោយផលដើម្បីចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងវិស័យធនាគារ ព្រមទាំងដាក់ចេញគោលនយោបាយជំរុញ ដើម្បីគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ
- សិក្សារៀបចំប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណ និងការអនុញ្ញាតសម្រាប់បុគ្គលផ្តល់សេវាទ្រព្យសកម្មគ្រីបតូ និង
- សិក្សារៀបចំប្រកាសស្តីពី បទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់អ៊ិចស្ចេញទ្រព្យសកម្មគ្រីបតូ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៣។***

# ជំពូក ៦
# វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

## I. ទិដ្ឋភាពទូទៅ

វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានវិវត្តខ្លួនយ៉ាងឆាប់រហ័សក្នុងរយៈកាល ២ ទសវត្សរ៍ចុងក្រោយ ទាំងកំណើន និងការធ្វើពិពិធកម្មវិស័យ។ ជាការកត់សម្គាល់ វិស័យហិរញ្ញវត្ថុមិនមែនធនាគារកម្ពុជា បាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ដល់ការជំរុញសន្ទុះកំណើនសេដ្ឋកិច្ចជាតិ។ គួយ៉ាង គិតត្រឹមឆ្នាំ ២០២៣ វិស័យធានារ៉ាប់រងបានចូលរួមអត្រាភាគទាន ១,១៦% ក្នុងសេដ្ឋកិច្ចជាតិ ជាមួយនឹងដង់ស៊ីតេធានារ៉ាប់រងចំនួន ២១,០២ ដុល្លារអាម៉េរិកក្នុងប្រជាជនម្នាក់ ដែលក្នុងនោះក៏មានការរួមចំណែកពីបច្ចេកវិទ្យាធានារ៉ាប់រងផងដែរ។ បន្ថែមពីនេះ នាឆ្នាំ ២០២៣ ទីផ្សារធានារ៉ាប់រងកម្ពុជារក្សាបាននូវសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលក្នុងនោះបុព្វលាភធានារ៉ាប់រងមានប្រមាណ ៣៥៤ លានដុល្លារអាម៉េរិក កើនឡើងប្រមាណ ៣,៦% ធៀបនឹងឆ្នាំ ២០២២ ចំណែកឯទ្រព្យសកម្មសរុបបានកើនឡើងលើសពី ១ ពាន់លានដុល្លារអាម៉េរិក ខណៈមូលនិធិភាគហ៊ុនិកមានចំនួនសរុបប្រមាណ ៥៥៣ លានដុល្លារអាម៉េរិក។ សម្រាប់វិស័យមូលបត្រ មូលធនូបនីយកម្មទីផ្សារសម្រាប់ទីផ្សារមូលបត្រមានចំនួនសរុប ៣,១៣ ប៊ីលានដុល្លារអាម៉េរិក មូលធនូបនីយកម្មទីផ្សារធៀបនឹងផលិតផលក្នុងស្រុកសរុបមានតម្លៃស្មើនឹង ៩,៧៩% ការប្រមូលសាច់ប្រាក់ពីទីផ្សារមូលបត្រមានចំនួនសរុប ៣៥៧,២៦ លានដុល្លារអាម៉េរិក និងទំហំជួញដូរនៃទីផ្សារឧបករណ៍និស្សន្ទមានចំនួនសរុប ២៨៣,៥ លាន ដុល្លារអាម៉េរិក នាឆ្នាំ ២០២៣។ សម្រាប់វិស័យបរធនបាលកិច្ច គិតត្រឹមឆ្នាំ ២០២៣ កម្ពុជាបានដាក់ឱ្យដំណើរការទីផ្សារបរធនបាលកិច្ចជាមួយនឹងប្រតិបត្តិការពេញលេញដែលក្នុងនោះបរធនបាលកិច្ចដែលបានចុះបញ្ជីកើនឡើងដល់ចំនួន ៧៨៨ ករណី ជាមួយនឹងបរធនទំហំ ១ ២៧១ លានដុល្លារអាម៉េរិក។

ឆ្លើយតបទៅនឹងការអភិវឌ្ឍ និងនិន្នាការនៃការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុនៅក្នុងតំបន់ អនុវិស័យធានារ៉ាប់រងនិងសោធនឯកជន អនុវិស័យមូលបត្រ អនុវិស័យសន្តិសុខសង្គម អនុវិស័យបរធនបាលកិច្ច អនុវិស័យគណនេយ្យនិងសវនកម្ម និងអនុវិស័យអចលនវត្ថុបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ត្រូវបានច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បញ្ញត្តិឱ្យអនុវិស័យខាងលើនេះស្ថិតក្រោមអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។ ការធ្វើសមាហរណកម្មលើអនុវិស័យទាំង ៦ នេះ ធានាបាននូវការគ្រប់គ្រង ការត្រួតពិនិត្យ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងបានលើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដោយមានការអនុវត្តនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យនេះ។

ទន្ទឹមនឹងការបង្កើតឱ្យមាននិយ័តករទាំង ៦ អ.ស.ហ. នៅមានអង្គភាពគាំទ្រចំនួន ២ បន្ថែមទៀត រួមមាន អគ្គលេខាធិការដ្ឋាន អ.ស.ហ. និងអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.។ អគ្គលេខាធិការដ្ឋាន អ.ស.ហ. មានតួនាទី និងភារកិច្ចជាសេនាធិការរបស់ អ.ស.ហ. ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងការតាមដានការវិវត្តន៍នៃទីផ្សារហិរញ្ញវត្ថុមិនមែនធនាគារជារួម សំដៅចូលរួមធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ។ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារត្រូវបានផ្តល់ការយកចិត្តទុកដាក់ជាពិសេសសម្រាប់ការអភិវឌ្ឍវិស័យនេះ ប្រកបដោយនវានុវត្តន៍និងបរិយាបន្ន។ ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន អ.ស.ហ. បានដើរតួនាទីជាសារវន្តដល់កិច្ចដំណើរការរបស់ អ.ស.ហ. និងក្រុមប្រឹក្សា អ.ស.ហ. លើផ្នែកកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកវិទ្យាព័ត៌មាន និងកិច្ចការគតិយុត្ត ព្រមទាំងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចដំណើរការរបស់ អ.ស.ហ. ផងដែរ។ អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. បំពេញ

មុខងារជាសេនាធិការជូនក្រុមប្រឹក្សា អ.ស.ហ. និងប្រធានក្រុមប្រឹក្សា អ.ស.ហ. លើការងារតាមដានត្រួតពិនិត្យលើភាពត្រឹមត្រូវ ភាពសមស្រប និងភាពគ្រប់គ្រាន់នូវអនុលោមភាព សមិទ្ធកម្ម ហិរញ្ញវត្ថុ ធនធានមនុស្ស ទ្រព្យសកម្ម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អង្គភាពក្រោមឱវាទ អ.ស.ហ.។

## II. សមិទ្ធផលរួមរបស់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

សមិទ្ធផលទាំងនោះបានឆ្លុះបញ្ចាំងឱ្យឃើញនូវការខិតខំប្រឹងប្រែងជាជំហានៗរបស់ អ.ស.ហ. ក្នុងការគិតគូរទៅលើការរៀបចំឱ្យមានកម្មវិធីការងាររបស់ អ.ស.ហ. ចំនួន ៤ ធំៗ រួមមាន៖ i/-ការរៀបចំឱ្យមានក្របខ័ណ្ឌគោល-នយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគាររួមទាំងក្របខ័ណ្ឌនៃការរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័ន ii/-ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមិនមែនធនាគារ ទាំងទិដ្ឋភាពនៃការធ្វើបញ្ញត្តិកម្ម ការជំរុញកំណើនទីផ្សារ ការលើកកម្ពស់បរិយាបន្ន និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការធានាសុចរិតភាពក្នុងទីផ្សារ iii/-ការរៀបចំឱ្យមាននូវយន្តការស្ថិរភាពហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ សំដៅចូលរួមធានាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុជាតិ និង iv/-ការធានាបាននូវកិច្ចដំណើរការរបស់ អ.ស.ហ. ប្រកបដោយប្រសិទ្ធភាព។ សមិទ្ធផលរបស់ អ.ស.ហ. ទៅតាមកម្មវិធីទាំង ៤ របស់ អ.ស.ហ. មានរៀបរាប់លម្អិត ដូចខាងក្រោម៖

**ទី១៖ អភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងអភិវឌ្ឍស្ថាប័ន**

ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងអភិវឌ្ឍស្ថាប័ន គឺជាអាទិភាពស្នូលរបស់ អ.ស.ហ., ម្ខាង, ដើម្បីកំណត់ទិសដៅអភិវឌ្ឍន៍នៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, និងមួយផ្នែកទៀតក៏ចូលរួមកសាងសមត្ថភាពរបស់ស្ថាប័នផងដែរ។ ក្នុងន័យនេះ ឯកសារដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងចក្ខុវិស័យ ក្នុងរយៈពេលខ្លី មធ្យម និងវែងមួយចំនួន ត្រូវបានរៀបចំ និងដាក់ចេញឱ្យអនុវត្ត រួមមាន៖ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជារយៈពេល ១០ ឆ្នាំ (២០២១-២០៣០) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ២០២៤-២០២៨ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជាឆ្នាំ ២០២១-២០៣០។ ដោយឡែក ផែនការអភិវឌ្ឍន៍ស្ថាប័ននឹងត្រូវបានរៀបចំក្រោមក្របខ័ណ្ឌ អ.ស.ហ. ជារួម និងទៅតាមអង្គភាពនីមួយៗ ព្រមទាំងផែនការសកម្មភាពសម្រាប់ ៣ ឆ្នាំ រំកិលសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័នរបស់អង្គភាពក្រោមឱវាទ អ.ស.ហ. ផងដែរ។

**ទី២៖ អភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមិនមែនធនាគារ**

ទន្ទឹមនឹងការរីកចម្រើនឥតឈប់ឈរនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ការគិតគូរទៅលើការពង្រឹង និងពង្រីកវិសាលភាពនៃលិខិតបទដ្ឋានគតិយុត្ត នឹងក្លាយជាអាទិភាពជាយុទ្ធសាស្ត្រមួយដ៏សំខាន់ផងដែរសំដៅធ្វើនិយ័តកម្មទីផ្សារឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងការបង្កើតឱ្យមានឧបករណ៍ហិរញ្ញវត្ថុថ្មីៗ ដើម្បីធ្វើពិពិធកម្ម និងជំរុញកំណើនទីផ្សារប្រកបដោយបរិយាបន្ន និងសុចរិតភាព ផងដែរ។ ក្នុងន័យនេះ សមិទ្ធផលគន្លឹះៗមួយចំនួនរួមមាន៖

- **វិស័យធានារ៉ាប់រង៖** អនុក្រឹត្យស្តីពីការធានារ៉ាប់រង ប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ប្រកាសស្តីពីនីតិវិធី និងវិធាននៃការគណនាប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង ប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង និងអនុក្រឹត្យស្តីពីការធានា-រ៉ាប់រងខ្នាតតូច។
- **វិស័យមូលបត្រ៖** ផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនចំនួន ៤ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងក្រុមហ៊ុនចំនួន ២ បោះផ្សាយលក់មូលបត្របំណុល។ ទន្ទឹមនឹងនេះ មានការអនុម័តនូវប្រកាសចំនួនប្រាំ រួមមាន ប្រកាសស្តីពីការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម ប្រកាសស្តីពីបរិវត្តនសាកល្បង

បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈរបស់ក្រុមហ៊ុនហ្វូលឌីង។

- **វិស័យសោធននៃប្រព័ន្ធសន្តិសុខសង្គម៖** អនុក្រឹត្យស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម អនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម សេចក្តីសម្រេចស្តីពីលក្ខខណ្ឌក្នុងការ-ជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងប្រព័ន្ធសន្តិសុខសង្គម និងសេចក្តីណែនាំស្តីពីការកំណត់ប្រភេទ និងទម្រង់របាយការណ៍របស់ប្រតិបត្តិករសន្តិសុខសង្គម និងភាគីពាក់ព័ន្ធ។
- **វិស័យបរធនបាលកិច្ច៖** ប្រកាសស្តីពី វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច អនុក្រឹត្យស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មនៅក្នុងវិស័យបរធន-បាលកិច្ច និងប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងការពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច។
- **វិស័យគណនេយ្យ និងសវនកម្ម៖** ប្រកាសស្តីពី ការគ្រប់គ្រងអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងប្រកាសស្តីពី ការស្នើសុំការិយបរិច្ឆេទគណនេយ្យពិសេស។
- **វិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន៖** អនុក្រឹត្យស្តីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ អនុក្រឹត្យស្តីពី ការគ្រប់គ្រងអាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ប្រកាសស្តីពី វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ប្រកាសស្តីពី វិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន និងប្រកាសស្តីពីអាជីវកម្មផ្តល់សេវាអចលនវត្ថុ។

**ទី៣៖ ការចូលរួមធានាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុជាតិ**

ស្របជាមួយនឹងយន្តការប្រមូល វិភាគ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងឃ្លាំមើលអនុវិស័យនីមួយៗ អ.ស.ហ. សម្រេចបានសមិទ្ធផលរួមមាន៖ កម្រងទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារប្រចាំគ្រា ៕-របាយការណ៍ស្តីពី ស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារប្រចាំត្រីមាស និងប្រចាំឆ្នាំ និងរបាយការណ៍ស្តីពី ការវិភាគស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ ជាមួយគ្នានេះ លិខិតបទដ្ឋានគតិយុត្តស្តីពី ការបង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា និងក្រុមការងារស្ថិរភាពហិរញ្ញវត្ថុប្រចាំ អ.ស.ហ. ត្រូវបានពិនិត្យឡើងវិញ។ លើសពីនេះ ប្រកាសស្តីពីធានារ៉ាប់រងបន្ត ប្រកាសស្តីពីព័ត៌មានចីរភាព ប្រកាសស្តីពីលក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុនៃក្រុមហ៊ុនធ្វើអាជីវកម្មគម្រោងវិនិយោគរួម និងសេចក្តីសម្រេចស្តីពីនីតិវិធីនិងយន្តការនៃការដោះស្រាយវិវាទ ឬបណ្តឹង ត្រូវបានដាក់ចេញ។

**ទី៤៖ ប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ អ.ស.ហ.**

លិខិតបទដ្ឋានគតិយុត្ត និងឯកសារដែលមានចរិតគាំទ្រដល់ប្រសិទ្ធភាពនៃកិច្ចដំណើការរបស់ អ.ស.ហ. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត រួមមាន៖ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា អ.ស.ហ. អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រកាសស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានរបស់និយ័តករ និងអង្គភាពក្រោមឱវាទរបស់ អ.ស.ហ. និងរបាយការណ៍សមិទ្ធផលប្រចាំឆ្នាំ និងទិសដៅការងារឆ្នាំបន្ទាប់ របស់ អ.ស.ហ. ដោយផ្សារភ្ជាប់ជាមួយនឹងការពិនិត្យ និងអនុម័តថវិកាប្រចាំឆ្នាំ របស់ អ.ស.ហ. ផងដែរ។

បន្ថែមពីនេះ ដើម្បីធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពនៃកិច្ចប្រតិបត្តិការរបស់អង្គភាពក្រោមឱវាទ អ.ស.ហ. បានដាក់ចេញ ៖ i/-ការរៀបចំបទប្បញ្ញត្តិ និងឯកសារសំខាន់ៗដែលជាស្តង់ដារប្រតិបត្តិបម្រើដល់ការងារផ្ទៃក្នុង និងការងារសវនកម្ម ii/-ការអភិវឌ្ឍកម្មវិធីព័ត៌មានវិទ្យាចាំបាច់បម្រើដល់ការងារគ្រប់គ្រងរដ្ឋបាល និងសវនកម្ម iii/-ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់អង្គភាពក្រោមឱវាទ អ.ស.ហ. និងបុគ្គលជាប់ពាក់ព័ន្ធលើមុខងារសវនកម្មផ្ទៃក្នុង iv/-ការតាមដានត្រួតពិនិត្យលើអង្គភាពក្រោមឱវាទ អ.ស.ហ. តាម-រយៈការចុះធ្វើសវនកម្ម និងការពិនិត្យឡើងវិញការអនុវត្តការប្រមូលចំណូល ការអនុវត្តចំណាយ ការបង់ភាគទាន និងការប្រើប្រាស់ភាគទាននិង v/-ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ទន្ទឹមនឹងសមិទ្ធផលសម្រេចបានគួរជាទីមោទនៈ អ.ស.ហ. ក៏បានជួបនូវបញ្ហាប្រឈម មួយចំនួន រួមមាន៖

- ឯកសារគតិយុត្តមិនទាន់មានភាពគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងប្រតិបត្តិករក្នុងទីផ្សារ។
- ក្របខ័ណ្ឌគាំពារអតិថិជនក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារមិនទាន់មានភាពគ្រប់គ្រាន់ ដោយបច្ចុប្បន្នមានត្រឹមការរៀបចំដាច់ដោយឡែកទៅតាមវិស័យនីមួយៗ។
- ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មរបស់ អ.ស.ហ. មិនទាន់មានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយដើម្បីវាស់វែងសមិទ្ធកម្មនៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ អ.ស.ហ. មានទិសដៅជាយុទ្ធសាស្ត្រទៅតាមអនុវិស័យនីមួយៗ ដូចមានកំណត់លម្អិតក្នុងជំពូកទី៦ ៧ ៨ ៩ ១០ ១១ និង ១២។

ដោយឡែក ទិសដៅយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន អ.ស.ហ. បានរៀបចំស្របតាមកម្មវិធីការងារទាំង ៥ របស់ អ.ស.ហ.។ ទិសដៅយុទ្ធសាស្ត្រនេះនឹងបង្ហាញពីចំណុចគោលរួម ដែលបានដាក់ចេញសម្រាប់អនុវត្តក្នុងរយៈពេលខ្លីទៅមធ្យម។

### ក. អភិវឌ្ឍន៍ក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងអភិវឌ្ឍន៍ស្ថាប័ន

-បន្តរៀបចំឯកសារណែនាំស្តីពីការតាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងយុទ្ធ-សាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងឯកសារគោលស្តីពី ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់វាស់វែងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

-ចូលរួមជាមួយភាគីពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ទៅតាមក្របខ័ណ្ឌពេល-វេលាកំណត់ ផងដែរ។

-បន្តចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិដែលមានលក្ខណៈប្រហាក់ប្រហែល សំដៅទាញយកនូវអត្ថប្រយោជន៍ពីកិច្ចសហប្រតិបត្តិការនោះ ទាំងទិដ្ឋភាពបណ្តុះបណ្តាលធនធានមនុស្ស និងជំនួយបច្ចេកទេស ជាដើម។

-ពិនិត្យលទ្ធភាពបង្កើតអង្គភាពទទួលបន្ទុកនិងរៀបចំក្របខ័ណ្ឌបរិស្ថាន សង្គម និងអភិបាលកិច្ច ដើម្បីឆ្លើយ-តបទៅនឹងនិន្នាការពិភពលោកក្នុងការជំរុញការអភិវឌ្ឍបៃតង។

### ខ. អភិវឌ្ឍទីផ្សារហិរញ្ញវត្ថុមិនមែនធនាគារ

-សហការរៀបចំបង្កើតគោលការណ៍ណែនាំមួយសម្រាប់តាមដានការអភិវឌ្ឍផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុថ្មីៗក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

-ចូលរួមរៀបចំក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំ ពាក់ព័ន្ធដើម្បីបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ។

-រៀបចំប្រព័ន្ធកិច្ចការពារអតិថិជន/អ្នកប្រើប្រាស់ ព្រមទាំងយន្តការស៊ើបអង្កេត និងដោះស្រាយបណ្តឹង ដោយសិក្សាស្រាវជ្រាវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅបណ្តាប្រទេសនានាក្នុងតំបន់អាស៊ាន ប្រទេសដៃគូអាស៊ាន និងស្ថាប័នអន្តរជាតិ ដើម្បីឈានទៅរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងគោលបំណងអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព។

-រៀបចំបង្កើតក្រុមការងារនិយ័តកម្មគម្រោងធានាឥណទាន ក្នុងគោលបំណងរៀបចំយន្តការការងារផែនការសកម្មភាពការងារ និងផែនទីបង្ហាញផ្លូវ ដើម្បីឈានដល់ការរៀបចំច្បាប់និងបទប្បញ្ញត្តិថ្មីៗ សម្រាប់ការគ្រប់គ្រងគម្រោងធានាឥណទាន នាពេលអនាគត។

-សិក្សា ស្រាវជ្រាវលើសមិទ្ធិលទ្ធភាពនៃការអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញប្បទានលើចលនវត្ថុ (Movable Asset Financing Strategy) និងយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានដល់អ្នកប្រើប្រាស់ (Consumer Financing Strategy) ព្រមទាំងនឹងរៀបចំ អនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រទាំងពីរនេះ ស្របតាមលទ្ធផលនៃការសិក្សាសមិទ្ធិ-លទ្ធភាព ផងដែរ។

-រៀបចំក្របខ័ណ្ឌលើកទឹកចិត្តពន្ធដារសម្រាប់វិស័យហិរញ្ញវត្ថុ ទាំងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុប្រកបដោយចីរភាព។

**គ. ការធានាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុមិនមែនធនាគារ**

-សម្របសម្រួលយន្តការគ្រប់គ្រង និងកាត់បន្ថយហានិភ័យក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ប្រព័ន្ធផ្តល់សញ្ញាជាមុន សម្រាប់ក្របខ័ណ្ឌ អ.ស.ហ នឹងបានរៀបចំ និងពង្រីកវិសាលភាពការងារ ដើម្បីចូលរួមក្នុងការរៀបចំបទ-ប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការធានាស្ថិរភាពហិរញ្ញវត្ថុ។

-រៀបចំរបាយការណ៍ "ម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ៖ ទស្សនវិស័យប្រចាំឆ្នាំ" នឹងត្រូវបានរៀបចំ ក្នុងគោលបំណងវាយតម្លៃពីកម្មវិបាកនៃម៉ាក្រូសេដ្ឋកិច្ចលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងការរួម-ចំណែករបស់វិស័យហិរញ្ញវត្ថុមិនមែនធនាគារទៅក្នុងសេដ្ឋកិច្ច។

-ជំរុញអនុលោមភាព និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ អ.ស.ហ. ក៏នឹងផ្តោតលើកិច្ចការមួយចំនួន ដូចខាង-ក្រោម៖

- ចូលរួមរៀបចំ និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- ចូលរួមរៀបចំវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពី ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
- តាមដាន និងជំរុញអនុលោមភាពរបស់និយ័តករក្រោមឱវាទ អ.ស.ហ. ឱ្យស្របតាមអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ និងពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព។
- លើកកម្ពស់ការយល់ដឹងដល់មន្ត្រីជំនាញ និងបុគ្គលរាយការណ៍របស់អង្គភាពក្រោមឱវាទ អ.ស.ហ. អំពីបទប្បញ្ញត្តិការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ឃ. ការជំរុញប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ អ.ស.ហ.**

-ពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការ ដោយរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍សមិទ្ធកម្ម ទៅតាមគ្រានឹងត្រូវបានរៀបចំជូនក្រុមប្រឹក្សា អ.ស.ហ. ពិនិត្យ និងផ្តល់ការតម្រង់ទិស ដោយប្រើប្រាស់យន្តការតាមដាន និងវាយ-តម្លៃសមិទ្ធកម្មរបស់ អ.ស.ហ. ធ្វើជាមូលដ្ឋាន។

-បន្តតាមដាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងច្រកចេញចូលតែមួយ ដើម្បីពង្រឹងស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងគិតគូរដល់ការរៀបចំបទប្បញ្ញត្តិក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់ អ.ស.ហ.។

-ធានានូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃប្រតិបត្តិការរបស់អង្គភាពក្រោមឱវាទដោយបន្តផ្តោតលើបេសកកម្មការងារធំៗចំនួន ២ រួមមាន៖ i/-ការលុបបំបាត់ភាពអសកម្មក្នុងប្រតិបត្តិការរបស់អង្គភាពក្រោមឱវាទ តាមរយៈប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការតាមដានត្រួតពិនិត្យអង្គភាពក្រោមឱវាទ និង ii/-ការបង្ការកុំឱ្យភាពអសកម្មកើតមានឡើងក្នុងប្រតិបត្តិការនៃបណ្តាអង្គភាពក្រោមឱវាទ តាមរយៈការអភិវឌ្ឍចំណេះដឹងពាក់ព័ន្ធនឹងមុខងារសវនកម្ម ព្រមទាំងការពង្រឹង និងពង្រីកការបញ្ជ្រាបការយល់ដឹង និងការផ្សព្វផ្សាយមុខងារសវនកម្មជូនមន្ត្រីក្រោមឱវាទ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៤។***



# ជំពូក ៧
# វិស័យធានារ៉ាប់រង

## I. ទិដ្ឋភាពទូទៅ

វិស័យធានារ៉ាប់រង ចាប់ផ្តើមមានវត្តមាននៅកម្ពុជាក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ ១៩៩០ ជាមួយនឹងការបង្កើតក្រុមហ៊ុនរដ្ឋមួយមានឈ្មោះថា ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាមិនកូ) ដែលដើរតួនាទីជាប្រតិបត្តិករផង និងជានិយ័តករផង។ បន្ទាប់ពីច្បាប់ស្តីពីការធានារ៉ាប់រងត្រូវបានអនុម័តឆ្នាំ ២០០០ មានការវិនិយោគបង្កើតក្រុមហ៊ុនធានារ៉ាប់រងទូទៅជាបន្តបន្ទាប់។ រហូតដល់ឆ្នាំ ២០១១ រាជរដ្ឋាភិបាលបានសម្រេចផ្តល់អាជ្ញាប័ណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចបណ្តោះអាសន្ន សម្រាប់ប្រជាពលរដ្ឋដែលមានចំណូលទាបនៅតាមទីជនបទ[៣] និងអនុញ្ញាតឱ្យមានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនាឆ្នាំ ២០១២។

យោងតាមទិន្នន័យដែលមិនទាន់រងសវនកម្ម បុព្វលាភដុលធានារ៉ាប់រងត្រូវបានព្យាករណ៍ កើនឡើងដល់ប្រមាណ ៣៧០ លានដុល្លារអាម៉េរិក។ បើគិតចាប់តាំងពីឆ្នាំ ២០១៤ ទំហំទីផ្សារធានារ៉ាប់រងកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ ២២%។ ទន្ទឹមនេះ ទោះក្នុងវិបត្តិកូវីដ-១៩ ទីផ្សារធានារ៉ាប់រងកម្ពុជានៅតែបន្តរក្សាបានកំណើនវិជ្ជមានក្នុងអត្រាប្រមាណ ១០% នាឆ្នាំ ២០២១ និង ១១% នាឆ្នាំ ២០២២។ ដង់ស៊ីតេធានារ៉ាប់រងបានកើនឡើងពី ៣,៩៧[4] ដុល្លារអាម៉េរិកក្នុងប្រជាជនម្នាក់ នាឆ្នាំ ២០១៤ ដល់ ២២,៣៣[5] ដុល្លារអាម៉េរិកក្នុងប្រជាជនម្នាក់ នាឆ្នាំ ២០២៤។ ក្នុងនោះ អត្រាភាគទានធានារ៉ាប់រងអាយុជីវិតមានអត្រាខ្ពស់ជាងអត្រាភាគទានធានារ៉ាប់រងទូទៅ និងជាកត្តាជំរុញដ៏សំខាន់មួយនៃកំណើនវិស័យធានារ៉ាប់រងទាំងមូល។ គួរបញ្ជាក់ថា អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចកម្ពុជា បានកើនឡើងពី ០,៣៧%[៦] នាឆ្នាំ ២០១៤ ដល់ ១,១៧[៧] នាឆ្នាំ ២០២៤, ប៉ុន្តែអត្រានេះស្ថិតក្នុងចំណោមអត្រាទាបបំផុតនៅក្នុងទីផ្សារធានារ៉ាប់រងអាស៊ាន និងទាបជាងអត្រាមធ្យមភាគពិភពលោកដែលមានអត្រាប្រមាណ ៧,៣%[៨]។

## II.ការកែទម្រង់ និងសមិទ្ធផល

ដើម្បីជំរុញកំណើនប្រកបដោយចីរភាព រាជរដ្ឋាភិបាល បានធ្វើកំណែទម្រង់ និងបានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

### ក. ការបង្កើតនិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.) ជាស្ថាប័នឯករាជ្យ ដែលមានតួនាទីនិងភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រងនៅកម្ពុជា

ន.ធ.ក. ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារបានគូសបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់ ន.ធ.ក. និងនាយកដ្ឋានក្រោមឱវាទចំនួន ៥។

---

[៣] ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០

[៤] ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

[៥] ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

[៦] ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

[៧] ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

[៨] ប្រភព៖ https://www.statista.com/statistics/381174/insurance-penetration-in-selected-countries-worldwide/

### ខ. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ ត្រូវបានរៀបចំ ទន្ទឹមនឹងការដាក់ចេញផែនការសកម្មភាពការងារត្រូវអនុវត្តក្នុងរយៈពេលខ្លី (២០២១-២០២៣) រយៈពេលមធ្យម (២០២៤-២០២៨) និងរយៈពេលវែង (២០២៩-២០៣០) ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សា អ.ស.ហ. នាខែ កញ្ញា ឆ្នាំ ២០២១។

### គ. ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងការអប់រំ

ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង ទិវាធានារ៉ាប់រងកម្ពុជាប្រចាំឆ្នាំ ក៏ត្រូវបានរៀបចំ គួបផ្សំនឹងការរៀបចំឱ្យមានសិក្ខាសាលាផ្សព្វផ្សាយតាមបណ្តាខេត្តទូទាំងប្រទេស ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ដូចជាបណ្តាញសារព័ត៌មាន និងបណ្តាញសង្គម។ ទន្ទឹមនេះ ដើម្បីបញ្ជ្រាបការយល់ដឹងពីវិស័យនេះ ឱ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយបន្ថែមទៀត វិស័យធានារ៉ាប់រងក៏ត្រូវបានគិតគូររៀបចំឱ្យមានការដាក់បញ្ចូលក្នុងកម្មវិធីសិក្សាផងដែរ។

### ឃ. ការបង្កើតវិទ្យាស្ថានធានារ៉ាប់រងកម្ពុជា

បន្ថែមពីការបញ្ជ្រាបការយល់ដឹង ការបង្កើតវិទ្យាស្ថានធានារ៉ាប់រងក៏ត្រូវបានគិតគូររៀបចំ ដូចមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០។ វិទ្យាស្ថានធានារ៉ាប់រងកម្ពុជា នឹងផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង រួមមានវគ្គបណ្តុះបណ្តាលសម្រាប់អន្តរការីធានារ៉ាប់រងដូចជា ដើងសា និងភ្នាក់ងារធានារ៉ាប់រង វគ្គជំនាញគណនាបុព្វលាភធានារ៉ាប់រង និងវាយតម្លៃហានិភ័យធានារ៉ាប់រង។

### ង. ក្របខ័ណ្ឌបញ្ញត្តិកម្ម

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារធានារ៉ាប់រងកម្ពុជាឱ្យកាន់តែបានគ្រប់ជ្រុងជ្រោយ គឺតម្រូវឱ្យមានការគិតគូររៀបចំលិខិតបទដ្ឋានគតិយុត្តបន្ថែមទៀត តួយ៉ាង អនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច និងប្រកាសមួយចំនួន គឺបានទទួលការអនុម័ត។ បន្ថែមពីនេះ អនុក្រឹត្យស្តីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច" និងបទប្បញ្ញត្តិគាំទ្រមួយចំនួនទៀត ក៏បាននិងកំពុងរៀបចំ ដើម្បីដាក់ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចឱ្យអនុវត្តជាបណ្តើរៗ ចំពោះយានយន្តគ្រប់ប្រភេទដែលធ្វើចរាចរលើផ្លូវថ្នល់សាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា។

### ច. ការត្រួតពិនិត្យហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារ

ដើម្បីពង្រឹងនូវយន្តការនៃការត្រួតពិនិត្យហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារ វិធីសាស្ត្រត្រួតពិនិត្យតាមទំហំហានិភ័យ (Risk-based supervision) ត្រូវបានដាក់ឱ្យអនុវត្ត ជាមួយនឹងការ កំណត់ដើមទុនតម្រូវតាមទំហំហានិភ័យរបស់ក្រុមហ៊ុននីមួយៗ (Solvency I)។ ជាមួយនោះផង នីតិវិធីប្រតិបត្តិសម្រាប់ការត្រួតពិនិត្យហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សារចំនួន ២ សម្រាប់ការត្រួតពិនិត្យលើឯកសារ (Off-site inspection) និង ២ សម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង (On-site inspection) ត្រូវបានរៀបចំ, ហើយនីតិវិធីប្រតិបត្តិសម្រាប់ការត្រួតពិនិត្យ AML ក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តផងដែរ។

### ឆ. បច្ចេកវិទ្យាធានារ៉ាប់រង និងឌីជីថល

ក្នុងគោលដៅជំរុញឌីជីថលូបនីយកម្ម និងបច្ចេកវិទ្យា គោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រង និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនសម្រាប់ ន.ធ.ក. បានរៀបចំ និងដាក់ឱ្យអនុវត្ត។

### ជ. ការអភិវឌ្ឍធនធានមនុស្ស និងជំនាញវិជ្ជាជីវៈ

កម្មវិធីបណ្តុះបណ្តាលសម្រាប់វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលគិតត្រឹមដំណាច់ឆ្នាំ ២០២៤ មានភ្នាក់ងារធានារ៉ាប់រងចំនួន ២៥.៤១១ រូប បានចុះបញ្ជីទទួលស្គាល់ដោយ ន.ធ.ក.។ បន្ថែមពី

នេះក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង និងក្រមសីលធម៌វិជ្ជាជីវៈជើងសាធានារ៉ាប់រង ក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តផងដែរ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

យ៉ាងណាមិញ យោងតាមអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចនិងដង់ស៊ីតេធានារ៉ាប់រងបញ្ជាក់ថា ទីផ្សារធានារ៉ាប់រងកម្ពុជា មានអត្រាទាបធៀបនឹងប្រទេសក្នុងតំបន់ ដែលត្រូវបានវាយតម្លៃថាបណ្តាលមកពីបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

### ក. ការយល់ដឹង និងអក្ខរកម្មធានារ៉ាប់រង

មូលហេតុចម្បងដែលបណ្តាលឱ្យអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចកម្ពុជានៅមានកម្រិតទាប គឺការខ្វះខាតព័ត៌មានអំពីសេវាធានារ៉ាប់រងនិងអក្ខរកម្មធានារ៉ាប់រង និងការខ្វះទំនុកចិត្តលើក្រុមហ៊ុនធានារ៉ាប់រង។ ការធានារ៉ាប់រងត្រូវបានយល់ឃើញថា ជាផលិតផលសន្សំដែលផ្តល់ប្រាក់ចំណេញតិចតួច ហើយម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវរង់ចាំរយៈពេលយូរសម្រាប់ការទទួលបានប្រាក់ចំណេញទាំងនេះ។

### ខ. ការអភិវឌ្ឍទីផ្សារ

#### ខ.១. ការធានារ៉ាប់រងជាកាតព្វកិច្ច

នៅបណ្តាប្រទេសជាច្រើន ការធានារ៉ាប់រងភារៈទទួលខុសត្រូវ បានរួមចំណែកខ្ពស់ក្នុងវិស័យធានារ៉ាប់រងទូទៅ ខណៈដែលនៅកម្ពុជា ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬការធានារ៉ាប់រងយានយន្តលើតតិយជន (សម្រាប់យានយន្តប្រកបអាជីវកម្ម) ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ និងការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ត្រូវបានកំណត់ជាកាតព្វកិច្ចធានារ៉ាប់រងក្រោមច្បាប់ស្តីពីការធានារ៉ាប់រង ឆ្នាំ ២០១៤ ប៉ុន្តែការអនុវត្តនៅមានកម្រិតនៅឡើយ។ លើសពីនេះ ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តដែលប្រើប្រាស់ជាលក្ខណៈគ្រួសារមិន-ទាន់ត្រូវបានកំណត់ឱ្យអនុវត្តជាកាតព្វកិច្ចនៅឡើយ។

#### ខ.២. ការធានារ៉ាប់រងខ្នាតតូច

បុព្វលាភធានារ៉ាប់រងដុលសរុបក្នុងទីផ្សារធានារ៉ាប់រងខ្នាតតូច (រួមបញ្ចូលបុព្វលាភធានារ៉ាប់រងពីក្រុមហ៊ុនធានា-រ៉ាប់រងខ្នាតតូច និងផលិតផលធានារ៉ាប់រងខ្នាតតូចដែលលក់ដោយក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត) បានកើនឡើងពី ៥៤,៨៧ លានដុល្លារអាម៉េរិក នាឆ្នាំ ២០២០ រហូតដល់ ៦០,៧៦[៦] លានដុល្លារអាម៉េរិក នាឆ្នាំ ២០២៤។ យ៉ាងណាមិញ បើធៀបនឹងទំហំទីផ្សារធានារ៉ាប់រងទាំងមូល គឺមានតែប្រមាណ ១៦% ប៉ុណ្ណោះ។

#### ខ.៣. ការធានារ៉ាប់រងកសិកម្ម និងគ្រោះមហន្តរាយ

ការធានារ៉ាប់រងបានដើរតួនាទីយ៉ាងសំខាន់ ក្នុងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ តាមរយៈការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកសិកម្ម។ គួរឱ្យកត់សម្គាល់ផងដែរ ការចូលរួមពីវិស័យឯកជនក្នុងការផ្តល់ការធានារ៉ាប់រងលើវិស័យកសិកម្ម នៅមានកម្រិតតិចតួចបំផុត។ ជាលទ្ធផល គិតត្រឹមដំណាច់ឆ្នាំ ២០២៤ ក្រុមហ៊ុនបានផ្តល់ការធានាដល់ផ្ទៃដីសរុបប្រមាណ ១៦ ម៉ឺនហិកតា ខណៈដែលផ្ទៃដីដាំដុះស្រូវសរុបនៅប្រទេសកម្ពុជាមានជាង ៣ លានហិកតា។ កន្លងមក បើទោះជាមានការសាកល្បងឧបត្ថម្ភធនពីរាជរដ្ឋាភិបាលក្នុងការបង់បុព្វលាភ ៥០ ភាគរយ ចំពោះផលិតផលធានារ៉ាប់រងកសិកម្មនៅតាមជនបទមួយចំនួនតូចក៏ដោយ ការឧបត្ថម្ភធនដល់ក្រុមហ៊ុនធានារ៉ាប់រងនៅមិនមានភាពច្បាស់លាស់ និងយូរអង្វែង ហើយម្យ៉ាងវិញទៀត ក្រុមហ៊ុនធានារ៉ាប់រងមិនមានឆន្ទៈក្នុងការផ្តល់ការធានាលើវិស័យនេះទេ ដោយសារចំណាយប្រតិបត្តិការខ្ពស់ទៅលើការបំពាក់ និងថែរក្សាឧបករណ៍តាមដានអាកាសធាតុ និងសំណើមដី បូករួមអត្រានៃការទាមទារសំណងខ្ពស់ ហើយប្រាក់ចំណេញទាប។

---

៦ ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

ជាមួយគ្នានេះ ការប្រែប្រួលអាកាសធាតុក៏បានបង្កផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជាផ្លូវថ្នល់ស្ពានៗល។ គិតមកទល់ពេលនេះ មិនទាន់មានយន្តការផ្ទេរហានិភ័យសមស្របណាមួយសម្រាប់រាជរដ្ឋាភិបាលនៅឡើយ។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវពិចារណាអំពីយន្តការរឹងមាំដែលអាចធានាលើហានិភ័យប្រែប្រួលអាកាសធាតុទាំងទៅលើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សម្រាប់រយៈពេលវែង និងប្រកបដោយចីរភាព។

**ខ.៤. តារាងមរណភាព និងការកើតជំងឺ**

បច្ចុប្បន្នកម្ពុជាមិនទាន់មានតារាងមរណភាព (Mortality table) និងតារាងការកើតជំងឺ (Morbidity table) នៅឡើយ ហើយក្រុមហ៊ុនធានារ៉ាប់រងនីមួយៗបានប្រើប្រាស់តារាងដែលរៀបចំដោយក្រុមហ៊ុនធានារ៉ាប់រងផ្ទាល់។ ការខ្វះទិន្នន័យទាំងនេះ ធ្វើឱ្យការគណនាបុព្វលាភធានារ៉ាប់រងមិនមានភាពត្រឹមត្រូវ និងច្បាស់លាស់ ដែលធ្វើឱ្យមានភាពលម្អៀងខ្ពស់។

**គ. ក្របខ័ណ្ឌត្រួតពិនិត្យ**

**គ.១. អភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង**

អភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានកំណត់ដោយប្រកាសស្តីពីអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង ដែលទទួលបានការអនុម័តនាខែ មីនា ឆ្នាំ ២០០៧ ហើយត្រូវបានកែសម្រួល និងដាក់ឱ្យអនុវត្តនាខែ មករា ឆ្នាំ ២០២៤[១០]។ ការពង្រឹងក្របខ័ណ្ឌអភិបាលកិច្ច ស្របតាមគោលការណ៍គ្រឹះធានារ៉ាប់រងរបស់សមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ គឺជាកត្តាសំខាន់ ជាពិសេសលើតួនាទីរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ចំពោះការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង។

**គ.២. វិធីសាស្ត្រត្រួតពិនិត្យតាមទំហំហានិភ័យ**

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ បានដាក់គោលដៅក្នុងការផ្លាស់ប្តូរពីវិធីសាស្ត្រត្រួតពិនិត្យតាមបទប្បញ្ញត្តិទៅជាវិធីសាស្ត្រត្រួតពិនិត្យតាមទំហំហានិភ័យ។ ជាក់ស្តែង វិធីសាស្ត្រត្រួតពិនិត្យតាមទំហំហានិភ័យ ត្រូវបានអនុវត្តតាំងពីឆ្នាំ ២០២២ តាមរយៈប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង និងនីតិវិធីប្រតិបត្តិសម្រាប់ការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង ដោយមានកំណត់សូចនាករហានិភ័យគន្លឹះ (KRIs) និងការវិភាគវាយតម្លៃកម្រិតហានិភ័យរបស់ក្រុមហ៊ុន។

យ៉ាងណាក៏ដោយ ការរៀបចំក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យក្រុមហ៊ុនធានារ៉ាប់រង សម្រាប់គោលបំណងសាធនភាព (ERM) ដែលតម្រូវឱ្យមានការកែសម្រួលទម្រង់របាយការណ៍ និង ឬការកំណត់សូចនាករហានិភ័យគន្លឹះឡើងវិញសម្រាប់វិស័យធានារ៉ាប់រង ជាកត្តាសំខាន់ ដែលនឹងត្រូវរៀបចំដើម្បីអនុលោមស្របតាមគោលការណ៍គ្រឹះធានារ៉ាប់រងលេខ ១៦។

**គ.៣. ការរាយការណ៍**

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ បានសង្កត់ធ្ងន់លើការត្រួតពិនិត្យ ដែលជាស្នូលក្នុងការធានាបាននូវស្ថិរភាពនៃវិស័យនេះ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការរាយការណ៍ ន.ធ.ក. បានរៀបចំ និងដាក់ឱ្យអនុវត្តបទប្បញ្ញត្តិមួយចំនួនដើម្បីកំណត់របបរាយការណ៍របស់ក្រុមហ៊ុនធានារ៉ាប់រងជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ក្នុងនោះរួមមាន៖ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។

យ៉ាងណាមិញ ក្រុមហ៊ុនធានារ៉ាប់រងមិនទាន់តម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃអំពីស្ថានភាពហិរញ្ញវត្ថុ (Financial condition report) ឡើយ។ គោលការណ៍គ្រឹះធានារ៉ាប់រង ក៏បានគូសបញ្ជាក់អំពីតម្រូវការនៃរបាយការណ៍នេះ ដែលរួមបញ្ចូលហានិភ័យនានាដែលក្រុមហ៊ុនធានារ៉ាប់រងកំពុងជួបប្រទះ សម្រាប់ការវាយតម្លៃរបស់អ្នកជំនាញ

[១០] ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

គណនាបុព្វលាភធានារ៉ាប់រង ដូចជាអត្រានៃបុព្វលាភធានារ៉ាប់រង ការវិភាគនៃអតិរេក អាយុកាលនៃផលិតផល ការវិភាគលើការវិនិយោគ និងចំណាយ ជាដើម។

**គ.៤. អនុលោមភាពគោលការណ៍គ្រឹះធានារ៉ាប់រង**

ន.ធ.ក. បានចូលជាសមាជិកនៃសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិនាថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០២៣ និងបានរៀបចំស្វ័យវាយតម្លៃលើអនុលោមភាពគោលការណ៍គ្រឹះធានារ៉ាប់រងនាឆ្នាំ ២០២៣ ដោយបានលទ្ធផលៈ ប្រតិបត្តិតាម (Observed) ចំនួន ៣ ICP ប្រតិបត្តិតាមភាគច្រើន (Largely Observed) ចំនួន ៩ ICP ប្រតិបត្តិតាមផ្នែក (Partly Observed) ចំនួន ១០ ICP និងមិនទាន់ប្រតិបត្តិតាម (Not Observed) ចំនួន ២ ICP។ យ៉ាងណាមិញ គោលការណ៍ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងអាទិភាពខ្ពស់គឺៈ គោលការណ៍លេខ ១៦ (ICP១៦) លេខ ២៤ (ICP២៤) លេខ៧ (ICP៧) លេខ១៧ (ICP១៧) លេខ១៨ (ICP៨) និងលេខ ១៣ (ICP១៣)។

**ឃ. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ**

**ឃ.១. ក្របខ័ណ្ឌបទប្បញ្ញត្តិ**

កន្លងមក លិខិតបទដ្ឋានគតិយុត្ត មួយចំនួន សម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានរៀបចំ ធ្វើបច្ចុប្បន្នកម្ម និងអនុម័តដាក់ឱ្យអនុវត្ត។ ទោះបីជាយ៉ាងណាក្របខ័ណ្ឌបទប្បញ្ញត្តិមួយចំនួនទៀតមិនទាន់ត្រូវបានរៀបចំនៅឡើយ ដូចជា បទប្បញ្ញត្តិពាក់ព័ន្ធនឹងការដាក់ការ-ធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តគ្រប់ប្រភេទជាកាតព្វកិច្ច បទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មតាមផលិតផល (សោធនឯកជន) បទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យសហគ្រាសសម្រាប់គោលបំណងសាធនភាព និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការដោះស្រាយសំណងធានារ៉ាប់រងខ្នាតតូច។

**ឃ.២. ក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

ក្នុងបេសកកម្មចូលរួមដកកម្ពុជាចេញពីបញ្ជីប្រផេះ នីតិវិធីក្នុងការរាយការណ៍ពីការប្រឆាំងការសម្អាតប្រាក់សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង សម្រាប់ជាមូលដ្ឋានក្នុងការត្រួតពិនិត្យបុគ្គលរាយការណ៍ដែលស្ថិតនៅក្នុងវិស័យធានារ៉ាប់រងត្រូវបានដាក់ឱ្យអនុវត្តនាខែ វិច្ឆិកា ឆ្នាំ ២០២២។ នីតិវិធីប្រតិបត្តិនេះ បានកំណត់តម្រូវការ ការរំពឹងទុក និងនីតិវិធីសម្រាប់ ន.ធ.ក. ចុះត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារចំពោះបុគ្គលរាយការណ៍ទាំងអស់ដែលស្ថិតនៅក្នុងវិស័យធានារ៉ាប់រង។ យ៉ាងណាមិញ ន.ធ.ក. មិនទាន់មានបទប្បញ្ញត្តិពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មខាងវិន័យ ចំពោះបុគ្គលរាយការណ៍ក្នុងវិស័យធានារ៉ាប់រង ដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ង. បច្ចេកវិទ្យាធានារ៉ាប់រង**

ដូចបានចង្អុលបង្ហាញក្នុង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០" និង "គោល-នយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨" ប្រព័ន្ធបច្ចេកវិទ្យាចំនួន ២ រួមមានៈ ១).ប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យ ដែលមានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់វិភាគនិងផ្តល់សញ្ញាមុន និង ២).ប្រព័ន្ធបច្ចេកវិទ្យានិយ័តកម្ម ដែលមានប្រព័ន្ធបច្ចេកវិទ្យាចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល និងប្រព័ន្ធបច្ចេកវិទ្យាចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យធានារ៉ាប់រង ត្រូវបានរៀបចំ។ យ៉ាងណាមិញ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោមៈ

- ប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យហិរញ្ញវត្ថុ ប្រព័ន្ធផ្តល់សញ្ញាជាមុន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យទីផ្សារធានារ៉ាប់រង នៅដាច់ដោយឡែកៗ មិនមានសមាហរណកម្មជាប្រព័ន្ធតែមួយ
- មិនទាន់មានមជ្ឈមណ្ឌលទិន្នន័យធានារ៉ាប់រងដែលមានតួនាទីអភិវឌ្ឍ គ្រប់គ្រង ថែទាំ និងធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងការធានារ៉ាប់រង

- ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រងមិនទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- ការខ្វះមូលធនមនុស្សផ្នែកបច្ចេកវិទ្យាក្នុងវិស័យធានារ៉ាប់រង និង
- អក្ខរកម្មបច្ចេកវិទ្យាធានារ៉ាប់រងនៅមានកម្រិត។

**ច. ការកសាងសមត្ថភាព**

ន.ធ.ក. បាននិងកំពុងអនុវត្តយ៉ាងសកម្មក្នុងការពង្រឹងទាំងសមត្ថភាពស្ថាប័ន និងសមត្ថភាពជំនាញ។ ទោះយ៉ាងណា បញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ មានដូចខាងក្រោម៖

- ខ្វះខាតធនធានមនុស្សជំនាញក្នុងវិស័យធានារ៉ាប់រង ដោយមិនមានកម្មវិធីសិក្សាច្បាស់លាស់ផ្នែកធានា-រ៉ាប់រងនៅតាមបណ្ដាគ្រឹះស្ថានឧត្ដមសិក្សា។
- ការខ្វះមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈធានារ៉ាប់រង ដូចជា វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង វិជ្ជាជីវៈជើងសារធានារ៉ាប់រង វិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រង និងវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង ជាដើម។ បច្ចុប្បន្នមានអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងដែលមានលក្ខណៈសម្បត្តិពេញលេញ ចំនួន ២ រូប (មកពី Society of Actuaries និង Institute of Actuaries) ផ្ដល់សេវាកម្មជំនាញដល់ក្រុមហ៊ុនធានារ៉ាប់រង។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យធានារ៉ាប់រង

### ក. ការលើកកម្ពស់ការយល់ដឹង

#### ក.១. រៀបចំការស្ទង់មតិលើការយល់ដឹង និងទំនុកចិត្តរបស់សាធារណជនលើសេវាធានារ៉ាប់រង

ការអង្កេតនឹងត្រូវបានរៀបចំឡើងដើម្បីវាស់ស្ទង់កម្រិតនៃការយល់ដឹង និងទំនុកចិត្តរបស់សាធារណជនលើសេវាធានារ៉ាប់រងនៅក្នុងប្រទេស។ របាយការណ៍ពីការអង្កេតនឹងជាធាតុចូលសម្រាប់ការរៀបចំខ្លឹមសារមាតិកាផ្សព្វផ្សាយដែលតម្រូវតាមក្រុមប្រជាសាស្ត្រនីមួយៗ និងការបង្កើតផលិតផលធានារ៉ាប់រងតាមតម្រូវការជាក់ស្ដែងសម្រាប់ម្ចាស់បណ្ណសន្យារ៉ាប់រង និងជាចុងក្រោយជួយឱ្យមានភាពកាន់តែប្រសើរឡើងនូវបទពិសោធន៍របស់អតិថិជនទាំងមូល។

ការស្ទង់មតិនេះនឹងចូលរួម៖ i/-បង្កើនការយល់ដឹងកាន់តែស៊ីជម្រៅស្ដីពីកម្រិតនៃការយល់ដឹង និងការយល់ឃើញរបស់សាធារណជននាពេលបច្ចុប្បន្ន ii/-កំណត់បរិបទសម្រាប់កម្មវិធីគំនិតផ្ដួចផ្ដើមដែលមានស្រាប់ពាក់ព័ន្ធនឹងការយល់ដឹង និង iii/-អនុញ្ញាតឱ្យមានការស្វែងយល់អំពីតម្រូវការសេវាធានារ៉ាប់រងជាក់ស្ដែង ដែលនឹងបង្កើតឱ្យមានជម្រើសផលិតផលធានារ៉ាប់រងកាន់តែសមស្របជាងមុន។

#### ក.២. ជំរុញការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង

សិក្ខាសាលាផ្សព្វផ្សាយអំពីប្រភេទ និងអត្ថប្រយោជន៍នៃផលិតផលធានារ៉ាប់រង គួរត្រូវបានរៀបចំឱ្យកាន់តែទូលំទូលាយទូទាំងប្រទេស ជាពិសេសផលិតផលធានារ៉ាប់រងជាកាតព្វកិច្ច ធានារ៉ាប់រងខ្នាតតូច ធានារ៉ាប់រងកសិកម្ម និងធានារ៉ាប់រងគ្រោះមហន្តរាយ។

### ខ. ការអភិវឌ្ឍទីផ្សារ

#### ខ.១. ការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច

ដើម្បីជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចនៅកម្ពុជាឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់ ជាពិសេសផ្ដល់សំណាញ់សុវត្ថិភាពជូនប្រជាពលរដ្ឋ ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច រួមទាំងយានយន្តដែលប្រើប្រាស់ជាលក្ខណៈគ្រួសារ នឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្ត។

**ខ.២. ការធានារ៉ាប់រងខ្នាតតូច**

ដើម្បីបង្ខិតសេវាធានារ៉ាប់រងខ្នាតតូចឱ្យកាន់តែកៀកនឹងប្រជាពលរដ្ឋ សិក្ខាសាលាដើម្បីបញ្ជ្រាបចំណេះដឹងអំពីធានារ៉ាប់រងខ្នាតតូច ជាពិសេសនៅតាមតំបន់ជនបទ និងតំបន់ខ្វះខាតសេវាធានារ៉ាប់រង និងបទប្បញ្ញត្តិដើម្បីជំរុញការដោះស្រាយសំណងឱ្យកាន់តែមានប្រសិទ្ធភាព នឹងត្រូវបន្តរៀបចំ។

**ខ.៣. ការធានារ៉ាប់រងកសិកម្ម និងគ្រោះមហន្តរាយ**

ដើម្បីចូលរួមអនុវត្តនូវយុទ្ធសាស្ត្រហិរញ្ញប្បទាន សម្រាប់ហានិភ័យគ្រោះមហន្តរាយ ២០២៣-២០២៨ និងជំរុញការផ្តល់ការធានារ៉ាប់រងកសិកម្ម និងគ្រោះមហន្តរាយ យន្តការនៃការផ្ទេរហានិភ័យដែលមានរយៈពេលវែង និងប្រកបដោយចីរភាព ដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល នឹងត្រូវគិតគូររៀបចំ។

**ខ.៤. តារាងមរណភាព និងការកើតជំងឺ**

តារាងមរណភាព (Mortality table) និងតារាងការកើតជំងឺ (Morbidity table) គួរត្រូវបានរៀបចំសម្រាប់ដាក់ឱ្យក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ប្រើប្រាស់ ដើម្បីជួយឱ្យការកំណត់បុព្វលាភធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងអាយុជីវិត និងសុខភាពកាន់តែមានសុក្រឹត្យភាព។

**គ. ក្របខ័ណ្ឌត្រួតពិនិត្យ**

**គ.១. អភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង**

ប្រកាសស្តីពីអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានធ្វើបច្ចុប្បន្នកម្ម កាលពីឆ្នាំ ២០២៤ ដោយមានការកែសម្រួលចំណុចមួយចំនួនអនុលោមតាមគោលការណ៍គ្រឹះធានារ៉ាប់រងលេខ ៧។ យ៉ាងណាមិញ ប្រកាសនេះគួរត្រូវបានធ្វើបច្ចុប្បន្នកម្មទៅតាមការវិវត្តន៍នៃទីផ្សារធានារ៉ាប់រងកម្ពុជា លើចំណុចមួយចំនួនបន្ថែមទៀត ដូចជាការបង្កើត និងកំណត់តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំងជាដើម។

**គ.២. ការត្រួតពិនិត្យតាមទំហំហានិភ័យ**

ដើម្បីពង្រឹងការគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង ក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យក្រុមហ៊ុនធានារ៉ាប់រងសម្រាប់គោលបំណងសាធនភាព (Enterprise Risk Management-ERM) ក្នុងរយៈពេលវែង នឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្ត បន្ទាប់ពីមានការសិក្សាច្បាស់លាស់ជាមុនអំពីក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យនៃទីផ្សារផ្សេងៗ។ ជាមួយគ្នានេះ ន.ធ.ក. ក៏ត្រូវរៀបចំផ្លាស់ប្តូរវិធីសាស្ត្រកំណត់ដើមទុនតម្រូវតាមទំហំហានិភ័យទៅកម្រិត ២ (Solvency II or RBC II) ក្នុងរយៈពេលវែង។

**គ.៣. ការរាយការណ៍**

ដើម្បីបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ក៏ដូចអនុលោមតាមគោលការណ៍គ្រឹះធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងតម្រូវឱ្យរៀបចំ និងផ្តល់មក ន.ធ.ក. នូវរបាយការណ៍វាយតម្លៃស្ថានភាពហិរញ្ញវត្ថុដែលរៀបចំដោយអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង។

**គ.៤. អនុលោមភាពគោលការណ៍គ្រឹះធានារ៉ាប់រង**

សម្រាប់គោលដៅរយៈពេលខ្លី ត្រូវបង្កើនអនុលោមភាពពីកម្រិត "ប្រតិបត្តិតាមផ្នែក" ទៅជា "ប្រតិបត្តិតាមភាគច្រើន" លើការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង (ICP៨)។ ចំពោះភាពគ្រប់ល្មមនៃដើមទុន (ICP១៧) និងអភិបាលកិច្ចក្រុមហ៊ុន (ICP៧) រំពឹងថាបង្កើនទៅកម្រិត "ប្រតិបត្តិតាមភាគច្រើន" ក្នុងរយៈពេលមធ្យម ចំណែកការគ្រប់គ្រងហានិភ័យក្រុមហ៊ុនធានារ៉ាប់រងសម្រាប់គោលបំណងសាធនភាព (ICP១៦) និងការឆ្លើយតបចំពោះបម្រែបម្រួលប្រយ័ត្ននិងការត្រួតពិនិត្យធានារ៉ាប់រង (ICP២៤) ត្រូវបង្កើនទៅកម្រិត "ប្រតិបត្តិតាមភាគច្រើន" ក្នុងរយៈពេលវែងផងដែរ។

### ឃ. ក្របខ័ណ្ឌគតិយុត្ត និងបទប្បញ្ញត្តិ

#### ឃ.១. ក្របខ័ណ្ឌបទប្បញ្ញត្តិធានារ៉ាប់រង

ន.ធ.ក. នឹងវាយតម្លៃលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យធានារ៉ាប់រង និងរៀបចំបទប្បញ្ញត្តិចាំបាច់ពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច និងការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មតាមផលិតផលដូចជា សោធននិវត្តន៍ជាដើម។

#### ឃ.២. ក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ន.ធ.ក. នឹងរៀបចំប្រកាសស្តីពីការដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យធានារ៉ាប់រងដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីពង្រឹងនូវប្រសិទ្ធភាពនៃការអនុវត្តរបស់បុគ្គលរាយការណ៍ ក្នុងរយៈពេលខ្លី។

### ង. បច្ចេកវិទ្យាធានារ៉ាប់រង

ដើម្បីទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាធានារ៉ាប់រង ន.ធ.ក. នឹង៖

- រៀបចំប្រព័ន្ធព័ត៌មានត្រួតពិនិត្យ (Supervisory Information System) ដោយធ្វើសមាហរណកម្មប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យហិរញ្ញវត្ថុ ប្រព័ន្ធផ្តល់សញ្ញាជាមុន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យទីផ្សារធានារ៉ាប់រង។ ប្រព័ន្ធនេះនឹងក្លាយជាបណ្តុំទទួលទិន្នន័យទាំងអស់របស់ក្រុមហ៊ុនធានារ៉ាប់រង (បំពេញទិន្នន័យប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំតាមបែបអេឡិចត្រូនិក) បូករួមជាមួយការផ្តល់សញ្ញាជាមុន
- រៀបចំបង្កើតមជ្ឈមណ្ឌលទិន្នន័យធានារ៉ាប់រង និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច និង
- រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង។

### ច. ការកសាងសមត្ថភាព

ន.ធ.ក. នឹងបន្តជំរុញការបង្កើតកម្មវិធីសិក្សាផ្នែកធានារ៉ាប់រងតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សា និងរៀបចំបង្កើតវិទ្យាស្ថានធានារ៉ាប់រងកម្ពុជាក្នុងគោលបំណងលើកកម្ពស់សមត្ថភាពមូលធនមនុស្សក្នុងវិស័យធានារ៉ាប់រងទាំងមូល។

## V. សកម្មភាពគួរពិចារណា

បន្ថែមដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធិភាព តម្រូវការធនធានហិរញ្ញវត្ថុគឺជាកត្តាចម្បងសម្រាប់រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រួតពិនិត្យ (Supervisory Information System) រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច និងជំរុញការលើកកម្ពស់អក្ខរកម្មធានារ៉ាប់រង។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៥។***

# ជំពូក ៨
# វិស័យសោធន

## I. ទិដ្ឋភាពទូទៅ

បច្ចុប្បន្នរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននៅកម្ពុជា បាននិងកំពុងគ្របដណ្តប់លើបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ។ ចំពោះបុគ្គលនៃវិស័យសាធារណៈ រាជរដ្ឋាភិបាល បានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) នាឆ្នាំ ២០០៨ និងបេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន (ប.ជ.អ.) នាឆ្នាំ ២០១០ ដើម្បីគ្រប់គ្រង និងចាត់ចែងបើកតាវកាលិក និងអត្ថប្រយោជន៍នានាជូនអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ នាឆ្នាំ ២០២២ បេឡាជាតិទាំងពីរ ត្រូវបានធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោម មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) អនុលោមតាមអនុក្រឹត្យ ស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ របបនេះ ត្រូវបានទ្រទ្រង់ទាំងស្រុងដោយថវិកាជាតិ និងមានទម្រង់ជាការទូទាត់តាមដំណើរ (Pay-as-you-go) ដែលមានន័យថារដ្ឋនឹងទូទាត់តាវកាលិកជូនមន្ត្រីសាធារណៈនៅពេលដែលពួក-គាត់ដល់វ័យចូលនិវត្តន៍ ទៅតាមរបបសោធនប្រភេទកំណត់តាវកាលិកជាមុន (Defined Benefit)។ នាឆ្នាំ ២០២៤ រាជរដ្ឋាភិបាលបានចំណាយថវិកាជាតិសរុបចំនួន ១.៥០២.០៩៥ លានរៀល ដើម្បីទ្រទ្រង់របបនេះ។ រីឯ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ របបសន្តិសុខសង្គម ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងនេះ ត្រូវបានអនុវត្តជាផ្លូវការនាខែ កក្កដា ឆ្នាំ ២០២២ និងចាប់ផ្តើមប្រមូលភាគទាន ក្នុងខែ តុលា ឆ្នាំ ២០២២ ដោយមានសមាជិកសរុបចំនួន ១,៧ លាននាក់ និងប្រមូលភាគទានបានសរុបប្រមាណ ១.៥៣០.៨១៩,៦ លានរៀល គិតត្រឹមឆ្នាំ ២០២៤។ របបនេះជាប្រភេទកំណត់តាវកាលិកជាមុន ដោយនិយោជក និងនិយោជិតមានកាតព្វកិច្ចបង់ភាគទានរួមគ្នា ចូលទៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)។

ជារួម គិតត្រឹមឆ្នាំ ២០២៤ ប្រព័ន្ធនេះគ្របដណ្តប់សមាជិកសកម្មទាំងបុគ្គលនៃវិស័យសាធារណៈ និងវិស័យឯកជនសរុបចំនួនប្រមាណ ២,០៥ លាននាក់ និងនិវត្តជនចំនួន ប្រមាណ ១២.៣ម៉ឺននាក់ ដែលការគ្របដណ្តប់នៅមានកម្រិតនៅឡើយ បើធៀបនឹងអត្រាប្រជាជនចូលរួមកម្លាំងពលកម្មដែលមានអាយុ១៥-៥៩ ឆ្នាំ ខណៈតាវកាលិកនៃរបបនេះ ក៏មិនទាន់មានសង្គតិភាពរវាងក្រុមគោលដៅនីមួយៗ។ ផ្អែកតាមការព្យាកររយៈពេលវែង (២ ទៅ ៣ ទសវត្សរ៍បន្ទាប់) កម្ពុជាអាចនឹងប្រឈមការកើនឡើងខ្ពស់នូវប្រជាជនមានអាយុចាស់ (Aging Population) ខណៈអត្រាបង្កកំណើតបានថយចុះជាបន្តបន្ទាប់។ កត្តាទាំងនេះ នឹងក្លាយជាបន្ទុកធ្ងន់ធ្ងរសម្រាប់សង្គម ទាំងទិដ្ឋភាពហិរញ្ញវត្ថុសុខាភិបាលសាធារណៈ និងប្រព័ន្ធគាំពារសង្គម ក៏ដូចជាចីរភាពហិរញ្ញវត្ថុនៃប្រព័ន្ធនេះ។

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយកែទម្រង់វិស័យសោធន តាមរយៈការដាក់ឱ្យដំណើរការរបបសោធនជាបន្តបន្ទាប់ ក្នុងនោះ បានបង្កើតនិយ័តករសន្តិសុខសង្គម (ន.ស.ស.) ដែលជាសេនាធិការរបស់ អ.ហ.ស. ទទួលបន្ទុកលើការងារនិយ័តកម្ម និងត្រួតពិនិត្យប្រតិបត្តិការរបបសន្តិសុខសង្គមក្នុងគោលដៅធានានូវតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុនៃប្រព័ន្ធសន្តិសុខសង្គមទាំងមូល។ បច្ចុប្បន្ន ន.ស.ស. ប្រើប្រាស់ធនធាន និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.) ដើម្បីអនុវត្តមុខងារដូចមានកំណត់ក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## II. ការកែទម្រង់ និងសមិទ្ធផល

តាមរយៈការកំណែទម្រង់ និងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនដើម្បីអាចគ្របដណ្តប់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើន ដោយគិតចាប់ពីការដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ មានដូចខាងក្រោម៖

**ក. ក្របខ័ណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**

រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលក្របខ័ណ្ឌនេះបាន និងកំពុងដើរតួយ៉ាងសំខាន់ ក្នុងការកសាង និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ជាពិសេសវិស័យសោធននៃប្រព័ន្ធសន្តិសុខសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន។ គិតចាប់ពីការដាក់ចេញនូវក្របខ័ណ្ឌនេះ មានលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ មួយចំនួន ត្រូវបានចេញ រួមមាន ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អនុក្រឹត្យស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម អនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម និងអនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ខ. ការអភិវឌ្ឍ ការគ្រប់គ្រង និងការចាត់ចែងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**

បច្ចុប្បន្នការវិនិយោគមូលនិធិសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជន ផ្តោតចម្បងលើការដាក់ប្រាក់បញ្ញើនៅធនាគារ។ អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ដើម្បីគ្រប់គ្រងមូលនិធិរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដែលក្នុងនោះ រួមមានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ដោយត្រូវរៀបចំគោលការណ៍នៃការគ្រប់គ្រងការវិនិយោគ ផែនការវិនិយោគប្រចាំឆ្នាំ ថវិកានីយកម្មហានិភ័យ ក៏ដូចជាការវាយតម្លៃហានិភ័យផងដែរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានធ្វើសមាហរណកម្មរវាង ប.ជ.អ. និងប.ជ.ស. ដើម្បីកាត់បន្ថយបន្ទុកចំណាយរដ្ឋបាល និងពង្រឹងសមត្ថភាពស្ថាប័ន។

**គ. ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន**

នាឆ្នាំ ២០២២ យុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងសមាជិកអំពីអត្ថប្រយោជន៍ និងសិទ្ធិក្នុងការចូលរួមក្នុងរបបសន្តិសុខសង្គម ត្រូវបានដាក់ឱ្យអនុវត្ត។ ផ្អែកតាមយុទ្ធសាស្ត្រនេះ ប្រតិបត្តិករសន្តិសុខសង្គម បានរៀបចំការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន ពិសេសសមាជិកនៃរបបសន្តិសុខសង្គមផងដែរ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ស្របពេលការសម្រេចបាននូវសមិទ្ធផល និងការដាក់ចេញកម្មវិធីការកែទម្រង់ខាងលើ ក៏នៅមានបញ្ហាប្រឈមសំខាន់ៗដែលត្រូវដោះស្រាយ ដូចខាងក្រោម៖

**ក. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ**

ទន្ទឹមនឹងការដាក់ចេញនូវបទដ្ឋានគតិយុត្តគោលដើម្បីអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជន ទាមទារឱ្យមានការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តបន្ថែមទៀត ដើម្បីធានាបាននូវចីរភាពហិរញ្ញវត្ថុនៃរបបនេះ។ រីឯ របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលបច្ចុប្បន្នទ្រទ្រង់ទាំងស្រុងដោយថវិកាជាតិ បាននិងកំពុងឈានទៅដាក់បន្ទុកធ្ងន់ធ្ងរដល់ថវិកាជាតិជាបណ្តើរៗ។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ក្នុងការកែទម្រង់ប្រព័ន្ធសោធនបុគ្គលសម្រាប់វិស័យសាធារណៈឱ្យមានសង្គតិភាពជាមួយរបបសោធនសម្រាប់វិស័យឯកជន ទាំងតារកាលិក និងភាគទាន ដែលកិច្ចការនេះជំរុញការរៀបចំបទដ្ឋានគតិយុត្តឱ្យសម្រេចបាននាពេលឆាប់ៗ។

**ខ. ក្របខ័ណ្ឌវិនិយោគ និងហិរញ្ញវត្ថុ**

កត្តាជាច្រើនបានជះឥទ្ធិពលក្នុងការគ្រប់គ្រង និងចាត់ចែងមូលនិធិប្រាក់សោធន ដែលក្នុងនោះរួមមាន៖

- **ឧបករណ៍ហិរញ្ញវត្ថុសម្រាប់វិនិយោគមិនទាន់មានភាពសម្បូរបែប៖** អតិរេកចំណូលនៃប្រាក់សោធន ត្រូវបានវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដើម្បីបង្កើនចំណូល ប៉ុន្តែ បច្ចុប្បន្ន ប.ស.ស. បានធ្វើការវិនិយោគជាប្រាក់បញ្ញើក្នុងធនាគារពាណិជ្ជដើម្បីទទួលបានការប្រាក់ ដែលនេះជាការវិនិយោគប្រមូលផ្តុំច្រើននៅក្នុងថ្នាក់ទ្រព្យសកម្មតែមួយ។ ការណ៍នេះ នឹងធ្វើឱ្យ ប.ស.ស. អាចជួបហានិភ័យ និងទទួលប្រាក់ចំណូលទាបដោយមិនបានធ្វើពិពិធកម្មនៃការវិនិយោគ។ ការវិនិយោគនេះពុំមានចីរភាពក្នុងរយៈពេលវែងនោះទេ។
- **ការមិនទាន់អនុវត្តនៅអត្រាភាគទានសម្រាប់វិស័យសាធារណៈ៖** បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៅតែបន្តរ៉ាប់រងទាំងស្រុងលើចំណាយបើកផ្តល់ប្រាក់សោធនជូននិវត្តន៍ជន ទៅតាមតម្រូវការចំណាយជាក់ស្តែងប្រចាំឆ្នាំដោយសារមិនទាន់មានការអនុវត្តនូវអត្រាភាគទានសម្រាប់មន្ត្រីសាធារណៈ។
- **បម្រែបម្រួលកត្តាប្រជាសាស្ត្រ៖** ក៏ជាកត្តាមួយនឹងប្រែក្លាយកម្ពុជាឱ្យទៅជាសង្គមចាស់ជរា ដោយសារការកើនឡើងនៃអាយុសង្ឃឹមរស់ និងការថយចុះនៃការបង្កកំណើត ជាដើម។ កត្តាទាំងនេះនឹងមានផលប៉ះពាល់កម្មវិបាកអវិជ្ជមានទៅលើនិរន្តរភាពនៃមូលនិធិសោធននៅរយៈពេលវែង ជាពិសេសរបបសោធនសម្រាប់វិស័យសាធារណៈបច្ចុប្បន្ន ដែលត្រូវបានធ្វើហិរញ្ញប្បទានពីថវិកាជាតិទាំងស្រុង។
- **ការបែកខ្ញែកនៃការគ្រប់គ្រងមូលនិធិសោធន៖** បច្ចុប្បន្ន របបខាងលើគ្រប់គ្រង និងចាត់ចែងដោយ ប.ស.ស. សម្រាប់វិស័យឯកជន និងដោយ ម.ជ.ជ. សម្រាប់វិស័យសាធារណៈ ខណៈស្ថាប័ន គ្រឹះស្ថាន និងសហគ្រាសសាធារណៈមួយចំនួនបាននិងកំពុងគ្រប់គ្រង និងចាត់ចែងរបបប្រាក់សោធនដោយខ្លួនឯង ដែលការណ៍នេះបានបណ្តាលឱ្យ មានអសង្គតិភាព និងមិនអាចប្រមូលផ្តុំជាមូលមូលនិធិរួមមួយដើម្បីធ្វើការវិនិយោគ។
- **ការគ្របដណ្តប់នៅមានកម្រិត៖** បន្ថែមនេះ យោងតាមអង្កេតកម្លាំងពលកម្មនាឆ្នាំ ២០១៩ កម្ពុជាមានប្រជាជនមានការងារធ្វើ (Employed Population) មានចំនួនសរុប ៧,៩ លាននាក់ ក្នុងនោះប្រជាជនមានការងារធ្វើក្នុងវិស័យក្នុងប្រព័ន្ធ (Formal Sector) មានចំនួនប្រមាណ ១,៧ លាននាក់ ឬស្មើនឹង ២១,៥% នៃប្រជាជនមានការងារធ្វើសរុប។ ដូចនេះ មានន័យថា ប្រជាជនមានការងារធ្វើប្រមាណ ៦,២ លាននាក់ផ្សេងទៀតបម្រើការក្នុងវិស័យក្រៅប្រព័ន្ធ (Informal sector) ដែលការណ៍នេះធ្វើឱ្យពួកគាត់បាត់បង់នូវគាវកាលិកនានាជាពិសេសរបបសោធនព្រមទាំងធ្វើឱ្យប្រព័ន្ធសោធនប្រឈមនឹងបញ្ហាចីរភាពហិរញ្ញវត្ថុ ដោយសារការកៀរគរប្រភពធនធានហិរញ្ញវត្ថុសម្រាប់ធ្វើការវិនិយោគមានទំហំតូច។

### គ. ក្របខ័ណ្ឌត្រួតពិនិត្យ និងដោះស្រាយវិវាទ

លិខិតបទដ្ឋានគតិយុត្តជាធរមានបានផ្តល់សមត្ថកិច្ចដល់ ន.ស.ស. ក្នុងការធ្វើនិយ័តកម្ម និងត្រួតពិនិត្យលើប្រតិបត្តិការរបបសន្តិសុខសង្គម។ ប៉ុន្តែរហូតដល់ឆ្នាំ ២០២៤ មិនទាន់មានការចាប់ផ្តើមចុះត្រួតពិនិត្យពេញលេញលើប្រតិបត្តិការរបស់ប្រតិបត្តិករសន្តិសុខសង្គម នៅឡើយទេ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ នៃរបបសន្តិសុខសង្គម ជាពិសេសផ្នែកប្រាក់សោធន[១១] ខណៈទាមទារឱ្យមានការរៀបចំបទដ្ឋានគតិយុត្តគាំទ្រការត្រួតពិនិត្យ និងការខ្វះទិន្នន័យក្នុងវិភាគឱ្យបានច្បាស់លាស់ ដែលជារឿយៗការបញ្ជូនរបាយការណ៍ជាក្រដាស មានភាពមិនពេញលេញ និងគ្រប់ជ្រុងជ្រោយ។

### ឃ. ការយល់ដឹងនៅមានកម្រិត

ការយល់ដឹងរបស់សាធារណៈជនអំពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន នៅមានកម្រិតនៅឡើយ ជាពិសេសកម្មករនិយោជិតមួយចំនួន ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅមិនទាន់បានក្លាយជាសមាជិករបស់ ប.ស.ស. នៅឡើយ ដោយសារភាពព្រងើយកន្តើយ ឬការគេចវេះក្នុងការចុះបញ្ជីរបស់សហគ្រាសមួយចំនួន។

---

[១១] គោលការណ៍ចម្បង និងឧត្តមានុវត្តន៍នៃការធ្វើនិយ័តកម្មផ្នែកប្រាក់សោធនត្រូវបានចេញដោយអង្គការអន្តរជាតិសម្រាប់អ្នកត្រួតពិនិត្យផ្នែកប្រាក់សោធន

ការណ៍នេះ ធ្វើឱ្យរាំងស្ទះដល់ការចូលរួម ឬការទទួលបានអត្ថប្រយោជន៍នានា ពីរបបនេះ។ ជារួម ដោយសារការខ្វះការយល់ដឹងអំពីផ្នែកប្រាក់សោធន និងអំពីអត្ថប្រយោជន៍ ដែលត្រូវទទួលបានក្រោមរបបនេះ។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យសោធន

### ក. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

ដើម្បីធានាបាននូវគណនេយ្យភាព តម្លាភាព និងចីរភាព នៃការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមផ្នែកប្រាក់សោធន ក្របខ័ណ្ឌបទប្បញ្ញត្តិសំខាន់ៗ មួយចំនួន បាននិងកំពុងបន្តរៀបចំ រួមមាន៖ មូលដ្ឋានគោលនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គម លក្ខខណ្ឌវិនិច្ឆ័យលើភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គម គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ និងបែងចែកផលចំណេញពីការវិនិយោគមូលនិធិសន្តិសុខសង្គម ការកំណត់ពិតានចំណាយប្រតិបត្តិការរបស់ ប.ស.ស. វិធានប្រុងប្រយ័ត្នលើការបែងចែកកញ្ចប់វិនិយោគនៃមូលនិធិសន្តិសុខសង្គម និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យក្នុងប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា។

ទន្ទឹមនេះ រាជរដ្ឋាភិបាលបាន និងកំពុងរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកសោធនបុគ្គលសម្រាប់វិស័យសាធារណៈ ដែលនឹងក្លាយជាបទដ្ឋានគតិយុត្តដ៏សំខាន់ក្នុងការអនុវត្តការកែទម្រង់របបសោធនសម្រាប់មន្ត្រីសាធារណៈ ក្នុងគោលដៅធានាបាននូវចីរភាព និងសង្គតិភាពនៃរបបសោធននៅកម្ពុជា។

### ខ. ក្របខ័ណ្ឌវិនិយោគ និងហិរញ្ញវត្ថុ

បន្ទាប់ពីក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ត្រូវបានបង្កើត ប.ស.ស. នឹងអាចចាប់ផ្តើមធ្វើការវិនិយោគមូលនិធិសន្តិសុខសង្គម ដូចមានកំណត់ក្នុងអនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម។ អនុលោមតាមអនុក្រឹត្យនេះ ប.ស.ស. មានកាតព្វកិច្ចរៀបចំគោលការណ៍នៃការគ្រប់គ្រងមូលនិធិសម្រាប់ការវិនិយោគ ផែនការវិនិយោគប្រចាំឆ្នាំ ការរៀបចំចរិកានីយកម្មហានិភ័យ ការវាយតម្លៃសមិទ្ធកម្មនៃការវិនិយោគប្រចាំឆ្នាំ ជាដើម។

ជាមួយគ្នានេះ ដើម្បីឆ្លើយតបនឹងការបែកខ្ញែកនៃការគ្រប់គ្រងមូលនិធិសោធន ក្រុមប្រឹក្សាជាតិគាំពារសង្គមនឹងពិនិត្យលទ្ធភាពរៀបចំគោលនយោបាយ ក៏ដូចជាបទប្បញ្ញត្តិចាំបាច់នានាដើម្បីជាមូលដ្ឋានសម្រាប់ការធ្វើសមាហរណកម្មមូលនិធិសោធនដែលកំពុងស្ថិតនៅដាច់ដោយឡែក។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងធ្វើការកែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដើម្បីធានាចីរភាពនៃប្រព័ន្ធសោធនជារួម និងការទ្រទ្រង់បាននៃថវិកាជាតិ តាមរយៈការបង្វែរពីការទ្រទ្រង់ទាំងស្រុងនៃថវិកាជាតិ មកជាប្រព័ន្ធបង់ភាគទានវិញ ដែលមានសង្គតិភាពជាមួយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបុគ្គលដទៃទៀត។

បន្ថែមពីនេះ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលស្វ័យនិយោជន៍ ទៅតាមបរិបទជាក់ស្តែង។ រាជរដ្ឋាភិបាលក៏នឹងពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធសោធនពហុកម្រិត (Multi-tiered Pension System) ដើម្បីពង្រីកការគ្របដណ្តប់ផ្នែកប្រាក់សោធនដល់ពលរដ្ឋផ្សេងទៀតដែលមិនទាន់ទទួលបានការគ្របដណ្តប់ ផងដែរ។

### គ. ក្របខ័ណ្ឌត្រួតពិនិត្យ

ន.ស.ស. នឹងរៀបចំប្រព័ន្ធវាស់វែងតាមដានការអនុវត្តសម្រាប់ ប.ស.ស. ដោយផ្អែកលើគោលការណ៍មូលដ្ឋាន ដូចជា៖ i/-ឯករាជ្យភាពក្នុងការគ្រប់គ្រង ii/-អភិបាលកិច្ចល្អ iii/-យុទ្ធសាស្ត្រវិនិយោគល្អ និង iv/-ការអនុវត្តយន្តការ

គ្រប់គ្រងហានិភ័យ។ លើសពីនេះ ការត្រួតពិនិត្យរបស់ ន.ស.ស. នឹងត្រូវអនុវត្តដោយផ្អែកលើផែនការត្រួតពិនិត្យប្រចាំឆ្នាំ និងសៀវភៅណែនាំស្តីពីការត្រួតពិនិត្យប្រតិបត្តិការរបបសន្តិសុខសង្គម។

ទន្ទឹមនេះ ដើម្បីពង្រឹងការប្រមូលភាគទាន និងការចុះបញ្ជី ប.ស.ស. នឹងជំរុញការរៀបចំបង្កើតអធិការសន្តិសុខសង្គម ក្នុងការពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

### ឃ. ក្របខ័ណ្ឌស្ថាប័ន

ការធ្វើឌីជីថលូបនីយកម្មជារឿងចាំបាច់ ដើម្បីគាំទ្រដល់ការអនុវត្តមុខងាររបស់ ន.ស.ស. ដែលក្នុងនោះមានដូចជាការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាផ្ទៃក្នុង ការអភិវឌ្ឍថ្នាលដោះស្រាយវិវាទឌីជីថល និងការធ្វើសន្ទានកម្មទិន្នន័យពីប្រតិបត្តិករក្នុងពេលជាក់ស្តែង។ ទន្ទឹមនេះ ការជ្រើសរើសធនធានមនុស្សឱ្យសមស្របទៅនឹងទំហំការងារ និងជំនាញក៏ជាកត្តាសំខាន់ផងដែរ ដើម្បីគាំទ្រដល់ការអនុវត្តមុខងារត្រួតពិនិត្យរបស់ ន.ស.ស.។ ន.ស.ស. បានរៀបចំ និងដាក់ឱ្យអនុវត្តក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពមន្ត្រី ន.ស.ស. ដែលក្របខ័ណ្ឌនេះត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ក្នុងគោលបំណងកសាង និងពង្រឹងសមត្ថភាពមន្ត្រី តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធផ្សេងៗ។

### ង. ការលើកកម្ពស់ការយល់ដឹង

ន.ស.ស. ត្រូវរៀបចំផែនការសកម្មភាពដើម្បីផ្សព្វផ្សាយ ឱ្យកាន់តែទូលំទូលាយដល់អ្នកទទួលផល ជាពិសេសអំពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃយន្តការផ្សព្វផ្សាយអំពីប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែ ទូលំទូលាយ ដោយការភ្ជាប់ទំនាក់ទំនងជាមួយអ្នកទទួលផល តាមរយៈបុគ្គលមានមានប្រជាប្រិយភាព។ រីឯសប្តាហ៍គាំពារសង្គមកម្ពុជា ក៏នឹងត្រូវពង្រីកទៅជាវេទិកាពិភាក្សាកម្រិតតំបន់ និងសកលផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការ និងសាសនា និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវសហការជាមួយ អ.ក.គ. ដើម្បីពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូលចំណេះដឹង ពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមទៅក្នុងកម្មវិធីសិក្សាជាតិ ទាំងក្នុងកម្រិតចំណេះទូទៅ និងឧត្តមសិក្សា។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៦។***

# ជំពូក ៩
# វិស័យមូលបត្រ

## I. ទិដ្ឋភាពទូទៅ

វិស័យមូលបត្រនៅកម្ពុជា មានវឌ្ឍនភាពសំខាន់ៗ ចំនួន ២ រួមមាន ៖ (១)ការបង្កើតគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ជាអាជ្ញាធរនៃវិស័យមូលបត្រ នាខែ កក្កដា ឆ្នាំ ២០០៨ ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជានិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) បន្ទាប់ពីការអនុម័តច្បាប់ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" និង (២)ការដាក់ឱ្យដំណើរការជាផ្លូវការនៃផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) នាឆ្នាំ ២០១១ ដែលដើរតួនាទីជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។ ន.ម.ក.បានផ្តល់អាជ្ញាប័ណ្ណដំបូង នាខែ តុលា ឆ្នាំ ២០១០ ដល់អ្នកចូលរួមក្នុងទីផ្សារមូលបត្រ ដែលមានក្រុមហ៊ុនមូលបត្រចំនួន ១៥ ក្នុងនោះ ក្រុមហ៊ុនជានាទិញមូលបត្រ ៧ ពាណិជ្ជករមូលបត្រ ៩ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ១៣ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ២។ គួរបញ្ជាក់ថា ក្រុមហ៊ុនដំបូងគេបង្អស់ដែលបានចុះបញ្ជីលក់មូលបត្រជាសាធារណៈនៅ ផ.ម.ក. គឺរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលជាសហគ្រាសសាធារណៈ និងបានចុះបញ្ជីនាខែ មេសា ឆ្នាំ ២០១២ ហើយសញ្ញាបណ្ណសាជីវកម្មដំបូង ត្រូវបានបោះផ្សាយលក់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត នាឆ្នាំ ២០១៨។ក្នុងទិសដៅជំរុញនូវការអភិវឌ្ឍវិស័យនេះប្រកបដោយប្រសិទ្ធភាព តម្លា-ភាព បរិយាបន្ន នវានុវត្តន៍ និងចីរភាពការកែទម្រង់និងអភិវឌ្ឍជាច្រើន ត្រូវបានដាក់ចេញជាបន្តបន្ទាប់ ដោយហេតុថា វិស័យនេះមានវិសាលភាពធំធេងសម្រាប់ការអភិវឌ្ឍ និងការរីកចម្រើននាពេលអនាគត។

## II. ការកែទម្រង់ និងសមិទ្ធផល

### ក. ការរៀបចំបទប្បញ្ញត្តិ

គិតត្រឹមឆ្នាំ ២០២៤ ច្បាប់ចំនួន ២ អនុក្រឹត្យចំនួន ៥ ប្រកាសចំនួន ៨២ និងគោលការណ៍ណែនាំ និងសេចក្តីសម្រេចចំនួន ៣៧ ព្រមទាំងលិខិតផ្លូវការជាច្រើនទៀត ត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសណ្តាប់ធ្នាប់ និងដើម្បីដាក់ឱ្យដំណើរការនូវប្រព័ន្ធអេកូឡូស៊ីនៃវិស័យមូលបត្រ ដែលរួមមាន តួអង្គ និងផលិតផល ដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុលដែលរាប់បញ្ចូលទាំងមូលបត្របំណុលចីរភាព ឧបករណ៍និស្សន្ទ និងគម្រោងវិនិយោគរួមជាដើម ដោយរាប់បញ្ចូលទាំងការកំណត់ពីលក្ខខណ្ឌតម្រូវ កាតព្វកិច្ច និងក្រមសីលធម៌វិជ្ជាជីវៈរបស់តួអង្គ និងលក្ខខណ្ឌតម្រូវនៃការបោះផ្សាយ ក៏ដូចជាការជួញដូរផលិតផល។ បន្ថែមពីនេះ ដើម្បីពង្រឹងកិច្ចគាំពារវិនិយោគិន ប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និងប្រកាសស្តីពី ការស៊ើបអង្កេតក្នុងវិស័យមូលបត្រ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត។

ជាកិច្ចឆ្លើយតបនឹងការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរិស្ថានសាក-ល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍទីផ្សារ និងសេវា និងផលិតផលថ្មីៗពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដូចជាទ្រព្យឌីជីថលជាដើម។

### ខ. ការចុះបញ្ជីមូលបត្រកម្មសិទ្ធិ

គិតត្រឹមឆ្នាំ ២០២៤ មានក្រុមហ៊ុនសរុបចំនួន ១១ បានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ដែលក្នុងនោះក្រុមហ៊ុនចំនួន ៩ បានចុះបញ្ជីនៅទីផ្សារគោល និងក្រុមហ៊ុនចំនួន ២ បានចុះបញ្ជីនៅទីផ្សារកំណើន ដោយបានរៀវគរមូលធនសរុបចំនួន ៥១៦,៧ ប៊ីលានរៀល (ប្រហែល ១២៩ លានដុល្លារអាម៉េរិក)។ ក្នុងចំណោមសហគ្រាស

សាធារណៈទាំង ១៥ នៅកម្ពុជា មានសហគ្រាសសាធារណៈចំនួន ៣ ប៉ុណ្ណោះដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

### គ. ការបោះផ្សាយលក់មូលបត្របំណុល

គិតត្រឹមឆ្នាំ ២០២៤ ក្រុមហ៊ុនចំនួន ១២ (ក្នុងនោះសញ្ញាបណ្ណរបស់ក្រុមហ៊ុនចំនួន ៥ បានដល់ឥណប្រតិទាន) បានចុះបញ្ជីសញ្ញាបណ្ណសាជីវកម្មនៅ ផ.ម.ក.។ សាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយលក់សញ្ញាបណ្ណនេះសរុបមានចំនួន ១.០៤៥,២ ប៊ីលានរៀល (ប្រមាណ ២៥៨,៣ លានដុល្លារអាម៉េរិក) ដែលក្នុងនោះរួមមានសញ្ញាបណ្ណបៃតង និងសញ្ញាបណ្ណចីរភាពដែលស្របតាមស្តង់ដារអន្តរជាតិ និងមានការគាំទ្រផ្នែកបច្ចេកទេសពី ADB និងពីវិទ្យាស្ថានអភិវឌ្ឍន៍កំណើនបៃតងសកលប្រចាំប្រទេសកម្ពុជា (GGGI) និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (ESCAP) ដោយមានកិច្ចសហប្រតិបត្តិការជាមួយសាជីវកម្មធានាឥណទានវិនិយោគ (CGIF) និងក្រុមហ៊ុន GuarantCo ក្រោមក្របខ័ណ្ឌកម្មវិធីជំរុញការបោះផ្សាយសញ្ញាបណ្ណបៃតងនៅកម្ពុជា។

នាឆ្នាំ ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសអំពីការបោះផ្សាយលក់មូលបត្ររដ្ឋ (សញ្ញាបណ្ណត្រូវចារឹកជាប្រាក់រៀល)។ គិតត្រឹមឆ្នាំ ២០២៤ រាជរដ្ឋាភិបាលបានបោះផ្សាយលក់មូលបត្ររដ្ឋសរុបចំនួន ៣២ លើក និងបានប្រមូលសាច់ប្រាក់ ៦០៦ ប៊ីលានរៀល (ប្រមាណ ១៥១ លានដុល្លារអាម៉េរិក)។ ការបោះផ្សាយលក់មូលបត្ររដ្ឋត្រូវបានធ្វើឡើងតាមរយៈការដេញថ្លៃនៅលើវេទិកាហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

### ឃ. គំនិតផ្តួចផ្តើមដើម្បីបង្កើនក្រុមហ៊ុនចុះបញ្ជី

កម្មវិធីជាច្រើនត្រូវបានធ្វើឡើងដើម្បីបង្កើនចំនួនក្រុមហ៊ុនចុះបញ្ជីនៅ ផ.ម.ក. និងជំរុញសន្ទនីយភាពទីផ្សារ។ ក្នុងន័យនេះ ន.ម.ក. បានបង្កើតកម្មវិធីឧត្តមភាព[១២] ដែលកម្មវិធីនេះបានជួយសហគ្រាសធុនតូចនិងមធ្យម ឱ្យត្រៀមខ្លួនសម្រាប់ការចុះបញ្ជីមូលបត្រនៅ ផ.ម.ក. តាមរយៈការផ្តល់ការគាំទ្រដល់ក្រុមហ៊ុនដើម្បីអាចបំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមានៃការចុះបញ្ជី។ តាមរយៈកម្មវិធីនេះ ក្រុមហ៊ុនចំនួន ២ បានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ ដោយក្រុម-ហ៊ុនចំនួន១ បានចុះបញ្ជីនៅទីផ្សារកំណើន និងក្រុមហ៊ុនចំនួន ១ ផ្សេងទៀត នៅទីផ្សារគោល។ គំនិតផ្តួចផ្តើមផ្សេងៗទៀតនឹងត្រូវដាក់ចេញដើម្បីជំរុញការចុះបញ្ជី ដូចជា ការចុះបញ្ជីផ្ទាល់ និងការចុះបញ្ជីរបស់ក្រុមហ៊ុនហូលឌីង ជាដើម។

ព្រមជាមួយនេះ ក៏មានការលើកទឹកចិត្តផ្នែកពន្ធដើម្បីទាក់ទាញក្រុមហ៊ុនឱ្យចុះបញ្ជីផងដែរដែលរួមមាន៖ ការកាត់បន្ថយពន្ធលើប្រាក់ចំណូលរយៈពេល ៣ ឆ្នាំនៃពន្ធលើប្រាក់ចំណូលដែលត្រូវបង់ ជាពិសេសទទួលបានការអនុគ្រោះបំណុលពន្ធដែលមានមុនពេលចុះបញ្ជី។ វិនិយោគិនក៏ទទួលបានការកាត់បន្ថយពន្ធកាត់ទុកចំនួន ៥០% លើចំណូលការប្រាក់ និង/ឬភាគលាភដែលទទួលបាន និងការលើកលែងពន្ធលើចំណេញមូលធនសម្រាប់រយៈពេល ៣ ឆ្នាំ ផងដែរ។

### ង. គំនិតផ្តួចផ្តើមដើម្បីបង្កើនការជួញដូរ

នាឆ្នាំ ២០២៣ កន្លងទៅ ប្រព័ន្ធសម្រាប់បើកគណនីជួញដូរអនឡាញជំនាន់ទី២ ដោយធ្វើសន្ធានកម្មនៃកម្មវិធីកុំព្យូ-ទ័រទៅកាន់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា និងប្រព័ន្ធផ្តល់លេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញរបស់ ន.ម.ក. ក៏ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ដែលវិនិយោគិនអាចទទួលបានគណនីជួញដូរ និងលេខអត្តសញ្ញាណវិនិ-យោគិនដោយស្វ័យប្រវត្តិ។ ប្រព័ន្ធជំនាន់ទី២នេះ បង្កើនភាពងាយស្រួលក្នុងការជួញដូរភាគហ៊ុននៅ ផ.ម.ក. ដោយវិនិយោគិនអាចបញ្ជាទិញ-លក់នៅក្នុងកម្មវិធីទូរសព្ទចល័តបាន។

[១២] កម្មវិធីឧត្តមភាព ជាគំនិតផ្តួចផ្តើម ដើម្បីគាំទ្រ SMEs ពាក់ព័ន្ធនឹងការបំពេញតាមក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិជាធរមាន ស្តង់ដារគណនេយ្យ និងអភិបាលកិច្ចសាជីវកម្ម

### ច. គម្រោងវិនិយោគរួម និងមូលនិធិ

ការបង្កើត និងការចុះបញ្ជីឯកតាមូលនិធិនៃគម្រោងវិនិយោគរួម ត្រូវបានលើកកម្ពស់ តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម ដែលកំណត់ពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ និងបន្តអាជ្ញាប័ណ្ណនិងកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មគម្រោងវិនិយោគរួម ដូចជា ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់-ទិញត្រឡប់មកវិញឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិ និងប្រកាសស្តីពី ការបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម។ កន្លងមក ក្រុមហ៊ុនចំនួន ២ ទទួលបានការអនុញ្ញាតឱ្យបោះផ្សាយលក់ឯកតាមូលនិធិនៃគម្រោងវិនិយោគរួម។

### ឆ. អ្នកចូលរួមក្នុងទីផ្សារ

គិតត្រឹមឆ្នាំ ២០២៤ ន.ម.ក. បានផ្តល់អាជ្ញាប័ណ្ណដល់អន្តរការីមូលបត្រជាច្រើន ដែលក្នុងនោះក្រុមហ៊ុនមួយចំនួនទទួលបានការអនុញ្ញាតឱ្យប្រកបអាជីវកម្មលើសពីមួយ និងអនុញ្ញាតឱ្យចូលរួមក្នុងសកម្មភាពទីផ្សារជាច្រើន។ អាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ដល់ក្រុមហ៊ុន មានប្រមាណជា ១២៧ ដូចជា ជ.ម.ក. ក្រុមហ៊ុនធ្វើអាជីវកម្មមូលបត្រ ក្រុមហ៊ុនធ្វើអាជីវកម្មឧបករណ៍និស្សន្ទ ក្រុមហ៊ុនធ្វើអាជីវកម្មគម្រោងវិនិយោគរួម ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ភ្នាក់ងារវាយតម្លៃលទ្ធភាពសង និងភ្នាក់ងារផ្សេងទៀត។ សមាគមក្រុមហ៊ុនមូលបត្រកម្ពុជា និងសមាគមឈ្មួញជើងសាឧបករណ៍និស្សន្ទកម្ពុជា ត្រូវបានទទួលស្គាល់ ក្នុងឆ្នាំ ២០២៣ និង ២០២៤។

### ជ. អភិបាលកិច្ចសាជីវកម្ម

ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវបានកែសម្រួលកាលពីខែ ធ្នូ ឆ្នាំ ២០១៨។ ប្រកាសនេះអនុវត្តចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ ខណៈដែលក្រុមហ៊ុនមិនបោះផ្សាយលក់មូលបត្រត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ដោយគិតគូរពីតម្រូវការ និងឧត្តមានុវត្តន៍ក្នុងតំបន់ លើការលើកកម្ពស់ស្តង់ដានៃការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនៅកម្ពុជា សេចក្តីព្រាង "ក្រមអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជា" ត្រូវបាននិងកំពុងរៀបចំ។

### ឈ. សមាហរណកម្មហិរញ្ញវត្ថុក្នុងតំបន់

ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការ ចែករំលែកព័ត៌មាន និងជួយគ្នាទៅវិញទៅមក ការបន្តធ្វើសមាហរណកម្មហិរញ្ញវត្ថុក្នុងតំបន់ ក៏នឹងបន្តក្លាយជាអាទិភាពជាយុទ្ធសាស្ត្រ ផងដែរ, ឆ្លុះបញ្ចាំងតាមរយៈការបន្តចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាច្រើនរវាង ន.ម.ក. ជាមួយនិយ័តករមូលបត្របរទេស ឧទា.ការបង្កើតនូវកិច្ចសហប្រតិបត្តិការយ៉ាងទូលំទូលាយ និងជិតស្និទ្ធក្រោមក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ និងអាស៊ានបូកបី ដែលបង្កើនឱកាសសម្រាប់មន្ត្រី ន.ម.ក. ចុះហ្វឹកហាត់ការងារដល់ទីកន្លែង និងធ្វើទស្សនកិច្ចសិក្សានៅបណ្តាប្រទេសជាច្រើន។ គួរបញ្ជាក់ដែរថា កាលពីឆ្នាំ ២០១៧ ន.ម.ក. បានក្លាយជាសមាជិកសមាការីនៃអង្គការគណៈកម្មការមូលបត្រអន្តរជាតិ និងបាននិងកំពុងបន្តនីតិវិធីស្នើសុំចូលជាសមាជិកពេញសិទ្ធិនៃអង្គការនេះ។ ជាមួយគ្នានេះ ន.ម.ក. បានចូលរួមចំណែកយ៉ាងសកម្មក្នុងក្របខ័ណ្ឌការងារវេទិកាទីផ្សារមូលធនអាស៊ាន (ACMF) ក្រុមប្រឹក្សាវត្តិករសាស្ត្រអាស៊ាន គណៈកម្មាធិការការងារអភិវឌ្ឍន៍ទីផ្សារមូលធនអាស៊ាន (WC-CMD) និងក្រុមការងារផ្សេងទៀតក្រោមក្របខ័ណ្ឌរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ព្រមទាំងវេទិកាទីផ្សារសញ្ញាបណ្ណអាស៊ាន+៣ (ABMF) ដើម្បីសម្រេចបាននូវគោលដៅរួមសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុអាស៊ាន។ ក្នុងនោះ ន.ម.ក ក្នុងឆ្នាំ ២០២២ កន្លងទៅ បាន

ធ្វើជាប្រធាន ACMF ហើយបច្ចុប្បន្នជាសហប្រធានក្រុមការងារកម្មវិធីអភិវឌ្ឍន៍ទីផ្សារ (A-MDP) នៃ ACMF ជាមួយគណៈកម្មការមូលបត្ររដ្ឋវៀតណាម (SSC) និងជាសហប្រធាន WC-CMD ជាមួយអាជ្ញាធរូបិយវត្ថុសិង្ហបុរី ចាប់ពីឆ្នាំ ២០២៤-២០២៦ ផងដែរ។

**៣. ចំណេះដឹងផ្នែកហិរញ្ញវត្ថុ**

កម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ត្រូវបានរៀបចំ ដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ ជារៀងរាល់ឆ្នាំ សម្រាប់សិស្សថ្នាក់វិទ្យាល័យ និស្សិតមហាវិទ្យាល័យ និងសាធារណជនទូទៅ នៅតាមបណ្តារាជធានី-ខេត្ត ដើម្បីបញ្ជ្រាបការយល់ដឹងឱ្យកាន់តែមានភាពទូលំទូលាយ។ ទន្ទឹមនឹងនេះ ការអប់រំផ្នែកមូលបត្របាននិងកំពុងត្រូវបានពិនិត្យលទ្ធភាពដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ដោយមានកិច្ចសហការពីក្រសួងអប់រំ យុវជន និងកីឡា ស្របពេលជំរុញកិច្ចសហប្រតិបត្តិការលើកកម្ពស់ការបណ្តុះបណ្តាល និងជំរុញការផ្សព្វផ្សាយ ជាពិសេសជាមួយបណ្តាសកលវិទ្យាល័យ និងប្រព័ន្ធផ្សព្វផ្សាយ ជាដើម។

**ង. ការកសាងសមត្ថភាព**

ន.ម.ក. ក៏បាន និងកំពុងរៀបចំវគ្គបណ្តុះបណ្តាលដល់ក្រុមហ៊ុនដែលធ្វើអាជីវកម្ម និងផ្តល់សេវាក្នុងវិស័យមូលបត្រ ដែលផ្តោតលើជំនាញបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់វិជ្ជាជីវៈជំនាញក្នុងទីផ្សារ និងបានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកក្នុងប្រព័ន្ធផ្សព្វផ្សាយ យ៉ាងហោចណាស់ ១លើកក្នុង ១ ឆ្នាំ ដើម្បីបន្តលើកកម្ពស់ការយល់ដឹង និងជំរុញប្រសិទ្ធភាពនៃការផ្សព្វផ្សាយពីទីផ្សារមូលបត្រនៅកម្ពុជា។ ទន្ទឹមនឹងនេះ ការពង្រឹងសមត្ថភាពមន្ត្រី ន.ម.ក. ត្រូវបានធ្វើឡើង តាមរយៈការរៀបចំការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ការចុះហ្វឹកហាត់ការងារដល់ទីកន្លែងនិយ័តករមូលបត្រក្នុងតំបន់អាស៊ានបូក៣ និងស្ថាប័នមួយចំនួននៅសហរដ្ឋអាមេរិក ការចូលរួមក្នុងសិក្ខាសាលា និងសន្និសីទផ្សេងៗ។

## III. ឧបសគ្គ បញ្ហាប្រឈម និងគាពខ្វះចន្លោះ

វិស័យមូលបត្រកម្ពុជានាពេលបច្ចុប្បន្ន នៅមានបញ្ហាប្រឈមលើទំហំ និងការអភិវឌ្ឍទីផ្សារ ដោយសារផលិតផល ចំនួនក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងវិនិយោគិនសកម្មមានចំនួនតិចនៅលើទីផ្សារ និងការចូលរួមរបស់វិនិយោគិនស្ថាប័នទាំងក្នុងស្រុក និងបរទេសពុំមានសកម្មភាពគួរឱ្យកត់សម្គាល់ក្នុងទីផ្សារមូលបត្រ។

- ជាទូទៅ វិនិយោគិនបរទេសជាវិនិយោគិនធំ ដើរតួនាទីដ៏សំខាន់នៅក្នុងទីផ្សារកំពុងងើបឡើង។ វិនិយោគិនបរទេសទាំងនោះ តែងតែមានបុរេលក្ខខណ្ឌមួយចំនួនមុននឹងវិនិយោគក្នុងទីផ្សារមូលបត្រដូចជា៖ i/-ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រខ្នាតធំ ដើម្បីធានាភាពជាអចិន្ត្រៃយ៍ និងសន្ទនីយភាព ii/-ការរក្សាសុវត្ថិភាពនិងការជួញដូរមូលបត្រ (បច្ចុប្បន្នមានភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ចំនួនមួយដែលទទួលបានការទទួលស្គាល់ពី ន.ម.ក.) iii/-ប្រព័ន្ធជួញដូរ និងទូទាត់ដែលអាចទុកចិត្តបាន iv/-វត្តមានរបស់ឈ្មួញជើងសាមូលបត្រអន្តរជាតិនៅក្នុងស្រុក ឬឈ្មួញជើងសាមូលបត្រក្នុងស្រុកដែលមានទំនាក់ទំនង ជាមួយឈ្មួញជើងសាមូលបត្រអន្តរជាតិ ដែលសម្រួលដល់ការបញ្ជាទិញ-លក់តាមរយៈក្រុមហ៊ុនមូលបត្រដែលអាចជឿទុកចិត្ត v/-ការធានាសមភាពដល់វិនិយោគិនទាំងក្នុងស្រុក និងបរទេស និង vi/-ភាពងាយស្រួលក្នុងការផ្ទេរទុនវិនិយោគចេញ-ចូលប្រទេស។
- ចំពោះវិនិយោគិនក្នុងស្រុក វិនិយោគិនរាយដោយផ្ទាល់ មិនអាចជាកម្លាំងជំរុញការអភិវឌ្ឍទីផ្សារនោះទេ។ ជាទូទៅវិនិយោគិនមិនផ្ទាល់ ដែលជាវិនិយោគិននៃឯកតាមូលនិធិនៃគម្រោងវិនិយោគរួម គឺជាតួអង្គដ៏សំខាន់នៅក្នុងការជំរុញតម្រូវការទីផ្សារ។ វិនិយោគិនស្ថាប័នក្នុងស្រុកដូចជា ក្រុមហ៊ុនធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍ បានពឹងផ្អែកទាំងស្រុងលើការដាក់ប្រាក់បញ្ញើនៅធនាគារ សម្រាប់ការវិនិយោគរយៈពេលវែង ដែលនេះមិនមែនជាដំណោះស្រាយសន្សំរយៈពេលវែងនោះទេ។

- ការចុះបញ្ជីលក់មូលបត្ររបស់ក្រុមហ៊ុនធំៗ ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងសហគ្រាសសាធារណៈធំៗ នៅមានកម្រិតនៅឡើយ ដែលការណ៍នេះ ពុំបានទាក់ទាញចំណាប់អារម្មណ៍វិនិយោគិនបរទេស និងបានដាក់កម្រិតលើលទ្ធភាពធ្វើពិពិធកម្មផលិតផល និងហានិភ័យ។ ទោះបីជា ន.ម.ក. និង ផ.ម.ក. ខិតខំប្រឹងប្រែងតាមរយៈការរៀបចំកម្មវិធីឧត្តមភាព ដើម្បីជំរុញការចុះបញ្ជី និងទាក់ទាញចំណាប់អារម្មណ៍ក្រុមហ៊ុនឱ្យបោះផ្សាយមូលបត្រនាពេលអនាគត ក៏ការចាប់អារម្មណ៍របស់ក្រុមហ៊ុននៅតែមានកម្រិត។
- ការកំណត់ប្រភេទរូបិយប័ណ្ណសម្រាប់មូលបត្រចុះបញ្ជីនៅ ផ.ម.ក. នៅតែជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់ទីផ្សារមូលបត្រ ដោយសារប្រាក់បញ្ញើ និងប្រតិបត្តិការហិរញ្ញវត្ថុភាគច្រើនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាម៉េរិក ស្របពេលដែលការប្រមូលទុនជាប្រាក់រៀលតាមរយៈការលក់មូលបត្រនៅលើទីផ្សារអាចប្រឈមហានិភ័យអត្រាប្តូរប្រាក់។ ស្របជាមួយនឹងគោលនយោបាយលើកកម្ពស់ប្រាក់រៀល ការកំណត់ថ្លៃទ្រព្យសកម្មនៅក្នុងទីផ្សារមូលបត្រជាប្រាក់រៀល អាចក្លាយជាឧបសគ្គដល់ការអភិវឌ្ឍទីផ្សារនេះ។
- ការត្រួតពិនិត្យ និងការស៊ើបអង្កេតចំពោះការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ គឺជាការងារស្មុគស្មាញដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងសណ្តាប់ធ្នាប់នៅក្នុងទីផ្សារមូលបត្រ និងបន្តរក្សាទំនុកចិត្តដល់វិនិយោគិនទាំងក្នុងស្រុកនិងបរទេស។ ក៏ប៉ុន្តែតាមរយៈការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា អំពើល្មើសបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ទំនុកចិត្តទីផ្សារ។
- ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធជួញដូរមូលបត្របច្ចុប្បន្ននៅមានកម្រិត ដែលទាមទារឱ្យមានការអភិវឌ្ឍបន្ថែម ដើម្បីដាក់ឱ្យដំណើរការនូវផលិតផល និងសេវាថ្មីៗ ដូចជាការសុំខ្ចី និងការឱ្យខ្ចីភាគហ៊ុន។
- ការកសាងសមត្ថភាព នៅតែជាបញ្ហាប្រឈម ជាពិសេសសមត្ថភាពផ្នែកបច្ចេកវិទ្យាព័ត៌មាន របស់មន្ត្រី ន.ម.ក. នៅមានកម្រិត ដូចនេះដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ ការពង្រឹងនូវជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់មន្ត្រី គឺជាការងារចាំបាច់សម្រាប់ ន.ម.ក.។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យមូលបត្រ

### ក. អ្នកចូលរួមទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធ

#### ក.១. ទាក់ទាញក្រុមហ៊ុនចុះបញ្ជីមូលបត្រនៅ ផ.ម.ក. និងទាក់ទាញវិនិយោគិន

ការចុះបញ្ជីមូលបត្ររបស់គ្រឹះស្ថានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងសហគ្រាសសាធារណៈធំៗ គឺជាកត្តាជំរុញការអភិវឌ្ឍទីផ្សារមូលបត្រសម្រាប់ទីផ្សារកំពុងអភិវឌ្ឍ ហើយតែងតែត្រូវបានលើកទឹកចិត្តឱ្យចុះបញ្ជី។ ការចុះ-បញ្ជីរបស់សហគ្រាសធុនតូចនិងមធ្យម ក៏ត្រូវបានលើកទឹកចិត្ត ដោយក្រុមហ៊ុនទាំងនេះជាអ្នកទាក់ទាញមូលនិធិវិនិ-យោគទាំងក្នុងស្រុកនិងបរទេស។ ចំណុចគន្លឹះមួយចំនួនទៀតដែលអាចជួយទាក់ទាញការចុះបញ្ជីមូលបត្រនៅ ផ.ម.ក. គឺកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ និងការបន្តគាំទ្រដល់ក្រុមហ៊ុនដែលមានសក្តានុពលចុះបញ្ជីលក់មូលបត្រ។

វិនិយោគិនបរទេសនឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍទីផ្សារមូលបត្ររហូតដល់ពេលដែលវិនិយោគិនស្ថាប័នក្នុងស្រុកមានវត្តមានសកម្មក្នុងទីផ្សារនេះ។ ការណ៍នេះ តម្រូវឱ្យមានការលើកទឹកចិត្តដល់ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្របរទេសចូលរួមក្នុងទីផ្សារ និងការលើកកម្ពស់ការយល់ដឹងអំពីទីផ្សារមូលបត្រនៅកម្ពុជា។

#### ក.២. ជំរុញការអភិវឌ្ឍទីផ្សារមូលបត្រ និងទីផ្សារមូលបត្ររដ្ឋ

គម្រោងវិនិយោគរួម (ជាពិសេសគម្រោងសង្គហធន) គឺជាមធ្យោបាយមួយសម្រាប់ប្រជាពលរដ្ឋដែលមានជីវភាពកម្រិតមធ្យមចូលរួមក្នុងទីផ្សារមូលបត្រ។ ជាទូទៅ មូលនិធិបើកមានភាពទាក់ទាញចំពោះវិនិយោគិនដែលមានចំណេះដឹងវិនិយោគតិច និងងាយស្រួលក្នុងការស្វែងយល់ ប៉ុន្តែតម្រូវឱ្យមានសន្ទនីយភាពទីផ្សារដើម្បីគាំទ្រដល់ការទិញត្រឡប់មកវិញ។ ក្នុងន័យនេះបទប្បញ្ញត្តិបន្ថែមដើម្បីគ្រប់គ្រង និងអភិវឌ្ឍគម្រោងវិនិយោគរួម បាននិង

កំពុងរៀបចំ, ហើយនឹងផ្តោតផងដែរទៅលើច្រកបែងចែកមូលនិធិ ជាពិសេសការបែងចែកតាមរយៈបណ្តាញសាខាធនាគារ។ ជាមួយគ្នានេះ ដើម្បីជំរុញការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ការរៀបចំឱ្យមានពាណិជ្ជករជំបូងនៅក្នុងទីផ្សារមូលបត្ររដ្ឋ គឺត្រូវបានគិតគូរ ក្រោមការដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយធនាគារជាតិនៃកម្ពុជា និង ន.ម.ក.។

### ខ. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

#### ខ.១. អភិវឌ្ឍទីផ្សារខុម្ម៉ូឌីធីអនាគត និងទីផ្សារឧបករណ៍និស្សន្ទ

ក្នុងរយៈពេលខាងមុខ ការអភិវឌ្ឍទីផ្សារខុម្ម៉ូឌីធីអនាគត នឹងក្លាយជាទិសដៅអាទិភាពក្នុងការពិនិត្យលទ្ធភាពអភិវឌ្ឍ បើទោះបីក្នុងពេលបច្ចុប្បន្នទីផ្សារនេះ មិនទាន់លេចរូបរាងនៅឡើយ ប៉ុន្តែទីផ្សារខុម្ម៉ូឌីធីរូបវន្តអាចផ្តល់ផលចំណេញច្រើនដល់អ្នកផលិត ដោយអាចរក្សាបាននូវស្ថិរភាពថ្លៃផលិតផល ហើយក៏អាចជួយជំរុញឱ្យមានការបង្កើតនូវស្តង់ដារនិងបង្កើនគុណភាពផលិតផលផងដែរ តែការបង្កើតទីផ្សារនេះគឺមានលក្ខណៈស្មុគស្មាញ និងចំណាយខ្ពស់។ ក្នុងនោះការបង្កើតទីផ្សារខុម្ម៉ូឌីធីអនាគត ដោយគ្មានទីផ្សាររូបវន្តកណ្តាលរួមអាចជាជម្រើសមួយ ប៉ុន្តែទាមទារឱ្យមានវិធីសាស្ត្រជាក់លាក់ក្នុងការកំណត់ឱ្យបានច្បាស់លាស់នូវទ្រព្យសកម្មមូលដ្ឋាន និងតម្លៃ និងត្រូវសិក្សាឱ្យបានស៊ីជម្រៅពីផលិតផល ដើម្បីធានាបាននូវនិរន្តរភាពសម្រាប់ផលិតផលទាំងនោះ។

ហេដ្ឋារចនាសម្ព័ន្ធបទប្បញ្ញត្តិសម្រាប់ការជួញដូរឧបករណ៍និស្សន្ទ ត្រូវបានដាក់ឱ្យប្រើប្រាស់ និងអនុវត្តដោយក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជា ដើម្បីជួញដូរឧបករណ៍និស្សន្ទបរទេសក្នុងនាមអតិថិជន។ ទ្រព្យសកម្មហិរញ្ញវត្ថុមួយក្នុងចំណោមទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងប្រទេស ដែលមានសន្ទនីយភាពខ្ពស់ គឺឧបករណ៍និស្សន្ទ USD/KHR ដែលនឹងផ្តល់ជាប្រយោជន៍ក្នុងការការពារហានិភ័យអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាម៉េរិក។ ន.ម.ក. កំពុងសិក្សាក្នុងការបង្កើតផលិតផលឧបករណ៍និស្សន្ទបន្ថែមទៀត។

#### ខ.២. ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិ និងអភិវឌ្ឍសមត្ថភាពអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនចុះបញ្ជីមូលបត្រ និងក្រុមហ៊ុនមិនបានចុះបញ្ជីមូលបត្រ

ចំពោះការអភិវឌ្ឍសមត្ថភាពសម្រាប់ការអនុវត្តកែទម្រង់អភិបាលកិច្ចសាជីវកម្ម កម្ពុជាមានគម្រោងក្នុងការបង្កើតនូវវិទ្យាស្ថានបណ្តុះបណ្តាលអភិបាល ក្នុងពេលខាងមុខ។ កម្ពុជាអាចទាញយកផលប្រយោជន៍ពីក្របខ័ណ្ឌការដាក់ពិន្ទុអភិបាលកិច្ចសាជីវកម្មអាស៊ាន ដើម្បីផ្សព្វផ្សាយពីការវាយតម្លៃ និងវឌ្ឍនភាពទាក់ទងនឹងក្របខ័ណ្ឌអភិបាលកិច្ចសាជីវកម្ម។

#### ខ.៣. បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ទ្រព្យឌីជីថល និង ក្រោដហ្វាន់ឌីង

ស្របតាមការបន្តអភិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថល សេចក្តីព្រាងបទប្បញ្ញត្តិស្តីពី ការផ្តល់អាជ្ញាប័ណ្ណនិងការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល និងបទប្បញ្ញត្តិស្តីពីការបោះផ្សាយលក់ទ្រព្យឌីជីថល បាននិងកំពុងរៀបចំ។ គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ និងសេចក្តីព្រាងបទប្បញ្ញត្តិខាងលើ បានកំណត់និយមន័យទ្រព្យឌីជីថលជាប្រភេទមួយនៃមូលបត្រស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ជាមួយគ្នានេះ ក្របខ័ណ្ឌបទប្បញ្ញត្តិបន្ថែមសម្រាប់គ្រប់គ្រងក្រោដហ្វាន់ឌីង អន្តរការីក្រោដហ្វាន់ឌីង និងផ្ទាលក្រោដហ្វាន់ឌីង នឹងត្រូវបានបង្កើតឱ្យមាននាពេលខាងមុខ ដើម្បីអនុញ្ញាតឱ្យអាជីវកម្មប្រភេទនេះ ដែលទទួលបានអាជ្ញាប័ណ្ណពី ន.ម.ក. នាពេលកន្លងមកអាចដំណើរការទៅបាន។

### គ. ក្របខ័ណ្ឌត្រួតពិនិត្យ៖ ពង្រឹងប្រសិទ្ធភាពនៃការស្វែងរកការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ

-ពង្រឹងការត្រួតពិនិត្យ និងផ្តន្ទាទោសលើការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ ព្រមទាំងសហការជាមួយនឹងក្រសួងយុត្តិធម៌សម្រាប់សំណុំរឿងប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ដូចមាននៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងវិស័យមូលបត្រដែលបានបញ្ញត្តិអំពីអាកប្បកិរិយាដែលត្រូវបានហាមឃាត់ និងការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ។

-រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ ការធ្វើវិសោធនកម្មបទប្បញ្ញត្តិ និង/ឬការរៀបចំអនុស្សរណៈនៃការយោគយល់គ្នាជាមួយនឹងស្ថាប័នអនុវត្តច្បាប់ផ្សេងៗ ដោយត្រូវកំណត់ឱ្យបានច្បាស់លាស់ពីបុគ្គលដែលប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ និងសហការជាមួយក្រសួងយុត្តិធម៌ដើម្បីរៀបចំយន្តការបញ្ជូនសំណុំរឿងប្រព្រឹត្តល្មើស។

-ពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានានូវនិរន្តរភាពនៃការវិភាគទិន្នន័យជួញដូរមូលបត្រ ដែលជាមូលដ្ឋានគ្រឹះក្នុងការស្វែងរកការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ និងកសាងសំណុំរឿង ដើម្បីចោទប្រកាន់បុគ្គលប្រព្រឹត្តល្មើស។

-រៀបចំដំឡើងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីស្វែងរកការប្រព្រឹត្តល្មើសក្នុងវិស័យមូលបត្រ និងអាចផ្តល់ភស្តុតាងសម្រាប់ចោទប្រកាន់បុគ្គលប្រព្រឹត្តល្មើស។

### ឃ. ការកសាងសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធ

#### ឃ.១. អភិវឌ្ឍសមត្ថភាពមន្ត្រី ន.ម.ក. និងអ្នកចូលរួមក្នុងទីផ្សារទាំងអស់

-បន្តលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ខ្លួន ដោយពង្រីកបណ្តាញទំនាក់ទំនងជាច្រើន ក្នុងការជំរុញឱ្យមន្ត្រីកសាងសមត្ថភាពបន្ថែម ដើម្បីពង្រីកទស្សនវិស័យ និងចំណេះដឹងអាជីវកម្ម។

-បន្តលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ និងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ តាមរយៈការបណ្តុះបណ្តាល និងផ្សព្វផ្សាយ និងពិនិត្យលទ្ធភាពបង្កើតវិទ្យាស្ថានជាតិមូលបត្រ។

#### ឃ.២. ពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ន.ម.ក. ដើម្បីគ្រប់គ្រងឯកសារដែលបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក

-ពង្រឹងបច្ចេកវិទ្យានិយ័តកម្ម ដើម្បីបង្កើនមុខងារ ដូចជា ការដាក់បញ្ជូនឯកសារ ការស្នើសុំអាជ្ញាប័ណ្ណ និងការ-បង្ហាញព័ត៌មានសាជីវកម្ម ជាដើម។

-សិក្សាបង្កើតជាផែនការលទ្ធកម្ម ដើម្បីទិញ ឬបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលសមស្រប។

#### ឃ.៣. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធជួញដូរ និងទូទាត់ឆ្លើយតបនឹងផលិតផលថ្មី និងកាត់បន្ថយហានិភ័យ

-ត្រូវបានគ្រោងនឹងដាក់ឱ្យដំណើរការ នូវឧបករណ៍ហិរញ្ញវត្ថុថ្មីៗមួយចំនួនដូចជា ហិរញ្ញប្បទានមូលបត្រ និងការជួញដូរតាមម៉ាជីន ជាដើម ដើម្បីពង្រឹងប្រព័ន្ធជួញដូរ និងការទូទាត់។

-អនុញ្ញាតឱ្យវិនិយោគិនជួញដូរភាគហ៊ុនមុនការទូទាត់ ទន្ទឹមនឹងការពង្រឹងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យឱ្យបានរឹងមាំជាងមុន។

### ង. ផ្នែកផ្សេងៗ

#### ង.១. កាត់បន្ថយឧបសគ្គនៃការអភិវឌ្ឍដែលបង្កឡើងដោយដុល្លារូបនីយកម្ម

-បង្កើតវិធីសាស្ត្រដែលមានភាពបត់បែន និងប្រកបដោយនវានុវត្តន៍ ដោះស្រាយបញ្ហាដែលគ្រប់មូលបត្រចុះ-បញ្ជី ត្រូវបានកំណត់តម្លៃជាប្រាក់រៀលស្របតាមគោលនយោបាយជាតិជំរុញការប្រើប្រាស់ប្រាក់រៀល ប៉ុន្តែប្រតិបត្តិការហិរញ្ញវត្ថុភាគច្រើនគិតជាប្រាក់ដុល្លារអាម៉េរិក ធ្វើឱ្យអ្នកចូលរួមក្នុងទីផ្សារមូលបត្រត្រូវបង្កើនចំណាយ និងប្រឈមហានិភ័យអត្រាប្តូរប្រាក់។

#### ង.២. គាំពារវិនិយោគិន

-សិក្សាអំពីការបង្កើតមូលនិធិគាំពារវិនិយោគិនក្នុងវិស័យមូលបត្រ ដែលមានគោលបំណងផ្តល់សំណងព្យសន-កម្មដល់វិនិយោគិនក្នុងករណី បុគ្គលដែលជាប់កាតព្វកិច្ចបំណុល ឬទ្រព្យសកម្មរបស់ក្រុមហ៊ុន មិនគ្រប់គ្រាន់ក្នុងការ-ទូទាត់សងតាមការទាមទាររបស់វិនិយោគិន។ មូលនិធិនេះក៏នឹងប្រើសម្រាប់គាំទ្រដល់ការលើកកម្ពស់ការយល់ដឹង និងការសិក្សាស្រាវជ្រាវរបស់វិនិយោគិនផងដែរ។

### ង.៣. បង្កើនកិច្ចសហការ ដើម្បីជំរុញការអភិវឌ្ឍវិស័យមូលបត្រ

-ពង្រឹងរចនាសម្ព័ន្ធអនុវត្តត្រឹមត្រូវ និង កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ប្រកបដោយភាពរឹងមាំ និងគណនេយ្យភាព តាមរយៈការបង្កើតគណៈកម្មាធិការ ដែលមានសមាជិកជាតំណាងមកពីស្ថាប័នពាក់ព័ន្ធ និងថ្នាក់ដឹកនាំជាន់-ខ្ពស់ ដោយមានលេខាធិការដ្ឋានក្នុងការរៀបចំរបៀបវារៈការងារ របាយការណ៍វឌ្ឍនភាពការងារ និងផ្តល់កិច្ចគាំទ្រដទៃទៀត។

### ង.៤. រៀបចំកញ្ចប់ថវិការយៈពេលមធ្យមសម្រាប់ ន.ម.ក.

ន.ម.ក. ត្រូវបានផ្តល់កញ្ចប់ថវិកាទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា និងមានគោលបំណងប្រែក្លាយខ្លួនជាស្ថាប័នដែលប្រើប្រាស់ថវិកាផ្ទាល់ខ្លួនសម្រាប់ចំណាយប្រតិបត្តិការ ដែលទទួលបានពីថ្លៃសេវាដែលបង់ដោយអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ប៉ុន្តែចំណូលនេះមិនទាន់អាចរ៉ាប់រងចំណាយបាននៅឡើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចពិចារណាលើការផ្តល់ការគាំទ្រថវិកាដល់ ន.ម.ក. តាមរយៈ៖ i/-ការអនុញ្ញាតឱ្យមានការចំណាយតែមួយដង និង ii/-ការពង្រីកក្របខ័ណ្ឌពេលវេលាក្នុងគម្រោងថវិកា សម្រាប់ផែនការចំណាយរយៈពេលវែងរបស់ ន.ម.ក.។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៧។***

# ជំពូក ១០
# វិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន

## I. ទិដ្ឋភាពទូទៅ

អនុលោមតាមមាត្រា ៥ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ ដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេង-ទៀត បានអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងត្រួត-ពិនិត្យវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។

នាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២១ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារត្រូវបានប្រកាសឱ្យប្រើប្រាស់ ដើម្បីបង្កើត អ.ស.ហ. ដែលមានឯករាជ្យភាពក្នុងការបំពេញមុខងាររបស់ខ្លួន ដោយធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រង និងត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលក្នុងនោះរួមមានវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។ ការគ្រប់គ្រងវិស័យអចលនវត្ថុ និងបញ្ចាំដែលកន្លងមកស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ ក.ស.ហ.វ. ត្រូវបានផ្ទេរភារកិច្ចឱ្យស្ថិតនៅក្រោមនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ (ន.អ.ប.) ដែលជាសេនាធិការនៃ អ.ស.ហ.។

ក្នុងវិស័យចលនវត្ថុ ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៤ គម្រោងអភិវឌ្ឍន៍អចលនវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណមានចំនួនសរុប ៣៦៥ គម្រោង ដែលក្នុងនោះ គម្រោងអភិវឌ្ឍន៍លំនៅឋានជាលក្ខណៈបុរីនិង អគារសហកម្មសិទ្ធិមានចំនួនច្រើនជាងគេ។ គិតត្រឹមចុងឆ្នាំ ២០២៤ គម្រោងអភិវឌ្ឍន៍លំនៅឋានជាលក្ខណៈបុរីមានចំនួន ៥៩% នៃគម្រោងអភិវឌ្ឍន៍អចលនវត្ថុដែលទទួលបានអាជ្ញាប័ណ្ណសរុប។ ទុនវិនិយោគក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុសរុបមានទំហំ ៧,២ ប៊ីលានដុល្លារអាម៉េរិក ដែលក្នុងនោះទុនវិនិយោគក្នុងស្រុកមានចំនួន៨៣% ស្មើនឹង ៦ ប៊ីលានដុល្លារអាម៉េរិក និងទុនវិនិយោគក្រៅស្រុកមានចំនួន ១៧% ស្មើនឹង ១,២ ប៊ីលានដុល្លារអាម៉េរិក។ ពាក់ព័ន្ធនឹងវិស័យបញ្ចាំ និងប្រាតិភោគវិញ ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៤ ក្រុមហ៊ុន/សហគ្រាសអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានដែលទទួលបានអាជ្ញាប័ណ្ណថ្មីមានចំនួនសរុប ៤២២ ក្រុមហ៊ុន/សហគ្រាស។ ទុនវិនិយោគក្នុងវិស័យនេះសរុបមានទំហំសរុប ៣២,៦ លានដុល្លារអាម៉េរិក។ ជាមួយគ្នានេះ កម្ចីសរុបក្នុងវិស័យបញ្ចាំ និងប្រាតិភោគដោយអនុ-ប្បទានមានទំហំ ១.០២៧,៤ លានដុល្លារអាម៉េរិក ដែលក្នុងនោះកម្ចីអចលនវត្ថុមានទំហំ ១៤៨ លានដុល្លារអាម៉េរិក ស្មើនឹង ១៤% នៃកម្ចីសរុប និងកម្ចីចលនវត្ថុមានទំហំ ៨៧៩,៤ លានដុល្លារអាម៉េរិក ស្មើនឹង ៨៦% នៃកម្ចីសរុប។

## II. ការកែទម្រង់ និងសមិទ្ធផល

### ក. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

ច្បាប់ស្តីពីអាជីវកម្មអចលនវត្ថុ និងច្បាប់ស្តីពីអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន កំពុងដំណើរការរៀបចំនិងពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ចំណែកលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត មានដូចជាៈ អនុក្រឹត្យពាក់ព័ន្ធវិស័យទាំងពីរត្រូវបានដាក់ឱ្យអនុវត្ត ហើយប្រកាសមួយចំនួនទៀតក៏ត្រូវបានរៀបចំថ្មីនិងកែសម្រួលឡើងវិញ ក៏ត្រូវបានដាក់ឱ្យអនុវត្តស្របតាមបរិការណ៍បច្ចុប្បន្នផងដែរ។

### ខ. ការស្នើសុំអាជ្ញាប័ណ្ណ

នាចុងឆ្នាំ ២០២១ ការស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានតាមថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលការណ៍នេះអនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាស អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងនេះតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលបានចូលរួមចំណែកក្នុងការធ្វើឱ្យដំណើរការស្នើសុំនេះ កាន់តែមានតម្លាភាព និងចូលរួមកាត់បន្ថយចំណាយពាក់ព័ន្ធផ្សេងៗ។ បច្ចុប្បន្នថ្នាលផ្លាស់ប្តូរទិន្នន័យនេះបាននិងកំពុងបន្តពង្រីកវិសាលភាព

ដើម្បីគ្រប់ដណ្ដប់លើការស្នើសុំអាជ្ញាប័ណ្ណសាខា ការបន្តសុពលភាពអាជ្ញាប័ណ្ណ និងការស្នើសុំផ្លាស់ប្ដូរព័ត៌មានក្រុមហ៊ុន ផងដែរ ខណៈក៏នឹងបន្ត ពង្រីកវិសាលភាព ចំពោះការស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មសេវាអចលនវត្ថុ ផងដែរ។

**គ. ការកសាងសមត្ថភាព**

ដើម្បីចូលរួមលើកកម្ពស់ដល់ការកសាងសមត្ថភាពទៅដល់ភាគីពាក់ព័ន្ធ សំដៅជំរុញដល់ការអភិវឌ្ឍនៅក្នុងវិស័យអចលនវត្ថុ និងវិស័យបញ្ចាំ ន.អ.ប. បានរៀបចំឱ្យមានដូចជា៖ (១) ការរៀបចំចុះអនុស្សរណៈជាមួយវិទ្យាស្ថាន ឬក្រសួងស្ថាប័នពាក់ព័ន្ធ (២) ការបណ្ដុះបណ្ដាលមន្ត្រីជំនាញ ន.អ.ប. និងមន្ត្រីពាក់ព័ន្ធនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមបណ្ដារាជធានី-ខេត្តទាំង ២៥ និង (៣) ការផ្សព្វផ្សាយបទប្បញ្ញត្តិពាក់ព័ន្ធដល់ក្រុមហ៊ុន/សហគ្រាសដែលទើបទទួលបានអាជ្ញាប័ណ្ណ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

បច្ចុប្បន្ន ច្បាប់ស្ដីពី អាជីវកម្ម និងសេវាអចលនវត្ថុ និងច្បាប់ស្ដីពី អាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន កំពុងស្ថិតក្នុងដំណាក់កាលរៀបចំនៅឡើយ ដោយមានត្រឹមតែអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធប៉ុណ្ណោះសម្រាប់ការគ្រប់គ្រងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន។ ការខ្វះខាតច្បាប់ទាំងពីរនេះ ជាបញ្ហាប្រឈមដែលធ្វើឱ្យ ន.អ.ប. មិនមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌទៅលើបុគ្គល/ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាប័ណ្ណ និងបុគ្គល/ក្រុមហ៊ុន/សហគ្រាសដែលគ្មានអាជ្ញាប័ណ្ណ ដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងៗ។

**ក. របាយការណ៍ត្រួតពិនិត្យ និងអនុលោមភាព**

ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន រាល់បុគ្គល/ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាប័ណ្ណពី ន.អ.ប. មានកាតព្វកិច្ចក្នុងការផ្ដល់របាយការណ៍អាជីវកម្មប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំដែលធ្វើសវនកម្មពីសវនករឯករាជ្យដល់ ន.អ.ប. ទៅតាមប្រភេទអាជីវកម្មផ្សេងៗក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន។ ទោះជាយ៉ាងនេះក្ដី ន.អ.ប. នៅជួបបញ្ហាប្រឈមជាច្រើនក្នុងការទទួលបានរបាយការណ៍ទាំងនេះ ដោយហេតុថាបុគ្គល/ក្រុមហ៊ុន/សហគ្រាស នៅមានការខ្វះខាតផ្នែកធនធានមនុស្ស និងជំនាញក្នុងការបំពេញកាតព្វកិច្ចនេះឱ្យបានគ្រប់ជ្រុងជ្រោយ។ ចំណែកទម្រង់របាយការណ៍នៅមានភាពខ្វះខាត និងត្រូវការកែលម្អ។

បញ្ហាទាំងនេះបានធ្វើឱ្យ ន.អ.ប. នៅមានការខ្វះខាតទិន្នន័យចាំបាច់មួយចំនួន សម្រាប់ការតាមដាន និងវាយតម្លៃស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុរបស់បុគ្គល/ក្រុមហ៊ុន/សហគ្រាស ក៏ដូចជាការស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាប្រឈមនានានៅក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ប្រកបដោយប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាព។

**ខ. ធនធានមនុស្ស**

ន.អ.ប. ដែលជាស្ថាប័នទើបបង្កើតថ្មី នាដើមឆ្នាំ ២០២១ នៅមិនទាន់អាចបំពេញការងារបានពេញលេញ និងគ្រប់ជ្រុងជ្រោយទៅតាមតួនាទី និងភារកិច្ចដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។ ធនធានមនុស្សនៅមានកម្រិត ដែលមិនទាន់អាចឆ្លើយតបទៅនឹងទំហំការងាររបស់ ន.អ.ប. ក្នុងការគ្រប់គ្រងនូវសកម្មភាពអាជីវកម្មក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ឱ្យបានគ្រប់ជ្រុងជ្រោយ។

**គ. ការខ្វះខាតនូវការយល់ដឹងជាសាធារណៈ**

អនុលោមភាពតាមបទប្បញ្ញត្តិជាធរមាននៅតែជាបញ្ហាប្រឈម សម្រាប់បុគ្គល/ក្រុមហ៊ុន/សហគ្រាសក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ដោយសារការយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិនៅមានកម្រិត។

### ឃ. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

សមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាននៅមានកម្រិត។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យដែលគ្រប់ជ្រុងជ្រោយនៅពុំទាន់មាននៅឡើយ ដែលធ្វើឱ្យការតាមដាន វិភាគ និងត្រួតពិនិត្យលើស្ថានភាពអាជីវកម្មរបស់បុគ្គល/ក្រុមហ៊ុន/សហគ្រាសដែលទទួលបានអាជ្ញាប័ណ្ណនៅពុំទាន់បានពេញលេញ។ ការតាមដាន វិភាគ និងត្រួតពិនិត្យនាពេលបច្ចុប្បន្នគឺត្រូវពឹងផ្អែកទៅលើរបាយការណ៍ប្រចាំគ្រាដែលទទួលបានពីប្រតិបត្តិករក្នុងទម្រង់របាយការណ៍ជាក្រដាស និងបញ្ចូលដោយដៃ។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យអចលនវត្ថុ វិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន

### ក. ការអភិវឌ្ឍស្ថាប័ន

ការអភិវឌ្ឍស្ថាប័ន រួមមាន៖ i/-ការសម្រួលដំណើរការរដ្ឋបាល ii/-ការពង្រឹងសមត្ថភាពមន្ត្រីក្នុងការផ្តល់សេវាសាធារណៈ iii/-ការតាមដាន និងវិភាគស្ថានភាពក្នុងវិស័យ iv/-ការបង្កើនតម្លាភាពការងារ និង v/-ការពង្រឹងនូវការអនុវត្តបទប្បញ្ញត្តិ។ ការអភិវឌ្ឍស្ថាប័ននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយពេលវេលា ចំណាយផ្សេងៗ ពាក់ព័ន្ធនឹងការទទួលបានអាជ្ញាប័ណ្ណ ការដាក់លិខិតស្នាមរបស់បុគ្គល/ក្រុមហ៊ុនពាក់ព័ន្ធ ព្រមទាំងលើកកម្ពស់ផលិតភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការគ្រប់គ្រងវិស័យនេះ។

### ខ. ការរៀបចំបទប្បញ្ញត្តិ និងគោលនយោបាយពាក់ព័ន្ធ

ការរៀបចំបទប្បញ្ញត្តិ និងគោលនយោបាយពាក់ព័ន្ធក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទានមានសារៈសំខាន់ក្នុងការធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យ ការពារសមភាពផលប្រយោជន៍អាជីវករនិងអតិថិជន ចូលរួមកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ ព្រមទាំងចូលរួមទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ បង្កើនជំនឿទុកចិត្តដល់អតិថិជន ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

### គ. ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ

ការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ក្រុមហ៊ុន/សហគ្រាស ភ្នាក់ងារ អតិថិជន និងសាធារណជនទូទៅ ក្នុងវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាននឹងចូលរួមចំណែកក្នុងការបង្កើនការយល់ដឹងអំពីបទប្បញ្ញត្តិ ដំណើរការប្រតិបត្តិការ និងកាតព្វកិច្ចក្នុងវិស័យទាំងនេះ ដែលនឹងចូលរួមលើកកម្ពស់ដល់ការអភិវឌ្ឍនៃវិស័យ និងការកាត់បន្ថយហានិភ័យពាក់ព័ន្ធ។

### ឃ. ទំនើបកម្ម និងការកសាងប្រព័ន្ធទិន្នន័យគ្រប់ជ្រុងជ្រោយ

ទំនើបកម្ម និងការកសាងប្រព័ន្ធទិន្នន័យគ្រប់ជ្រុងជ្រោយ មានសារៈសំខាន់ក្នុងការសម្រួលដល់ដំណើរការប្រតិបត្តិការ និងការតាមដាន ព្រមទាំងអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធអាចទាញយកទិន្នន័យមកប្រើប្រាស់សម្រាប់ជាប្រយោជន៍ក្នុងការសម្រេចចិត្ត ការគ្រប់គ្រងហានិភ័យ និងការដាក់ចេញនូវយន្តការអន្តរាគមន៍នានា ដើម្បីឆ្លើយតបឱ្យបានកាន់តែប្រសើរទៅនឹងតម្រូវការរបស់ធុរជន។

### ង. កិច្ចសហប្រតិបត្តិការ

កិច្ចសហប្រតិបត្តិការរវាង ន.អ.ប. និងក្រសួង-ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន មានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍវិស័យអចលនវត្ថុ វិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ប្រកបដោយប្រសិទ្ធភាព និងចីរភាព

ដោយអនុញ្ញាតឱ្យមានការរួមបញ្ចូលគ្នានៃធនធាន ការចែករំលែកចំណេះដឹង និងការដាក់ចេញវិធានការដែលមានសង្គតិភាព និងបំពេញឱ្យគ្នា ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៨។***

# ជំពូក ១១
# វិស័យគណនេយ្យ និងសវនកម្ម

## I. ទិដ្ឋភាពទូទៅ

### ក. និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.)

នាឆ្នាំ ២០០៣ ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលជាស្ថាប័ននិយ័តកម្មក្នុងវិស័យគណនេយ្យនិងសវនកម្ម ត្រូវបានបង្កើតឡើងតាមរយៈច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ។ ដោយសារ អ.ស.ហ. ត្រូវបានបង្កើតឡើង តាមរយៈច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២១ ក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបានប្រែក្លាយជានិយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) ហើយត្រូវបញ្ញត្តិឱ្យស្ថិតក្រោមរចនាសម្ព័ន្ធរបស់ អ.ស.ហ.។ យ៉ាងណាមិញ ន.គ.ស. បន្តអនុវត្តមុខងារនិងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគណនេយ្យក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា ដើម្បីរួមចំណែកកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច និងការអភិវឌ្ឍលើគ្រប់វិស័យ រួមមាន ធុរកិច្ចទូទៅ វិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ ន.គ.ស. ជានិយ័តករកំណត់ស្តង់ដារគណនេយ្យនិងសវនកម្មសម្រាប់វិស័យឯកជន អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងវិស័យសាធារណៈ និងទទួលខុសត្រូវលើការលើកកម្ពស់ការអនុវត្តច្បាប់ និងស្តង់ដារគណនេយ្យនិងសវនកម្ម ដើម្បីធានាបាននូវតម្លាភាពគណនេយ្យភាព និងអភិបាលកិច្ចល្អ។

### ខ. លក្ខខណ្ឌរាយការណ៍នៅកម្ពុជា

សហគ្រាសទាំងអស់លើកលែងតែសហគ្រាសជាប់ពន្ធតូច និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មក ន.គ.ស. តាមរយៈប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ (E-Filing) ដែលមាននៅលើគេហទំព័រផ្លូវការរបស់ ន.គ.ស.។ សហគ្រាសត្រូវបំពេញព័ត៌មានដោយផ្ទាល់ទៅក្នុងប្រព័ន្ធនេះ ដោយប្រើប្រាស់ទម្រង់របាយការណ៍ហិរញ្ញវត្ថុដែលកំណត់ដោយ ន.គ.ស. ព្រមទាំងស្កេនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន បញ្ចូលទៅក្នុងប្រព័ន្ធដើម្បីជាឯកសារយោង។ គួរបញ្ជាក់ថា បច្ចុប្បន្ននេះ មិនទាន់មានប្លង់គណនេយ្យរួម សម្រាប់សហគ្រាសរាយការណ៍ក្នុងវិស័យផ្សេងៗនៅឡើយទេ (លើកលែងតែវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ)។ ន.គ.ស. បានចាត់ថ្នាក់គណនីហិរញ្ញវត្ថុ សម្រាប់សហគ្រាសរាយការណ៍នៅក្នុងប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ ទៅតាមវិស័យនីមួយៗ។ សហគ្រាសដែលខកខានមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទាន់ពេលវេលាត្រូវប្រឈមនឹងការពិន័យ ដោយយោងតាមអនុក្រឹត្យ លេខ៧៩ អនក្របក. ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

## II. ការកែទម្រង់ និងសមិទ្ធផល

### ក. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

បច្ចុប្បន្ន មានលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដែលត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តនៅកម្ពុជា ដូចជា៖ ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២១ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងប្រកាស និងសារាចរណែនាំមួយចំនួនទៀត។

## ខ. ការគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

### ខ.១. អាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

យោងតាមប្រកាសលេខ០១៩ អ.ស.ហ.ប្រក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម អាជ្ញាប័ណ្ណត្រូវបានបែងចែកជា ៣ ប្រភេទ រួមមាន៖ i/-អាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ ii/-អាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត២ និង iii/-អាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈសវនកម្ម។

ដើម្បីចូលរួមអនុវត្តអនុក្រឹត្យ ស្តីពី "ការរៀបចំការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន" ប្រព័ន្ធផ្តល់និងគ្រប់គ្រងអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមអនឡាញ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងខែ កញ្ញា ឆ្នាំ ២០២៣ ខណៈបានដាក់បញ្ចូលការស្នើសុំអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ក្នុងប្រព័ន្ធផ្លាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cam DX)។

### ខ.២. សមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា

គិតត្រឹមខែ ធ្នូ ឆ្នាំ ២០២៤ សមាជិកជារូបវន្តបុគ្គលដែលបានចុះឈ្មោះនៅវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (វ.គ.ស.ក.) ដោយរាប់បញ្ចូលទាំងជនបរទេស មានចំនួន ៨៣៤ រូប ដែលក្នុងនោះ សមាជិកសកម្មជាគណនេយ្យករមានចំនួន ២៤ រូប សមាជិកសកម្មជាសវនករមានចំនួន ១៧៧ រូប សមាជិកចូលរួមមានចំនួន ២០៨ រូប សមាជិកសមាគតមានចំនួន ២៥ រូប និងសមាជិកជានិស្សិត មានចំនួន ៦៧៨ រូប។ រីឯសមាជិក វ.គ.ស.ក. ជានិស្សិត មានចំនួន៩៨៥ រូប។

### ខ.៣. កម្មវិធីសិក្សា

**១/-កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (Cambodia CPA)៖** កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ ដោយប្រកាសលេខ ៣១៨ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២០ ស្តីពី ការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាចែកចេញជា ៣ កម្រិត រួមមាន ១៤ មុខវិជ្ជា ដែលក្នុងចំណោមនោះ សិស្ស-និស្សិតត្រូវប្រឡងបញ្ចប់១២ មុខវិជ្ជាជាចាំបាច់។ កម្មវិធីនេះ គ្រប់គ្រងដោយគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដែលមានសមាសភាពចម្រុះអន្តរក្រសួង-ស្ថាប័ន។ គណៈកម្មាធិការ មានអនុគណៈកម្មាធិការចំនួន ៣ ក្រោមចំណុះ គឺអនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង និងអនុគណៈកម្មាធិការទទួលស្គាល់ការអប់រំនិងគុណភាពបណ្តុះបណ្តាល។

**២/-កម្មវិធីសិក្សាអ្នកបច្ចេកទេសគណនេយ្យ (ATQ)៖** កម្មវិធីសិក្សាអ្នកបច្ចេកទេសគណនេយ្យ (ATQ) មាន ៨ មុខវិជ្ជា ដែលមានចាប់ពីការកត់ត្រាប្រតិបត្តិការ រហូតដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហើយត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការក្រោមជំនួយឧបត្ថម្ភពី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងជំនួយបច្ចេកទេសពី Institute of Chartered Accountants in English and Wales (ICAEW) និងស្ថិតក្រោមការគ្រប់គ្រងរបស់ វ.គ.ស.ក.។

**៣/-ការត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម**

**ការពង្រឹងអនុលោមភាពតាមរយៈការត្រួតពិនិត្យ៖** តាមរយៈការពង្រឹងអនុលោមភាពតាមច្បាប់ទៅលើកាតព្វកិច្ចនៃការកាន់បញ្ជីគណនេយ្យ ការរៀបចំ របាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាររបាយការណ៍គណនេយ្យដែលបានដាក់ឱ្យអនុវត្តជាធរមាន និងសហគ្រាសដែលជាប់កាតព្វកិច្ចត្រូវរងសវនកម្មដោយសវនករឯករាជ្យ ដោយផ្តោតលើការពង្រឹងអនុលោមភាពគតិយុត្ត (Legal Compliance) ប៉ុន្តែមិនទាន់បានពង្រឹងអនុលោមភាពបច្ចេកទេសនៅឡើយ (Technical Compliance)។ គួរបញ្ជាក់ថា ចាប់តាំងពីឆ្នាំ ២០២១ ន.គ.ស. បានចុះត្រួតពិនិត្យដល់ទីកន្លែង លើការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសេវាសវនកម្មរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ ការចាប់ផ្តើមគិតគូរ គឺផ្តោតទៅលើការអនុវត្តកាតព្វកិច្ចរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ជាអាទិ៍ កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវន-

កម្មឯករាជ្យ ព្រមទាំងកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. តាមប្រព័ន្ធអនឡាញ (E-Filing)។ ដូចគ្នានេះដែរ ដើម្បីពង្រឹងកម្រិតអនុលោមភាព ន.គ.ស. បានស្នើដាក់ឱ្យអនុវត្ត "សន្ធានុក្រមគណនេយ្យនិងសវនកម្ម" និងទទួលបានការអនុម័តនៅក្នុងសម័យប្រជុំលើកទី២០ អាណត្តិទី១ នៃក្រុមប្រឹក្សា អ.ស.ហ. កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤។

**ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ (E-Filing)៖** តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការ-ដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសរងសវនកម្មឯករាជ្យ ក្នុងឆ្នាំ ២០២១។ ថ្នាលអនឡាញនេះ អនុញ្ញាតឱ្យប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រមូលទិន្នន័យហិរញ្ញវត្ថុ សម្រាប់ការសិក្សាស្រាវជ្រាវទីផ្សារ វិភាគនិងព្យាករណ៍អំពីហិរញ្ញ-វត្ថុ និង ក្នុងខែ កុម្ភៈ ឆ្នាំ ២០២២ ន.គ.ស. ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី២ ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់។ ប្រព័ន្ធនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់សហគ្រាសរងសវនកម្មឯករាជ្យ និងសហគ្រាសដែលមិនរងសវនកម្មឯករាជ្យ ដោយបានធ្វើបច្ចុប្បន្នភាពលើមុខងារដែលមានស្រាប់ និងបានបន្ថែមមុខងារថ្មីមួយទៀតគឺមុខងារជូនដំណឹងអំពីការប្រើប្រាស់ភាសានៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រ ពាក់ព័ន្ធផ្សេងៗ។ ក្នុងខែ មិថុនា ឆ្នាំ ២០២២ ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ក៏ត្រូវបានធ្វើទំនើបកម្មផងដែរ។ ប្រព័ន្ធនេះ មានមុខងារសំខាន់ ៣ គឺ៖ i/-មុខងារស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុ ii/-មុខងារដាក់របាយការណ៍ហិរញ្ញវត្ថុ និង iii/-មុខងារជូនដំណឹងអំពីការប្រើប្រាស់ភាសានៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ ព្រមទាំងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងៗ។

**ការត្រួតពិនិត្យគុណភាពសេវាសវនកម្ម៖** កម្ពុជាបានចាប់ផ្តើមអនុវត្តការត្រួតពិនិត្យគុណភាពសេវាសវនកម្មសាកល្បង នាឆ្នាំ ២០១៧ តាមរយៈការបង្កើតនិងដាក់ឱ្យដំណើរការគណៈកម្មការត្រួតពិនិត្យគុណភាពសវនកម្មក្នុងគោលបំណងធានានូវប្រសិទ្ធភាពនៃការអនុវត្តស្តង់ដារសវនកម្មនិងការអះអាង ស្តង់ដារគុណភាពសេវាសវនកម្មស្តង់ដារគ្រប់គ្រងគុណភាព និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញនិងសវនករប្រតិស្រុត ដោយមានការចូលរួមពីតំណាងភាគីពាក់ព័ន្ធរួមមាន ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រនៃកម្ពុជា (បច្ចុប្បន្នហៅថា និយ័តករមូលបត្រកម្ពុជា) អគ្គនាយកដ្ឋានឧស្សាហកម្មនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីចូលរួមក្នុងការងារត្រួតពិនិត្យគុណភាពសេវាសវនកម្ម។ ការត្រួតពិនិត្យគុណភាពសេវាសវនកម្មសាកល្បង ត្រូវបានធ្វើឡើងលើក្រុមហ៊ុនសវនកម្មចំនួន ៧៩ ចាប់ពីឆ្នាំ ២០១៧ ដល់ ២០២៤ ក្រោមជំនួយបច្ចេកទេសរបស់ ICAEW និងត្រូវបានដឹកនាំត្រួតពិនិត្យគុណភាពដោយ Programma Uitzending Managers (PUM)។ លទ្ធផលនៃការត្រួតពិនិត្យបង្ហាញថា គុណភាពមិនទាន់មានភាពល្អប្រសើរនៅឡើយ ក្នុងនោះមានក្រុមហ៊ុនសវនកម្មប្រមាណ ២៧,៧៣% ទទួលបានការពេញចិត្ត ១៦,៩៥% ត្រូវធ្វើការកែលម្អ និង ៥៩,៣២% មិនទទួលបានការពេញចិត្ត។ រហូតដល់ឆ្នាំ ២០២៤ ពុំទាន់មានបទប្បញ្ញត្តិគ្រប់គ្រាន់ដើម្បីគ្រប់គ្រងគុណភាពសវនកម្មនិងអនុវត្តទោសទណ្ឌលើក្រុមហ៊ុនដែលមិនទទួលបានលទ្ធផលល្អ (មិនគួរជាទីពេញចិត្ត) នៅឡើយ។ ម្យ៉ាងទៀត សមត្ថភាពជំនាញរបស់មន្ត្រី ន.គ.ស. នៅមានកម្រិតនិងមិនអាចក្លាយជាអ្នកត្រួតពិនិត្យឯករាជ្យ (Independent Reviwers) និងត្រូវអភិវឌ្ឍសមត្ថភាពបន្ថែម។ កិច្ចការនេះ ត្រូវការរយៈពេលយូរ ហើយ ន.គ.ស. នៅតែត្រូវការអ្នកត្រួតពិនិត្យពីក្រៅ (Outsource)។

**ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យគណនេយ្យនិងសវនកម្ម៖** ដើម្បីឆ្លើយតបនឹងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥ និងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ការរៀបចំប្រព័ន្ធគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្ម ត្រូវធ្វើឡើងក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាននិងបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)។ ក្នុងក្របខ័ណ្ឌនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានអភិវឌ្ឍ ដើម្បីពង្រឹងការគ្រប់គ្រងនិងលើកកម្ពស់កម្រិតអនុលោមភាព ដែលរួមមាន៖

- ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស តាមអនឡាញ

- ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញតាមអនឡាញ
- ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម តាមអនឡាញ
- ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឌីជីថល
- ប្រព័ន្ធគ្រប់គ្រងការដាក់ពាក្យស្នើសុំសិក្សាកម្មវិធីគណនេយ្យករជំនាញកម្ពុជា និង
- កម្មវិធីទូរស័ព្ទឆ្លាតវៃសម្រាប់សន្ទានុក្រមវិស័យគណនេយ្យនិងសវនកម្ម។

**ការបង្កើតវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា៖** វ.គ.ស.ក. គឺជាស្ថាប័នវិជ្ជាជីវៈគណនេយ្យរបស់កម្ពុជា ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពី គណនេយ្យសហគ្រាសសវនកម្ម និងវិជ្ជាជីវៈគណនេយ្យ ឆ្នាំ ២០០៣ និងបន្ទាប់មកត្រូវបានជំនួសដោយច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ឆ្នាំ ២០១៦។ វ.គ.ស.ក. គឺជាស្ថាប័នមិនស្វែង-រកប្រាក់ចំណេញ និងឯករាជ្យក្នុងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតែមួយគត់នៅកម្ពុជា។

**៤/-កម្មវិធីកសាងសមត្ថភាពនិងបណ្តុះបណ្តាល**

**ការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាលប្រចាំឆ្នាំ៖** វ.គ.ស.ក. បានចាប់ផ្តើមធ្វើការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាលប្រចាំឆ្នាំ តាមរយៈការកំណត់តម្រូវការជាក់លាក់របស់សមាជិកស្របតាមទីផ្សារ។

**វឌ្ឍនភាពនៃការអនុវត្តស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាក្នុងវិស័យហិរញ្ញវត្ថុ៖** ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរ-ជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងឯកសារបកស្រាយនិងវិសោធនកម្មស្តង់ដារនានា ដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (IASB) កម្ពុជាបានដាក់ចេញនូវស្តង់ដារគណនេយ្យចំនួន ២ សម្រាប់វិស័យហិរញ្ញវត្ថុគឺ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម។ ក្រុមហ៊ុនទទួលខុសត្រូវជាសាធា-រណៈទាំងអស់ ដែលមានដូចជា ក្រុមហ៊ុនចុះបញ្ជីមូលបត្រ ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងក្រុមហ៊ុនធានារ៉ាប់រងត្រូវអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ សហគ្រាសផ្សេងទៀតក្រៅពីក្រុមហ៊ុនទទួលខុសត្រូវជាសាធារណៈដូចបានរៀបរាប់ខាងលើ ត្រូវអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ឬស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាតាមការស្ម័គ្រចិត្ត។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានចាប់ផ្តើមអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ បន្ទាប់ពីពន្យាពេលអនុវត្តចំនួន ២ ដង កាលពីឆ្នាំ ២០១២ និងឆ្នាំ ២០១៦។ អនុលោមភាពតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា៖ ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទាំងអស់ បានផ្លាស់ប្តូរមកអនុវត្តតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាដោយជោគជ័យ តាមកាលកំណត់នៃកាល-បរិច្ឆេទរាយការណ៍ហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩។ បន្ថែមពីនេះ ក្រុមហ៊ុនធានារ៉ាប់រងក៏បានផ្លាស់ប្តូរនិងអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**៥/-ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព**

**ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពវិស័យឯកជន៖** រហូតមកដល់ឆ្នាំ ២០២៤ ន.គ.ស. និង វ.គ.ស.ក. បានរៀបចំសិក្ខាសាលានិងការបណ្តុះបណ្តាលបច្ចេកទេសស្តង់ដារ គុណភាពសវនកម្ម ក្រមសីល-ធម៌វិជ្ជាជីវៈទាំងដោយផ្ទាល់និងទាំងអនឡាញ ជាច្រើនលើកជូនដល់ មន្ត្រីសាធារណៈ វិនិយោគិន ធុរជន តំណាងសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ សវនករ សាស្ត្រាចារ្យ និស្សិត និងសាធារណៈជន

ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងនិងជំនាញបច្ចេកទេសរបស់វិស័យសាធារណៈ វិស័យឯកជន និងបុគ្គលពាក់ព័ន្ធផ្សេងទៀតនៅក្នុងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។

**ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពមន្ត្រីសាធារណៈ:** ដូចគ្នានេះដែរ ន.គ.ស. និង វ.គ.ស.ក. បានអនុវត្តកម្មវិធីកសាងសមត្ថភាពមន្ត្រីនិងបុគ្គលិកវិស័យសាធារណៈ (មន្ត្រីអគ្គនាយកដ្ឋានពន្ធដារ) និងស្ថាប័នរបស់ខ្លួនពាក់ព័ន្ធនឹង ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង ស្តង់ដារបច្ចេកទេស ការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ការត្រួតពិនិត្យគុណភាពសវនកម្ម និងប្រព័ន្ធព័ត៌មានវិទ្យា។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

### ក. ធនធានមនុស្ស

**ផ្នែកតម្រូវការ៖** សហគ្រាសធុនតូចនិងមធ្យមជាច្រើន មានចំណេះដឹងនិងសមត្ថភាពនៅមានកម្រិត ក្នុងការយល់ដឹងនិងអនុវត្តស្តង់ដារគណនេយ្យដែលត្រឹមត្រូវ ហើយមានបញ្ហាប្រឈមក្នុងការអនុវត្តកាតព្វកិច្ចរបាយការណ៍ហិរញ្ញវត្ថុដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ដូច្នេះ ទីផ្សារត្រូវការគណនេយ្យករកម្រិតទាបនិងមធ្យម (គណនេយ្យករនៅតាមសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ) ដែលមានគុណវុឌ្ឍិ។

**ផ្នែកផ្គត់ផ្គង់៖** កម្ពុជានៅខ្វះខាតគណនេយ្យករកម្រិតទាបនិងមធ្យម អ្នកជំនាញគណនេយ្យនិងសវនកម្មដែលមានចំណេះដឹង និងបទពិសោធន៍អំពីស្តង់ដារគណនេយ្យ។ ការខ្វះខាតអ្នកឯកទេសជំនាញគណនេយ្យ ក្នុងការជួយណែនាំនិងអនុវត្តស្តង់ដាគណនេយ្យនិងសវនកម្ម សម្រាប់សហគ្រាសធុនតូចនិងមធ្យម បានជះឥទ្ធិពលអវិជ្ជមានដល់អនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ក៏ដូចជា ការដាក់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសមក ន.គ.ស.។

ដូចគ្នានេះដែរ ការខ្វះខាតសវនករសម្រាប់សេវាសវនកម្មឯករាជ្យ ក៏ជាបញ្ហាប្រឈម នៅពេលដែល ន.គ.ស. ពង្រឹងអនុលោមភាពនិងគុណភាពសវនកម្មបន្ថែមទៀត និងពេលដែលសវនករជាជនបរទេស លែងមាននីតិសម្បទាផ្តល់សេវាវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម នៅកម្ពុជា។

### ខ. ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ

ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការបញ្ជូនព័ត៌មានហិរញ្ញវត្ថុ នៅតែជាកិច្ចការដ៏លំបាក និងចំណាយពេលច្រើនសម្រាប់អ្នកប្រើប្រាស់ថ្មី។ ទោះយ៉ាងណា ន.គ.ស. បាននិងកំពុងចាត់វិធានការរៀបចំប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យកាន់តែងាយស្រួលប្រើ បង្កើតសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ និងបង្កើតថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល ព្រមទាំងធ្វើការផ្សព្វផ្សាយនិងបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់តាមរយៈសិក្ខាសាលាដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។

### គ. ការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម

#### គ.១. សមត្ថភាពរបស់ ន.គ.ស.

មន្ត្រីរបស់ ន.គ.ស. នៅមានចំនួនតិច និងមានសមត្ថភាពបច្ចេកទេសនិងបទពិសោធន៍ការងារនៅមានកម្រិត។

#### គ.២. សមត្ថភាពធនធានមនុស្សក្នុងវិស័យ

សមត្ថភាពរបស់បុគ្គលិកគណនេយ្យរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ក្នុងការកាន់បញ្ជី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមស្តង់ដារគណនេយ្យដែលបានអនុម័តនៅមានកម្រិតនៅឡើយ។ កម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលជំនាញគណនេយ្យដល់និស្សិត មិនទាន់ត្រូវបានរៀបចំកែសម្រួលនិងធ្វើទំនើបកម្ម ស្របតាមតម្រូវការទីផ្សារ និងការវិវត្តន៍នៃវិស័យនិងវិជ្ជាជីវៈនេះនៅលើពិភពលោក និងនៅក្នុងតំបន់។

### គ.៣. ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ

នាឆ្នាំ ២០២១ ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសដែលមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រូវបានដាក់ឱ្យអនុវត្ត ហើយក៏បានពង្រីកវិសាលភាពដល់ សហគ្រាសដែលមិនមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញនាឆ្នាំ ២០២២ ផងដែរ។ យ៉ាងណាមិញ ធាតុនៃរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់តាមប្រភេទជាមុន អាចមិនទាន់សមស្របទៅនឹងសហគ្រាសទាំងអស់ក្នុងវិស័យផ្សេងៗ នៅឡើយទេ។

### ឃ. ការបង្កើតប្លង់គណនេយ្យរួម (CoA) សម្រាប់រាយការណ៍ជូន ន.គ.ស.

គួរបញ្ជាក់ឡើងវិញថា ប្លង់គណនេយ្យរួមសម្រាប់វិស័យទាំងអស់ នៅមិនទាន់ត្រូវបានបង្កើតនៅឡើយទេ ប៉ុន្តែបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ទៅតាមប្រភេទសហគ្រាស និងអង្គភាព។ ការបង្កើតប្លង់គណនេយ្យរួមមួយស្របតាមស្តង់ដា មានសារៈសំខាន់ក្នុងការធ្វើឱ្យដំណើរការរាយការណ៍កាន់តែរលូន និងព័ត៌មានហិរញ្ញវត្ថុដែលបានរាយការណ៍ កាន់តែមានអនុលោមភាព សង្គតិភាព និងតម្លាភាពសម្រាប់វិស័យទាំងអស់។ កត្តានេះនឹងជួយឱ្យនិយ័តករងាយស្រួលក្នុងការត្រួតពិនិត្យ វាយតម្លៃ និងប្រៀបធៀបព័ត៌មានហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពទាំងនោះ ហើយអ្នកប្រើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសនឹងមានភាពទុកចិត្តលើរបាយការណ៍និងសម្រេចចិត្តវិនិយោគ។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យគណនេយ្យនិងសវនកម្ម

ក្នុងការអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥" ត្រូវបានរៀបចំដោយ ន.គ.ស. បានទទួលការអនុម័តដោយក្រុមប្រឹក្សា អ.ស.ហ. ក្នុងកិច្ចប្រជុំលើកទី២០ អាណត្តិទី១ របស់ខ្លួន កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤។

គោលដៅជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រនេះ គឺ "ប្រព័ន្ធគណនេយ្យនិងសវនកម្មដែលរឹងមាំ មានតម្លាភាព និងអាចជឿទុកចិត្តបាន" ដោយស្តែងឡើងតាមរយៈសសរស្តម្ភចំនួន ៦ (Pillars) គឺ៖

- ការពង្រឹងនិងពង្រីកសមត្ថភាពរបស់ស្ថាប័ន
- ការកសាងមូលធនមនុស្សជំនាញគណនេយ្យនិងសវនកម្មសម្រាប់ទីផ្សារ
- ការដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេស
- ការលើកកម្ពស់កម្រិតអនុលោមភាព
- ការលើកកម្ពស់គុណភាពសវនកម្ម និងការអះអាង
- ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម។

គោលដៅយុទ្ធសាស្ត្រអាទិភាព និងសកម្មភាពលម្អិតសម្រាប់សសរស្តម្ភនីមួយៗ បានរំលេចនៅក្នុងឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម ២០២៥-២០៣៥" របស់ ន.គ.ស.។

*ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី៩។*

# ជំពូក ១២
# វិស័យបរធនបាលកិច្ច

## I. និដ្ឋភាពទូទៅ

ក្របខ័ណ្ឌនៃការគ្រប់គ្រង និងអភិវឌ្ឍវិស័យបរធនបាលកិច្ចត្រូវបានពង្រីកវិសាលភាព ដែលគ្របដណ្តប់លើបរធនបាលកិច្ចទូទៅ នៅក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គម តាមរយៈក្របខ័ណ្ឌច្បាប់ស្តីពីបរធនបាលកិច្ច ឆ្នាំ ២០១៩ ដែលត្រូវបានប្រកាសឱ្យប្រើនាថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៩។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងដំណាក់កាលនៃការអនុវត្តបណ្តោះអាសន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុចំនួន ៩ ដែល មានទំហំបរធន ឬទំហំធនធានហិរញ្ញវត្ថុប្រមាណ ១១៥,៨០៨,១២៣ ដុល្លារអាម៉េរិក។

អនុលោមតាមច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ ២០២១ និយ័តករបរធនបាលកិច្ច ហៅកាត់ថា ន.ប.ធ. ត្រូវបានបង្កើតជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យបរធនបាលកិច្ច។ ចាប់តាំងពីការបង្កើត ន.ប.ធ. នាឆ្នាំ ២០២១ និងការប្រកាសពីការបង្កើតបាននូវអត្តិភាពទីផ្សារ បរធនបាលកិច្ច ជាមួយនឹងប្រតិបត្តិការពេញលេញដោយជោគជ័យ នាដើមឆ្នាំ ២០២៣ កំណើននៃការចុះបញ្ជី បរធនបាលកិច្ច មានការកើនឡើងយ៉ាងឆាប់រហ័ស ដោយចំនួនបរធនបាលកិច្ចដែលបានបង្កើត និងចុះបញ្ជី ត្រឹមត្រូវតាមច្បាប់ បានកើនឡើងពី ១៧ ករណី ជាមួយទំហំបរធនសរុបចំនួនប្រមាណ ១៥៦ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២១ ដល់ចំនួន ១,១១៥ ករណី ជាមួយទំហំបរធនសរុបចំនួនប្រមាណ ១,៧៤១ លានដុល្លារអាម៉េរិក គិតត្រឹមឆ្នាំ ២០២៤។

ជាមួយនឹងការវិវត្តន៍យ៉ាងឆាប់រហ័សនៃកំណើនចុះបញ្ជីបរធនបាលកិច្ចពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៤ ទីផ្សារបរធនបាលកិច្ចនៅកម្ពុជា ត្រូវបានគ្របដណ្តប់ដោយបរធនបាលកិច្ចពាណិជ្ជកម្ម ចំនួន ១,០៩៤ ករណី ជាមួយទំហំបរធនប្រមាណ ១,២៥២ លានដុល្លារអាម៉េរិក (៩៨% នៃទំហំបរធនចុះបញ្ជី) ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ដោយក្នុងនោះ ភាគច្រើនជាបរធនបាលកិច្ចអចលនវត្ថុ ដែលវិនិយោគដោយវិនិយោគិនបរទេសក្នុងវិស័យអចលនវត្ថុ នៅកម្ពុជា ដែលក្នុងនោះមានចំនួន ៧៧៦ ករណី ជាមួយនឹងទំហំបរធនប្រមាណ ៧៥៧ លានដុល្លារអាម៉េរិក ដែលស្មើនឹង ៧១% នៃទំហំបរធនចុះបញ្ជីសរុបនៃបរធនបាលកិច្ចពាណិជ្ជកម្ម និងបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ចំនួន ៧៧៦ ករណី ជាមួយនឹងទំហំបរធន ប្រមាណ ៧៥៧ លានដុល្លារអាម៉េរិក ដែលស្មើនឹង ២២.៣២% នៃទំហំបរធនចុះបញ្ជីសរុបនៃបរធនបាលកិច្ចពាណិជ្ជកម្ម ហើយនិន្នាការនេះ រំពឹងថានឹងបន្តមានការកើនឡើង។ ក្រៅពីនោះ បរធននៃបរធនបាលកិច្ចពាណិជ្ជកម្មដែលបានចុះបញ្ជី ក៏ត្រូវបានបរធនបាលកិច្ចគ្រប់គ្រងនិងចាត់ចែងវិនិយោគ ផងដែរក្នុងវិស័យមូលបត្រ និងវិស័យពាក់ព័ន្ធផ្សេងទៀត ដែលនៅមានចំនួនតិចតួចនៅឡើយ រួមមាន៖ (១). ការវិនិយោគតាមរយៈការដាក់ប្រាក់បញ្ញើមានកាលកំណត់ (Money Market Trusts) ចំនួន ៣.១១% (២). ការវិនិយោគ ជាមួយមូលនិធិសោធននិវត្តន៍ឯកជន ចំនួន ២.៩៣% (៣). ការវិនិយោគជាមួយមូលនិធិភាគហ៊ុនិក ចំនួន ០.០៩% និង (៤). ការវិនិយោគជាមួយសញ្ញាបណ្ណបៃតង ចំនួន ០.៥៥%។

## II. ការកែទម្រង់ និងសមិទ្ធផល

ដោយមានការគាំទ្រ និងយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ន.ប.ធ. បាននិងកំពុងបន្តកសាងនូវសមិទ្ធផលជាច្រើន ដោយចាប់ផ្តើមពីការធ្វើស្ថាប័ននីយកម្មទាំងក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនិងការរៀបចំការប្រព្រឹត្តទៅរបស់ស្ថាប័ន ធនធាន ផែនការអភិវឌ្ឍន៍ស្ថាប័នសម្រាប់រយៈពេលខ្លី មធ្យម និងវែង និងទាំងក្នុងក្របខ័ណ្ឌប្រតិបត្តិការ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ របស់ស្ថាប័ន ហេតុ

ដល់ការបង្កើតអត្តិភាពទីផ្សារបរធនបាលកិច្ចជាមួយនឹងប្រតិបត្តិការពេញលេញដោយជោគជ័យនៅដើមឆ្នាំ ២០២៣ ដើម្បីបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។ ជាមួយនឹងការបង្កើត ន.ប.ធ. កម្ពុជាបានបង្កើតអត្តិភាពទីផ្សារបរធនបាលកិច្ចដោយជោគជ័យ និងសម្រេច បានសមិទ្ធផលសំខាន់ៗជាច្រើនទៀត (គិតត្រឹមឆ្នាំ ២០២៤) មានជាអាទ៍៖

- បង្កើតឱ្យមាននូវបទដ្ឋានគតិយុត្តនានា សម្រាប់គ្រប់គ្រងវិស័យបរធនបាលកិច្ចប្រកបដោយ ប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និងមានសណ្តាប់ធ្នាប់ រួមមាន៖ ច្បាប់ ចំនួន ២ អនុក្រឹត្យ ចំនួន ៤ ប្រកាស ចំនួន ១៣ និងសេចក្តីសម្រេច សេចក្តីណែនាំ និងគោលការណ៍ណែនាំ ចំនួន ១៦
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សរបស់ស្ថាប័ន ដោយក្នុងនោះ ន.ប.ធ. បានធ្វើស្ថាប័ននីយកម្មរបស់ខ្លួនដោយរលូន និងដោយជោគជ័យ ទាំងក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ស្ថាប័ន ធនធាន និងថវិកា ផែនការអភិវឌ្ឍន៍ស្ថាប័នសម្រាប់រយៈពេលខ្លី និងមធ្យម និងក្នុងក្របខ័ណ្ឌប្រតិបត្តិការ និងហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័នក្នុងការអនុវត្តតួនាទី និងភារកិច្ចជានិយ័តករ គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ច
- ផ្តល់អាជ្ញាប័ណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់/ការចុះបញ្ជីប្រតិបត្តិករការបរធនបាល និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងការចុះបញ្ជីបរធនបាលកិច្ច ដោយក្នុងនោះរួមមាន៖ ការផ្តល់ អាជ្ញាប័ណ្ណ និងការអនុញ្ញាតដល់ក្រុមហ៊ុនបរធនបាល ចំនួន ១៤ ក្រុមហ៊ុន ការផ្តល់អាជ្ញាប័ណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ដល់បរធនបាល ចំនួន ៦៩ រូប (បរធនបាលរូបវន្តបុគ្គល ៣១ រូប និងបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ៣៨ រូប) ការផ្តល់អាជ្ញាប័ណ្ណ និងការអនុញ្ញាតដល់ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ចំនួន ២៥ ធនាគារពាណិជ្ជ ការផ្តល់ការទទួលស្គាល់ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ចំនួន ១៧ ក្រុមហ៊ុន និងការផ្តល់ការទទួលស្គាល់ ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ចំនួន ១៥ ក្រុមហ៊ុន
- តាមដាន និងត្រួតពិនិត្យកាតព្វកិច្ចផ្តល់របាយការណ៍ការជូនដំណឹង និងការស្នើសុំការអនុញ្ញាត របស់បរធនបាលកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- ជំរុញ និងពង្រឹងការអនុវត្តច្បាប់
- ចុះត្រួតពិនិត្យដល់ទីកន្លែង និងអធិការកិច្ចក្នុងវិស័យបរធនបាលកិច្ច
- សិក្សាស្រាវជ្រាវដំណើរការអភិវឌ្ឍន៍ និងនវានុវត្តន៍ក្នុងវិស័យបរធនបាលកិច្ច
- រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយពីវិស័យបរធនបាលកិច្ចដល់សាធារណជន និងភាគីពាក់ព័ន្ធនានា និង
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេស/តំបន់។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

តាមរយៈការវិភាគអំពីស្ថានភាព និងនិន្នាការវិវត្តន៍របស់ទីផ្សារ បានបង្ហាញថាវិស័យបរធនបាលកិច្ចប្រឈមនឹងឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះមួយចំនួន ដូចខាងក្រោម៖

- វិស័យបរធនបាលកិច្ច នៅជាសញ្ញាណថ្មីនៅឡើយ
- ធនធានមនុស្ស គុណវុឌ្ឍិ និងសមត្ថភាពជំនាញ ព្រមទាំងចំនួនធនធានមនុស្សនៅក្នុងវិស័យនៅមានកម្រិត និងមិនទាន់អាចឆ្លើយតបទៅនឹងការវិវត្តន៍របស់ទីផ្សារបាននៅឡើយ
- ហេដ្ឋារចនាសម្ព័ន្ធគាំទ្រនៅមិនទាន់គ្រប់គ្រាន់ស្របតាមសម្ទុះនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ច
- ចំណេះដឹង និងការយល់ដឹងពីវិស័យបរធនបាលកិច្ច រួមទាំងទំនាក់ទំនង និងការសម្របសម្រួល និងសហប្រតិបត្តិការ រវាងវិស័យរដ្ឋ និងវិស័យឯកជននៅមានកម្រិតនៅឡើយ

- ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច និងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ នៅមិនទាន់មានវិសាលភាពនៃការយល់ដឹងទូលំទូលាយនៅឡើយ
- អស្ថិរភាពហិរញ្ញវត្ថុដែលនាំឱ្យមានវិបត្តិរហូតចេញនូវមូលធន និងវិបត្តិនៃការរីករាលដាលជម្ងឺឆ្លង ព្រមទាំងវិបត្តិសាកលផ្សេងៗទៀត
- ការរីកសាយភាយអាវុធមហាប្រល័យ នៅតែជាបញ្ហាប្រឈមដល់ការអភិវឌ្ឍវិស័យបរធនបាលកិច្ច
- សេចក្តីត្រូវការបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធ និងក្របខ័ណ្ឌគតិយុត្តគាំទ្រមួយចំនួនបន្ថែមទៀត

សម្ទុះនៃនវានុវត្តន៍បច្ចេកវិទ្យាបច្ចុប្បន្ន បានបង្កើតបញ្ហាប្រឈមមួយចំនួន សម្រាប់វិស័យ បរធនបាលកិច្ច មានដូចជា៖ ការត្រៀមចាប់យកវិស័យឌីជីថលនៅមានកម្រិតទាប ហេដ្ឋារចនាសម្ព័ន្ធ ឌីជីថលនៅមិនទាន់គ្រប់គ្រាន់ ភាពជឿទុកចិត្តនៃបច្ចេកវិទ្យាមិនទាន់ពេញលេញ ធនធានមនុស្ស ចំណេះដឹង និងជំនាញនៅមិនទាន់ឆ្លើយតបនឹងតម្រូវការជាក់ស្តែង។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យបរធនបាលកិច្ច

ផ្អែកលើមូលដ្ឋាននៃសមិទ្ធផលដែលសម្រេចបាន ក្នុងរយៈពេល ៣ ឆ្នាំជាងមកនេះ រួមជាមួយ ការវិភាគ ស្ថានភាពទីផ្សារ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យបរធនបាលកិច្ច ត្រូវបានកំណត់យុទ្ធសាស្ត្រអាទិភាព ចំនួន ៤ រួមមាន៖ i/-ការអភិវឌ្ឍទីផ្សារ ប្រតិបត្តិករ និងផលិតផលបរធនបាលកិច្ចថ្មីៗ ii/-ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួម iii/-ការបង្កើតយន្តការគ្រប់គ្រង និងប្រតិបត្តិការតាមនវានុវត្តន៍បច្ចេកវិទ្យា និង iv/-ការជំរុញនិងពង្រឹងការអនុវត្តច្បាប់។

យុទ្ធសាស្ត្រអាទិភាពទី១៖ ការអភិវឌ្ឍទីផ្សារ ប្រតិបត្តិករ និងផលិតផលបរធនបាលកិច្ចថ្មីៗ បានដាក់ចេញនូវវិធានការយុទ្ធសាស្ត្រ ចំនួន ៥ រួមមាន៖ i/-ការស្រាវជ្រាវអំពីយុទ្ធសាស្ត្រនានាដើម្បីអភិវឌ្ឍវិស័យបរធនបាលកិច្ច ii/-ការរៀបចំគម្រោងផែនការអភិវឌ្ឍទីផ្សារ ប្រតិបត្តិករ និង ផលិតផលបរធនបាលកិច្ចថ្មីៗ iii/-ការសិក្សាវាយតម្លៃលើនវានុវត្តន៍បរធនបាលកិច្ច ផលប៉ះពាល់ និងអត្ថប្រយោជន៍សម្រាប់អ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច iv/-ការចូលរួមធ្វើសុខុមនីយកម្មនៃក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងតំបន់ និង v/-ការរៀបចំវចនានុក្រមសម្រាប់វិស័យបរធន-បាលកិច្ច។

យុទ្ធសាស្ត្រអាទិភាពទី២៖ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួម បានដាក់ចេញនូវវិធានការយុទ្ធសាស្ត្រ ចំនួន ៧ រួមមាន៖ i/-ការពង្រឹងការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹង ពីវិស័យបរធនបាលកិច្ចដល់សាធារណជន ជាពិសេសតួអង្គពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចដោយផ្ទាល់ និង តាមប្រព័ន្ធអនឡាញ ii/-ការអនុវត្តការងារបណ្តុះបណ្តាល អប់រំ កសាងសមត្ថភាព និងផ្សព្វផ្សាយពីវិស័យបរធនបាលកិច្ច iii/-ការជំរុញឱ្យមានការចូលរួមក្នុងវិស័យបរធនបាលកិច្ចឱ្យបានកាន់តែទូលំទូលាយ iv/-ការរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច សម្រាប់ប្រតិបត្តិករក្នុងទីផ្សារ ក្រុមហ៊ុនពាក់ព័ន្ធ និងសាធារណជន v/-ការរៀបចំវេទិកានិងសន្និសីទពីវឌ្ឍនភាព បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរធនបាលកិច្ច vi/-ការបង្កើតកិច្ចសហប្រតិបត្តិការជាមួយបណ្តាបណ្តាលគ្រឹះស្ថានអប់រំ បណ្តុះបណ្តាល និងអាកាដេមិក ដើម្បីបញ្ចូលការសិក្សាពីវិស័យបរធនបាលកិច្ចក្នុងកម្មវិធីសិក្សានៃជំនាញណាមួយ និងកម្មវិធីសិក្សាអប់រំជាតិ និង vii/-ការដាក់ឱ្យដំណើរការកម្មវិធីទូរស័ព្ទ (Trust Regulator App) ដើម្បីផ្តល់ភាពងាយស្រួលដល់ភាគីពាក់ព័ន្ធ និងសាធារណជន ស្វែងរកព័ត៌មានពីវិស័យបរធនបាលកិច្ច និងលើកកម្ពស់ការចូលរួមក្នុងទីផ្សារបរធនបាលកិច្ច។

យុទ្ធសាស្ត្រអាទិភាពទី៣៖ ការបង្កើតយន្តការគ្រប់គ្រង និងប្រតិបត្តិការតាមនវានុវត្តន៍បច្ចេកវិទ្យា បានដាក់ចេញនូវវិធានការយុទ្ធសាស្ត្រ ចំនួន ៥ រួមមាន៖ i/-ការជំរុញ និងអភិវឌ្ឍប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ii/-ការកសាងថ្នាលឌីជីថលគ្រឹះ ដើម្បីជួយសម្រួល និងបង្កើនគុណភាព ការងារ ដែលធ្វើឱ្យប្រតិបត្តិការ

បរធនបាលកិច្ច អាចប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព តម្លាភាព និងសុវត្ថិភាព iii/-ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីអភិវឌ្ឍ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារប្រកបដោយសុវត្ថិភាព និងកាត់បន្ថយពេលវេលា iv/-ការបង្កើតយន្តការឬបទដ្ឋានគតិយុត្តដើម្បីរក្សាសុវត្ថិភាព និងការពារហានិភ័យតាមប្រព័ន្ធអនឡាញ សម្រាប់រាល់សកម្មភាពបរធនបាលកិច្ចដែលប្រើប្រាស់ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង v/-ការបង្កើតកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបង្កើតយន្តការគ្រប់គ្រង និងប្រតិបត្តិការតាមនវានុវត្តន៍បច្ចេកវិទ្យា។

យុទ្ធសាស្ត្រអាទិភាពទី៨៖ ការជំរុញ និងពង្រឹងការអនុវត្តច្បាប់ បានដាក់ចេញនូវវិធានការយុទ្ធសាស្ត្រ ចំនួន ៦ រួមមាន៖ i/-ការរៀបចំសិក្ខាសាលានិង/ឬវគ្គបណ្តុះបណ្តាលបញ្ជ្រាបការយល់ដឹងក្នុងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដល់ភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ii/-ការជំរុញឱ្យមានការចូលរួមប្រយុទ្ធប្រឆាំងនឹងសកម្មភាពសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធ មហាប្រល័យ (AML/CFT&CPF) ក្នុងវិស័យបរធនបាលកិច្ច iii/-ការរៀបចំនិងស្នើឡើង និង/ឬធ្វើសោធនកម្មក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់កិច្ចដំណើរការអភិវឌ្ឍវិស័យបរធនបាលកិច្ច iv/-ការចុះអនុស្សរណៈជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីសហការរួមគ្នាក្នុងក្របខ័ណ្ឌរៀបចំគោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ដែលមានភាពពាក់ព័ន្ធអន្តរក្រសួង-ស្ថាប័ន v/-ការសហការរៀបចំបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រងលើការងាររបបពន្ធក្នុងវិស័យបរធនបាលកិច្ច និង vi/-ការចុះធ្វើអធិការកិច្ច ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ ឆែកឆេរ ព្រមទាំងពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់បុគ្គលទទួលបានការអនុញ្ញាតពាក់ព័ន្ធនឹងការបង្កើតនិងចុះបញ្ជីបរធនបាលកិច្ច បុគ្គលទទួលបានការអនុញ្ញាតនិង/ឬការចុះបញ្ជីធ្វើជាប្រតិបត្តិករបរធនបាលកិច្ចរូបវន្តបុគ្គល/នីតិបុគ្គលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ចនិងអ្នកចូលរួមដទៃទៀត។

ជាមួយគ្នានេះ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តការងារដែលបានដាក់ចេញយុទ្ធសាស្ត្រនេះ ទាមទារឱ្យក្រសួង-ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ជាពិសេសតួអង្គពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ចូលរួមបន្តទៀតជាសារវន្ត ប្រកបដោយភាពក្លាវក្លាក្នុងការខិតខំបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានឆន្ទៈខ្ពស់ក្នុងការបំពេញការងារប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងស្របតាមការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាក្នុងសម័យឌីជីថល។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១០។***

# ជំពូក ១៣
# បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

## I. ទិដ្ឋភាពទូទៅ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ជាពិសេស ក្នុងអំឡុងនិងក្រោយវិបត្តិកូវីដ-១៩ និងកំពុងផ្តល់វិភាគទានយ៉ាងសំខាន់ដល់ការជំរុញសន្ទុះកំណើនសេដ្ឋកិច្ចជាតិ។ បច្ចេកវិទ្យាត្រូវបានរាជរដ្ឋាភិបាលកំណត់យកជាអាទិភាពគន្លឹះទី៥នៃយុទ្ធសាស្ត្របញ្ចកោណ-ជំណាក់កាលទី១ បន្ទាប់ពី "មនុស្ស ផ្លូវ ទឹក និងភ្លើង" សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ព្រមទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច។

ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ស្ថិតនៅជំណាក់កាលលូតលាស់ដំបូង ដ្បិតថាការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យនេះមិនទាន់មានលក្ខណៈរស់រវើក ដែលជាហេតុធ្វើឱ្យគ្រប់តួអង្គសង្គមមិនទាន់អាចទាញយកអត្ថប្រយោជន៍ជាអតិបរមាពីឌីជីថលភាវូបនីយកម្មនិងបរិវត្តកម្មឌីជីថលនៅឡើយ។ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ នាឆ្នាំ ២០២១ អ.ស.ហ. ត្រូវបានបង្កើតដោយច្បាប់ដែលមានឯករាជ្យភាព ក្នុងការបំពេញមុខងាររបស់ខ្លួនដោយធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រង និងការត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ ទន្ទឹមនេះ មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលជាយន្តការស្ថាប័នអំណោយផលដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងទីផ្សារត្រូវបានបង្កើតដោយអនុក្រឹត្យក្រោមអគ្គលេខាធិការដ្ឋាន អ.ស.ហ. ក្នុងទិសដៅលើកកម្ពស់ការអភិវឌ្ឍនិងនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។ មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. ទទួលបន្ទុកអភិវឌ្ឍ ធ្វើនិយ័តកម្ម បណ្តុះបណ្តាល និងផ្សព្វផ្សាយ បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ខណៈដែលនិយ័តករក្រោមឱវាទ អ.ស.ហ. ទទួលបន្ទុកលើកកម្ពស់ការអភិវឌ្ឍនិង ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងការជំរុញបរិវត្តកម្មឌីជីថលក្រោមសមត្ថកិច្ចរបស់ខ្លួន។ មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. បាននិងកំពុងខិតខំបំពេញបេសកកម្ម មុខងារ តួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីបុរេសកម្មនិងអន្តរសកម្ម សហថាមពល សហអភិវឌ្ឍន៍ សហនវានុវត្តន៍ សហការទទួលខុសត្រូវ និងសិនិទ្ធភាពជាមួយនឹងគ្រប់តួអង្គសង្គមពាក់ព័ន្ធ ជាពិសេសជាមួយនឹងនិយ័តករនិងអង្គភាពក្រោមឱវាទ អ.ស.ហ. ស្របតាមអភិក្រមដើម្បីជំរុញការកសាងមូលដ្ឋានគ្រឹះនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគាររដ្ឋាភិបាលទាំងមូលនឹងជីវភាពនៃប្រព័ន្ធតួអង្គតែមួយ ក្នុងការលើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលរួមបញ្ចូលទាំងការជំរុញបរិវត្តកម្មឌីជីថល។

## II. ការកែទម្រង់ និងសមិទ្ធផល

ក្នុងនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាលកំណត់យក "ការកែទម្រង់និងការពង្រឹងអភិបាលកិច្ច" ជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ជំណាក់កាលទី១ ដែលជាបាវចនានៃការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។ អនុលោមតាមស្នូលនៃយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលសម្រេចបានប្រកបដោយជោគជ័យនូវសមិទ្ធផលគន្លឹះ៦ពាក់ព័ន្ធនឹងការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល (Policy Enablers) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះ ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និងការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលជាផ្នែកទាំង៤ នៃដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្នុងស្មារតីកសាងមូលដ្ឋានគ្រឹះនៃប្រព័ន្ធ អេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក។

### ក. ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល

ក្នុងទិដ្ឋភាពគោលនយោបាយនិងយុទ្ធសាស្ត្រ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលក្នុងនោះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ មានអាទិភាពយុទ្ធសាស្ត្រដែលផ្តោត លើ "ការជំរុញ និងការលើកទឹកចិត្តដល់ការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ"។ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ក៏បានដាក់ចេញនូវទិសដៅនិងវិធានការគោលនយោបាយពាក់ព័ន្ធនឹង ការ-ជំរុញបរិវត្តកម្មឌីជីថលក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ចនិងសង្គមឌីជីថល រួមទាំងការលើកកម្ពស់ការអភិវឌ្ឍនិង ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ។ ក្រៅពីនេះ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ បានដាក់ចេញនូវវិធានការគោលនយោបាយពាក់ព័ន្ធនឹងការជំរុញបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងសេវាសាធារណៈកាលទី១ ខណៈដែលគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ផ្តោតលើការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដោយឈរលើមូលដ្ឋានដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដើម្បីកសាងសេដ្ឋកិច្ចនិង សង្គមឌីជីថលកម្ពុជាជំរស់រវើក ស្របតាមចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ ២០៣០ ដែលផ្តោតលើការជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ទន្ទឹមនេះ ក្នុងការជំរុញបច្ចេកវិទ្យានៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ លិខិតបទដ្ឋានមួយចំនួនត្រូវបានរៀបចំ រួមមានជាអាទិ៍ ប្រកាសស្តីពី បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារឆ្នាំ ២០២៣ គោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រឆ្នាំ ២០២៣ គោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាធានារ៉ាប់រងឆ្នាំ ២០២៣ និងគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ចឆ្នាំ ២០២៣។ ទន្ទឹមនេះ និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ កំពុងសិក្សារៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន។ រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់សំខាន់ៗ ដែលមានកម្មវិបាកលើការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមមានជាអាទិ៍ សេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្មនិងសេវាអចលនវត្ថុ សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងអាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន សេចក្តីព្រាងច្បាប់ស្តីពី សន្តិសុខសាយប័រ សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន សេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារទិន្នន័យបុគ្គល និងសេចក្តីព្រាងច្បាប់ស្តីពី ការផ្ទេរបច្ចេកវិទ្យា។

### ខ. ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ

រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដែលជាថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋា-ភិបាល ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្លាស់ប្តូរទិន្នន័យ ដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័ររវាង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ ជាមួយនឹងវិស័យឯកជន ដែលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដោយសុវត្ថិភាព តាមរយៈប្រព័ន្ធអ៊ីនធឺណិតឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា ដែលជាប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា ដែលប្រតិបត្តិការដោយប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ថ្នាលបច្ចេកវិទ្យាប្លុកឆេនកម្ពុជា ដើម្បីសាកល្បងកម្មវិធីអេប៣ ដើម្បីជំរុញការប្រើប្រាស់និងនវានុវត្តន៍បច្ចេក-វិទ្យា ដែលកំពុងលេចឡើងថ្មីៗ ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh ដែលជាថ្នាលបច្ចេកវិទ្យារបស់រាជរដ្ឋាភិបាលដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារដែលមានដាក់បញ្ចូល ស្តង់ដាខ្យូអរកូត និងថ្នាលរដ្ឋាភិបាលឌីជីថលផ្សេងទៀត។ និយ័តករក្រោមឱវាទ អ.ស.ហ. បាននិងកំពុងប្រើប្រាស់ និងពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់ថ្នាលដែលមានស្រាប់ខាងលើក៏ដូចជាអភិវឌ្ឍថ្នាលនិង/ឬប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មានគាំទ្រដល់ការធ្វើឌីជីថលភាវូបនីយកម្មលើការផ្តល់សេវាក្រោមសមត្ថកិច្ចរបស់ខ្លួន ជាពិសេស

ក្នុងក្របខ័ណ្ឌ នៃការរៀបចំប្រព័ន្ធចុះបញ្ជីនិងសេវាសាធារណៈ ការទទួលស្គាល់នីតិសម្បទា ឬការអនុញ្ញាតប្រតិបត្តិការ។ ន.ម.ក. បាននិងកំពុងប្រើប្រាស់ និងអនុញ្ញាតឱ្យមានការប្រើប្រាស់នូវប្រព័ន្ធចុះឈ្មោះ និងការបង់ថ្លៃតាមអនឡាញសម្រាប់ វគ្គបណ្តុះបណ្តាលនិងការប្រឡង និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យមូលបត្រ ប្រព័ន្ធជួញដូរចល័តនិងកម្មវិធីទូរសព្ទ ស៊ីអេសអ៊ិកត្រេដ (CSX Trade) ប្រព័ន្ធផ្តល់លេខអត្តសញ្ញាណវិនិយោគិនតាមប្រព័ន្ធអនឡាញ និងកម្មវិធីទូរស័ព្ទជួញដូរឧបករណ៍និស្សន្ទ ប្រព័ន្ធបើកគណនីជួញដូរមូលបត្រតាមអនឡាញ ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមអនឡាញ និងកំពុងអភិវឌ្ឍប្រព័ន្ធស្នើសុំ ឬផ្តល់អាជ្ញាប័ណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់តាមអនឡាញ ក៏ដូចជាអភិវឌ្ឍប្រព័ន្ធ គ្រប់គ្រងឯកសារចូល-ចេញតាមអនឡាញ ប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមហ៊ុន និងប្រព័ន្ធគ្រប់គ្រងការដាក់បញ្ជូន របាយការណ៍ហិរញ្ញវត្ថុ។ លើសពីនេះ ន.ម.ក. កំពុងអភិវឌ្ឍបច្ចេកវិទ្យាត្រួតពិនិត្យតាមដានប្រតិបត្តិការអាជីវកម្ម ជួញដូរឧបករណ៍និស្សន្ទ ដែលជា បច្ចេកវិទ្យាត្រួតពិនិត្យ និងបច្ចេកវិទ្យានិយ័តកម្ម។ ក្រៅពីនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា និងកំពុងអភិវឌ្ឍឃ្លាំងទិន្នន័យ និងថ្នាលវិភាគទិន្នន័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឌីជីស៊ីតេអេប និងប្រព័ន្ធហត្ថលេខាឌីជីថល។ ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានគាំទ្រដល់ការរៀបចំជាអាទិ៍កម្មវិធីពន្លឿនអាជីវកម្មនវានុវត្តន៍បញ្ញាស វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា មហោស្រពបច្ចេកវិទ្យាហិរញ្ញវត្ថុពិភពលោក និងវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុនៃពិព័រណ៍បច្ចេកវិទ្យាកម្ពុជា។

**គ. ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ**

បន្ថែមពីលើគោលនយោបាយនិងយុទ្ធសាស្ត្រ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ជាអាទិ៍ គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០ និងផែនទីបង្ហាញផ្លូវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍កម្ពុជាឆ្នាំ ២០៣០ និយ័តករនិងអង្គភាពក្រោមឱវាទ អ.ស.ហ. បានរៀបចំនិងចូលរួមវគ្គ បណ្តុះបណ្តាល សិក្ខាសាលានិងទស្សនកិច្ចសិក្សា និងរៀបចំខ្លឹមសារផ្សព្វផ្សាយតាមបណ្តាញសង្គម បន្ថែមទៅលើការអប់រំបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាល។ ទន្ទឹមនេះ អ.ស.ហ. បានរៀបចំផតថលបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីចែករំលែកទិន្នន័យ ព័ត៌មាន ឯកសារ និងចំណេះដឹងផ្សេងៗពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងកម្រងបទប្បញ្ញត្តិគតិយុត្តជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសទ្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជំរុញនិងលើកកម្ពស់ការយល់ដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តក៏ដូចជាបច្ចេកសព្ទបច្ចេកវិទ្យាហិរញ្ញវត្ថុ។

**ឃ. ការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ**

ការអភិវឌ្ឍនិងនវានុវត្តន៍ផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ។ បច្ចុប្បន្ន ផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារដែលមានការអភិវឌ្ឍនិងនវានុវត្តន៍គួរឱ្យកត់សម្គាល់ រួមមានផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធានារ៉ាប់រង (បច្ចេកវិទ្យាធានារ៉ាប់រង) និងផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ។

## III. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មិនទាន់មានលក្ខណៈរស់រវើក ដែលអាចឱ្យគ្រប់តួអង្គសង្គមចាប់យកអត្ថប្រយោជន៍បានជាអតិបរមាពីនិន្នាការឌីជីថលភាវូបនីយកម្មនិងបរិវត្តកម្មឌីជីថលនៅឡើយ ព្រោះតែមានឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះគន្លឹះៗដូចខាងក្រោម៖

- ការខ្វះខាតក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រដាក់លាក់ក្នុងការជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

- ការខ្វះខាតច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលកំណត់អំពីក្របខ័ណ្ឌគតិយុត្តនិងនិយ័តកម្មពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក៏ដូចជាការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។
- ការខ្វះខាតការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលត្រូវបានអភិវឌ្ឍដោយក្រសួង-ស្ថាប័ននិងការខ្វះថ្នាលឌីជីថលគ្រឹះថ្មីៗ ដែលរួមបញ្ចូលទាំងថ្នាលនិង/ឬប្រព័ន្ធឌីជីថលដែលមានលក្ខណៈរួមក្នុងក្របខ័ណ្ឌ អ.ស.ហ.។
- ការខ្វះខាតធនធានមនុស្សដែលមានសមត្ថភាពនិងជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។
- ការខ្វះខាតការចាប់យក ការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ជាពិសេសបច្ចេកវិទ្យាចុងក្រោយថ្មីៗក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។
- ការខ្វះខាតការប្រើប្រាស់ផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុដែលកំពុងមានក្នុងទីផ្សារ ក៏ដូចជាការខ្វះការធ្វើពិពិធកម្មផលិតផលនិងសេវាបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ដែលមានលក្ខណៈនវានុវត្តន៍។

## IV. ផែនការយុទ្ធសាស្ត្រសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

អនុលោមតាមមុំទី៥ "ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ" នៃបញ្ចកោណទី៥ "ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ឌីជីថល" នៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ទិសដៅយុទ្ធសាស្ត្រនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ផ្ដោតលើគោលដៅយុទ្ធសាស្ត្រចំនួន ៤ រួមមាន៖ i/-ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល ii/-ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ iii/-ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និង iv/-ការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលជាផ្នែកទាំង៤ នៃដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

### ក. ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល

-រៀបចំ និងការធ្វើសុក្រឹតកម្មក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រ ការរៀបចំនិងការធ្វើវិសោធនកម្មក្របខ័ណ្ឌគតិយុត្ត និងនិយ័តកម្ម ការរៀបចំក្របខ័ណ្ឌអន្តរប្រតិបត្តិការនិងអន្តរតំណភាព ការលើកកម្ពស់ភាពជឿទុកចិត្ត ការពង្រឹង កិច្ចសហការនិងកិច្ចសហប្រតិបត្តិការ និងការផ្តួចផ្តើមគំនិតនវានុវត្តន៍ផ្សេងៗ។

-គាំទ្រដល់ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ព្រមទាំងការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

-ដាក់ចេញនូវអាទិភាពការងារពាក់ព័ន្ធនឹងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុនិងការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

### ខ. ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ

-ជំរុញការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់ដែលបានអភិវឌ្ឍ ដោយក្រសួង-ស្ថាប័ន និងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះថ្មីៗចាំបាច់ដទៃទៀត សម្រាប់គាំទ្រដល់ការអភិវឌ្ឍ បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងការអភិវឌ្ឍឌីជីថល។

-អភិវឌ្ឍថ្នាលឌីជីថលគ្រឹះជាប្រព័ន្ធអេកូឡូស៊ី និងដាក់ចេញនូវអាទិភាពការងារពាក់ព័ន្ធនឹងការរៀបចំបទប្បញ្ញត្តិដើម្បីបំពាក់មុខងារបន្ថែមឱ្យមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. ជាអង្គភាពបរិវត្តកម្មឌីជីថល នៃ អ.ស.ហ.។

-រៀបចំផែនការយុទ្ធសាស្ត្រប្រតិបត្តិកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងការស្រាវជ្រាវ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះ ដែលរួមបញ្ចូលទាំងថ្នាលនិង/ឬប្រព័ន្ធឌីជីថលដែលមានលក្ខណៈរួមក្នុង អ.ស.ហ. រួមទាំងថ្នាលនិង/ឬប្រព័ន្ធប្រមូល គ្រប់គ្រង និងចែករំលែកទិន្នន័យ។

**គ. ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ**

-ជំរុញនិងការលើកកម្ពស់ការកសាងសមត្ថភាពនិងជំនាញបច្ចេកវិទ្យានិងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការចាប់យកការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាចុងក្រោយថ្មីៗ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។

-ជំរុញការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ដោយដាក់ចេញអាទិភាពការងារពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

-ជំរុញនិងការលើកកម្ពស់ការកសាង សមត្ថភាព និងជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលគាំទ្រដល់ការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

**ឃ. ការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ**

-ជំរុញពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រកបដោយនវានុវត្តន៍ ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឱ្យកាន់តែមានលក្ខណៈសម្បូរបែប ដែលអាចដើរស្របនឹងបទពិសោធន៍ ឧត្តមានុវត្តន៍ និន្នាការតំបន់និងសកល ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

-ធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុមិនមែនធនាគារ ភាពជឿទុកចិត្ត និង គុណភាពជីវិតរបស់អ្នក-ប្រើប្រាស់ តាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងវិស័យធានារ៉ាប់រងនិងសោធនឯកជន មូលបត្រ សន្តិសុខសង្គម បរធនបាលកិច្ច គណនេយ្យនិងសវនកម្ម និងអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ព្រមទាំងសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុផ្សេងទៀត។

-ជំរុញការអភិវឌ្ឍនិងនវានុវត្តន៍ សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការដាក់ចេញនូវអាទិភាពការងារពាក់ព័ន្ធនឹងការស្រាវជ្រាវអំពីសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុដែលមានលក្ខណៈ និងការរៀបចំកម្មវិធីនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយផ្តោតលើការធ្វើនិយ័តកម្មនិងពិពិធកម្ម ជំរុញនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១១។***

# ជំពូក ១៤

# បញ្ហាអន្តរវិស័យពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

## I. ការចែករំលែកព័ត៌មានឥណទាន

### ក. ទិដ្ឋភាពទូទៅ

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) គឺជាអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទានមានទ្រព្យសកម្មសរុបប្រមាណ ៨៧,៤ ប៊ីលានរៀល និងមានគ្រឹះស្ថានជាសមាជិកចំនួន ១៩៩ ក្នុងនោះ ធនាគារពាណិជ្ជ ៦១ ធនាគារឯកទេស ១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៦ គ្រឹះស្ថានភតិសន្យា-ហិរញ្ញវត្ថុ ១៥ និងគ្រឹះស្ថានឥណទានជនបទ ២៣។

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ប្រមូលទិន្នន័យឬព័ត៌មានឥណទានរបស់អតិថិជនជារូបវន្ត និងក្រុមហ៊ុនសហគ្រាសទូទាំងប្រទេសពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយសមាជិកនីមួយៗអាចប្រើប្រាស់ទិន្នន័យទាំងនោះក្នុងការវាយតម្លៃអតិថិជនតាមរយៈប្រវត្តិឥណទាន ដើម្បីកាត់បន្ថយហានិភ័យឥណទាន ព្រមទាំងបង្កភាពងាយស្រួលដល់អតិថិជនខ្ចីប្រាក់ដែលមានប្រវត្តិឥណទានល្អ។ គិតត្រឹមដំណាច់ឆ្នាំ ២០២៤ ឥណទានសរុបដែលអ្នកផ្តល់ទិន្នន័យបានបញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានចំនួនសរុប ២៣៦,៤ ទ្រីលានរៀល ស្មើនឹង ៤.៣០០.៣១៣ គណនី ក្នុងនោះ៖ i/-ឥណទានឯកកត្តបុគ្គលមានចំនួន ២០៥,៥ ទ្រីលានរៀល ស្មើនឹង ៤.២៩៤.០៦៨ គណនី និង ii/-ឥណទានក្រុមហ៊ុនមានចំនួន ៣០,៩ ទ្រីលានរៀល ស្មើនឹង ៦.២៤៣ គណនី។ សំពៀតឥណទានសរុបត្រូវបានបញ្ចូលដោយអ្នកផ្តល់ទិន្នន័យនីមួយៗ រួមមាន៖ ធនាគារពាណិជ្ជ ២១១,១ ទ្រីលានរៀល ធនាគារឯកទេស ២,៤ ទ្រីលានរៀល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១៤,៣ ទ្រីលានរៀល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧,១ ទ្រីលានរៀល គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១,៥ ទ្រីលានរៀល និងគ្រឹះស្ថានឥណទានជនបទ ៨៤,៥ ប៊ីលានរៀល។

### ខ. ការកែទម្រង់ និងសមិទ្ធផល

ប្រតិបត្តិការរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) បានបន្តរីកចម្រើនគួរឱ្យកត់សំគាល់ ដោយគ្រឹះស្ថានជាសមាជិកបានចូលប្រើប្រាស់របាយការណ៍ឥណទាន សរុបមានចំនួន ៦,៧ លានប្រតិបត្តិការ ក្នុងនោះ ធនាគារពាណិជ្ជ ៤,២ លានប្រតិបត្តិការ (៦២,៧%) ធនាគារឯកទេស ១៦៩,១ ពាន់ប្រតិបត្តិការ (២,៥%) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១,៣ លានប្រតិបត្តិការ (១៩,៧%) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៧៤,៣ ពាន់ប្រតិបត្តិការ (១៣,១%) គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ៧៤,០ ពាន់ប្រតិបត្តិការ (១,១%) និងគ្រឹះស្ថានឥណទានជនបទ ៥៦,៥ ពាន់ប្រតិបត្តិការ (០,១%)។ ទន្ទឹមនេះ ទិន្នន័យមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីដែលផ្តល់ដោយអ្នកផ្តល់ទិន្នន័យក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានសរុបមានចំនួន ៧.៧២៥ ប្រតិបត្តិការ ស្មើនឹង ៤.៦២៩ គណនី និងសមតុល្យសរុបចំនួន ២,៦ ទ្រីលានរៀល។

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានបន្តយកចិត្តទុកដាក់ និងពង្រីកជាបន្តបន្ទាប់ តាមរយៈវឌ្ឍនភាពសំខាន់ៗ រួមមាន៖ i/-ការចុះអនុស្សរណៈយោគយល់ត្រីភាគីរវាងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (កូរ៉េ) និងធនាគារ JEONBUK ស្តីពី កិច្ចសហការចែករំលែកព័ត៌មានឥណទានឆ្លងដែន រវាងប្រទេសកម្ពុជា និងសាធារណរដ្ឋកូរ៉េ នាខែ ឧសភា នៅសាធារណរដ្ឋកូរ៉េ និង ii/-ការដាក់ឱ្យដំណើរការគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor-FTC) រវាងប្រទេសកម្ពុជា និងប្រទេសសិង្ហបុរី នាខែ មិថុនា ឆ្នាំ ២០២៤ នៅប្រទេសសិង្ហបុរី។ លើសពីនេះ សេវាផ្ទៀងផ្ទាត់អចលនទ្រព្យនៅលើគេហទំព័រ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) គឺជាសេវាកម្មថ្មីដែលទើបត្រូវបានសម្ពោធជាផ្លូវការកាលពីខែ ធ្នូ ដោយប្រើប្រាស់ប្រព័ន្ធកម្មវិធីអន្តរកម្មផ្លាស់ប្តូរទិន្នន័យរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា)។ ព័ត៌មាន

សំខាន់ៗ ដូចជា ស្ថានភាពអចលនទ្រព្យ ម្ចាស់កម្មសិទ្ធិ ប្រវត្តិជួលអចលនទ្រព្យ និងប្រវត្តិជាប់បន្ទុក នឹងមានបង្ហាញភ្លាមៗនៅក្នុងរបាយការណ៍អចលនទ្រព្យ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចទាញយករបាយការណ៍នេះ តាមរយៈប្រព័ន្ធអនឡាញ សម្រាប់ជាមូលដ្ឋានមួយក្នុងការវិភាគ និងវាយតម្លៃឥណទាន ដោយពុំចាំបាច់ចំណាយពេលវេលាក្នុងការស្វែងរក ឬ ផ្ទៀងផ្ទាត់ព័ត៌មានអចលនទ្រព្យនៅមន្ទីរ ឬ ក្រសួង។ សមិទ្ធផលនេះ គឺជាកិច្ចសហការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី និងក្រុមហ៊ុន ហ្វាន់ហ្គាយ ឯ.ក។ ទន្ទឹមនេះ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ក៏បានគាំទ្រលើការងារកិច្ចការពារអ្នកប្រើប្រាស់ តាមរយៈការចែករំលែកព័ត៌មានឥណទាន ផងដែរ។

បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បានចែករំលែកបទពិសោធន៍ក្នុងការបង្កើត ការដាក់ឱ្យដំណើរការ និងការត្រួតពិនិត្យអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន ជូនដល់គណៈប្រតិភូមកពីធនាគារកណ្តាលពីប្រទេសប៉ាពួញូហ្គីនេ កោះសូឡូម៉ូន និងវ៉ានូទូ ជាដើម។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ព័ត៌មានឥណទានពេញលេញពីគ្រប់អ្នកផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធនឹងជួយដល់គ្រឹះស្ថានក្នុងការទទួលបានប្រវត្តិឥណទានរបស់អ្នកខ្ចីប្រាក់ និងវាយតម្លៃលទ្ធភាពទូទាត់សងរបស់អតិថិជនកាន់តែច្បាស់លាស់។ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា មិនតម្រូវឱ្យចែករំលែកទិន្នន័យជាមួយអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទានទេ។ ដូច្នេះហើយ ក្រុមហ៊ុន ក្រេឌីតប្យូរ៉ូ ខេមបូឌា មិនមានព័ត៌មានឥណទានពេញលេញនៅឡើយទេ ហើយព័ត៌មានឥណទានមិនពេញលេញប៉ះពាល់ការខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយបំណុលលើសលប់ និងការគ្រប់គ្រងហានិភ័យជាប្រព័ន្ធ។

ប្រព័ន្ធដាក់ពិន្ទុឥណទានអតិថិជនរបស់ក្រុមហ៊ុន ក្រេឌីតប្យូរ៉ូ ខេមបូឌា ដែលហៅកាត់ថា "K-Score" ប្រើប្រាស់តែព័ត៌មានឥណទានទទួលបានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាសមាជិករបស់ខ្លួនដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាតែប៉ុណ្ណោះ។ ហេតុនេះ "K-Score" មិនបានផ្តល់នូវការវាយតម្លៃលទ្ធភាពទូទាត់សងពិតប្រាកដរបស់អ្នកខ្ចីប្រាក់ទាំងអស់ទេ។

## ឃ. ផែនការយុទ្ធសាស្ត្រសម្រាប់ការចែករំលែកព័ត៌មានឥណទាន

ដើម្បីពង្រឹងការប្រមូលទិន្នន័យឥណទានរបស់ក្រុមហ៊ុន ក្រេឌីតប្យូរ៉ូ ខេមបូឌា ឱ្យបានពេញលេញនិងគ្រប់ជ្រុងជ្រោយ ទិន្នន័យពីវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលមិនស្ថិតក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជានឹងជួយបំពេញការខ្វះខាតផ្នែកទិន្នន័យឥណទាន និងបង្កើនប្រសិទ្ធភាពនៃការវិភាគវាយតម្លៃពីលទ្ធភាពសងរបស់អតិថិជនបន្ថែមទៀត។ ធនាគារជាតិនៃកម្ពុជានឹងសហការជាមួយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដើម្បីជំរុញការប្រមូលទិន្នន័យពាក់ព័ន្ធពីវិស័យផ្សេងៗដែលស្ថិតក្រោមបទប្បញ្ញត្តិជារូមរបស់ អ.ស.ហ. ត្រូវបានចែករំលែកជាមួយអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១២។***

## II. ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

### ក. ទិដ្ឋភាពទូទៅ

សេដ្ឋកិច្ចនៅទូទាំងពិភពលោកបាននិងកំពុងប្រឈមនឹងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ ហិរញ្ញប្បទានភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស បទល្មើសព្រៃឈើនិងសត្វព្រៃ បទល្មើសបច្ចេកវិទ្យា និងបទល្មើសផ្សេងៗទៀត។ កត្តាទាំងនេះបណ្តាលឱ្យកើតមានការសម្អាតប្រាក់ ដែលជួយដល់ការបិទបាំងផលនៃបទល្មើស និងអាចប៉ះពាល់ដល់យន្តការទីផ្សារ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

កម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ដោយបានកែសម្រួលជាច្រើន ក្នុងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ធាតុសំខាន់ៗនៃក្របខ័ណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលមានក្នុងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ រួមមាន៖ ការបញ្ចូលអង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការមិនស្វែងរកប្រាក់ចំណេញ (NPOs) ក្រុមហ៊ុនអចលនទ្រព្យ សារការី មេធាវី ឈ្មួញដើងសាមូលបត្រនិងឈ្មួញដើងសាឧបករណ៍និស្សន្ទ និងគណនេយ្យករ ទៅក្នុងក្របខ័ណ្ឌ AML/CFT ព្រមទាំងពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនៃវិស័យកាស៊ីណូ និងវិស័យអចលនវត្ថុ ការបង្កើនសមត្ថភាពបុគ្គលិករបស់ ស.ហ.ក. លើការងារវិភាគនិងត្រួតពិនិត្យ ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យនិងស្ថិតិពាក់ព័ន្ធនឹង AML/CFT ការលើកកម្ពស់ការយល់ដឹង និងការបង្កើនសមត្ថភាពរបស់បុគ្គលរាយការណ៍អំពី AML/CFT។

### ខ. ការកែទម្រង់ និងសមិទ្ធផល

#### ខ.១. ការវាយតម្លៃអញ្ញមញ្ញ

នាខែ កញ្ញា ឆ្នាំ ២០១៧ ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) បានចេញផ្សាយរបាយការណ៍វាយតម្លៃអញ្ញមញ្ញ (MER) ដែលបានលើកឡើងថា ទោះបីជាកម្ពុជាបានធ្វើឱ្យប្រសើរឡើងនូវកម្រិតនៃការអនុលោមតាមបច្ចេកទេសជាមួយនឹងស្តង់ដារ ក្រុមការងារ (FATF) ចាប់តាំងពីការវាយតម្លៃអញ្ញមញ្ញឆ្នាំ ២០០៧ កម្ពុជាត្រូវកែលម្អបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការកាត់បន្ថយកត្តាគំរាមកំហែង និងភាពងាយរងគ្រោះពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ML/TF)។

បច្ចុប្បន្ន ក្នុងចំណោមអនុសាសន៍ទាំង ៤០ កម្ពុជាទទួលបានចំណាត់ថ្នាក់អនុលោមភាព ចំនួន ២ ចំណាត់ថ្នាក់អនុលោមតាមភាគច្រើន ចំនួន ៣១ ចំណាត់ថ្នាក់អនុលោមតាមផ្នែក ចំនួន ៦ និងចំណាត់ថ្នាក់មិនអនុលោមតាមចំនួន ១។ លទ្ធផលនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងការពង្រឹងប្រព័ន្ធ AML/CFT។

វឌ្ឍនភាព និងការកែលម្អត្រូវបានធ្វើឡើងក្នុងផ្នែកជាច្រើននៃក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ក្របខ័ណ្ឌស្ថាប័ន និងប្រសិទ្ធភាពប្រតិបត្តិការតាមស្តង់ដារដែលដាក់ចេញដោយ FATF។ ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានប្រកាសឱ្យប្រើប្រាស់ នាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២០ ដែលមានគោលបំណង កំណត់អំពីវិធានការត្រួតពិនិត្យ បង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា។ ទន្ទឹមនឹងការដាក់ចេញនូវច្បាប់នេះ ក៏មានការដាក់ចេញសេចក្តីណែនាំមួយចំនួន ដូចជា វិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ធនាគារឆ្លើយឆ្លងនិងទំនាក់ទំនងប្រហាក់ប្រហែល ការផ្ទេរប្រាក់ដោយផ្ទាល់និងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ការត្រួតពិនិត្យផ្ទៃក្នុង និងការដាក់ទណ្ឌកម្មចំពោះការមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ជាមួយគ្នានេះ ច្បាប់និងបទប្បញ្ញត្តិសំខាន់ៗផ្សេងទៀត ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បី

កែលម្អយន្តការត្រួតពិនិត្យ AML/CFT នៅកម្រិតថ្នាក់ជាតិ ស្របនឹងនិន្នាការពិភពលោកក្នុងការបង្កើនតម្រូវការអនុលោមភាពរបស់អង្គភាព ឬបុគ្គលរងនិយ័តកម្ម និងមិនរងនិយ័តកម្ម មានដូចជា៖ ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងសេចក្តីណែនាំផ្សេងៗទៀត។

### ខ.២. ការវាយតម្លៃហានិភ័យថ្នាក់ជាតិ

ការវាយតម្លៃហានិភ័យថ្នាក់ជាតិ (NRA) ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០១៦ បានផ្តល់ឱ្យអាជ្ញាធរទាំងអស់យល់ដឹងអំពីបញ្ហាប្រឈម និងឧបសគ្គចម្បងៗ រួមមាន៖ ការយល់ដឹងអំពីហានិភ័យ ML/TF ការបង្កើតវិធានការកាត់បន្ថយហានិភ័យ ការអភិវឌ្ឍយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុក។ កម្ពុជាបានប្រកាន់ជំហរអនុវត្ត NRA រៀងរាល់ ៥ ឆ្នាំម្តង។ ជាមួយគ្នានេះ ធនាគារពិភពលោក (WB) នៅបន្តផ្តល់ការគាំទ្រនិងណែនាំ ដោយផ្តល់នូវឧបករណ៍និងជំនួយ ដើម្បីអនុវត្ត NRA ទីពីរ (NRA II) ដោយរួមបញ្ចូលអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត NGOs និង NPOs ជាដើម។

### ខ.៣. ការកសាងសមត្ថភាព

ស.ហ.ក. ត្រួតពិនិត្យបុគ្គលរាយការណ៍តាមរយៈការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង ដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិស្តីពី AML/CFT។ ការត្រួតពិនិត្យបុគ្គលរាយការណ៍ត្រូវបានអនុវត្តនិងតាមដានតាមរយៈវិធានការនានាដូចជា ការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងការត្រួតពិនិត្យលើឯកសារ ជាដើម។ ស.ហ.ក. បានរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងអំពី AML/CFT ដើម្បីអនុលោមតាមការតម្រូវរបស់ FATF និងការបណ្តុះបណ្តាលដែលបានបញ្ចូលនូវលក្ខខណ្ឌតម្រូវថ្មីៗនៃច្បាប់ បទប្បញ្ញត្តិ និងនិន្នាការដែលមានការប្រែប្រួលនិងវិធីសាស្ត្រថ្មីៗនៃ AML/CFT ព្រមទាំងសេចក្តីណែនាំ ឬ របាយការណ៍ថ្មីៗ របស់ FATF APG ឬ ក្រុមអ៊ិកម៉ុង (Egmont Group) ព្រមទាំងបានផ្សព្វផ្សាយដល់បុគ្គលរាយការណ៍ក្នុងគោលបំណងជំរុញការយល់ដឹងអំពីស្តង់ដារអន្តរជាតិស្តីពី AML/CFT និងការផ្លាស់ប្តូរដែលអាចកើតឡើង ដើម្បីធានាបាននូវអភិបាលកិច្ច AML/CFT កម្រិតខ្ពស់នៅកម្ពុជា។

កម្ពុជានឹងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ FATF និង APG ដើម្បីពង្រឹងអភិបាលកិច្ច និងក្របខ័ណ្ឌ AML/CFT របស់ខ្លួន ព្រមទាំងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានការអនុលោមតាមពេញលេញក្នុងការវាយតម្លៃរបស់ FATF នាពេលខាងមុខ និងបង្កើតកេរ្តិ៍ឈ្មោះល្អសម្រាប់ប្រតិបត្តិការនៅក្នុងទីផ្សារហិរញ្ញវត្ថុដែលមានសុវត្ថិភាព ជាមួយនឹងវិធានការកាន់តែប្រសើរ ដើម្បីចៀសផុតពីហានិភ័យ ML/TF។

### ខ.៤. សមត្ថភាពស៊ើបអង្កេតករណី ML/TF

កម្ពុជាបានជំរុញសកម្មភាពអនុវត្តច្បាប់ដើម្បីប្រឆាំងនឹង ML/TF ដោយការបង្កើនធនធានមនុស្សទទួលបន្ទុកឆ្លើយតបបទល្មើសហិរញ្ញវត្ថុ និងការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារ (SOPs) ផ្សេងៗ ដែលនាំឱ្យមានការកើនឡើងនូវការស៊ើបអង្កេត ហិរញ្ញវត្ថុចំពោះបទល្មើសមានហានិភ័យខ្ពស់ដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ការស៊ើបអង្កេតទាំងនេះក៏បានឈានទៅដល់ការបង្កក ការចាប់យក និងរឹបអូសទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងសំអាងនៃបទល្មើស និងការសម្អាតប្រាក់។ លទ្ធផលដ៏ល្អប្រសើរដែលសម្រេចបានទាំងនេះភាគច្រើនជាលទ្ធផលនៃការបង្កើតក្រុមការងារដោយក្រសួង និងស្ថាប័នដែលអនុវត្ត SOPs បានសមស្រប ដោយធានាបាននូវក្របខ័ណ្ឌស្ថាប័ន និងប្រតិបត្តិការដ៏រឹងមាំសម្រាប់ AML/CFT។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទប់ស្កាត់បទល្មើសសម្អាតប្រាក់។ ប៉ុន្តែហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅតែជាបញ្ហាចម្បង ដែលទាមទារការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស វិស័យដែលមានប្រតិបត្តិការសាច់ប្រាក់ទំហំធំ។ ការយល់ដឹងក្នុងការរាយការណ៍របាយការណ៍ប្រតិបត្តិការសង្ស័យ (STRs)

និងរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ (CTRs) នៅក្នុងវិស័យមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ (DNFBPs) នៅមានកម្រិត និងអាជីវកម្មតាមបណ្តោយព្រំដែនភាគច្រើនដែលទូទាត់ជាសាច់ប្រាក់នៅជាការព្រួយបារម្ភរបស់អាជ្ញាធរ។ រាជរដ្ឋាភិបាលកម្ពុជាបានណែនាំដល់អាជ្ញាធរពាក់ព័ន្ធ ត្រូវចាត់ទុកការងារប្រឆាំងការសម្អាតប្រាក់ជាការងារអាទិភាព និងមានការទទួលខុសត្រូវខ្ពស់ ដោយសារការងារនេះមានសារៈសំខាន់ចំពោះប្រទេសជាតិ។ កម្ពុជាបានពង្រឹងគោលការណ៍គតិយុត្ត ប៉ុន្តែការអនុវត្តច្បាប់នៅមានកម្រិតដោយសារការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសជនសង្ស័យនៅមិនទាន់ស្របតាមស្តង់ដាររបស់ FATF នៅឡើយ។

**ឃ. ផែនការយុទ្ធសាស្ត្រសម្រាប់ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

**ឃ.១. ការវាយតម្លៃអញ្ញមញ្ញរបស់ក្រុមការងារហិរញ្ញវត្ថុ**

**អនុលោមភាពស្របតាមអនុសាសន៍របស់ FATF៖** ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានបង្ហាញវឌ្ឍនភាពការងារយ៉ាងច្រើនក្នុងការពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបន្តធ្វើការងារជាមួយសាខាថ្នាក់តំបន់របស់ FATF ដែលមានកម្ពុជាជាសមាជិក ដើម្បីអនុវត្តអនុសាសន៍ដែលបានរកឃើញក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញ។ ជាមួយគ្នានេះ ការតាមដានវឌ្ឍនភាពទាន់ពេលវេលា កិច្ចសហប្រតិបត្តិការល្អរវាងភាគីពាក់ព័ន្ធនិងតម្លាភាពនៃរបាយការណ៍វឌ្ឍនភាព បង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការអនុលោមតាមស្តង់ដារអន្តរជាតិស្តីពី AML/CFT ព្រមទាំងបានជួយកម្ពុជាក្នុងការចេញពីបញ្ជីប្រផេះបានដោយជោគជ័យ។ លើសពីនេះ ដើម្បីរក្សាបានចីរភាពក្នុងការអនុលោមតាមអនុសាសន៍របស់ FATF គឺតម្រូវឱ្យមានការបង្កើតនូវយន្តការវាយតម្លៃខ្លួនឯងជាប្រចាំ ការធានាបាននូវការអភិវឌ្ឍជាបន្តបន្ទាប់ និងការសម្របខ្លួនទៅនឹងការវិវត្តន៍នៃលក្ខខណ្ឌគតិយុត្តជាដើម ដែលនឹងជំរុញឱ្យមានវប្បធម៌បុរេសកម្មនៃអនុលោមភាព (Proactive Compliance)។

**ឃ.២. ការវាយតម្លៃហានិភ័យថ្នាក់ជាតិ**

**ការវាយតម្លៃហានិភ័យថ្នាក់ជាតិ (NRA) ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម៖** រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តការវាយតម្លៃហានិភ័យថ្នាក់ជាតិជាប្រចាំចំពោះវិស័យនានា និងផ្តោតលើវិស័យដែលមានហានិភ័យខ្ពស់។ វិធីសាស្ត្រជាយុទ្ធសាស្ត្ររបស់កម្ពុជាក្នុងការពង្រឹងក្របខ័ណ្ឌ AML/CFT រួមមាន ការរៀបចំ NRA II ដោយរួមបញ្ចូលវិស័យមួយចំនួនដូចជាអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត (VASPs) NGOs និង NPOs ជាដើម។ វិធីសាស្ត្រនេះរៀបចំឡើងដើម្បីពង្រីកវិសាលភាពនៃការត្រួតពិនិត្យ និងកាត់បន្ថយភាពខ្វះខាតដែលត្រូវបានកំណត់ NRA ដោយធានាការអនុវត្តវិធានការឱ្យបានរហ័សនិងមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងភាពងាយរងគ្រោះ ព្រមទាំងរៀបចំ NRAIII ដែលបង្ហាញពីការយកចិត្តទុកដាក់ ក្នុងការអនុលោមតាមស្តង់ដារដែលកំណត់ដោយ FATF។

**ឃ.៣. កាតព្វកិច្ចសមស្របនិងត្រឹមត្រូវសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ**

ការវាយតម្លៃឱ្យបានច្បាស់លាស់ឡើងវិញលើកាតព្វកិច្ចសមស្របនិងត្រឹមត្រូវនឹងធ្វើឡើងសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីកំណត់អំពីភាពខ្វះចន្លោះឱ្យស្របតាមស្តង់ដារអន្តរជាតិ។ ការវាយតម្លៃនេះ នឹងផ្តោតសំខាន់ទៅលើការបំពេញចន្លោះខ្វះខាតភ្លាមៗឱ្យបានទាន់ពេលវេលា ដើម្បីធានាបាននូវក្របខ័ណ្ឌច្បាប់ដ៏រឹងមាំមួយ។ យុទ្ធសាស្ត្រនេះត្រូវសម្រេចឱ្យបាននូវការអនុលោមយ៉ាងពេញលេញលើកាតព្វកិច្ចសមស្របនិងត្រឹមត្រូវ លើកកម្ពស់សុចរិតភាព និងគណនេយ្យភាពនៅក្នុងវិស័យហិរញ្ញវត្ថុ។

**ឃ.៤. ការពង្រឹងតួនាទីរបស់ ស.ហ.ក.**

**ក្របខ័ណ្ឌរឹងមាំនៃបទប្បញ្ញត្តិ និងការត្រួតពិនិត្យ៖** ស.ហ.ក. ត្រួតពិនិត្យបុគ្គលរាយការណ៍ឱ្យស្របតាមលក្ខខ័ណ្ឌតម្រូវនៃ AML/CFT និងធានាថាចន្លោះខ្វះខាតនិងលទ្ធផលទាំងនោះ ត្រូវបានផ្តល់ត្រលប់ទៅបុគ្គលរាយការណ៍វិញ ដើម្បីពង្រឹងប្រព័ន្ធនិងការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព។ ស.ហ.ក. នឹងបន្តសហការជាមួយ APG ដើម្បីពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ស្របតាមការតម្រូវរបស់ FATF។ ស.ហ.ក. នឹងធានាឱ្យមាន

ការបណ្តុះបណ្តាលស្តីពី អនុលោមភាព (Mandatory Compliance Certification Courses) ដល់បុគ្គលរាយការណ៍ ដោយមានបញ្ចូលចំណុចពាក់ព័ន្ធនឹងហានិភ័យ ML/TF ដែលត្រូវបានកំណត់នៅក្នុងរបាយការណ៍ NRA I និង NRA II ស្របតាមស្ថានភាពអាជីវកម្ម។ ស.ហ.ក. ក៏នឹងចេញផ្សាយការណែនាំលម្អិតដល់បុគ្គលរាយការណ៍សម្រាប់អនុវត្តការវាយតម្លៃហានិភ័យ ML/TF ដែលនឹងបញ្ចូលការកំណត់ហានិភ័យ ML/TF ការថ្លឹងប៉ារ៉ាម៉ែត្រហានិភ័យនានា និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ។ ការណ៍នេះនឹងពង្រឹងការអនុលោមតាមនិងជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយភាពធន់និងសុវត្ថិភាព។

**ការរៀបចំកម្មវិធីបង្កើនការយល់ដឹង៖** ស.ហ.ក. នឹងធានាថាកម្មវិធីបង្កើនការយល់ដឹងជាបន្តបន្ទាប់សម្រាប់បុគ្គលរាយការណ៍ មានភាពសមស្របតាមស្តង់ដាររបស់ FATF និងស្តង់ដារអន្តរជាតិផ្សេងៗទៀតស្តីពី AML/CFT ដោយរួមបញ្ចូលវគ្គបណ្តុះបណ្តាលអំពីបទប្បញ្ញត្តិថ្មីៗ និន្នាការថ្មីៗ និងឧត្តមានុវត្តន៍ពាក់ព័ន្ធនឹង AML/CFT។ ទន្ទឹមនេះ ក្នុងការបង្កើនគុណភាពរបាយការណ៍ពាក់ព័ន្ធ AML/CFT ដែលបញ្ជូនដោយបុគ្គលរាយការណ៍ ស.ហ.ក. នឹងផ្តល់ការណែនាំដល់បុគ្គលរាយការណ៍ ដើម្បីកែលម្អនិងបង្កើនសុក្រឹតភាពព័ត៌មាននៅក្នុងរបាយការណ៍ និងធានាថារបាយការណ៍ទាំងនោះ ស្របតាមស្តង់ដារ AML/CFT អន្តរជាតិ។ គំនិតផ្តួចផ្តើមនេះ នឹងរួមបញ្ចូលផងដែរនូវការអនុវត្តបច្ចេកវិទ្យាទំនើបៗ និងឧបករណ៍វិភាគទិន្នន័យផ្សេងៗ ដើម្បីបង្កើនប្រសិទ្ធភាពនៃការស្វែងរកប្រតិបត្តិការសង្ស័យ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ ធ្វើឡើងដើម្បីពង្រឹងសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មហិរញ្ញវត្ថុប្រកបដោយភាពជាក់លាក់និងការយកចិត្តទុកដាក់ខ្ពស់។

### ឃ.៥. ការជំរុញការអនុលោមតាមច្បាប់សម្រាប់អាជីវកម្មពឹងផ្អែកលើសាច់ប្រាក់

**ការវាយតម្លៃអាជីវកម្មមានហានិភ័យខ្ពស់៖** នាឆ្នាំ ២០២៣ ក្រុមអ្នកជំនាញរបស់ FATF បានបញ្ចប់ការចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីវាយតម្លៃវឌ្ឍនភាពរបស់កម្ពុជាទៅតាមផែនការដែលបានគ្រោងទុក និងបានផ្តល់ការសន្និដ្ឋានជាវិជ្ជមាន។ ទោះបីជាយ៉ាងនេះក្តី ការវាយតម្លៃអាជីវកម្មដែលមានហានិភ័យ ML/TF ខ្ពស់នៅក្នុងប្រទេសនៅតែធ្វើឡើងជាបន្តបន្ទាប់។ នាពេលខាងមុខ កម្មវិធីវាយតម្លៃនឹងរួមបញ្ចូលនូវបទពិសោធន៍កន្លងមក ព្រមទាំងលទ្ធផលពីការចុះត្រួតពិនិត្យដល់ទីកន្លែងនិងវិធីសាស្ត្រវាយតម្លៃផ្អែកលើហានិភ័យ។

### ឃ.៦. ការបង្កើនសមត្ថភាពគាំទ្រការស៊ើបអង្កេត

**ការពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** រាជរដ្ឋាភិបាលកម្ពុជានឹងកំណត់ និងអនុម័តនូវគោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីឈានទៅរឹបអូសទ្រព្យសម្បត្តិ ដូចជា ការបង្វិលទ្រព្យទៅប្រទេសដើម ការចែករំលែក និងការសងវិញនូវផលនៃបទល្មើសនិងទ្រព្យដែលមានតម្លៃស្មើ។ គោលនយោបាយទាំងនេះ នឹងរួមបញ្ចូលការផ្តល់អាទិភាពនិងការអនុវត្តសំណើកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកំណត់តួនាទី-ភារកិច្ចរបស់ ស.ហ.ក. ទាក់ទងនឹងការចែករំលែកព័ត៌មានហិរញ្ញវត្ថុ និងការរំពឹងទុករបស់បណ្តាប្រទេសផ្សេងៗចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ម្យ៉ាងទៀត ត្រូវមានប្រព័ន្ធគ្រប់គ្រងសំណុំរឿងដើម្បីគ្រប់គ្រងការទទួលសំណើ និងការធ្វើសំណើដោយក្រសួងយុត្តិធម៌។

**ការបង្កើនការស៊ើបអង្កេត និងការចោទប្រកាន់បទសម្អាតប្រាក់៖** អាជ្ញាធរអនុវត្តច្បាប់ (LEAs) នឹងដើរតួនាទីដោយបុរេសកម្មដល់ការបង្កើនការស៊ើបអង្កេត និងការចោទប្រកាន់បទសម្អាតប្រាក់។ ការរក្សាកំណត់ត្រាលម្អិតនៃករណីទាំងនេះ ការផ្តោតទៅលើកិច្ចសហប្រតិបត្តិការជាមួយ ស.ហ.ក. និងការបង្ហាញពីភាពជោគជ័យនៃការកើនឡើងក្នុងការចោទប្រកាន់នឹងបង្ហាញពីភាពរីកចម្រើននៃការស៊ើបអង្កេត និងការចោទប្រកាន់បទសម្អាតប្រាក់។ បន្ថែមលើនេះ ការបន្តឱ្យមាននូវវគ្គបណ្តុះបណ្តាលសម្រាប់អ្នកស៊ើបអង្កេត និងការអនុវត្តកម្មវិធីបច្ចេកវិទ្យាទំនើបសម្រាប់ការវិភាគការស៊ើបការណ៍ហិរញ្ញវត្ថុនឹងជំរុញដល់ការអនុលោមតាមគោលបំណងនេះ។

### ឃ.៧. ការកែលម្អការប្រមូលទិន្នន័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

**ការពង្រឹងការបញ្ជូនព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ និងទិន្នន័យពាក់ព័ន្ធផ្សេងទៀតទៅ LEAs ដែលមានទំនាក់ទំនងនឹងបទល្មើសមានហានិភ័យខ្ពស់៖** ស.ហ.ក. នឹងពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីបង្កើនការស៊ើបការណ៍ដែលមានគុណភាពខ្ពស់បន្ថែមទៀត និងចែករំលែកព័ត៌មានជាមួយ LEAs រួមមាន ការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វិភាគជាយុទ្ធសាស្ត្រ ដែលទទួលបានពីបុគ្គលរាយការណ៍ផ្សេងៗ។ ក្នុងន័យនេះ ស.ហ.ក. នឹងអនុវត្តការងារជាជំហានៗ ដូចជា៖ i/-វិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យ ii/-នីតិវិធីប្រតិបត្តិស្តង់ដារ iii/-របាយការណ៍វិភាគ iv/-កំណត់ត្រានៃការបញ្ជូនរបាយការណ៍ v/-ការចងក្រងឯកសារដោយប្រើប្រាស់បច្ចេកវិទ្យា និង vi/-យន្តការផ្តល់មតិកែលម្អ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១៣។***

## III. ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

### ក. ទិដ្ឋភាពទូទៅ

ដុល្លារូបនីយកម្មបានកើតឡើងក្នុងសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មក និងបានស្ថិតក្នុងកម្រិតខ្ពស់ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងតាមរយៈសមាមាត្រនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងរូបិយវត្ថុទូទៅស្មើនឹងជាង ៨០%។ ទោះបីជាបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនក្នុងដំណាក់កាលដំបូងនៃការស្តារសេដ្ឋកិច្ចឡើងវិញក៏ដោយ ដុល្លារូបនីយកម្មបានបណ្តាលឱ្យសេដ្ឋកិច្ចកម្ពុជាដែលបានកើនឡើង និងមានសមាហរណកម្មជាលំដាប់ទៅក្នុងតំបន់ មានភាពងាយរងគ្រោះទៅនឹងវិបត្តិ ជាពិសេសដោយសារតែមិនមានឯករាជ្យពេញលេញក្នុងការអនុវត្តនយោបាយរូបិយវត្ថុ ដើម្បីរួមចំណែករក្សាស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចនិងជំរុញកំណើន។ វិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺកូវីដ-១៩ បានបង្ហាញយ៉ាងច្បាស់ពីផលលំបាកនេះ ហើយដែលតម្រូវឱ្យកម្ពុជាបន្តកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត។

### ខ. ការកែទម្រង់ និងសមិទ្ធផល

នៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ចរាចរណ៍ប្រាក់រៀលបានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងអត្រាជាមធ្យម ១០% ហើយប្រាក់បញ្ញើជាប្រាក់រៀលបានកើនឡើងក្នុងអត្រា ២៧%។ ទន្ទឹមគ្នានេះ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសក៏បានកើនឡើងក្នុងល្បឿនលឿនផងដែរ ក្នុងអត្រា ១៧,៩%។ ទោះបីជាការកើនឡើងនៃចរាចរណ៍ប្រាក់រៀលមិនបានកាត់បន្ថយកម្រិតដុល្លារូបនីយកម្មក្តី ប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង សម្រាប់ការទូទាត់តម្លៃកាន់តែធំទៅៗ។ ការសម្រេចបានលទ្ធផលទាំងនេះ គឺដោយសារការអនុវត្តគោលនយោបាយ និងវិធានការជាច្រើន ដូចជា៖

- ការតម្រូវឱ្យការបង់ពន្ធត្រូវបានធ្វើឡើងជាប្រាក់រៀល ហើយការទូទាត់ថ្លៃទឹក ភ្លើង ជាទូទៅ ក៏ត្រូវបានតម្រូវឱ្យទូទាត់ជាប្រាក់រៀលផងដែរ
- ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់អេឡិចត្រូនិក ដូចជា ប្រព័ន្ធទូទាត់បាគង ដែលសម្រួលដល់ការទូទាត់ជាពិសេសចំពោះប្រាក់រៀល ដែលមានកំណើនប្រើប្រាស់លឿនជាងប្រាក់ដុល្លារអាម៉េរិក
- ការតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ផ្តល់ឥណទានជារូបិយវត្ថុជាតិយ៉ាងតិច ១០% នៃសំពៀតឥណទានសរុប។ នាឆ្នាំ ២០២៤នេះ សមាមាត្រនៃឥណទានជាប្រាក់រៀលធៀបនឹងឥណទានសរុប ស្ថិតនៅកម្រិតប្រមាណ ១៣,៣%
- កំណើនឥណទានជាប្រាក់រៀលនេះ ក៏ត្រូវបានរួមចំណែកគាំទ្រដោយការដាក់ចេញឧបករណ៍នយោបាយ-រូបិយវត្ថុនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសន្ទនីយភាពជាប្រាក់រៀល
- ការតម្រូវឱ្យប្រើប្រាស់ប្រាក់រៀលក្នុងការចារឹកថ្លៃ ព្រមទាំងការទិញ-លក់មូលបត្ររដ្ឋ ជាប្រាក់រៀលចាប់ពីខែកញ្ញា ឆ្នាំ ២០២២មក
- ការប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលទ្ធកម្មសាធារណៈនៅខែ ឧសភា ឆ្នាំ ២០២៣ ដែលបានតម្រូវឱ្យរាល់ការទូទាត់នៅក្រោមកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រូវតែធ្វើឡើងជាប្រាក់រៀល លើកលែងតែកិច្ចសន្យាសម្រាប់អនុវត្តលទ្ធកម្មនៅក្រៅប្រទេស ដែលការទូទាត់អាចធ្វើឡើងជារូបិយប័ណ្ណបរទេស និង
- ការតម្រូវឱ្យអាជីវកម្ម និងអ្នកផ្តល់សេវាទាំងអស់នៅក្នុងប្រទេសកម្ពុជាដាក់តាំងស្លាកតម្លៃផលិតផលនិងសេវាជារៀល ដែលក្រសួងពាណិជ្ជកម្មបានដាក់ចេញប្រកាសនៅឆ្នាំ ២០១៧ និងសេចក្តីជូនដំណឹងច្រើនរំលឹកនាឆ្នាំ ២០២៣ ជាដើម។

### គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក៏មានការប្រឈមនឹងឧបសគ្គជាច្រើនផងដែរ រួមមាន៖

- ការនិយម និងភាពងាយស្រួលក្នុងការប្រើប្រាស់ប្រាក់ដុល្លារអាម៉េរិក សម្រាប់ការទូទាត់តម្លៃធំ ហើយការតាំងស្លាកតម្លៃ នៅបន្តយកប្រាក់ដុល្លារជាគោល ដែលធ្វើឱ្យការទូទាត់ជាប្រាក់រៀលមានការខាតបង់ដោយសារតែអត្រាប្តូរប្រាក់របស់អាជីវករមិនស្របតាមអត្រាប្តូរប្រាក់លើទីផ្សារ
- ការសន្សំនិងឥណទានភាគច្រើនជាប្រាក់ដុល្លារអាម៉េរិក ដោយសារតែប្រាក់ខែភាគច្រើនជាប្រាក់ដុល្លារ-អាម៉េរិក ហើយការទិញទំនិញ ឬសេវាធំៗ ធ្វើឡើងជាដុល្លារអាម៉េរិក
- ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនៅក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង និងការកំណត់ប្រាក់បៀវត្សរ៍នៅក្នុងវិស័យជាច្រើនផ្សេងទៀត នៅតែជាប្រាក់ដុល្លារអាម៉េរិក
- ចំណូលរដ្ឋមួយចំនួននៅតែជារូបិយប័ណ្ណបរទេសនៅឡើយ ដូចជា សំបុត្រចូលទស្សនារមណីយដ្ឋានទេសចរណ៍ ពន្ធព្រលានយន្តហោះ ថ្លៃទិដ្ឋាការ ការធ្វើលិខិតឆ្លងដែន ជាដើម និង
- ចំណាយរដ្ឋមួយចំនួន រួមទាំង ការវិនិយោគសាធារណៈ ត្រូវបានទូទាត់ជាប្រាក់ដុល្លារអាម៉េរិក។ លើសពីនេះ ក្រុមហ៊ុន-សហគ្រាសរដ្ឋ (ដូចជា ក្នុងវិស័យកសិឧស្សាហកម្ម និងសេវាទឹក ភ្លើង និងសំរាម) កំពុងធ្វើប្រតិបត្តិការដោយប្រើរូបិយប័ណ្ណចម្រុះ។

## ឃ. ផែនការយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ប្រាក់រៀល

ផ្អែកលើបទពិសោធន៍អន្តរជាតិ ក៏ដូចជានៅកម្ពុជានាពេលបីទសវត្សរ៍កន្លងមកនេះ ដុល្លារូបនីយកម្មនឹងមិនងាយថយចុះទេ ប្រសិនបើការជំរុញការប្រើប្រាស់ប្រាក់រៀលមិនបានធ្វើឡើងប្រកបដោយសង្គតិភាពនិងភាពសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលរួមមាន ក្រសួង-ស្ថាប័នសាធារណៈ វិស័យឯកជន និងប្រជាជនទូទៅ បើទោះបីជាកម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចប្រសើរយ៉ាងណាក៏ដោយ។

ដើម្បីឈានទៅសម្រេចឱ្យបានការបង្កើនការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចជាលំដាប់ វិធានការសំខាន់មួយចំនួន ចាំបាច់ក្នុងការអនុវត្ត រួមមាន៖

- ការបង្កើតឱ្យមានយុទ្ធសាស្ត្រថ្នាក់ជាតិលើការលើកកម្ពស់ប្រាក់រៀល ដើម្បីបង្កើនការចូលរួមនិងសហការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ សំដៅជំរុញការប្រើប្រាស់ប្រាក់រៀលប្រកបដោយនិរន្តរភាព
- ការកំណត់ប្រាក់ឈ្នួលអប្បបរមាជាប្រាក់រៀល និងការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការទូទាត់តាមស្ថាប័នរដ្ឋ ក៏ដូចជាការពង្រីកការអនុវត្តទៅដល់សេវាសាធារណៈនានា ដូចជា ចំណូលពីសេវាអប់រំ ព្យាបាល លិខិតឆ្លងដែន និងចំណាយលើគម្រោងអភិវឌ្ឍន៍សាធារណៈ ការអភិវឌ្ឍធនធានមនុស្ស កម្មវិធីជំនួយសង្គម ។ល។
- ការបង្កើនការយល់ដឹងនិងការលើកទឹកចិត្តវិស័យឯកជន ក៏ដូចជាប្រជាជនទូទៅ ឱ្យពង្រឹងការប្រើប្រាស់ប្រាក់រៀល ដូចជា ការបើកប្រាក់បៀវត្សរ៍និងការទូទាត់ធំៗនានាជាប្រាក់រៀលជាលំដាប់ ព្រមទាំងបង្កើនការបើកគណនីជាប្រាក់រៀល
- ការសម្រួលដល់លទ្ធភាព និងភាពងាយស្រួលក្នុងការទទួលបានប្រាក់រៀល ដូចជា ការបន្ថយកម្រៃសេវាសម្រាប់ការប្រើប្រាស់ប្រាក់រៀល និងការដាក់ធនបត្រតម្លៃតូចនិងធំទៅក្នុងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យ-ប្រវត្តិ និង

- ការរៀបចំកម្មវិធីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃប្រាក់រៀលឱ្យកាន់តែទូលំទូលាយដល់ក្រុមហ៊ុន-សហគ្រាស និងជាពិសេសក្នុងចំណោមយុវជន តាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម កម្មវិធី-អប់រំ និងវេទិកាពិភាក្សាសាធារណៈ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១៥។***

## IV. ហិរញ្ញវត្ថុប្រកបដោយចីរភាព

### ក. ទិដ្ឋភាពទូទៅ

កម្ពុជាបានចាប់ផ្តើមផ្តោតលើហិរញ្ញវត្ថុប្រកបដោយចីរភាព ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តាមរយៈតម្រូវការនិងកាលានុវត្តភាពក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។ តម្រូវការហិរញ្ញប្បទានដើម្បីសម្រេចផែនការរួមចំណែករបស់ជាតិ (Nationally Determined Contribution) របស់កម្ពុជា ដើម្បីបន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សុទ្ធ ៤២% ក្នុងលក្ខខណ្ឌអាជីវកម្មដូចធម្មតា (Business As Usual) នាមុនឆ្នាំ ២០៣០ មានចំនួនប្រមាណ ៨ ប៊ីលានដុល្លារអាម៉េរិក ក្នុងនោះ ប្រមាណ ៥,៨ ប៊ីលានដុល្លារអាម៉េរិក សម្រាប់ការងារកាត់បន្ថយសកម្មភាពដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុ និងប្រមាណ ២ ប៊ីលានដុល្លារអាម៉េរិក សម្រាប់ការងារបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ឧបករណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព មានដូចជាសញ្ញាបណ្ណបៃតង សញ្ញាបណ្ណចីរភាព និងសញ្ញាបណ្ណផ្សារភ្ជាប់នឹងចីរភាព និងឥណទានទៅលើគម្រោងបៃតង ដើរតួនាទីជាឧបករណ៍បំណុលដ៏មានប្រសិទ្ធភាព ដើម្បីកៀរគរមូលនិធិ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

### ខ. ការកែទម្រង់ និងសមិទ្ធផល

ហិរញ្ញវត្ថុប្រកបដោយចីរភាព គឺជាការងារថ្មីសម្រាប់វិស័យហិរញ្ញវត្ថុកម្ពុជា។ ធនាគារជាតិនៃកម្ពុជា និង ន.ម.ក. បានដើរតួនាទីយ៉ាងសកម្ម ក្នុងការរៀបចំគោលនយោបាយ យន្តការគាំទ្រ និងគំនិតផ្តួចផ្តើមនានា ដែលចាំបាច់ដល់ការកៀរគរហិរញ្ញប្បទានប្រកបដោយចីរភាព។ សមិទ្ធផលសំខាន់ៗនៅក្នុងកិច្ចការហិរញ្ញវត្ថុប្រកបដោយចីរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានដូចខាងក្រោម៖

- សមាគមធនាគារនៅកម្ពុជា បានផ្សព្វផ្សាយនូវគោលការណ៍ និងសេចក្តីណែនាំសម្រាប់ការអនុវត្តហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា របស់ក្រុមការងារផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា (CSFI) ដែលបានបង្កើតឡើងនាឆ្នាំ ២០១៦ ដើម្បីអភិវឌ្ឍនិងពង្រឹងការការពារផ្នែកហិរញ្ញវត្ថុ និងស្តង់ដារនៃការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម។ នាឆ្នាំ ២០១៩ ដោយមានការគាំទ្រពីធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា បានបង្កើតគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា (CSFP) សម្រាប់ការអនុវត្តរបស់បណ្តាសមាជិកក្នុងវិស័យធនាគារ។
- នាឆ្នាំ ២០១៩ ធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងក្រសួងបរិស្ថានបានចុះអនុស្សរណៈយោគយល់ ដើម្បីសហការអភិវឌ្ឍ និងអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព សម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ។
- ចាប់ពីឆ្នាំ ២០១៦ សមាគមធនាគារនៅកម្ពុជា បានចូលជាសមាជិកនៃបណ្តាញធនាគារប្រកបដោយចីរភាព (SBN) និងបានរៀបចំសិក្ខាសាលាជាច្រើន លើប្រធានបទនានា ពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រកបដោយចីរភាព។
- ធនាគារជាតិនៃកម្ពុជាបានសហការជាមួយដៃគូអភិវឌ្ឍន៍នានា សម្រាប់ការវាយតម្លៃទីផ្សារហិរញ្ញវត្ថុប្រកបដោយចីរភាព ដូចជា៖ i/-សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិលើគម្រោងសិក្សាស្តីពី ការកំណត់វិសាលភាព និងការស្រាវជ្រាវពីទីផ្សារហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា និង ii/-គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP) ស្តីពី ការសិក្សា និងការវិភាគទីផ្សារហិរញ្ញវត្ថុប្រកបដោយចីរភាពនិងបៃតងនៅកម្ពុជា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមវាយតម្លៃហានិភ័យដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ដោយសហការជាមួយធនាគារពិភពលោក។
- ធនាគារជាតិនៃកម្ពុជាសហការជាមួយអង្គការ UNESCAP ក្នុងការរៀបចំអភិវឌ្ឍផែនទីបង្ហាញផ្លូវហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា។

- ធនាគារជាតិនៃកម្ពុជាសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងការអភិវឌ្ឍប្រព័ន្ធវដ្តករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាព ដែលកំណត់លក្ខណៈសកម្មភាពសេដ្ឋកិច្ច ឬ ការវិនិយោគដែលមានចីរភាព។
- ធនាគារជាតិនៃកម្ពុជាបានរួមបញ្ចូលគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទៅក្នុងគោលការណ៍ណែនាំស្តីពី ការវិនិយោគទុនបម្រុងអន្តរជាតិ និងបានវិនិយោគលើសញ្ញាបណ្ណប្រកបដោយចីរភាព។
- ន.ម.ក. ដោយមានកិច្ចសហការជាមួយ ADB បានដាក់ចេញនូវគោលការណ៍ណែនាំលម្អិតសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណបៃតងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ណែនាំស្តីពី ការបោះផ្សាយសញ្ញា-បណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណចីរភាព។ ទន្ទឹមនេះ ន.ម.ក. បាននិងកំពុងសហការជាមួយលេខាធិការដ្ឋានអាស៊ានក្នុងការរៀបចំគោលការណ៍ណែនាំស្តីពី ការបោះផ្សាយសញ្ញាបណ្ណផ្សារភ្ជាប់នឹងចីរភាពនៅកម្ពុជា។ ការដាក់ចេញនូវបទប្បញ្ញត្តិទាំងនេះ នាំឱ្យមានការបោះផ្សាយលក់សញ្ញាបណ្ណប្រកបដោយចីរភាពក្នុងទីផ្សារសញ្ញាបណ្ណនៅកម្ពុជា។ គិតត្រឹមដំណាច់ឆ្នាំ ២០២៤ សញ្ញាបណ្ណប្រកបដោយចីរភាពចំនួន ៣ ត្រូវបានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា រួមមាន សញ្ញាបណ្ណបៃតងដែលបានបោះផ្សាយកាលពីដើមឆ្នាំ ២០២៣ ដែលអនុលោមទៅតាមស្តង់ដារសញ្ញាបណ្ណបៃតងអាស៊ាន និងសញ្ញាបណ្ណបៃតង និងសញ្ញាបណ្ណចីរភាព ដែលបានបោះផ្សាយនៅចុងឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ដោយអនុលោមតាមគោល-ការណ៍សញ្ញាបណ្ណប្រកបដោយចីរភាពរបស់សមាគមទីផ្សារមូលធនអន្តរជាតិ (ICMA)។
- ដើម្បីលើកកម្ពស់ការបោះផ្សាយលក់សញ្ញាបណ្ណប្រកបដោយចីរភាព និងយន្តការនៃការរាយការណ៍ពាក់ព័ន្ធនឹង ESG ន.ម.ក. បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ដូចជា ADB WB UNESCAP និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសាកល (GGGI)។ ទន្ទឹមនេះ ក៏មានការផ្តល់ការលើកទឹកចិត្តពន្ធដារសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណបៃតង ដូចដែលមានចែងក្នុងអនុក្រឹត្យដែលបានដាក់ឱ្យប្រើប្រាស់ នាឆ្នាំ ២០២២ ផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយកាត់បន្ថយ ៥០% លើពន្ធនៃប្រាក់ចំណូលដែលត្រូវបង់សម្រាប់រយៈពេល ៣ ឆ្នាំ។ ដោយឡែក ចំពោះសញ្ញាបណ្ណប្រកបដោយចីរភាពនឹងទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធជាពិសេស។
- ន.ម.ក. បានក្លាយជាសមាជិក SBFN ក្នុងឆ្នាំ ២០២៤ ដែលតាមរយៈសមាជិកភាពនេះ នឹងជួយពង្រឹងបន្ថែមនៃការធ្វើហិរញ្ញប្បទានជំរុញការអភិវឌ្ឍប្រកបដោយចីរភាព។
- ន.ម.ក. ដោយមានជំនួយបច្ចេកទេសពីធនាគារពិភពលោក បានដាក់ឱ្យប្រើប្រាស់នូវប្រកាសស្តីពី ការបង្ហាញព័ត៌មានចីរភាព។

## គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

### គ.១. ជំនាញបច្ចេកទេស និងសមត្ថភាពស្ថាប័ន

ការខ្វះខាតចំណេះដឹង និងសមត្ថភាពក្នុងការអនុវត្តហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់បណ្តាភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា ក្រុមហ៊ុនបោះផ្សាយលក់សញ្ញាបណ្ណ អ្នករៀបចំគោលនយោបាយ ក្រុមហ៊ុនឯកជន និងសាធារណជន នៅតែជាបញ្ហាប្រឈមដ៏ចម្បងក្នុងការជំរុញការអភិវឌ្ឍហិរញ្ញវត្ថុប្រកបដោយចីរភាព។ បញ្ហានេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈសមត្ថភាពនៃវិស័យឯកជននៅមានកម្រិត ព្រមទាំងមិនត្រូវបានចាត់ទុកជាការងារអាទិភាពពេញលេញនៅឡើយ។ សេវាកម្មគាំទ្រមួយចំនួន ដូចជា សេវាច្បាប់ និងគណនេយ្យ សេវាចែករំលែកព័ត៌មាន និងសេវាសម្រប-សម្រួល មិនទាន់មានការអភិវឌ្ឍឬមិនទាន់មាននៅលើទីផ្សារនៅឡើយ។ ទោះបីជាមានការខិតខំប្រឹងប្រែងពីរាជរដ្ឋាភិ-បាល និងភាគីពាក់ព័ន្ធនានា ដូចជា ធនាគារជាតិនៃកម្ពុជា គ.ស.ហ.វ ន.ម.ក. សមាគមធនាគារនៅកម្ពុជា និងដៃគូ

អភិវឌ្ឍន៍ផ្សេងទៀតក៏ដោយ ក៏ការខ្វះខាតផ្នែកជំនាញបច្ចេកទេសនិងការយល់ដឹង ពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ស្ថាប័ននានា នៅតែជាឧបសគ្គចម្បងចំពោះការលូតលាស់នៃហិរញ្ញវត្ថុប្រកបដោយចីរភាព[២៨]។

**គ.២. ភាពមានកម្រិតនៃទីផ្សារមូលបត្រ**

ទីផ្សារមូលបត្រនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់នាប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែចាំបាច់ត្រូវមានយន្តការជំរុញការរីកចម្រើននេះ ឈានទៅរកកិច្ចការពារបរិស្ថាននិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដែលអាចសម្រេចបានតាមរយៈឧបករណ៍ហិរញ្ញវត្ថុដែលយកចិត្តទុកដាក់ទៅលើ ESG ពីបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ ដូចជា ការបោះផ្សាយសញ្ញាបណ្ណបៃតង សញ្ញាបណ្ណសង្គម និងសញ្ញាបណ្ណចីរភាព ជាដើម។ ទីផ្សារសញ្ញាបណ្ណសាជីវកម្មនៅកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ និងមានការខ្វះខាតការចូលរួមពីវិនិយោគិនស្ថាប័នក្នុងស្រុកផ្សេងទៀត ក្រៅពីធនាគារពាណិជ្ជនិងក្រុមហ៊ុនធានារ៉ាប់រង។ សន្ទនីយភាពក្នុងទីផ្សារនៅមានកម្រិត ដោយវិនិយោគិនស្ថាប័នក្នុងស្រុកជាទូទៅកាន់កាប់សញ្ញាបណ្ណរហូតដល់កាលប្រតិទាន។ ការអនុវត្តស្តង់ដាររបាយការណ៍ស្តីពី ការអនុវត្តប្រកបដោយចីរភាព អាចនឹងធ្វើឱ្យទីផ្សារមូលបត្រនៅកម្ពុជាជួបប្រទះបញ្ហាប្រឈមដែលបានរំពឹងទុកមួយចំនួន បើទោះបីជាមានការជំរុញយន្តការនៃការរាយការណ៍ក្នុងទីផ្សារយ៉ាងណាក្តី។ បញ្ហាប្រឈមសំខាន់មួយ ក្នុងចំណោមបញ្ហាទាំងនេះ គឺតម្រូវការទិន្នន័យពីគ្រប់ភាគីពាក់ព័ន្ធ អាជ្ញាធរ និងក្រុមហ៊ុនឯកជន សម្រាប់កិច្ចសហប្រតិបត្តិការក្នុងការរៀបចំមូលដ្ឋានទិន្នន័យ ដើម្បីឱ្យយន្តការនៃការរាយការណ៍អាចសម្រេចទៅបាន ប្រកបដោយប្រសិទ្ធភាព។

**ឃ. ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព**

**ឃ.១. ការអភិវឌ្ឍគម្រោងលំហូរវិនិយោគសម្រាប់ហិរញ្ញប្បទានប្រកបដោយចីរភាព**

**រៀបចំមូលដ្ឋានទិន្នន័យសម្រាប់គម្រោងប្រកបដោយចីរភាព៖** កម្ពុជាចាំបាច់ត្រូវបង្កើតមូលដ្ឋានទិន្នន័យមជ្ឈការថ្នាក់ជាតិ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិនក្នុងការទទួលបានព័ត៌មានស្តីពីឱកាសវិនិយោគលើគម្រោងវិនិយោគប្រកបដោយចីរភាព។ ក្រសួងបរិស្ថាន រួមជាមួយនឹងក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងធ្វើការសិក្សាបង្កើតមូលដ្ឋានទិន្នន័យសាធារណៈស្តីពី គម្រោងហេដ្ឋារចនាសម្ព័ន្ធនានា។ រាជរដ្ឋាភិបាលកម្ពុជានឹងតាមដានយ៉ាងយកចិត្តទុកដាក់ និងគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់វេទិកាទីផ្សារមូលធនអាស៊ានក្នុងការអភិវឌ្ឍមូលដ្ឋានទិន្នន័យសម្រាប់តំបន់អាស៊ាន។ វេទិកាទីផ្សារមូលធនអាស៊ានគ្រោងនឹងបង្កើតមូលដ្ឋានទិន្នន័យពិស្តារ ដោយរួមបញ្ចូលទាំងមូលដ្ឋានទិន្នន័យនៃផលិតផលនៃគម្រោងប្រកបដោយចីរភាព ដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធនៃគម្រោងលំហូរវិនិយោគរបស់អូស្ត្រាលីនិងនូវែលសេឡង់ (ANZIP)។

**ឃ.២. ការកែសម្រួលយន្តការនៃការរាយការណ៍ ដោយគ្រឹះស្ថានហិរញ្ញវត្ថុ ឱ្យស្របតាមស្តង់ដារអន្តរជាតិ**

**ពង្រឹងស្តង់ដារនៃការរាយការណ៍ប្រកបដោយចីរភាពរបស់សាជីវកម្ម៖** ការរាយការណ៍ពីសកម្មភាពចីរភាពសាជីវកម្មនឹងបង្កើនតម្លាភាព និងពង្រឹងលទ្ធភាពវិនិយោគិនក្នុងការទទួលបានព័ត៌មាន ចាំបាច់អំពីការប្តេជ្ញាចិត្ត និងលទ្ធផលការអនុវត្តរបស់សាជីវកម្ម។ ការរាយការណ៍ពីសកម្មភាពចីរភាពត្រូវបានក្លាយជាបទដ្ឋានគំរូនៅក្នុងប្រទេសជាច្រើន ដោយប្រទេសជាសមាជិកក្នុងតំបន់អាស៊ានចំនួន ៦ (ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងវៀត-ណាម) បានដាក់កាតព្វកិច្ចរាយការណ៍ពីសកម្មភាពចីរភាព និងសេចក្តីណែនាំថ្នាក់ជាតិស្តីពី ការរាយការណ៍[២៩]។ និយ័តករទីផ្សារមូលបត្រនៃប្រទេសក្នុងតំបន់ទាំងនេះ បាននិងកំពុងយកចិត្តទុកដាក់ខ្ពស់លើការរាយការណ៍ពីសកម្មភាពចីរភាពរបស់បណ្តាក្រុមហ៊ុនដែលបានចុះបញ្ជី។

---

[២៨] ប្រភព៖ អង្គការសហប្រជាជាតិ គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ការវិភាគទីផ្សារហិរញ្ញវត្ថុបៃតង និងចីរភាព៖ ការផ្តល់ហិរញ្ញប្បទានដល់កម្ពុជានាអនាគត (បាងកក អង្គការសហប្រជាជាតិ ឆ្នាំ ២០២២)

[២៩] ប្រភព៖ ផែនការយុទ្ធសាស្ត្រសម្រាប់ទីផ្សារមូលធនអាស៊ានប្រកបដោយចីរភាព

ន.ម.ក. កំពុងសិក្សាអភិវឌ្ឍបទប្បញ្ញត្តិស្តីពី ការបង្ហាញព័ត៌មានចីរភាពសាជីវកម្មសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រ ដែលស្របតាមស្តង់ដារអន្តរជាតិ ដូចជា ស្ថាប័នគំនិតផ្តួចផ្តើមការរាយការណ៍សកល (Global Reporting Initiative-GRI) ក្រុមប្រឹក្សាស្តង់ដារគណនេយ្យប្រកបដោយចីរភាព (Sustainability Accounting Standards Board-SASB) និងក្រុមប្រឹក្សាលើកិច្ចការការធ្វើសមាហរណកម្មរបាយការណ៍អន្តរជាតិ (International Integrated Reporting Council-IIRC) សម្រាប់ក្រុមហ៊ុនចុះបញ្ជី។ សមាគមធនាគារនៅកម្ពុជាបានដាក់ចេញសេចក្តីណែនាំផ្អែកលើគោលការណ៍ស្ម័គ្រចិត្តស្តីពី គំនិតផ្តួចផ្តើមហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា។ ធនាគារជាតិនៃកម្ពុជានឹងជំរុញបទដ្ឋានរាយការណ៍ស្តីពី សកម្មភាពចីរភាពនេះ។ នៅក្នុងរយៈពេលខ្លីដល់មធ្យម ធនាគារជាតិនៃកម្ពុជា ន.ម.ក. និងផ្សារមូលបត្រកម្ពុជានឹងចូលរួមគាំទ្រកសាងសមត្ថភាពសហគ្រាសសាជីវកម្មលើការរាយការណ៍សកម្មភាពចីរភាព។

ក្រោមជំនួយបច្ចេកទេសពី WB អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារបានដាក់ចេញប្រកាសស្តីពី ការបង្ហាញព័ត៌មានចីរភាពដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០២៤នេះ។ គោលបំណងនៃប្រកាសនេះ គឺដើម្បីលើកកម្ពស់ការរាយការណ៍របស់ក្រុមហ៊ុនចុះបញ្ជីក្នុងទីផ្សារមូលបត្រស្តីពី ការអនុវត្តសកម្មភាពពាក់ព័ន្ធសង្គម បរិស្ថាន និងអភិបាលកិច្ច ដើម្បីធានាបាននូវតម្លាភាព ការប្រៀបធៀប និងគណនេយ្យភាពលើហានិភ័យផ្សេងៗដែលអាចកើតមានឡើងពីបរិស្ថាន ឬ សហគមន៍ដែលក្រុមហ៊ុនចុះបញ្ជីទាំងនោះកំពុងមានប្រតិបត្តិការ និងជំរុញការអនុវត្តអភិបាលកិច្ច និងបទដ្ឋានសង្គមល្អ។

**ឃ.៣. ការកសាងសមត្ថភាព និងការពង្រីកការយល់ដឹងអំពីហិរញ្ញវត្ថុប្រកបដោយចីរភាព**

**ផ្តល់ជំនួយបច្ចេកទេសដល់អ្នកគ្រប់គ្រង៖** សមាគមធនាគារនៅកម្ពុជាបាននិងកំពុងរៀបចំសិក្ខាសាលាជាច្រើនលើប្រធានបទនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រកបដោយចីរភាព និងតម្រូវការ ESG សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ន.ម.ក. ក៏បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពាក់ព័ន្ធនឹងការបោះផ្សាយលក់និងវិនិយោគលើសញ្ញាបណ្ណប្រកបដោយចីរភាពជាប្រចាំផងដែរ។ ធនាគារជាតិនៃកម្ពុជានឹងបន្តចូលរួមសហការជាមួយដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធនានាក្នុងការសម្របសម្រួលឱ្យមានសិក្ខាសាលាលក្ខណៈបច្ចេកទេសឱ្យបានកាន់តែច្រើន នាពេលអនាគត។ សិក្ខាសាលានិងវគ្គបណ្តុះបណ្តាលទាំងនេះ គួរតែផ្តោតអាទិភាពជាបឋមទៅដល់អ្នកគ្រប់គ្រងនៃបណ្តាភាគីពាក់ព័ន្ធ។ ចំពោះធនាគារជាតិនៃកម្ពុជា និង ន.ម.ក. សិក្ខាសាលាគួរផ្តោតសំខាន់ទៅលើការត្រួតពិនិត្យ ឧត្តមានុវត្តន៍អន្តរជាតិ និងការសិក្សាបទពិសោធន៍នៅក្រៅប្រទេសជាដើម។ សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្ម ដូចជា ក្រុមហ៊ុនដែលបានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជានិងក្រុមហ៊ុនបោះផ្សាយសក្តានុពល ជំនួយបច្ចេកទេសគួរផ្តោតសំខាន់ទៅលើហានិភ័យទាក់ទងនឹងការអនុវត្តតាមបទដ្ឋានផលិតផលចីរភាព តម្រូវការរាយការណ៍សម្រាប់សាជីវកម្ម ការចាំបាច់និងតម្រូវការរបស់សហគ្រាសធុនតូចនិងមធ្យម។ វិនិយោគិនស្ថាប័ន ក៏ជាភាគីត្រូវទទួលការបណ្តុះបណ្តាលផងដែរ ជាពិសេសលើបទដ្ឋានមូលនិធិការវិនិយោគប្រកបដោយទំនួលខុសត្រូវ និងការបញ្ចូលកត្តាបរិស្ថាន សង្គម និងអភិបាលកិច្ចទៅក្នុងដំណើរការបែងចែកការវិនិយោគរបស់ខ្លួន។

**បង្កើនការយល់ដឹងរបស់សាធារណជនអំពីហិរញ្ញវត្ថុប្រកបដោយចីរភាព៖** ការយល់ដឹងរបស់សាធារណជនទូទៅអំពីហិរញ្ញវត្ថុប្រកបដោយចីរភាពនឹងត្រូវបានលើកកម្ពស់តាមរយៈកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់សមាគម និងអាជ្ញាធរពាក់ព័ន្ធ ដូចជា ធនាគារជាតិនៃកម្ពុជា និង ន.ម.ក.។ ការប្រែប្រួលអាកាសធាតុក៏ជះឥទ្ធិពលដល់សាធារណជនទូទៅ ដោយការបាត់បង់ទ្រព្យសម្បត្តិ និងការធ្លាក់ចុះកម្រិតជីវភាពប្រចាំថ្ងៃ ដែលទាមទារនូវការទទួលបានការយល់ដឹងអំពីការចូលរួមនៃកិច្ចអន្តរាគមន៍ទាំងថ្នាក់ជាតិនិងអន្តរជាតិ ព្រមទាំងគម្រោងនៃការកាត់បន្ថយនិងការពារការប្រែប្រួលអាកាសធាតុ។ ន.ម.ក. នឹងសហការបន្ថែម ជាមួយវេទិកាទីផ្សារមូលធនអាស៊ាន ដើម្បីរៀបចំកម្មវិធីផ្សព្វផ្សាយហិរញ្ញវត្ថុប្រកបដោយចីរភាព និងយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងដល់សាធារណជន។

ការរៀបចំកម្មវិធីបង្ហាញនិងវេទិកាហិរញ្ញវត្ថុប្រកបដោយចីរភាពប្រចាំឆ្នាំ គឺជាវិធីមួយផ្សេងទៀតនៃការផ្សព្វផ្សាយអំពីឱកាសនៃហិរញ្ញវត្ថុប្រកបដោយចីរភាព ផលិតផលវិនិយោគសម្រាប់វិនិយោគិនរាយ និងកម្រិតស្ថាប័នផងដែរ។ ន.ម.ក. និងធនាគារជាតិនៃកម្ពុជានឹងសិក្សារៀបចំកម្មវិធីផ្សព្វផ្សាយ ដោយសហការជាមួយដៃគូភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ពីជំនាញលើប្រធានបទ និងជំនាញផ្សព្វផ្សាយ និងការអប់រំ។

**សម្របសម្រួលក្នុងការផ្ទេរចំណេះដឹង៖** សមាគមធនាគារនៅកម្ពុជាបានផ្សព្វផ្សាយគោលការណ៍និងសេចក្ដីណែនាំស្ដីពី ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅលើគេហទំព័ររបស់ខ្លួន។ ចំណែកឯ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរ-ភាព ក៏បានរៀបចំការបោះពុម្ពផ្សព្វផ្សាយសំខាន់ៗស្ដីពី ហិរញ្ញប្បទានពាក់ព័ន្ធអាកាសធាតុ ដូចជា ការត្រួតពិនិត្យ និងវាយតម្លៃលើការចំណាយផ្សេងៗពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ និងផែនការប្រចាំឆ្នាំទាក់ទងនឹងហិរញ្ញប្ប-ទានអាកាសធាតុ ប៉ុន្តែមិនមានមជ្ឈមណ្ឌលចំណេះដឹងរួម ដើម្បីរក្សាទុកព័ត៌មានស្ដីពី ហិរញ្ញវត្ថុប្រកបដោយចីរភាពទេ។ ធនាគារជាតិនៃកម្ពុជានឹងសិក្សារៀបចំមជ្ឈមណ្ឌលចំណេះដឹងរួមដែល ដើរតួនាទីជាបណ្ណាល័យរក្សាទុកអត្ថបទស្រាវជ្រាវ អត្ថបទភាពជាអ្នកដឹកនាំសេចក្ដីណែនាំស្ដីពី ការរាយការណ៍សម្រាប់សាជីវកម្ម និងសេចក្ដីប្រកាសព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

**ឃ.៤. ជំរុញការចេញផ្សាយសញ្ញាបណ្ណតាមវិស័យ (Thematic Bonds) ក្នុងប្រទេសកម្ពុជា**

**បោះផ្សាយសញ្ញាបណ្ណបៃតងរបស់រដ្ឋាភិបាល៖** រាជរដ្ឋាភិបាលកម្ពុជានឹងសិក្សាអំពីការបោះផ្សាយលក់សញ្ញាបណ្ណតាមវិស័យ (Thematic Bonds) ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដូចជា ADB និង WB ជាដើម។ ការសិក្សានេះនឹងធ្វើឡើងបន្ថែមពីលើបទពិសោធន៍ដែលទទួលបានពីការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋាភិបាល ព្រមទាំងការបោះផ្សាយសញ្ញាបណ្ណតាមវិស័យ ដែលបោះផ្សាយដោយវិស័យឯកជននៅកម្ពុជា។ ក្នុងចំណោមសញ្ញាបណ្ណទាំងនោះ សញ្ញាបណ្ណបៃតងជាប្រភេទសញ្ញាបណ្ណដែលពេញនិយមបំផុតសម្រាប់ហិរញ្ញប្បទានប្រកបដោយចីរភាពដោយបច្ចុប្បន្នមានទំហំច្រើនជាង ១ ទ្រីលាន ដុល្លារអាម៉េរិកនៅទូទាំងពិភពលោក។ តម្រូវការសញ្ញាបណ្ណបៃតងនៅកម្ពុជាមានការកើនឡើងកាន់តែច្រើន[៣] ខណៈដែលលំហូរវិនិយោគនៃគម្រោងប្រកបដោយចីរភាពដែលអាចវិនិយោគបាន មានការរីកសុះសាយច្រើននៅកម្ពុជា។ ការបោះផ្សាយលក់សញ្ញាបណ្ណបៃតងរបស់រាជរដ្ឋាភិបាលមិនត្រឹមតែជួយដល់ការផ្ដល់ហិរញ្ញប្បទានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចផ្ដល់សន្ទនីយភាពកាន់តែច្រើនទៅក្នុងទីផ្សារសញ្ញាបណ្ណដែលកំពុងរីកចម្រើនផងដែរ។ ការបោះផ្សាយលក់សញ្ញាបណ្ណតាមវិស័យរបស់រដ្ឋាភិបាលនឹងក្លាយជាគំរូសម្រាប់អ្នកបោះផ្សាយផ្សេងៗទៀតដែលមានចំណាប់អារម្មណ៍លើការបោះផ្សាយស្រដៀងគ្នានេះ។ សញ្ញាបណ្ណតាមវិស័យផ្សេងៗទៀត ក៏ទទួលបានការចាប់អារម្មណ៍ពីបណ្ដាវិនិយោគិននៅក្នុងប្រទេសផ្សេងទៀតនៅក្នុងតំបន់អាស៊ាន និងបានគាំទ្រដោយប្រយោលនូវការចាប់ផ្ដើមអនុវត្តសកម្មភាពចីរភាពនៅកម្ពុជា។ ជាក់ស្ដែង សញ្ញាបណ្ណសម្រាប់គម្រោងស្តារជីវភាពស្ត្រី SSB ដែលបោះផ្សាយលក់ដោយ Investment Exchange (IIX) នៅប្រទេសសិង្ហបុរីបានផ្ដល់កម្ចីទៅកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។

**លើកទឹកចិត្តឱ្យមានការសម្រួលក្នុងដំណើរការនៃការបោះផ្សាយលក់សញ្ញាបណ្ណតាមវិស័យ៖** សញ្ញាបណ្ណបៃតងរបស់ក្រុមហ៊ុនសាជីវកម្មដំបូងគេនៅកម្ពុជាបានបោះផ្សាយដោយក្រុមហ៊ុនអចលនទ្រព្យ និងត្រូវបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា នាខែ មករា ឆ្នាំ ២០២៣។ ការបោះផ្សាយលក់សញ្ញាបណ្ណនេះ ប្រមូលទុនបានចំនួន ៦ ប៊ីលានរៀល (ប្រមាណជា ១,៥ លានដុល្លារអាម៉េរិក)។ នាក្នុងឆ្នាំដដែល ក្រុមហ៊ុនទូរគមនាគមន៍ដ៏ធំមួយ បានបោះផ្សាយលក់នូវប្រភេទសញ្ញាបណ្ណតាមវិស័យ ដែលមានឈ្មោះថាសញ្ញាបណ្ណចីរភាព ប្រមូលទុន ចំនួន ៨២,៥ ប៊ីលានរៀល (ប្រមាណជា ២០ លានដុល្លារអាម៉េរិក) ខណៈដែលឆ្នាំ ២០២៤ តំបន់សេដ្ឋកិច្ចពិសេសបានបោះផ្សាយលក់សញ្ញាបណ្ណ

---

[៣] ការស្ទង់មតិលើទីផ្សារមូលបត្របៃតងសម្រាប់កម្ពុជា របស់ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០២២

ប្រភេទនេះ និងប្រមូលទុន ៥០ ប៊ីលានរៀល (ប្រមាណជាជិត ១០ លានដុល្លារអាម៉េរិក)។ សញ្ញាបណ្ណបៃតងត្រូវបានបោះផ្សាយ និងចុះបញ្ជីដោយមានជំនួយបច្ចេកទេសពី ADB ដែលស្របតាមស្តង់ដារសញ្ញាបណ្ណបៃតងអាស៊ាន (ASEAN Green Bonds Standards)[៧] និង ICMA។ ទន្ទឹមនឹងនេះ ការបោះផ្សាយសញ្ញាបណ្ណបៃតង និងសញ្ញាបណ្ណចីរភាព ក៏ទទួលបានជំនួយបច្ចេកទេសពី ESCAP និង GGGI ផងដែរ។ ការបោះផ្សាយនេះជាកាតាលីករជំរុញការបោះផ្សាយសញ្ញាបណ្ណតាមវិស័យកាន់តែច្រើនថែមទៀត។ ការស្ទាបស្ទង់មតិអំពីទីផ្សារសញ្ញាបណ្ណបៃតងនៅកម្ពុជាបានបង្ហាញថា ក្រុមហ៊ុនបោះផ្សាយត្រូវការជាចាំបាច់នូវការឧបត្ថម្ភធន ដើម្បីស្វែងរកអ្នកជំនាញវាយតម្លៃឯករាជ្យដើម្បីបញ្ជាក់ពីអនុលោមភាពតាមស្តង់ដាសញ្ញាបណ្ណបៃតង។ ទន្ទឹមនេះ ន.ម.ភ. ក៏សិក្សាស្វែងរកវិធីដើម្បីកាត់បន្ថយចំណាយក្នុងការបោះផ្សាយសញ្ញាបណ្ណតាមវិស័យ និងផ្តល់ការលើកទឹកចិត្តផ្សេងៗផងដែរ។ ការលើកទឹកចិត្តដែលប្រទេសមួយចំនួនក្នុងតំបន់អាស៊ានកំពុងយកមកប្រើប្រាស់ មានដូចជា ការទូទាត់សងត្រឡប់វិញលើថ្លៃសេវាចុះបញ្ជី ការចំណាយលើការចាត់ថ្នាក់ឥណទាន ការគាំទ្រផ្នែកច្បាប់ ការចំណាយលើថ្លៃសេវាពីអ្នកជំនាញវាយតម្លៃឯករាជ្យ និងការចំណាយពាក់ព័ន្ធផ្សេងៗទៀត។ វិធីសាស្ត្រផ្សេងៗទៀតដែលអាចយកមកពិចារណាបានគឺការសិក្សាលើការរៀបចំដំណើរការនិងរចនាសម្ព័ន្ធនៃការបោះផ្សាយសញ្ញាបណ្ណក្នុងទម្រង់ជាជំនួយបច្ចេកទេស។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១៥។***

[៧] ប្រភព៖ គេហទំព័រភ្នំពេញប៉ុស្តិ៍

## V. យុទ្ធសាស្ត្រផ្នែកព័ត៌មាន អប់រំ និងទំនាក់ទំនង

### ក. ទិដ្ឋភាពទូទៅ

វិស័យហិរញ្ញវត្ថុនៅកម្ពុជាបានឆ្លងកាត់ការវិវត្តន៍គួរឱ្យកត់សម្គាល់ ដោយសារកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរ របស់រាជរដ្ឋាភិបាលកម្ពុជា និងការអនុវត្តផែនការសកម្មភាពនានាដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ហិរញ្ញវត្ថុ។ ទោះយ៉ាងណាវិស័យហិរញ្ញវត្ថុនៅតែមានបញ្ហាប្រឈមទាក់ទងនឹងភាពមានកម្រិតនៃចំណេះដឹងហិរញ្ញវត្ថុ ទីផ្សារហិរញ្ញវត្ថុ ផលិតផល និងសេវាដែលមាននៅលើទីផ្សារ។ ក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹង បញ្ហាប្រឈមទាំងនេះ យុទ្ធសាស្ត្រទំនាក់ទំនងត្រឹមត្រូវមិនត្រឹមតែមានសារៈសំខាន់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចកាន់តែប្រសើរទៀតផង។

### ខ. ការកែទម្រង់ និងសមិទ្ធផល

យុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ ២០១៩-២០២៥ គឺជាឯកសារលម្អិតគ្រប់ជ្រុងជ្រោយមួយដែលបង្ហាញ អំពីគម្រោងផ្តួចផ្តើមនានា អមដោយផែនការសកម្មភាព សំដៅសម្រេចឱ្យបានគោលដៅកំណត់។ ឯកសារនេះក៏ បានគូសបញ្ជាក់ពីសកម្មភាពអាទិភាពចំនួន ៦ សម្រាប់ជាជំនួយដល់ភាគីពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាប្រឈម ក្នុងសកម្មភាពលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ភាគីពាក់ព័ន្ធដែលទទួលខុសត្រូវលើការអនុវត្តបានចាប់ផ្តើមអនុវត្ត គំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់សម្រាប់វិស័យអាទិភាពទាំងនេះ។

- ន.ធ.ក.គ្រោងនឹងបង្កើតវិទ្យាស្ថានធានារ៉ាប់រងកម្ពុជា ដែលជាផ្នែកមួយនៃគោលដៅរយៈពេលខ្លីនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជាឆ្នាំ ២០២១-២០៣០ សម្រាប់ផ្តល់ការបណ្តុះបណ្តាល វិជ្ជាជីវៈដល់អន្តរការីធានារ៉ាប់រងដូចជា ជើងសា និងភ្នាក់ងារធានារ៉ាប់រងជាដើម ដែលលទ្ធភាពបង្កើត វិទ្យាស្ថាននេះកំពុងត្រូវបានសិក្សានិងរៀបចំ។ ក្រុមហ៊ុនធានារ៉ាប់រង និងសមាគមធានារ៉ាប់រងកម្ពុជាបានរៀបចំ វគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកក្នុងវិស័យធានារ៉ាប់រង។ ទិវាធានារ៉ាប់រងកម្ពុជាត្រូវបានប្រារព្ធធ្វើឡើង ជារៀងរាល់ឆ្នាំ ហើយវីដេអូផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃសេវាធានារ៉ាប់រងត្រូវបាន ចែកចាយយ៉ាងទូលំទូលាយជាប្រចាំនៅក្នុងបណ្តាញទំនាក់ទំនងសង្គម។ ន.ធ.ក. មានគោលបំណងបន្តអនុវត្ត កម្មវិធីរបស់ខ្លួន ក្នុងគោលដៅលើកកម្ពស់ការយល់ដឹង និងចំណេះដឹងផ្នែកធានារ៉ាប់រង។
- ន.ម.ក. ក៏បានរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលដែលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យ មូលបត្រផងដែរ។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងជាពិសេសសម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ក្រុម-ហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ ការអនុញ្ញាត និង/ឬ ការទទួលស្គាល់ដោយ ន.ម.ក. ដើម្បីអាចប្រកបការងារ ក្នុងវិស័យមូលបត្រ។ ទន្ទឹមនេះ អ្នកដែលបានប្រឡងជាប់ ត្រូវតែចូលរួមវគ្គបណ្តុះបណ្តាលគុណវុឌ្ឍិបន្តរៀង រាល់ ២ ឆ្នាំម្តង ដើម្បីរក្សាសុពលភាពគុណវុឌ្ឍិ។ វគ្គទាំងនោះរួមមាន៖ វគ្គសិក្សារយៈពេលខ្លីនិងវគ្គសិក្សាកម្រិត ខ្ពស់ ដែលគ្របដណ្តប់លើមូលដ្ឋាននៃការជួញដូរមូលបត្រ ការអនុវត្តជាក់ស្តែង បញ្ហាប្រឈម និងបទ-ប្បញ្ញត្តិនានា។ ន.ម.ក. មានភារកិច្ចទទួលខុសត្រូវលើការផ្សព្វផ្សាយចំណេះដឹងហិរញ្ញវត្ថុ ការអប់រំវិនិ-យោគិន និងការរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលជាច្រើន។
- ទោះបីកិច្ចដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ស្ថិតក្នុងបរិបទនៃសេដ្ឋកិច្ចសាកលដែលមាន ភាពមិនប្រាកដប្រជា វិបត្តិជំងឺឆ្លងនិងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយយ៉ាងណាក្តី សម្រាប់ការអភិវឌ្ឍ វិស័យបរធនបាលកិច្ច ន.ប.ធ. នៅតែបន្តអនុវត្តបេសកកម្មចម្បងរបស់ខ្លួនស្របតាមផែនការអភិវឌ្ឍ វិស័យបរធនបាលកិច្ចយ៉ាងសកម្មពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីវិស័យបរធន-បាលកិច្ចដល់តួអង្គពាក់ព័ន្ធនៅក្នុងទីផ្សារ។ ចាប់តាំងពី ន.ប.ធ. និងវិស័យបរធនបាលកិច្ច ត្រូវបានបង្កើតក្នុង គោលដៅជំរុញការយល់ដឹងពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ន.ប.ធ. បានផ្តោតជាសំខាន់លើការបណ្តុះ-បណ្តាលដល់គ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច រួមមាន៖

- ការអប់រំវិនិយោគិន សមាគមធុរកិច្ចជាតិនិងអន្តរជាតិនៅកម្ពុជា អ្នកសារព័ត៌មាន គ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងសាធារណជន ព្រមទាំងស្ថាប័នរដ្ឋ/ឯកជន ធនាគារ ឬ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបុគ្គលពាក់ព័ន្ធដទៃទៀតដល់ទីកន្លែង និង/ឬ តាមប្រព័ន្ធអនឡាញ
- ការបណ្តុះបណ្តាលដល់ក្រុមហ៊ុនបរធនបាល និងបុគ្គលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច
- វេទិកា និង/ឬ សន្និសីទស្តីពី វឌ្ឍនភាព បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរធនបាលកិច្ច ដែលកម្មវិធីនេះ បានបើកឱកាសឱ្យសាធារណជន ក្រុមហ៊ុន និងស្ថាប័ន ពាក់ព័ន្ធនានាទទួលបានព័ត៌មាន និងចំណេះដឹងបន្ថែមស្តីពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច
- ការបណ្តុះបណ្តាលសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ និង
- ការបណ្តុះបណ្តាលសម្រាប់ការអប់រំវិជ្ជាជីវៈបន្ត។

កន្លងមក ទោះបី ន.ប.ធ. បានផ្តោតសំខាន់លើការជំរុញការយល់ដឹងអំពីវិស័យបរធនបាលកិច្ចដល់សាធារណជន ន.ប.ធ. ក៏តែងជួបប្រទះនឹងបញ្ហាប្រឈម ដោយភាគីពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច នៅតែមិនទាន់យល់ច្បាស់អំពីវិស័យបរធនបាលកិច្ចនៅឡើយ។ ក្នុងន័យនេះ ន.ប.ធ. ត្រូវបន្តពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងបន្ថែមពីវិស័យបរធនបាលកិច្ចឱ្យបានកាន់តែទូលំទូលាយទៅដល់ធុរជន សមាគមធុរកិច្ច អ្នកសារព័ត៌មាន គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល និងអាកាដេមិក សាធារណជន និងតួអង្គពាក់ព័ន្ធផ្សេងទៀតក្នុងក្របខ័ណ្ឌទូទាំងរាជធានី-ខេត្ត។

### គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ

បញ្ហាប្រឈមមួយចំនួនដែលវិស័យហិរញ្ញវត្ថុបន្តជួបប្រទះទាក់ទងនឹងចំណេះដឹង និងការយល់ដឹងផ្នែកហិរញ្ញវត្ថុមានដូចខាងក្រោម៖

- **កម្រិតទាបនៃបរិយាបន្នហិរញ្ញវត្ថុនៅជនបទ៖** អត្រាបរិយាបន្នហិរញ្ញវត្ថុនៅទីក្រុងនៅកម្ពុជាមាន ៧៤% ក្នុងចំណោមមនុស្សពេញវ័យ គឺខ្ពស់ជាងនៅជនបទ ដែលមានអត្រាបរិយាបន្ន ៦៩% ក្នុងចំណោមមនុស្សពេញវ័យ[២៩]។ ទោះបីជាប្រជាជនរស់នៅតាមជនបទមានដល់ទៅ ៧៥% នៃចំនួនប្រជាជនសរុប[៣០] គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការបានដាក់ទីតាំងបណ្តាញប្រតិបត្តិការសំខាន់របស់ខ្លួនតែនៅតំបន់ជិតទីប្រជុំជនក្នុងក្រុងប៉ុណ្ណោះ។ បណ្តាញប្រតិបត្តិការទាំងនោះរួមមាន សាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ម៉ាស៊ីនឆូតកាត និងសេវាធនាគារអេឡិចត្រូនិក។ សម្រាប់ប្រជាជនរស់នៅតំបន់ជនបទដែលចង់ទទួលសេវាហិរញ្ញវត្ថុ ពួកគេត្រូវធ្វើដំណើរឆ្ងាយពីទីតាំងរស់នៅ ដែលត្រូវចំណាយពេល និងថវិកាបន្ថែម។
- **ការយល់ដឹង និងការប្រើប្រាស់ផលិតផលហិរញ្ញវត្ថុក្នុងចំណោមសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) នៅមានកម្រិត៖** MSMEs ដើរតួនាទីយ៉ាងសំខាន់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចដោយសារ MSMEs តំណាងប្រមាណ ៩០% នៃសហគ្រាសទាំងអស់ ហើយបានផ្តល់ការងារដល់ទៅជិត ៧០% នៃកម្លាំងពលកម្មសរុប និងរួមចំណែកដល់ទៅជាងពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុប។ ទោះយ៉ាងណា សហគ្រាសធុនតូច និងមធ្យម (SMEs) ៩៥% នៅមិនទាន់បានចុះបញ្ជីត្រឹមត្រូវនៅឡើយ។ ការមិនបានចុះបញ្ជីត្រឹមត្រូវបង្កផលលំបាកដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការផ្តល់សេវាហិរញ្ញវត្ថុដល់ SMEs រួមទាំង ធនាគារសហគ្រាសធុនតូច និងមធ្យម ដែលបង្កើតឡើងដើម្បីបំពេញតម្រូវការឥណទានដល់ SMEs និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ លើសពីនេះ SMEs អាចមិនមានរបាយការណ៍ហិរញ្ញវត្ថុសមស្រប ដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យឥណទានពីគ្រឹះស្ថានផ្តល់ឥណទាន។ ហេតុផលចម្បងដែល SMEs មិនបានចុះបញ្ជី និងមិនអាន

[២៩] ប្រភព៖ យុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុ (UNSCAP)
[៣០] ប្រភព៖ ទិន្នន័យរបស់ WB

របាយការណ៍ហិរញ្ញវត្ថុសមស្រប គឺដោយសារការភ័យខ្លាចជាប់កាតព្វកិច្ចពន្ធបន្ថែម។ ក្រសួងពាណិជ្ជកម្ម បានកំណត់ឱ្យប្រតិបត្តិការអាជីវកម្មអនឡាញត្រូវចុះបញ្ជី ឱ្យបានមុនថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២២ ដោយបញ្ជាក់ថានឹងដាក់ពិន័យចំពោះអ្នកយឺតយ៉ាវ ហើយក្រសួងនៅបន្តខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការលើកកម្ពស់ប្រសិទ្ធភាពប្រព័ន្ធស្វ័យប្រវត្តិកម្មនេះសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម។ ការចុះបញ្ជីអាជីវកម្មក៏អាចធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យ (CamDX) ដែលជាថ្នាលឌីជីថល ដើម្បីចុះបញ្ជីពាណិជ្ជកម្ម និងសុំអាជ្ញាប័ណ្ណអាជីវកម្មបានដោយប្រសិទ្ធភាពពីក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមមានក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

- **បុគ្គលភាគច្រើនប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ ១ ឬ ២ ប្រភេទ៖** ៦១% នៃមនុស្សពេញវ័យដែលប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការនិងសេវាហិរញ្ញវត្ថុតែមួយប្រភេទប៉ុណ្ណោះនៅក្នុងឆ្នាំ ២០២១ ហើយមានតែ ៣% ប៉ុណ្ណោះដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ ៤ ប្រភេទ[៣១]។ នេះបង្ហាញថាមានមនុស្សតិចតួចប៉ុណ្ណោះដែលទទួលបានប្រយោជន៍ពីការប្រើប្រាស់ប្រភេទសេវាកម្មហិរញ្ញវត្ថុដ៏សំបូរបែប។ បុគ្គលខ្លះបានបំពេញតម្រូវការហិរញ្ញវត្ថុរបស់ពួកគេដោយមិនប្រើប្រាស់សេវាហិរញ្ញវត្ថុពីគ្រឹះស្ថានផ្លូវការនោះទេ ហើយជំនួសវិញដោយការពឹងលើគ្រួសារ និងមិត្តភក្តិសម្រាប់ការខ្ចីប្រាក់ ឬសន្សំ ដែលអាចប៉ះពាល់ប្រសិទ្ធភាពនៃការរីកចម្រើននៃវិស័យនេះ។
- **ការប្រើប្រាស់ឧបករណ៍គម្រោងវិនិយោគរួមនៅមានកម្រិត៖** ការប្រើប្រាស់ឧបករណ៍វិនិយោគរួមនៅកម្ពុជានៅមានកម្រិត ដោយសារប្រជាជនមានការយល់ដឹងតិចតួចបំផុតអំពីឧបករណ៍វិនិយោគទាំងនេះ។ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃឧបករណ៍វិនិយោគ និងសារៈសំខាន់របស់ឧបករណ៍ទាំងនេះសម្រាប់ជាមធ្យោបាយសន្សំសម្រាប់អនាគតអាចផ្តល់អត្ថប្រយោជន៍ច្រើនដល់គម្រោងវិនិយោគរួម ការធានារ៉ាប់រងអាយុជីវិត ប្រាក់សោធននិវត្តន៍ និងកម្មវិធីផ្សេងៗទៀត។

ទោះបីវិស័យបរធនបាលកិច្ចមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក៏ប៉ុន្តែវិស័យនេះ ហាក់នៅជាសញ្ញាណថ្មីនៅឡើយ ដែលទាមទារឱ្យត្រូវមានការយកចិត្តទុកដាក់បន្ថែមក្នុងការពង្រឹង និងបណ្តុះបណ្តាលសមត្ថភាពជំនាញបន្ថែម ដើម្បីពង្រឹងនូវសមត្ថភាពធនធានមនុស្សនៅក្នុងវិស័យនេះឱ្យកាន់តែមានប្រសិទ្ធភាព និងដើម្បីឆ្លើយតបនឹងទំហំ និងតម្រូវការការងារនាពេលអនាគត។ ស្ថិតក្នុងដំណាក់កាលបញ្ជ្រាបការយល់ដឹងអំពីវិស័យបរធនបាលកិច្ច យន្តការសម្របសម្រួលអន្តរស្ថាប័ន-អង្គភាព របស់និយ័តករ ប្រតិបត្តិករ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត នៅមិនទាន់មានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយនៅឡើយ ដោយសារស្ថាប័នរដ្ឋ និងឯកជនមួយចំនួននៅមិនទាន់យល់ដឹងច្បាស់អំពីវិស័យបរធនបាលកិច្ច និងសារៈសំខាន់នៃប្រតិបត្តិការបរធនបាលកិច្ចនៅឡើយ ជាហេតុទាមទារនូវពេលវេលាបន្ថែមក្នុងការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង។ ជារួម វិស័យបរធនបាលកិច្ចហាក់មិនទាន់មានវិសាលភាពនៃការយល់ដឹងទូលំទូលាយនៅឡើយទេ ដោយសារ៖ i/-ការចូលរួមពីតួអង្គពាក់ព័ន្ធនៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ii/-ការយកចិត្តទុកដាក់ពីសាធារណជនលើវិស័យនេះនៅមានកម្រិត និង iii/-ការផ្សព្វផ្សាយនៅមិនទាន់មានភាពគ្រប់គ្រាន់និងគ្របដណ្តប់បានទូលំទូលាយនៅឡើយ។

## ឃ.ផែនការយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រផ្នែកព័ត៌មាន អប់រំ និងទំនាក់ទំនងសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីផលិតផលនិងសេវាហិរញ្ញវត្ថុនានា សំដៅបង្កើនវិសាលភាពនៃការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុទាំងនោះ និងជំរុញកំណើននៃវិស័យហិរញ្ញវត្ថុ។ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារបានកត់សម្គាល់ឃើញមានឧបសគ្គជាក់លាក់ ហើយវិធានការដោះស្រាយកម្រិតយុទ្ធសាស្ត្រនឹងត្រូវ

[៣១] ប្រភព៖ ឯកសារ MAP

បានអនុវត្ត។ ជាងនេះទៀត អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារក៏ប្ដេជ្ញាចំពោះការបង្កើនការកៀរគរទុនបន្ថែមលើវឌ្ឍនភាពដែលសម្រេចបាននាពេលបច្ចុប្បន្ន។

**ឃ.១. លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងបង្កើនការយល់ដឹងពីផលិតផលហិរញ្ញវត្ថុដល់សាធារណជន**

**បញ្ចូលខ្លឹមសារទាក់ទងនឹងហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សា៖** ការបញ្ចូលទស្សនទានហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សានឹងជួយបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់កុមារ និងយុវជន ព្រមទាំងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ការណ៍នេះនឹងជួយពង្រឹងសមត្ថភាពយល់ដឹងអំពីទស្សនទានពាក់ព័ន្ធនឹងហិរញ្ញវត្ថុផ្ទាល់ខ្លួន ក្នុងដំណើរការនៃការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់។ ធនាគារជាតិនៃកម្ពុជា និងក្រសួងអប់រំ យុវជន និង កីឡា បានចាប់ផ្តើមធ្វើការងារនេះ និងបានអនុវត្តគម្រោងសំខាន់ៗ ដែលមានគោលបំណងបញ្ចូលការអប់រំផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ។ អ.ស.ហ. នឹងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំដាក់បញ្ចូលមេរៀនកម្រិតមូលដ្ឋានទាក់ទងនឹងការធានារ៉ាប់រង បេឡាសន្តិសុខសង្គម ទីផ្សារមូលបត្រ គណនេយ្យ សវនកម្ម បរធនបាលកិច្ច អចលនទ្រព្យ បញ្ចាំនិងប្រាតិភោគដោយអនុប្បទាន ជាដើម ចូលទៅក្នុងកម្មវិធីសិក្សាសាលាចំណេះទូទៅ។ គ្រឹះស្ថានអប់រំនឹងត្រូវបានលើកទឹកចិត្តឱ្យរៀបចំកម្មវិធីប្រកួតប្រជែងករណីសិក្សា (ដោយផ្អែកលើប្រធានបទពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ) ដើម្បីបង្កើនការយល់ដឹងផ្នែកហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយ ក្នុងចំណោមយុវជនកម្ពុជា។

**ពង្រីកបណ្តាញអន្តរការីហិរញ្ញវត្ថុ និងពង្រឹងបណ្តាញចែកចាយរបស់គ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុ៖** ការពង្រីកវិសាលភាពនៃសេវាហិរញ្ញវត្ថុឱ្យទៅដល់តំបន់ក្រៅទីប្រជុំជន និងជនបទគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងៗរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ គ្រឹះស្ថានផ្តល់សេវានឹងត្រូវណែនាំឱ្យពង្រឹងបណ្តាញអន្តរការីហិរញ្ញវត្ថុរបស់ពួកគេ ដែលរួមមាន ភ្នាក់ងារធានារ៉ាប់រង ឈ្មួញកណ្តាល និងបុគ្គលិកផ្សព្វផ្សាយ ជាដើម ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមស្តីពីការយល់ដឹងនៅមានកម្រិតនៅក្នុងតំបន់ទាំងនេះ។ អន្តរការីទាំងនេះនឹងបំពេញតួនាទីជាអ្នកសម្របសម្រួលក្នុងការធ្វើទំនាក់ទំនងជាមួយអតិថិជន និងការផ្តល់សេវាដល់អតិថិជន។ លើសពីនេះ អន្តរការីទាំងនេះក៏នឹងទទួលបានជំនួយបច្ចេកទេស និងការបណ្តុះបណ្តាល ទាក់ទងនឹងការផ្តល់ការគាំទ្រសមស្រប ក្រោយពេលដែលពួកគេបានលក់សេវាដល់អតិថិជន ព្រមទាំងបង្កើនទំនាក់ទំនងថែមទៀត ដើម្បីបង្កើតឱកាសលក់សេវាឆ្លងវិស័យផង និងក្នុងវិស័យខ្លួនឯងផង។

**អនុវត្តយុទ្ធនាការផ្សព្វផ្សាយទូទៅក្នុងគោលបំណងពង្រឹងការយល់ដឹង និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ៖** សកម្មភាពសិក្សាតាមគម្រោងផ្តួចផ្តើមដែលមានស្រាប់នឹងត្រូវបានវិភាគ ដើម្បីរៀបចំវិធីសាស្ត្រផ្សព្វផ្សាយសមស្រប សម្រាប់ពង្រឹងការយល់ដឹង និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ ប្រព័ន្ធផ្សព្វផ្សាយដែលជាប្រភេទត្រូវបោះពុម្ព ដូចជា សៀវភៅសរសេរ សៀវភៅរូបភាព ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី និងកម្រងអត្ថបទផ្សេងៗ ជាដើម នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនឹងរៀបចំមាតិកាក្នុងខ្លឹមសារផ្សព្វផ្សាយ និងអប់រំពីវិស័យធានារ៉ាប់រងកម្ពុជា វិស័យមូលបត្រកម្ពុជា វិស័យសន្តិសុខសង្គម វិស័យបរធនបាលកិច្ច វិស័យគណនេយ្យនិងសវនកម្ម និងវិស័យអចលនវត្ថុ និងបញ្ចាំដោយប្រតិភោគនិងអនុប្បទាន។ សម្ភារផ្សព្វផ្សាយទាំងនេះនឹងត្រូវបានបោះពុម្ពផ្សាយ និងទុកដាក់យ៉ាងត្រឹមត្រូវសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធយកទៅប្រើប្រាស់ប្រកបដោយភាពងាយស្រួល។ លើសពីនេះ កម្មវិធីកសាងសមត្ថភាព ដូចជា សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ នឹងត្រូវបានរៀបចំ ដើម្បីផ្សព្វផ្សាយអំពីទស្សនទានថ្មីៗទាក់ទងនឹងវិស័យហិរញ្ញវត្ថុ។

**ផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលដើម្បីពង្រីកការយល់ដឹង និងបង្កើនការប្រើប្រាស់ផលិតផលហិរញ្ញវត្ថុ៖** យុទ្ធនាការផ្សព្វផ្សាយទូទៅខាងលើក៏នឹងត្រូវបានបំពេញបន្ថែម ដោយការអនុវត្តគំនិតផ្តួចផ្តើមធ្វើយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលផងដែរ។ ការបង្កើតមាតិកាក្នុងកម្មវត្ថុបង្កើនការយល់ដឹង តាមរូបភាពផ្សព្វផ្សាយពាណិជ្ជកម្ម ភាពយន្តឯកសារ និងវីដេអូខ្លីៗ ព្រមទាំងការផ្សព្វផ្សាយតាមទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គម នឹងជួយបង្កើនការយល់ដឹងកាន់តែទូលំទូលាយអំពីទស្សនទានហិរញ្ញវត្ថុបានមួយកម្រិតថែមទៀត។ សម្ភារផ្សព្វផ្សាយទាំងនេះ នឹងត្រូវបានរៀបចំឱ្យមានច្រើនទម្រង់ សមស្របតាមចរិតលក្ខណៈរបស់ក្រុមគោលដៅ។ ជាងនេះទៀត និយ័តករនឹងលើកទឹកចិត្តក្រុមហ៊ុននានា

ឱ្យបង្កើតនិងច្នៃប្រឌិតកម្មវិធីកម្សាន្តបង្កប់ខ្លឹមសារអប់រំ (ដោយផ្អែកលើការរៀបចំផែនការហិរញ្ញវត្ថុ) ដើម្បីបង្កើនវិសាលភាពប្រើប្រាស់សេវាហិរញ្ញវត្ថុមិនមែនធនាគារថែមទៀត។

**រៀបចំយុទ្ធសាស្ត្រលើកកម្ពស់ចំណេះដឹង និងការយល់ដឹងផ្នែកហិរញ្ញវត្ថុសម្រាប់វិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ៖** ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគម្រោងដែលត្រូវបានស្នើឡើង ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង និងការយល់ដឹងផ្នែកហិរញ្ញវត្ថុនឹងទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ រវាង អ.ស.ហ. និងនិយ័តករដែលស្ថិតក្រោមឱវាទរបស់អាជ្ញាធរនេះ ព្រមទាំងភាគីពាក់ព័ន្ធផ្សេងទៀត។ យុទ្ធសាស្ត្រច្បាស់លាស់មួយព្រមទាំងផែនទីមគ្គុទេសក៍នឹងត្រូវបានរៀបចំឡើង។ បន្ថែមពីនេះ តារាងវិភាគពីភាគីពាក់ព័ន្ធមួយនឹងត្រូវបានបង្កើតឡើងដើម្បីធានាថាភាគីពាក់ព័ន្ធទាំងអស់យល់ដឹងច្បាស់ពីការងារដែលខ្លួនទទួលខុសត្រូវ និងអនុវត្តសកម្មភាពដែលត្រូវបានចាត់តាំង។ គម្រោងស្ទង់មតិបឋមមួយនឹងត្រូវបានអនុវត្ត ដើម្បីវាយតម្លៃកម្រិតយល់ដឹងរបស់សាធារណជនអំពីផលិតផល និងសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ទិន្នន័យវិភាគក្នុងគម្រោងស្ទង់មតិព្រមទាំងឧត្តមានុវត្តន៍ល្អៗ នឹងត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំយុទ្ធសាស្ត្រសមស្រប។ យុទ្ធសាស្ត្រនោះនឹងបង្ហាញពីកម្មវត្ថុនានា ក្រុមគោលដៅសារគន្លឹះ ទិសដៅទំនាក់ទំនង និងវិធីសាស្ត្រវាយតម្លៃ សម្រាប់ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ នៅក្នុងវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ មិនតែប៉ុណ្ណោះ ក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃមួយនឹងត្រូវរៀបចំសម្រាប់វាយតម្លៃវឌ្ឍនភាព និងផលប៉ះពាល់នៃសកម្មភាពអនុវត្តជាក់ស្តែង។ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រនានាគឺការបង្កើតគណៈកម្មាធិការចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធ្វើសកម្មភាពជាក់ស្តែងប្រកបដោយប្រសិទ្ធភាព សំដៅលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ឃ.២. ជំរុញឱ្យមានការរៀបចំផែនការច្បាស់លាស់ ក្នុងចំណោមសហគ្រិន និងសហគ្រាស ព្រមទាំងសម្រួលឱ្យសាធារណជនមានលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុកាន់តែខ្ពស់**

**បង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ SMEs៖** ក្រសួងពាណិជ្ជកម្មនឹងអនុវត្តយុទ្ធសាស្ត្រពហុទិសដៅដើម្បីធានាថា ៨០%-៩៥% នៃចំនួន SMEs នឹងត្រូវបានចុះបញ្ជីពាណិជ្ជកម្ម តាមគោលដៅកំណត់នៅក្នុងគោល-នយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ របស់ប្រទេសកម្ពុជា។ យុទ្ធសាស្ត្រនេះ ទាមទារឱ្យមានសេចក្តីណែនាំសមស្របសម្រាប់ SMEs ទាក់ទងនឹងច្បាប់និងនីតិវិធីចុះបញ្ជី ព្រមទាំងមានសេចក្តីពន្យល់អំពីផ្នែកពន្ធដារផងដែរ។ ក្រៅពីនេះ ក្រសួងពាណិជ្ជកម្មនឹងរៀបចំសិក្ខាសាលា ដើម្បីណែនាំសហគ្រាសធុនតូច និងមធ្យមពីនីតិវិធីចុះបញ្ជីពាណិជ្ជកម្ម។

**ការកសាងសមត្ថភាពសម្រាប់ SMEs និងសហគ្រិន៖** កម្មវិធីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗនឹងត្រូវបានរៀបចំយ៉ាងជាក់លាក់សម្រាប់ SMEs ព្រមទាំងសហគ្រិន។ កម្មវិធីទាំងនេះនឹងត្រូវបានរៀបចំដោយមានប្រធានបទនានា ដូចជា ការរៀបចំផែនការថវិកា ការគ្រប់គ្រងលំហូរសាច់ប្រាក់ ការរៀបចំផែនការហិរញ្ញវត្ថុ កិច្ចព្រមព្រៀងឥណទាន គោលការណ៍គណនេយ្យ បទប្បញ្ញត្តិពន្ធដារ និងប្រធានបទជាច្រើនផ្សេងទៀត។ ក្នុងពិព័រណ៍ពាណិជ្ជកម្មក៏ដូចជាព្រឹត្តិការណ៍ជំរុញពាណិជ្ជកម្មផ្សេងទៀតនឹងត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល ក្នុងទម្រង់ជាវីដេអូអប់រំវគ្គបណ្តុះបណ្តាលខ្លីៗ និងកម្មវិធីកំសាន្តបង្កប់ខ្លឹមសារយល់ដឹង ជាដើម។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១៦។***

## VI. កិច្ចការពារអតិថិជន

### ក. ទិដ្ឋភាពទូទៅ

កិច្ចការពារអតិថិជនគឺជាធាតុផ្សំមួយដ៏ចាំបាច់សម្រាប់រក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសប្រទេសកម្ពុជាដែលមានសេដ្ឋកិច្ចរីកចម្រើនឆាប់រហ័សក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ បន្ទាប់ពីការដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ កិច្ចការជាច្រើនត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល និងនិយ័តករក្នុងវិស័យហិរញ្ញវត្ថុ រួមមាន ធនាគារជាតិនៃកម្ពុជា និងនិយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ យន្តការការពារប្រាក់បញ្ញើរបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងយន្តការការពារវិនិយោគិនរបស់និយ័តករមូលបត្រកម្ពុជា និយ័តករសន្តិសុខសង្គម និងនិយ័តករធានារ៉ាប់រងកិច្ច រួមជាមួយនឹងយន្តការផ្សេងទៀត ដែលបានបង្ហាញក្នុងផ្នែកខាងលើនៃយុទ្ធសាស្ត្រនេះ គឺជាឧទាហរណ៍មួយចំនួននៃគំនិតផ្តួចផ្តើមរបស់បញ្ញត្តិករក្នុងវិស័យហិរញ្ញវត្ថុ។ ទោះបីយ៉ាងនេះក្តី ការអភិវឌ្ឍក្របខ័ណ្ឌកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ នៅមានកម្រិតបើធៀបទៅនឹងការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ។ ការណ៍នេះទាមទារឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចឱ្យបាននូវក្របខ័ណ្ឌកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុដ៏រឹងមាំ។

### ខ. ការកែទម្រង់ និងសមិទ្ធផល

និយ័តករក្នុងវិស័យហិរញ្ញវត្ថុបាននិងកំពុងជំរុញការអភិវឌ្ឍការងារមួយចំនួន ដើម្បីការពារអ្នកប្រើប្រាស់សេវា-ហិរញ្ញវត្ថុ បន្ទាប់ពីយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ត្រូវបានដាក់ឱ្យអនុវត្ត។ របាយការណ៍សិក្សាស្តីពី "ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជា" របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលចេញផ្សាយកាលពីឆ្នាំ ២០១៥ បានផ្តល់នូវអនុសាសន៍សម្រាប់ពង្រឹងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដោយក្នុងនោះ អនុសាសន៍មួយចំនួនត្រូវបានអនុវត្ត ដូចជា៖

#### ខ.១. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ

- ប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០១៧ ដើម្បីបង្កើតនូវយន្តការសម្រាប់ដោះស្រាយបណ្តឹង ដែលទទួលបានពីអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ គិតត្រឹមឆ្នាំ ២០២៤ ធនាគារជាតិនៃកម្ពុជា បានបង្កើតលេខទូរស័ព្ទហតឡាញ (Hotline) ចំនួន ២៦ ខ្សែ នៅទីស្នាក់ការកណ្តាល និងគ្រប់សាខាខេត្តរាជធានី-ខេត្តរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់សម្របសម្រួលដោះស្រាយបណ្តឹងអតិថិជន។ ក្នុងឆ្នាំ ២០២៤ ធនាគារជាតិនៃកម្ពុជាទទួលបានបណ្តឹង និងការសាកសួរព័ត៌មានសរុបចំនួន ៤២៣ ករណី ដែលបណ្តឹងនៅទីស្នាក់ការកណ្តាលមានចំនួន ២៥៦ ករណី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្ត មានចំនួន ១៦៧ ករណី[៣២]។
- ក្រមប្រតិបត្តិ សម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដោយសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យាកម្ពុជា ក្នុងគោលបំណងលើក-កម្ពស់សិទ្ធិរបស់អតិថិជន និងពង្រឹងសុចរិតភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ក្នុងន័យនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តក្រមប្រតិបត្តិនេះ ដោយបច្ចុប្បន្នគ្រឹះស្ថានភាគច្រើនកំពុងចូលរួមអនុវត្តគោលការណ៍នៃក្រមប្រតិបត្តិនេះ។
- វិធានផ្តល់ឥណទានដែលជាការវិវឌ្ឍដ៏សំខាន់មួយក្នុងការពង្រឹងកិច្ចការពារអតិថិជន ត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០១៦ ដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ វិធាននេះត្រូវបានពង្រីកវិសាលភាពអនុវត្តចំពោះគ្រឹះស្ថាន

---

[៣២] ប្រភព៖ https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2024_KHM.pdf.

ធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលដៅកាត់បន្ថយបំណុលលើសលប់និងការទូទាត់បំណុលយឺតយ៉ាវ ដែលបណ្ដាលមកពីការជំពាក់បំណុលពីច្រើនគ្រឹះស្ថាន និងកំណើនឆាប់រហ័សនៃបំណុលគ្រួសារ។

- ប្រកាសស្ដីពី ការកំណត់ពិដានអត្រាការប្រាក់ឥណទាន បានកំណត់អត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទខ្ពស់បំផុតត្រឹម ១៨% ក្នុងមួយឆ្នាំ ក្នុងទិសដៅការពារអតិថិជនពីការគណនាអត្រាការប្រាក់ខ្ពស់ហួសហេតុ។
- ប្រកាសស្ដីពី នីតិវិធីនៃការទទួលនិងដោះស្រាយបណ្ដឹងធានារ៉ាប់រង ត្រូវបានដាក់ឱ្យអនុវត្ត កាលពីឆ្នាំ ២០២០។ ប្រកាសនេះផ្ដល់នូវយន្តការច្បាស់លាស់សម្រាប់ដោះស្រាយបណ្ដឹងវិស័យធានារ៉ាប់រង និងកសាងទំនុកចិត្តសាធារណជនមកលើសេវាធានារ៉ាប់រង។
- ច្បាប់ស្ដីពី កិច្ចការពារអ្នកប្រើប្រាស់ ត្រូវបានដាក់ឱ្យអនុវត្តកាលពីឆ្នាំ ២០១៩ ដោយក្រសួងពាណិជ្ជកម្ម ដើម្បីកំណត់វិធាននិងបទប្បញ្ញត្តិសម្រាប់បង្កើតនូវបរិយាកាសនៃការធ្វើពាណិជ្ជកម្ម ដែលសិទ្ធិនិងអត្ថប្រយោជន៍របស់អតិថិជនត្រូវបានការពារ និងការប្រកួតប្រជែងដោយស្មើភាពគ្នាត្រូវបានរក្សារាល់ពេលធ្វើពាណិជ្ជកម្ម។ ទោះបីយ៉ាងនេះក្ដី ច្បាប់នេះពុំមានវិសាលភាពអនុវត្តចំពោះវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារនោះទេ។
- ក្រសួងពាណិជ្ជកម្មនិងធនាគារជាតិនៃកម្ពុជាបានចេញសេចក្ដីប្រកាសព័ត៌មានរួមស្ដីពី "ការអនុវត្តច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្ដីពី ខសន្យាមិនសុចរិត ក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ" ក្នុងគោលដៅលើកកម្ពស់ស្ថិរភាពសេដ្ឋកិច្ច និងធានាថាសិទ្ធិរបស់អតិថិជនត្រូវបានការពារ។ គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានណែនាំឱ្យធ្វើប្រតិបត្តិការស្របតាមច្បាប់ស្ដីពី កិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្ដីពី ខសន្យាមិនសុចរិតក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីជំរុញឱ្យការប្រកួតប្រជែងប្រព្រឹត្តទៅដោយតម្លាភាព និងធានាដល់ការការពារសិទ្ធិរបស់អតិថិជន។

**ខ.២. ការបង្កើតស្ថាប័នគាំទ្រ**

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការទប់ស្កាត់បញ្ហាបំណុលលើសលប់ និងបង្ការការខ្ចីឥណទានច្រើនហួសសមត្ថភាព។ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ក៏បានទទួលមុខងារក្នុងការផ្ដល់របាយការណ៍តាមដានលើការអនុវត្តវិធានផ្ដល់ឥណទានជាប្រចាំខែ។

នាយកដ្ឋានកិច្ចការពារអតិថិជន ត្រូវបានបង្កើតឡើងនៅធនាគារជាតិនៃកម្ពុជា នាចុងឆ្នាំ ២០២៤ ដើម្បីពង្រឹងកិច្ចការពារអតិថិជន និងសម្របសម្រួលដោះស្រាយបណ្ដឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្របតាមវិសាលភាព និងការអភិវឌ្ឍនៃប្រព័ន្ធធនាគារ។

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវបានបង្កើតតាមរយៈអាណត្តិដែលត្រូវបានផ្ដល់ដោយច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ក្រោមអនុក្រឹត្យដែលកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ។ អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ដែលជាលេខាធិការដ្ឋានមានតួនាទីក្នុងការអនុវត្តសកម្មភាពការពារអ្នកប្រើប្រាស់ ដែលរួមមាន ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រនិងគោលនយោបាយសម្រាប់សុខុមាលភាព សុវត្ថិភាព និងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ សហការជាមួយភ្នាក់ងារពាក់ព័ន្ធដើម្បីការពារការក្លែងបន្លំ និងធានាគុណភាព សុវត្ថិភាព និងអនុលោមភាពនៃផលិតផលនិងសេវាកម្ម។ ទោះយ៉ាងណាគណៈកម្មាធិការជាតិនេះពុំមានវិសាលភាពអនុវត្តចំពោះវិស័យហិរញ្ញវត្ថុមិនមែនធនាគារនោះទេ។

**គ. ឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះចន្លោះ**

ក្របខ័ណ្ឌកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុដែលមានជាធរមានកំពុងត្រូវបានពង្រឹងស្របតាមស្តង់ដារអន្តរជាតិ។

### គ.១. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ

ក្របខ័ណ្ឌកិច្ចការពារអតិថិជនដែលមានជាធរមាន មានលក្ខណៈមិនទាន់គ្រប់ជ្រុងជ្រោយ បើប្រៀបធៀបទៅនឹងស្តង់ដារអន្តរជាតិ។ សម្រាប់វិស័យធនាគារ គឺមានក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងនាយកដ្ឋានទទួលបន្ទុកដោះស្រាយនិងសម្របសម្រួលបណ្តឹងអតិថិជន។ ដោយឡែកកិច្ចការពារអតិថិជនក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ នៅមិនទាន់មានក្របខ័ណ្ឌគតិយុត្តនៅឡើយ ដោយសារច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ពុំបានរាប់បញ្ចូលនូវសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

### គ.២. យន្តការដោះស្រាយវិវាទ

ប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់យន្តការសម្រាប់អតិថិជនប្តឹងតវ៉ាទៅកាន់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាចប្តឹងបន្តទៅធនាគារជាតិនៃកម្ពុជា ប្រសិនបើអតិថិជនមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់គ្រឹះស្ថាន។ ក្នុងករណីដែលបញ្ហាមិនត្រូវបានដោះស្រាយ ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងអំពីសិទ្ធិរបស់ភាគីនៃបណ្តឹងក្នុងការប្តឹងបន្តទៅតុលាការ ឬមជ្ឈត្តកម្ម។

ចំពោះវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឌីជីថលូបនីយកម្មនៃយន្តការដោះស្រាយវិវាទ ត្រូវបានរៀបចំនិងកំពុងដំណើរការសម្រាប់និយ័តករមួយចំនួន។ ទោះជាយ៉ាងនេះក្តី ការអនុវត្តនេះមិនទាន់ត្រូវបានធ្វើឡើងនៅក្នុងគ្រប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅឡើយទេ។

## ឃ. ផែនការយុទ្ធសាស្ត្រ

### ឃ.១. ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ

ក្របខ័ណ្ឌច្បាប់កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុមិនមែនធនាគារ នឹងត្រូវបានរៀបចំក្រោមការដឹកនាំរបស់ ក.ស.ហ.វ. ដើម្បីធានាឱ្យបាននូវគោលការណ៍ណែនាំត្រឹមត្រូវសម្រាប់និយ័តករពាក់ព័ន្ធ ក៏ដូចជាអ្នកប្រើប្រាស់។ ក្របខ័ណ្ឌនេះ នឹងរួមបញ្ចូលទាំងបទប្បញ្ញត្តិ និងការត្រួតពិនិត្យការអនុវត្តតាមទីផ្សារ ព្រមទាំងកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុ ដើម្បីជំរុញឱ្យអ្នកប្រើប្រាស់ប្រើសិទ្ធិក្នុងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុប្រកបដោយការពិចារណាច្បាស់លាស់ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមិនមែនធនាគារ កំណត់ស្តង់ដារសម្រាប់ជំនាញវិជ្ជាជីវៈផ្នែកលក់និងទីផ្សារ និងផ្តល់យន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ក្របខ័ណ្ឌនេះ នឹងត្រូវបានយកទៅពិចារណា និងបំពេញបន្ថែមទៅលើក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលមានជាធរមាន។ ការសិក្សាអំពីសមិទ្ធិលទ្ធភាពនឹងត្រូវបានអនុវត្តដើម្បីកំណត់ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនៃកិច្ចការពារអ្នកប្រើប្រាស់ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយសារវិស័យនេះមិនស្ថិតក្រោមវិសាលភាពនៃច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់។ ធាតុសំខាន់ៗនៃកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជាដែលនៅសេសសល់ជាច្រើននឹងត្រូវបានដាក់បញ្ចូលក្នុងដំណើរការវិវឌ្ឍនៃយុទ្ធសាស្ត្រនេះ។ បទប្បញ្ញត្តិនិងការត្រួតពិនិត្យការអនុវត្តតាមទីផ្សារនឹងត្រូវយកចិត្តទុកដាក់ដូចគ្នានឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យប្រុងប្រយ័ត្នផងដែរ។

ស្របពេលដែលធនាគារជាតិនៃកម្ពុជា បានបង្កើតឱ្យមាននាយកដ្ឋានដែលទទួលបន្ទុកលើការងារកិច្ចការពារអតិថិជន អង្គភាពទទួលបន្ទុកកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដែលស្ថិតក្រោមអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនឹងត្រូវរៀបចំបង្កើតឡើង ផងដែរ។ សមត្ថភាពរបស់មន្ត្រីនៃអាជ្ញាធរសេវាហិរញ្ញវត្ថុពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនឹងត្រូវពង្រឹងតាមរយៈវគ្គបណ្តុះបណ្តាលអំពីឧត្តមានុវត្តន៍ និងឧបករណ៍ត្រួតពិនិត្យនានា។ យន្តការសម្របសម្រួលរវាងផ្នែកទទួលបន្ទុកកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងផ្នែកទទួលបន្ទុកកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនឹងត្រូវបានបង្កើតឡើង។

### ឃ.២. យន្តការដោះស្រាយវិវាទ

- ព័ត៌មានទាក់ទងនឹងសិទ្ធិនិងនីតិវិធីនៃការដាក់ពាក្យបណ្តឹងនឹងត្រូវបានផ្តល់ជូនអតិថិជន តាមរយៈមធ្យោបាយឌីជីថលនៅពេលព្រមព្រៀងប្រើប្រាស់ផលិតផល ឬ សេវាហិរញ្ញវត្ថុ។ ព័ត៌មានទាំងនេះអាចផ្តល់ក្នុងរូបភាពជាសំណួរដែលបានសាកសួរញឹកញាប់ ឬ តាមរយៈកម្មវិធីទូរសព្ទដៃ ជាដើម។ អតិថិជនក៏គួរតែដឹងពីយន្តការដោះស្រាយវិវាទផ្សេងទៀតផងដែរ។
- និយ័តករត្រូវធានា រាល់ពាក្យបណ្តឹងអាចទទួលបានតាមរយៈមធ្យោបាយឌីជីថល បន្ថែមលើមធ្យោបាយដែលមានស្រាប់ បើទោះបីជាផលិតផល ឬ សេវាហិរញ្ញវត្ថុត្រូវបានព្រមព្រៀងប្រើប្រាស់តាមវិធីណាក៏ដោយ។
- យន្តការសម្រាប់មជ្ឈត្តករសេវាធានារ៉ាប់រងនឹងត្រូវបានបង្កើតឡើង នាឆ្នាំ ២០៣០ ដើម្បីទទួលបានទំនុកចិត្តពីអតិថិជន និង
- ធនាគារជាតិនៃកម្ពុជានឹងសិក្សាស្រាវជ្រាវអំពីការពង្រឹងយន្តការដោះស្រាយបណ្តឹងអតិថិជននិងវិវាទក្នុងវិស័យធនាគារ។

***ផែនការអនុវត្តលម្អិតត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធក្នុងតារាងទី១៧។***

# ជំពូក ១៥
# ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ
# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម និងឧបសគ្គដែលអាចកើតឡើងជាយថាហេតុនៅក្នុងដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវក្របខ័ណ្ឌនៃការតាមដាន និងវាយតម្លៃដែលមានបីកម្រិត និងមានមុខងារភារកិច្ច ដូចខាងក្រោម៖

I. **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** (**គ.ស.ហ.**) ត្រូវបំពេញតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តវិធានការ ដែលត្រូវបានដាក់ចេញ និងសម្របសម្រួលជាមួយស្ថាប័នទទួលបន្ទុក ដើម្បីជំរុញការអនុវត្តវិធានការដែលមានវឌ្ឍនភាពយឺត ឬ មិនមានវឌ្ឍនភាព
- ណែនាំ និងតម្រង់ទិសការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង
- រាយការណ៍វឌ្ឍនភាព និងការស្នើនូវវិធានការនានាជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

សមាសភាពនៃ គ.ស.ហ. ត្រូវបានកំណត់នៅក្នុង ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

II. **គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ** (**គ.អ.ហ.**) ត្រូវបំពេញតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការរបស់ គ.ស.ហ. ក្នុងការអនុវត្តការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ដឹកនាំ សម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពនៃ «យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ» របស់រាជរដ្ឋាភិបាល
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ" តាមការចាំបាច់
- ផ្តួចផ្តើម និងដាក់ចេញនូវវិធានការសមស្រប ដើម្បីជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្លើយតបទៅនឹងគោលបំណងរបស់ "យុទ្ធសាស្ត្របញ្ចកោណ" និង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ" របស់រាជរដ្ឋាភិបាល
- សម្របសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង
- អនុវត្តកិច្ចការផ្សេងទៀតតាមការចង្អុលបង្ហាញ គ.ស.ហ និងរាជរដ្ឋាភិបាល។

សមាសភាពនៃ គ.អ.ហ. ត្រូវបានកំណត់នៅក្នុង អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២៥ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងសេចក្តីសម្រេចលេខ ៣៨ សសរចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

III. **ក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ** ត្រូវបំពេញតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងក្នុងកិច្ចព្រមព្រៀងឥណទានឱ្យទទួលបានជោគជ័យ

- តាមដាន និងត្រួតពិនិត្យនូវការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិការប្រចាំសាមីស្ថាប័ននីមួយៗក្នុងនាមជាជំនួយការឱ្យ គ.អ.ហ.
- ពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០ របស់រាជរដ្ឋាភិបាល
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម «យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ» តាមការចាំបាច់
- សម្របសម្រួលឱ្យមានការឯកភាពរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជ-កម្ម ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា លើរាល់បញ្ហាដែលពាក់ព័ន្ធ
- រៀបចំរបាយការណ៍ជាទៀងទាត់ជូន គ.អ.ហ. អំពីការវិវត្តន៍នៃផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញ-វត្ថុ និង
- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់ គ.អ.ហ.។

សមាសភាពនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវកំណត់ដោយ សេចក្តីសម្រេចរបស់ប្រធាន ស្ថាប័នមានសមត្ថកិច្ចរៀងៗខ្លួន ដូចមានចង្អុលបង្ហាញនៅក្នុង សេចក្តីសម្រេចលេខ ៩០ សសរ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២២ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

# ជំពូក ១៦
# សេចក្តីសន្និដ្ឋាន

ការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយភាពជឿជាក់ និងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយ បានបង្កើនតម្រូវការសេវាហិរញ្ញវត្ថុយ៉ាងឆាប់រហ័ស ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃប្រាក់បញ្ញើឥណទាន សេវាធានារ៉ាប់រង និងសេវាហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀត។ ទោះយ៉ាងណា វិបត្តិកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យចម្បងៗនៃសេដ្ឋកិច្ច ដូចជា ទេសចរណ៍ សំណង់ និងកាត់ដេរ ដែលបាននាំឱ្យកំណើនធ្លាក់ចុះនាឆ្នាំ ២០២០។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានដាក់ចេញវិធានការគាំទ្របន្ទាន់ជាបន្តបន្ទាប់ ដែលនាំទៅដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។

បន្ទាប់ពីវិបត្តិកូវីដ-១៩ ពិភពលោកក៏បានជួបនឹងបញ្ហាប្រឈមថែមទៀត ជាពិសេស ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចនិងនយោបាយ និងសម្ពាធអតិផរណាដែលបង្កើនភាពមិនប្រាកដប្រជាខ្លាំង។ លើសពីនេះ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាបានរួមចំណែកកាន់តែសកម្មនៅក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ហើយក៏ភ្ជាប់មកជាមួយនូវហានិភ័យថ្មីៗផងដែរ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ និងបន្តគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព កម្ពុជាបានផ្តល់អាទិភាពទៅលើភាពធន់នៃវិស័យហិរញ្ញវត្ថុ ការធ្វើពិពិធកម្ម និងនវានុវត្តន៍ឌីជីថល ក្រោមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០ ដែលផ្តោតលើការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ការលើកកម្ពស់ការត្រួតពិនិត្យ បរិវត្តកម្មឌីជីថល ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការពង្រីកលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ជាពិសេសសម្រាប់ប្រជាជនដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ។ល។

ជាមួយគ្នានេះ ការប្រែប្រួលអាកាសធាតុកាន់តែកើតឡើងញឹកញាប់ ហើយបានបង្កនូវផលប៉ះពាល់ទៅដល់វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងស្ថានភាពដែលកម្ពុជាមានវិស័យកសិកម្មដែលនៅពឹងផ្អែកលើអាកាសធាតុនៅឡើយ ការទប់ទល់និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ជាកត្តាចាំបាច់ ដើម្បីរួមចំណែករក្សានិរន្តរភាពនៃកំណើននិងភាពធន់នៃសេដ្ឋកិច្ច ក៏ដូចជាវិស័យហិរញ្ញវត្ថុ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការពង្រឹងការអភិវឌ្ឍនិងលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ដែលជាផ្នែកមួយសំខាន់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែងនេះផងដែរ។

យុទ្ធសាស្ត្រនេះបានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចសហការដ៏រឹងមាំនិងជិតស្និទ្ធក្នុងចំណោមស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការដោះស្រាយបញ្ហាអន្តរវិស័យពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ជាពិសេសការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល យុទ្ធសាស្ត្រផ្នែកព័ត៌មាន អប់រំ និងទំនាក់ទំនង និងកិច្ចការពារអ្នកប្រើប្រាស់។

# ឧបសម្ព័ន្ធ ១
# តារាងផែនការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០២៥-២០៣០

## វិស័យធនាគារ

*តារាងទី ១៖ ផែនការអនុវត្តសម្រាប់វិស័យធនាគារ*

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **ក. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ** | | | | |
| **ការបង្កើតនិងអនុវត្តប្រព័ន្ធការពារប្រាក់បញ្ញើ** | • អនុម័តប្រកាសស្តីពីកិច្ចការពារប្រាក់បញ្ញើក្នុងគោលបំណងបង្កើតនូវយន្តការកិច្ច-ការពារប្រាក់បញ្ញើសំដៅរួមចំណែកការពារអ្នកដាក់ប្រាក់បញ្ញើបង្កើនទំនុកចិត្តសាធា-រណជននិងរក្សាស្ថិរភាពហិរញ្ញវត្ថុ<br>• រៀបចំសេចក្តីព្រាងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងសមាជិកភាព បុព្វលាភ ទំហំសំណង និងនីតិវិធីនៃការផ្តល់សំណង និង<br>• កសាងសមត្ថភាពមន្ត្រី-បុគ្គលិកនៃនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ។ | • ពិនិត្យនិងអនុម័តលើក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលបានអនុវត្តក្នុងសកម្មភាពរយៈពេលខ្លី<br>• រៀបចំការវាយតម្លៃតម្រូវការបណ្តុះបណ្តាលដើម្បីវាយតម្លៃកម្រិតចំណេះដឹង និងជំនាញរបស់បុគ្គលិកនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ<br>• អនុវត្តគំនិតផ្តួចផ្តើមកសាងសមត្ថភាពសម្រាប់បុគ្គលិកនៃនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ និងភាគីពាក់ព័ន្ធផ្សេងទៀត និង<br>• បន្តកសាងសមត្ថភាពមន្ត្រី-បុគ្គលិកនៃនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ។ | • សិក្សាលើក្របខ័ណ្ឌវិធីសាស្ត្រ ដើម្បីជួយសម្រួលដល់ការធ្វើអន្តរកាលទៅកាន់ការគណនាបុព្វលាភផ្អែកលើហានិភ័យ។ | • ធនាគារជាតិនៃកម្ពុជា និង<br>• ក.ស.ហ.វ. |
| **ការយល់ដឹងអំពីប្រព័ន្ធការពារប្រាក់បញ្ញើ** | • អនុវត្តយុទ្ធនាការលើកកម្ពស់ចំណេះដឹងសាធារណជនអំពីកិច្ចការពារប្រាក់បញ្ញើ និង<br>• បង្កើតមគ្គុទ្ទេសក៍សម្រាប់អ្នកដាក់ប្រាក់បញ្ញើដែលគូសបញ្ជាក់ពីលក្ខណៈសំខាន់ៗនៃយន្តការកិច្ចការពារប្រាក់បញ្ញើ។ | • បន្តអនុវត្តយុទ្ធនាការលើកកម្ពស់ចំណេះដឹងសាធារណជនអំពីកិច្ចការពារប្រាក់បញ្ញើ និង<br>• បង្កើនការយល់ដឹងអំពីយន្តការកិច្ចការពារប្រាក់បញ្ញើបទដ្ឋាន និងនីតិវិធីពាក់ព័ន្ធដោយប្រើប្រាស់ឧបករណ៍ជំនួយជាទស្សនីយភាពនិងសំឡេង។ | • បង្កើតការយល់ដឹងទាក់ទងនឹងយន្តការដោះស្រាយវិវាទដែលត្រូវបានដាក់ចេញដើម្បីគ្រប់គ្រងភាពមិនស្របគ្នាក្នុងការសងប្រាក់ (ក្នុងករណីមានការសម្រុកទៅដកប្រាក់ពីធនាគារ)។ | • ធនាគារពាណិជ្ជ<br>• គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ<br>• សមាគមធនាគារនៅកម្ពុជា និង<br>• សមាគមមីក្រូហិរញ្ញវត្ថុ |

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **ខ. ស្ថិរភាពហិរញ្ញវត្ថុ** | | | | |
| **ក្របខ័ណ្ឌត្រៀមទប់ទល់និងគ្រប់គ្រងវិបត្តិ** | • រៀបចំក្របខ័ណ្ឌបង្ការនិងគ្រប់គ្រងវិបត្តិតាមវិស័យ និង<br>• ពង្រឹងការតាមដាន និងវាយតម្លៃតាមដានស្ថិរភាពហិរញ្ញវត្ថុ។ | • ពង្រឹងក្របខ័ណ្ឌគ្រប់គ្រងវិបត្តិតាមវិស័យ និង<br>• ពង្រឹងការតាមដាន និងវាយតម្លៃស្ថិរភាពហិរញ្ញវត្ថុដោយបង្កើនការចេញផ្សាយរបាយការណ៍ស្ដីពី ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ។ | • ពង្រឹងបន្ថែមលើក្របខ័ណ្ឌគ្រប់គ្រងវិបត្តិតាមវិស័យ។ | • គណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុ<br>• ធនាគារជាតិនៃកម្ពុជា<br>• អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងនិយ័តករទាំង៦ និង<br>• ក.ស.ហ.វ. |
| **ក្របខ័ណ្ឌដំណោះស្រាយធនាគារ ដែលមានបញ្ហា** | • បញ្ចប់សេចក្ដីព្រាងច្បាប់ ឬបទប្បញ្ញត្តិទាក់ទងនឹងក្របខ័ណ្ឌដំណោះស្រាយធនាគារ ដែលមានបញ្ហា។ | • អនុម័តច្បាប់ ឬបទប្បញ្ញត្តិ។ | • ពិនិត្យមើលក្របខ័ណ្ឌដំណោះស្រាយធនាគារដែលមានបញ្ហា ដោយផ្អែកលើការអនុវត្តហើយកែតម្រូវប្រសិនមានការចាំបាច់។ | • ធនាគារជាតិនៃកម្ពុជា |
| **ការពង្រឹងសន្តិសុខសាយប័រ និងអភិបាលកិច្ចទិន្នន័យ ដើម្បីធានាស្ថិរភាព និងការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ** | • បញ្ចប់សេចក្ដីព្រាងច្បាប់ និងបទប្បញ្ញត្តិស្ដីពីសន្តិសុខសាយប័រ និងកិច្ចការពារទិន្នន័យបុគ្គល។ | • អនុម័តច្បាប់ និងបទប្បញ្ញត្តិ។ | • ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ និងប្រព័ន្ធត្រួតពិនិត្យដើម្បីការពារវិស័យហិរញ្ញវត្ថុ។ | • ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>• ធនាគារជាតិនៃកម្ពុជា<br>• ក.ស.ហ.វ. និង<br>• អ.ស.ហ. |
| **គ. លទ្ធភាពទទួលបានហិរញ្ញវត្ថុ** | | | | |
| **ការតាមដាន និងអនុវត្តយុទ្ធសាស្ត្រជាតិ ស្ដីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ ២០១៩-២០២៥ (NFIS)** | • ពិនិត្យមើលស្ថានភាពនៃការអនុវត្តចំណុចសកម្មភាពដែលមាននៅក្នុង NFIS និង<br>• ធ្វើការកែតម្រូវចាំបាច់នានាផ្អែកតាមរបាយការណ៍ត្រួតពិនិត្យដើម្បីសម្រេចបានគោលដៅរបស់ NFIS<br>• បន្តការអនុវត្ត NFIS ផ្អែកលើសមិទ្ធផលសម្រេចបាននៃ NFIS ២០១៩-២០២៥ និង | • បន្តការអនុវត្តចំណុចសកម្មភាពតាមលទ្ធផលនៃការពិនិត្យ។ | • អនុវត្តចំណុចសកម្មភាពដើម្បីពង្រឹងបន្ថែមនូវបរិយាបន្នហិរញ្ញវត្ថុនៅក្នុងប្រទេស។ | • ធនាគារជាតិនៃកម្ពុជា<br>• ក.ស.ហ.វ.<br>• អ.ស.ធ.<br>• ន.ធ.ក.<br>• ន.ម.ក. និង<br>• និយ័តករផ្សេងទៀត |

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| | • ពិនិត្យពីលទ្ធភាពក្នុងការធ្វើបច្ចុប្បន្នកម្មលើយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ។ | | | |
| **ការពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃផ្សារលគណនីត្រូវទទួល (AR) និងមូលនិធិអាកាសធាតុយុទ្ធសាស្ត្រ (SCF)** | • បង្កើតការលើកទឹកចិត្តសមស្រប (រួមមានការគាំទ្រផ្នែកហិរញ្ញវត្ថុ ការប្រឹក្សា និងបច្ចេកទេស) ដើម្បីជំរុញដល់អាជីវកម្មដែលទើបបើកថ្មី/ស្ថាប័ន ក្នុងការអភិវឌ្ឍផ្សារ AR និង SCF បន្ថែមទៀត<br>• សម្របសម្រួលការចូលរួមរបស់សាជីវកម្មធានាឥណទានកម្ពុជា ក្នុងផ្សារ AR និង SCF និង<br>• ជំរុញការចូលរួមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងប្រតិបត្តិការ Factoring នៅក្នុងផ្សារ។ | • បង្កើនការធានារបស់សាជីវកម្មធានាឥណទានកម្ពុជា ដោយមានការចូលរួមពីក្រុមហ៊ុនធានារ៉ាប់រង និងការគាំទ្រចាំបាច់ពីរដ្ឋាភិបាល<br>• កំណត់អាណត្តិនៃការអនុម័តផ្សារទាំងនេះ ក្នុងបណ្តាក្រសួងពាក់ព័ន្ធ និងនាយកដ្ឋានថ្នាក់ក្រោមជាតិ និង<br>• បង្កើតយន្តការដោះស្រាយ ដើម្បីគ្រប់គ្រងវិវាទដែលអាចកើតចេញពីភាពមិនស្របគ្នាក្នុងការទូទាត់។ | • ដឹកនាំ SOEs ក្នុងការប្រើប្រាស់ផ្សារទាំងនេះ ក្នុងការធ្វើប្រតិបត្តិការជាមួយ MSMEs និង<br>• ជំរុញការចូលរួមរបស់សហគ្រាសឯកជនលើផ្សារទាំងនេះ។ | • ធនាគារជាតិនៃកម្ពុជា<br>• ក.ស.ហ.វ<br>• សាជីវកម្មធានាឥណទានកម្ពុជា<br>• ន.ធ.ក.<br>• ក្រសួងពាណិជ្ជកម្ម<br>• បណ្តាក្រសួងពាក់ព័ន្ធ និង<br>• ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ |
| **ការសម្របសម្រួលការអនុវត្តហិរញ្ញប្បទានសន្និធិ** | • ដាក់ចេញសេចក្តីណែនាំលើការផ្តល់ហិរញ្ញប្បទានសន្និធិ និង<br>• បង្កើតគំរូសម្រាប់កិច្ចព្រមព្រៀងត្រួតពិនិត្យសន្និធិ (SMA) និងកិច្ចព្រមព្រៀងគ្រប់គ្រងទ្រព្យធានា (CoMA)។ | • រៀបចំវគ្គលើកកម្ពស់ចំណេះដឹង អំពីនីតិវិធី និងគុណប្រយោជន៍នៃហិរញ្ញប្បទានសន្និធិ។ | • ជំរុញការអភិវឌ្ឍនៃផ្សារអេឡិចត្រូនិកសម្រាប់ជួយសម្រួលដល់ការផ្តល់ហិរញ្ញប្បទានសន្និធិ។ | • ធនាគារជាតិនៃកម្ពុជា<br>• ក.ស.ហ.វ.<br>• ន.ម.ក.<br>• ន.អ.ប. និង<br>• ក្រសួងពាណិជ្ជកម្ម |
| **ការរៀបចំយុទ្ធសាស្ត្រលើកកម្ពស់ចំណេះដឹង និងការយល់ដឹងក្នុងវិស័យធនាគារ** | • វាយតម្លៃពីឥទ្ធិពលនៃវិធានការ ដែលបានណែនាំ និងកំណត់ចំណុចសក្តានុពលដែលត្រូវការកែលម្អ<br>• រៀបចំយុទ្ធសាស្ត្រជាក់លាក់មួយដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពីផលិតផល និងសេវាហិរញ្ញវត្ថុ និង | • បង្កើតក្រុមការងារបច្ចេកទេសដើម្បីសម្របសម្រួលការអនុវត្តវិធានការអន្តរាគមន៍ដែលបានស្នើឡើង។ | • ការអនុវត្តវិធានការដែលបានស្នើឡើង និងបង្កើតវិធានការបន្ថែមក្នុងគោលបំណងប្រើប្រាស់នូវវឌ្ឍនភាពដែលសម្រេចបាន។ | • ធនាគារជាតិនៃកម្ពុជា<br>• សមាគមធនាគារនៅកម្ពុជា និង<br>• សមាគមមីក្រូហិរញ្ញវត្ថុ និងស្ថាប័នផ្សេងទៀត |

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| | • អភិវឌ្ឍន៍ផែនទីមគ្គុទ្ទេសក៍ និងតារាងម៉ាទ្រីសភាគីពាក់ព័ន្ធដើម្បីជួយសម្រួលដល់ការអនុវត្តវិធានការដែលបានគ្រោងទុក។ | | | |
| **ឃ. ការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្ររដ្ឋ** | | | | |
| **ការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្ររដ្ឋ** | • ស្វែងរកលទ្ធភាពអភិវឌ្ឍអត្រាការប្រាក់គូរីន័រពេញលេញ ដើម្បីដាក់ធ្វើសន្ទនីយភាពលើស និងទទួលបានមូលនិធិរយៈកាលខ្លីរវាងធនាគារក្នុងអត្រាការប្រាក់សមរម្យ<br>• រៀបចំបទប្បញ្ញត្តិសម្រាប់ទីផ្សារអន្តរធនាគារ និង<br>• បង្កើតទីផ្សារបន្ទាប់សម្រាប់ការជួញដូរមូលបត្ររដ្ឋនិងសម្រួលដល់ប្រតិបត្តិការទីផ្សារចំហ (OMOs)។ | • អភិវឌ្ឍន៍ថ្នាលសម្រាប់ជួញដូរ និងផាត់ទាត់នៅក្នុងទីផ្សារអន្តរធនាគារសម្រាប់ការរកឃើញតម្លៃល្អសមរម្យ<br>• អភិវឌ្ឍន៍មុខងារថ្នាល និងរៀបចំបទដ្ឋានគតិយុត្តសម្រាប់ការជួញដូរឧបករណ៍ហិរញ្ញវត្ថុ និង<br>• អភិវឌ្ឍទីផ្សារមូលបត្ររដ្ឋជារូបិយវត្ថុជាតិឱ្យកាន់តែស៊ីជម្រៅ និងប្រើប្រាស់ប្រភពធនធានសម្រាប់គម្រោងវិនិយោគសាធារណៈជាយុទ្ធសាស្ត្រ។ | | • ធនាគារជាតិនៃកម្ពុជា<br>• ក.ស.ហ.វ.<br>• អ.ស.ហ.<br>• ជ.ម.ក. និង<br>• ន.ម.ក. |

## វិស័យភតិសន្យាហិរញ្ញវត្ថុ និងហាយភើផែស

*តារាងទី ២៖ ផែនការអនុវត្តសម្រាប់ភតិសន្យាហិរញ្ញវត្ថុ និងហាយភើផែស*

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **ក. ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ភតិសន្យាហិរញ្ញវត្ថុ** | | | | |
| **កិច្ចសន្យាហាយភើផែស** | • ធ្វើការសិក្សាសមិទ្ធិលទ្ធភាពអំពីការដាក់ចេញបទប្បញ្ញត្តិកិច្ចសន្យាហាយភើផែស។ | • ដាក់ចេញបទប្បញ្ញត្តិស្ដីពីកិច្ចសន្យាហាយភើផែសបើមានលទ្ធភាព។ | • ត្រួតពិនិត្យហានិភ័យឥណទាននៃប្រតិបត្តិការហាយភើផែស ដែលធ្វើឡើងដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និង<br>• ត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តកិច្ចសន្យាហាយភើផែស។ | • ធនាគារជាតិនៃកម្ពុជា |
| **ជំរុញប្រសិទ្ធភាពប្រព័ន្ធចុះបញ្ជីវត្ថុបញ្ចាំ** | • វាយតម្លៃយន្តការចំពោះការធានាទ្រព្យដែលបានជួល<br>• ពិនិត្យនិងស្វែងរកលទ្ធភាពនៃការដាក់បញ្ចូលប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុនៅក្នុងបញ្ជីឈ្មោះប្រតិបត្តិការមានកិច្ចធានានៅក្រសួងពាណិជ្ជកម្ម និង<br>• បញ្ជាក់ជាមួយនាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម។ | • លើកកម្ពស់ការប្រើប្រាស់បញ្ជីឈ្មោះប្រតិបត្តិការដែលមានកិច្ចធានា ប្រសិនបើរកឃើញថាអាចធ្វើទៅបាន និង<br>• ត្រួតពិនិត្យប្រសិទ្ធភាពនៃបញ្ជីឈ្មោះប្រតិបត្តិការមានកិច្ចធានា។ | • ស្វែងរកការធ្វើការកែទម្រង់ឬបច្ចុប្បន្នកម្មចំពោះមុខងារបន្ថែមដែលងាយស្រួលប្រើក្នុងករណីចាំបាច់។ | • ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រសួងយុត្តិធម៌<br>• ក្រសួងសាធារណការ និងដឹកជញ្ជូន និង<br>• អ.ស.ហ. |
| **ខ. ការសិក្សាទៅលើលក្ខខណ្ឌនៃសំវិធានធន និងស្តង់ដារគណនេយ្យសម្រាប់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ** | | | | |
| **ការពិនិត្យលើសំវិធានធនសម្រាប់ការគិតពន្ធ** | | • សិក្សាពីលទ្ធភាពក្នុងការអនុញ្ញាតឱ្យអនុវត្តសំវិធានធនសម្រាប់វិស័យភតិសន្យាហិរញ្ញវត្ថុដោយផ្អែកលើបញ្ហាជាក់ស្តែង និងឧត្តមានុវត្តន៍អន្តរជាតិ។ | • រៀបចំការអនុវត្តក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុ ប្រសិនបើការសិក្សាពីលទ្ធភាពអនុវត្តសំវិធានធនសម្រាប់វិស័យភតិសន្យាហិរញ្ញវត្ថុអាចទទួលយកបាននិងមានលក្ខណៈសមស្រប។ | • អគ្គនាយកដ្ឋានពន្ធដារ<br>• សមាគមធនាគារនៅកម្ពុជា និង<br>• សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **គ. ការបន្ថយលក្ខខណ្ឌគណនេយ្យ** | | | | |
| **ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដើម្បីលើកទឹកចិត្តក្នុងការប្រកាន់ខ្ជាប់នូវស្តង់ដារគណនេយ្យ** | • រៀបចំសិក្ខាសាលាស្តីពីស្តង់ដារគណនេយ្យអន្តរជាតិចុងក្រោយបំផុតដែលអនុវត្តចំពោះគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។ | • វាយតម្លៃលទ្ធភាព និងការត្រៀមខ្លួនរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុក្នុងការប្តូរទៅ CIFRS 16។ | • ផ្សព្វផ្សាយ និងជួចផ្តើមការពង្រឹងចំណេះដឹងក្នុងចំណោមបុគ្គលិកនិយ័តកម្មលើស្តង់ដារគណនេយ្យដែលបានធ្វើបច្ចុប្បន្ន និង<br>• កំណត់ពេលវេលាសម្រាប់ការអនុម័តពេញលេញនៃស្តង់ដារគណនេយ្យ ប្រសិនបើមានលទ្ធភាពសម្រាប់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។ | • ន.គ.ស. |
| **ឃ. ការដោះស្រាយវិវាទពាណិជ្ជកម្មឱ្យបានរហ័ស** | | | | |
| **ការបង្កើតតុលាការពាណិជ្ជកម្មសម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្ម** | • បញ្ចប់ការរៀបចំវិធាន បទប្បញ្ញត្តិ តួនាទី និងការទទួលខុសត្រូវរបស់តុលាការពាណិជ្ជកម្ម។ | • បើកឱ្យដំណើរការតុលាការពាណិជ្ជកម្ម និង<br>• ស្វែងរកវិធានការជំនួសដើម្បីការពារការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្មក្នុងអំឡុងពេលបណ្តោះអាសន្ន។ | • រៀបចំកម្មវិធីបណ្តុះបណ្តាលផ្នែកតុលាការលើសកម្មភាពភតិសន្យាហិរញ្ញវត្ថុសម្រាប់ចៅក្រម និង<br>• អប់រំគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុអំពីតួនាទីរបស់តុលាការពាណិជ្ជកម្មក្នុងការការពារផលប្រយោជន៍ភតិកៈ។ | • ក្រសួងយុត្តិធម៌<br>• គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និង<br>• ធនាគារជាតិនៃកម្ពុជា<br>• ក្រសួងពាណិជ្ជកម្ម<br>• ក្រសួងមហាផ្ទៃ<br>• ក.ស.ហ.វ និង<br>• អ.ស.ហ. |
| **ការទាមទារទ្រព្យដែលបានជួលមកវិញដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្នុងករណីភតិកៈមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យា** | • ពិភាក្សា និងស្វែករកដំណោះស្រាយសមស្របក្នុងការទាមទារទ្រព្យដែលបានជួលមកវិញដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។ | • លើកទឹកចិត្តឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុទាមទារទ្រព្យដែលបានជួលមកវិញដោយផ្ទាល់ ប្រសិនបើដំណោះស្រាយនោះសមស្រប និងអាចអនុវត្តបាន។ | • លើកទឹកចិត្តឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុទាមទារទ្រព្យដែលបានជួលមកវិញដោយផ្ទាល់ ប្រសិនបើដំណោះស្រាយនោះសមស្រប និងអាចអនុវត្តបាន។ | • ក្រសួងយុត្តិធម៌<br>• ធនាគារជាតិនៃកម្ពុជា និង<br>• ក្រសួង-ស្ថាប័នពាក់ព័ន្ធ |

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **ង. ការពង្រឹងចំណេះដឹងសម្រាប់ភតិសន្យាហិរញ្ញវត្ថុ** | | | | |
| **ការវាយតម្លៃសមិទ្ធិលទ្ធភាពនៃការបង្កើតសមាគមភតិ-សន្យា/គណៈកម្មាធិការភតិ-សន្យាហិរញ្ញវត្ថុ** | • សិក្សាពីសមិទ្ធិលទ្ធភាពនិងវាស់ស្ទង់ចំណាប់អារម្មណ៍ក្នុងការបង្កើតសមាគមភតិសន្យាហិរញ្ញវត្ថុ និង<br>• ស្វែងយល់ពីសមិទ្ធិលទ្ធភាពនៃការបង្កើតគណៈកម្មាធិកាភតិសន្យាហិរញ្ញវត្ថុក្រោមសមាគមធនាគារនៅកម្ពុជា/សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។ | • រៀបចំស្ថាប័ន/អង្គភាពភតិសន្យាហិរញ្ញវត្ថុប្រសិនបើមានលទ្ធភាព។ | • អញ្ជើញសមាជិកភាពឱ្យចូលក្នុងស្ថាប័ន/អង្គភាពភតិសន្យាហិរញ្ញវត្ថុ។ | • ធនាគារជាតិនៃកម្ពុជា |

## ប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុ

*តារាងទី ៣៖ ផែនការអនុវត្តសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ និងនវានុវត្តន៍ហិរញ្ញវត្ថុ*

| គោលដៅអភិវឌ្ឍន៍ | សកម្មភាពសម្រាប់ឆ្នាំ ២០២៥-២០២៦ | សកម្មភាពសម្រាប់ឆ្នាំ ២០២៧-២០២៨ | សកម្មភាពសម្រាប់ឆ្នាំ ២០២៩-២០៣០ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់** | • ដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់សងប្រាក់រូម<br>• ដាក់ចេញវិធាន និងនីតិវិធីសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់រូម។ | • តាមដានពីវឌ្ឍនភាព និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។ | • តាមដានពីវឌ្ឍនភាព និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។ | • ធនាគារជាតិនៃកម្ពុជា |
| **សេវាទូទាត់សងប្រាក់** | • បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិគ្រប់ជ្រុងជ្រោយដើម្បីគ្រប់គ្រងថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ និង<br>• បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសមស្របដែលអនុញ្ញាតឱ្យភ្នាក់ងារធ្វើប្រតិបត្តិការក្នុងកម្រិតជាក់លាក់មួយតំណាងឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ | • អនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិគ្រប់ជ្រុងជ្រោយដើម្បីគ្រប់គ្រងថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ។ | • បន្តអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិគ្រប់ជ្រុងជ្រោយដើម្បីគ្រប់គ្រងថ្នាលហិរញ្ញប្បទានបច្ចេកវិទ្យាហិរញ្ញវត្ថុ។ | • ធនាគារជាតិនៃកម្ពុជា |
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ២៥៦ អនក្រ.បក ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២៥ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- បានឃើញសេចក្តីសម្រេចលេខ០៤ សសរ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

**សម្រេច**

**ប្រការ១ ._**

ត្រូវបានតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ សរសេរជាអក្សរកាត់ថា "គ.អ.ហ." ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោកជំទាវ **ជា សិរី** | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- | ឯកឧត្តម **ម៉ី វ៉ាន់** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | អនុប្រធាន |
| ៣- | ឯកឧត្តម **រ័ត្ន សុវណ្ណនរៈ** | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- | ឯកឧត្តម **ឃឹម លាត** | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៥- | ឯកឧត្តម **ប្រាក់ សុខឃួរ** | រដ្ឋលេខាធិការប្រចាំការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦- | លោកជំទាវ **តឹករ៉ែត អំរេខ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ៧- | ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៨- | ឯកឧត្តម **ទេព តិយ៉ោវិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- | ឯកឧត្តម **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គនាយកនៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| ១០- | ឯកឧត្តម **ស៊ូ សុជាតិ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១១- | ឯកឧត្តម **សុខ ដារ៉ា** | អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ១២- | ឯកឧត្តម **ម៉ៅ ថារិន** | អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ១៣- | ឯកឧត្តម **ម៉ៅ ច័ន្ទតិរ្ធ** | អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១៤- | ឯកឧត្តម **ជូ វណ្ណៈ** | អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| ១៥- | ឯកឧត្តម **ឈុន សម្បត្តិ** | ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ១៦- | ឯកឧត្តម **ត្រឹុយ វាសនា** | អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា និងជាឧបការីទេសាភិបាល | សមាជិក |
| ១៧- | ឯកឧត្តម **គីមធី ភោមលី** | អគ្គនាយកប្រតិបត្តិការនៃធនាគារជាតិនៃកម្ពុជា និងជាឧបការីទេសាភិបាល | សមាជិក |
| ១៨- | ឯកឧត្តម **គិត សុវណ្ណារិទ្ធ** | អគ្គនាយកត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា និងជាឧបការីទេសាភិបាល | សមាជិក |
| ១៩- | ឯកឧត្តម **ហោង បូមភរា** | ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |

| | | |
|---|---|---|
| ២០- លោក **ឃូ ខុណ្ឌារី** | អគ្គនាយកគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិនៃធនាគារជាតិនៃកម្ពុជា និងជាឧបការីទេសាភិបាល | សមាជិក |
| ២១- លោក **ឡាយ សុខហេង** | អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា និងជាឧបការីទេសាភិបាល | សមាជិក |
| ២២- លោក **អែម កំណាន់** | អគ្គនាយករងត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៣- លោក **ខ៉េត សុវណ្ណារិទ្ធ** | អនុប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ២៤- លោក **ឡុង ធីបុណ្យឫទ្ធ** | អគ្គនាយករងប្រតិបត្តិការនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៥- លោកស្រី **ម៉ក់ ស្មើ** | អគ្គនាយករងបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា និងជាប្រធាននាយកដ្ឋានបទប្បញ្ញត្តិ | សមាជិក និងលេខាធិការ។ |

**ប្រការ២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤ កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២៥
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :៩០...សសរ...**

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

# សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត "ក្រុមការងារបច្ចេកទេស" ចំនួន ២ ជាសេនាធិការឱ្យ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (គ.អ.ហ.) ដែល ក្រុមការងារបច្ចេកទេសទី១ ស្ថិតក្រោមការគ្រប់គ្រងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង ក្រុមការងារបច្ចេកទេសទី២ ស្ថិតក្រោមការគ្រប់គ្រងនៃធនាគារជាតិនៃកម្ពុជា។

សមាសភាពនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធានស្ថាប័នមានសមត្ថកិច្ចរៀងៗខ្លួន។

**ប្រការ២ .-**

ក្រុមការងារបច្ចេកទេសនីមួយៗ មានតួនាទី និងភារកិច្ច ដូចតទៅ÷

- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងក្នុងកិច្ចព្រមព្រៀងឥណទាន ឱ្យទទួលបានជោគជ័យ
- តាមដាន និងត្រួតពិនិត្យនូវការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិការប្រចាំសាមីស្ថាប័ននីមួយៗ ក្នុងនាមជាជំនួយការឱ្យ គ.អ.ហ.
- ពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ" តាមការចាំបាច់
- សម្របសម្រួលឱ្យមានការឯកភាពរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា លើរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹង÷
    - ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
    - ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង
    - ការត្រួតពិនិត្យលើការអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងប្រើប្រាស់
- រៀចំរបាយការណ៍ជាទៀងទាត់ជូន គ.អ.ហ. អំពីការវិវត្តនៃផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់ គ.អ.ហ.។

**ប្រការ៣ .-**

ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច ៣ (បី) ដង ក្នុង ១ (មួយ) ឆ្នាំ និង/ឬ តាមការចាំបាច់ និងត្រូវរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ ជូន គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

សមាជិកនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេច ដើម្បីចូលរួមជំនួសក្នុងករណីអវត្តមាន។

**ប្រការ៤ .-**

ក្រុមការងារបច្ចេកទេសនីមួយៗ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញផ្សេងទៀតនៃក្រសួង-ស្ថាប័នពាក់ព័ន្ធចូលរួមក្នុងក្រុមការងារតាមការចាំបាច់។

ក្រុមការងារបច្ចេកទេសនីមួយៗ មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត ចូលរួមកិច្ចប្រជុំតាមការចាំបាច់។

**ប្រការ៥ .-**

សេចក្តីសម្រេចលេខ ៥៩ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ...០០៣.........អ.ស.ហ.ស.ស.ក

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៥៦ អនក្រ.បក ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៩០ សសរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## សម្រេច

**ប្រការ ១.**_

ត្រូវបានតែងតាំងសមាសភាព **ក្រុមការងារបច្ចេកទេសទី១ នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ** សរសេរជាអក្សរកាត់ថា “**ក.អ.ហ.**” ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ី វ៉ាន់** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ប្រធាន |
| ២. ឯកឧត្តម **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គនាយក នៃនិយ័តករសន្តិសុខសង្គម | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម **ស៊ូ សុជាតិ** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា | អនុប្រធាន |
| ៤. ឯកឧត្តម **សុខ ដារ៉ា** | អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច | អនុប្រធាន |
| ៥. ឯកឧត្តម **ម៉ូ ថារិន** | អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម | អនុប្រធាន |
| ៦. ឯកឧត្តម **ម៉ូ ចំន្ទតិរ្ធ** | អគ្គនាយក នៃនិយ័តករធានារ៉ាប់រងកម្ពុជា | អនុប្រធាន |
| ៧. ឯកឧត្តម **ជូ វណ្ណៈ** | អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | អនុប្រធាន |
| ៨. ឯកឧត្តម **ឈុន សម្បត្តិ** | ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | អនុប្រធាន |
| ៩. លោកបណ្ឌិត **សោម ផៃ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | អនុប្រធានប្រចាំការ |
| ១០. ឯកឧត្តម **ហូ ស៊ីចយ៉ុង** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១. ឯកឧត្តម **ម៉ុក វ៉ាឌី** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១២. ឯកឧត្តមបណ្ឌិត **ទិន តក្តី** | អគ្គនាយករង នៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១៣. ឯកឧត្តម **ណី សាគល** | អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ១៤. លោក **អ៊ុន មាត្រា** | អគ្គនាយករង នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| ១៥. លោកស្រីបណ្ឌិត **ហោ សុវឌ្ឍនា** | អគ្គនាយករង នៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១៦. លោក **លាច គួចប៊ុណ្ណារ៉ាត់** | ប្រធាននាយកដ្ឋានគោលនយោបាយ នៃអគ្គលេខា-ធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ១៧. លោកស្រី **ហ៊ី លីគា** | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ នៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| ១៨. លោក **យស់ សំអុល** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៩. លោក **ម៉ៅ ពៅ** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ និងកិច្ចការ គតិយុត្តនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| ២០. លោក **សៀង ចំណាន** | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និង សហប្រតិបត្តិការ នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | សមាជិក |
| ២១. លោក **ខូច អៀហៃ** | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ២២. លោក **ជា បុល្លិកា** | ប្រធាននាយកដ្ឋានផ្សះផ្សាវិវាទនិងការពារសិទ្ធិ អ្នកទទួលផល នៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| ២៣. លោក **លឹម ចាន់ណា** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអង្គភាពសវនកម្ម ផ្ទៃក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | សមាជិក |
| ២៤. លោក **ខួន សំរតនា** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអង្គភាព សវនកម្មផ្ទៃក្នុង នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែន ធនាគារ | សមាជិក |

| | | |
|---|---|---|
| ២៥. លោក **ឆឹម សត្យា** | អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ<br>នៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ២៦. លោក **ណាង សេរីវុធ** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល<br>និងសហប្រតិបត្តិការ នៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| ២៧. កញ្ញា **ពេជ្រ ម៉ានីឡា** | អនុប្រធាននាយកដ្ឋានបច្ចេកទេស<br>នៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| ២៨. លោក **ឡេង សុខឡុង** | ទីប្រឹក្សានៃនិយ័តករសន្តិសុខសង្គម ទទួលបន្ទុក<br>នាយកដ្ឋានត្រួតពិនិត្យ | សមាជិក។ |

**ប្រការ ២.**_

**ក្រុមការងារបច្ចេកទេសទី១ នៃ គ.អ.ហ.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សិក្សាលើឧត្តមានុវត្តអន្តរជាតិ អំពីការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងក្នុងកិច្ចព្រមព្រៀងឥណទាន ឱ្យទទួលបានជោគជ័យ
- តាមដាន និងត្រួតពិនិត្យនូវការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិការប្រចាំសាមីស្ថាប័ននីមួយៗ ក្នុងនាមជាជំនួយការឱ្យ គ.អ.ហ.
- ពិនិត្យ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ" តាមការចាំបាច់
- សម្របសម្រួលឱ្យមានការឯកភាពរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា លើរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹង÷
    - ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
    - ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង
    - ការត្រួតពិនិត្យលើការអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងប្រើប្រាស់
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាពក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍ជាទៀងទាត់ជូន គ.អ.ហ. អំពីការវិវត្តនៃផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់ប្រធាន **ក្រុមការងារបច្ចេកទេសទី១ នៃ គ.អ.ហ.**។

**ប្រការ ៣.**_

**ក្រុមការងារបច្ចេកទេសទី១ នៃ គ.អ.ហ** មាននាយកដ្ឋានគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. ជាលេខាធិការដ្ឋាន។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ក្រុមការងារបច្ចេកទេសទី១ នៃ គ.អ.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក្រុមការងារបច្ចេកទេសទី១ នៃ គ.អ.ហ.**។

**ប្រការ ៤.**_

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន និងត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។

ប្រធានមានសិទ្ធិអញ្ជើញជំនាញការចូលរួមប្រជុំ និងអាចប្រគល់សិទ្ធិជូនអនុប្រធានរូបណាមួយដឹកនាំកិច្ចប្រជុំជំនួស តាមការចាំបាច់។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាព ក្រោមនិវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតនិងចាត់តាំងក្រុមការងារបច្ចេកទេសធនាគារជាតិនៃកម្ពុជា ដើម្បីសហការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០ របស់រាជរដ្ឋាភិបាល

៚

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពី ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៦ អនក្រ.បក ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ ស្តីពី ការកែសម្រួលអនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៣៨ សសរ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ ស្តីពី ការតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៩០ សសរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ស្តីពី ការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិ



ប្រអប់សំបុត្រលេខ ២៥, ទូរលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតនិងចាត់តាំង **ក្រុមការងារបច្ចេកទេសធនាគារជាតិនៃកម្ពុជា** ដើម្បីទទួលបន្ទុកសហការរៀបចំការធ្វើបច្ចុប្បន្នកម្មលើយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ ឱ្យទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០ របស់រាជរដ្ឋាភិបាល ដែលតទៅនេះហៅថា "**ក្រុមការងារបច្ចេកទេស**" មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១/- **ឯកឧត្តម រ័ត្ន សុវណ្ណនរៈ** | ទេសាភិបាលរង | ប្រធាន |
| ២/- **លោក យូ វុណ្ណី** | ឧបការីទេសាភិបាល និងជា អគ្គនាយកគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣/- **ឯកឧត្តម តីមទី កោមលី** | ឧបការីទេសាភិបាល និងជា អគ្គនាយកប្រតិបត្តិការ | អនុប្រធាន |
| ៤/- **ឯកឧត្តម គិត សុវណ្ណារិទ្ធ** | ឧបការីទេសាភិបាល និងជា អគ្គនាយកត្រួតពិនិត្យ | អនុប្រធាន |
| ៥/- **ឯកឧត្តម ហោង បូមករា** | ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | អនុប្រធាន |
| ៦/- **លោក ឡាយ សុខហេង** | ឧបការីទេសាភិបាល និងជា អគ្គនាយកបទប្បញ្ញត្តិ និង បរិយាបន្នហិរញ្ញវត្ថុ | អនុប្រធាន |
| ៧/- **លោក អ៊ិត អេរ៉ូ** | អគ្គនាយករងគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធាននាយកដ្ឋានស្ថិតិ | សមាជិក |
| ៨/- **លោក ឡុង វិបុណ្យឫទ្ធ** | អគ្គនាយករងប្រតិបត្តិការ | សមាជិក |
| ៩/- **លោក អ៊ុក សារ៉ាត** | អគ្គនាយករងប្រតិបត្តិការ និងជា ប្រធាននាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ | សមាជិក |
| ១០/- **លោក អែម កំណាន់** | អគ្គនាយករងត្រួតពិនិត្យ | សមាជិក |
| ១១/- **លោកស្រី ម៉ក់ រស្មី** | អគ្គនាយករងបទប្បញ្ញត្តិ និង បរិយាបន្នហិរញ្ញវត្ថុ និងជា ប្រធាននាយកដ្ឋានបទប្បញ្ញត្តិ | សមាជិកា |
| ១២/- **លោក ង៉ែត សុវណ្ណារិទ្ធ** | អនុប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ១៣/- **លោក ដួង សុភ័ក្ត្រ** | ប្រធាននាយកដ្ឋានសហ-ប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤/- **លោក សេង យូរ៉ាដែន** | ប្រធាននាយកដ្ឋានស្ថិរភាពហិរញ្ញវត្ថុ | សមាជិក |
| ១៥/- **លោក ម៉ែន ភក្តី** | ប្រធាននាយកដ្ឋានកិច្ចការពារអតិថិជន | សមាជិក |
| ១៦/- **លោកស្រី ប៊ុន ដាលីន** | ប្រធាននាយកដ្ឋានបរិយាបន្នហិរញ្ញវត្ថុ | សមាជិកា |
| ១៧/- **លោក សោម គុសុម** | ប្រធាននាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ | សមាជិក |
| ១៨/- **លោកស្រី ស៊ុំ សុទ្ធី** | ប្រធាននាយកដ្ឋានគ្រប់គ្រងទុនបម្រុង | សមាជិកា |
| ១៩/- **លោក អេង សុភា** | ប្រធាននាយកដ្ឋានសេវាធនាគារ | សមាជិក |

២០/- **លោក លន់ សំអុល** ប្រធាននាយកដ្ឋានត្រួតពិនិត្យ១ សមាជិក

២១/- **លោក លឹម ឆាយាជា** ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យនិងវាយតម្លៃហានិភ័យ សមាជិក និង

២២/- **លោកស្រី សោម នីតា** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានអង្គភាពទំនាក់ទំនង លេខាធិការ។

**ប្រការ២.-**

**ក្រុមការងារបច្ចេកទេសនេះ** មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ពិនិត្យ តាមដាន និងរៀបចំរបាយការណ៍ស្ដីពី វឌ្ឍនភាព បញ្ហាប្រឈម និងការលើកឡើងនូវដំណោះស្រាយថ្មីៗនៃផែនការសកម្មភាពតាមវិស័យនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ របស់រាជរដ្ឋាភិបាលកន្លងមក
- សហការរៀបចំ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុតាមការចាំបាច់
- សហការ និងសម្របសម្រួលឱ្យមានសង្គតិភាពផ្នែកការងារបច្ចេកទេសរវាងអន្តរនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍នានា ដើម្បីសម្រេចការងារខាងលើ
- ធ្វើជាជំនួយការឱ្យគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្នុងការតាមដាន និងត្រួតពិនិត្យនូវវឌ្ឍនភាពនៃការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រសួង-ស្ថាប័ន និងនាយកដ្ឋាន-អង្គភាពពាក់ព័ន្ធប្រចាំសាមីស្ថាប័ននីមួយៗ និង
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ លោកជំទាវ ទេសាភិបាល និងប្រធានក្រុមការងារបច្ចេកទេសនេះ។

**ប្រការ៣.-**

អគ្គលេខាធិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកប្រតិបត្តិការ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជានិងសាមីជន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៥

**ទេសាភិបាល**

**ជា សិរី**

**កន្លែងទទួល**៖

- ដូចប្រការ១ និងប្រការ៣
  "ដើម្បីជូនជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ